ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ នៅក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុទៅសាលាក្តីខ្មែរក្រហមគឺជាកាតព្វកិច្ចរបស់អាស៊ាន

◆ រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោកស្រី ហ៊ីលឡារី គ្លីនតុន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣២ ខែធ្នូ ឆ្នាំ២០១០

# ស្វែងរកការពិត

លេខ១៣២ ខែធ្នូ ឆ្នាំ២០១០


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆នៅក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុទៅសាលាក្តីខ្មែរក្រហម............................១

**ផ្នែកឯកសារ**

◆ខ្មែរក្រហម ៖ ការកេណ្ឌទ័ព និងការជ្រើសរើស....................................៣

◆វេទិកាពិភាក្សានៅភ្នំវល្លិ៍..........................................................១៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆តើការអត់ឱនទោសអាចធ្វើបានដែរឬទេ? ....................................២៧

**ផ្នែកច្បាប់**

◆ការចោទប្រកាន់អំពីការអនុវត្តផ្នែកសុខាភិបាល ............................៣០

**វេទិកាពិភាក្សាសាធារណៈ**

◆លទ្ធភាពនៃការចោទប្រកាន់អំពើប្រល័យពូជសាសន៍......................៣៥

◆រូបថតជនរងគ្រោះនៅមន្ទីរស-២១ .........................................៤៣

◆រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក លោកស្រី គ្លីនតុន..................៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆វិញ្ញាណចងចាំ ....................................................................៦០




លោកស្រី ហ៊ីលឡារី គ្លីនតុន ទស្សនកិច្ចសារមន្ទីរទួលស្លែង



ជនរងគ្រោះនៅមន្ទីរស-២១


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នារលេខនេះ ៖** ហ្គ្រីហ្គោរី ប្រកណ្ឌ, អាន ហេនឌល, ឡូរ៉ា វីលីម, ជេមស៍ ស៊ី. រ៉ូប៊ីត, ថៃ ច័ន្ទរិទ្ធ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ ៖** ដា ដល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** ញាណ សុជាតិ, ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ ៖** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ៖*

# នៅក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុទៅសាលាក្តីខ្មែរក្រហម គឺជាភាគព្វកិច្ចរបស់អាស៊ាន

កម្ពុជាបានស្វាគមន៍ដំណើរមកដល់របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន មកកាន់ប្រទេសកម្ពុជា ។ វត្តមានរបស់លោក បាន គីមូន នៅពេលនេះគឺក្នុងនាមជាមន្ត្រីជាន់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិ ប៉ុន្តែលោកក៏ជាប្រជាពលរដ្ឋម្នាក់នៅក្នុងតំបន់អាស៊ីរបស់យើងដែរ ។ អំឡុងពេលនៃការស្នាក់នៅក្នុងប្រទេសកម្ពុជា លោក បាន គីមូន នឹងទៅធ្វើទស្សនកិច្ចសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សារមន្ទីរទួលស្លែងគឺជាទីកន្លែងរំឭកការចងចាំដែលរៀបចំឡើង និងអភិរក្សដោយប្រជាជនកម្ពុជាសម្រាប់ឧទ្ទិសដល់ជនរងគ្រោះប្រមាណ ១៤.០០០នាក់ ដែលត្រូវបានធ្វើទារុណកម្ម និងសម្លាប់ក្នុងរបបខ្មែរក្រហមកាលពីសាមសិបឆ្នាំកន្លងទៅ ។ ចំណែកឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាកិច្ចខំប្រឹងប្រែងរួមមួយរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាក្នុងការស្ថាបនាពីភាពរន្ធត់របស់ខ្មែរក្រហមទៅរកថ្ងៃអនាគតមួយដោយផ្តោតទៅលើការគោរពសិទ្ធិមនុស្សនិងនីតិរដ្ឋ ។ ដំណើរទស្សនកិច្ចរបស់លោក បាន គីមូន អាចជាសារដ៏សំខាន់មួយជូនទៅទ្វីបអាស៊ីទាំងមូលជាពិសេសទៅកាន់ប្រទេសដែលជាសមាជិកនៃសមាគមអាស៊ានទាំងជប់អំពីសារសំខាន់នៃសាលាក្តីខ្មែរក្រហម និងការកាត់ទោសមេដឹកនាំសំខាន់ៗនៃរបបខ្មែរក្រហមក្នុងសំណុំរឿង០០២ រួមមាន អៀង សារី, នួន ជា, ខៀវ សំផន, និង អៀង ធីរិទ្ធ ។ នេះគឺជាតុលាការកាត់ទោសពីអំពើប្រល័យពូជសាសន៍លើកទីមួយដែលកំពុងធ្វើឡើងនៅទ្វីបអាស៊ី ។



អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន

ក្តីរំពឹងដ៏ធំបំផុតរបស់ប្រជាជនកម្ពុជាក្នុងការទាមទារយុត្តិធម៌មិនទំនងជាអាចទទួលបានទៅតាមសេចក្តីប៉ងប្រាថ្នាទាំងស្រុងទេ ដោយសារភាពចាស់ជរារបស់ជនចុងចោទ ការពន្យារពេលអស់ជាច្រើនឆ្នាំនៃដំណើរការកាត់ទោស ការធ្វើបណ្តឹងជំទាស់របស់ចុងចោទនិងដោយសារកំណត់ហេតុមិនល្អនៃប្រព័ន្ធច្បាប់របស់កម្ពុជាតាំងពីមុនមក ។ តែទោះបីជាយ៉ាងណាក៏ដោយក៏សាលាក្តីនេះនឹងផ្តល់ផលប្រយោជន៍សំខាន់ៗបីដល់កម្ពុជាដែរ ។ ទីមួយសាលាក្តីនេះអាចផ្តល់ឱកាសមួយដែលជួយដល់ប្រជាជនកម្ពុជាក្នុងការទទួលបានចម្លើយពីសំណួរមួយចំនួនអំពីការកាត់ទោស និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។ ទីពីរសាលាក្តីនេះអាចជំរុញឲ្យមានការពិភាក្សាក្នុងស្រទាប់ប្រជាជនថាតើប្រព័ន្ធច្បាប់របស់ខ្លួនមានដំណើរការយ៉ាងដូចម្តេចនិងថាតើប្រជាជនកម្ពុជាចង់បានប្រព័ន្ធច្បាប់របស់ខ្លួនបែបណា ។ ទីបី ត្រឹមតែមួយជំនាន់ក្រោយរបបប្រល័យពូជសាសន៍ប៉ុណ្ណោះ ក្មេងៗជាច្រើនមិនជឿថាឪពុកម្តាយរបស់ខ្លួនធ្លាប់ឆ្លងកាត់យុគសម័យដ៏ឈឺចាប់នៃរបបខ្មែរក្រហមទេ ។

ហេតុដូច្នេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះនឹងរំឭកឡើងវិញនូវអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងសាលាក្តីនេះក៏នឹងជំរុញទឹកចិត្តឲ្យមនុស្សគ្រប់រូបចេះការពារនិងទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែរ ។ ទោះបីជាលទ្ធផលយ៉ាងណាក៏ដោយ ក៏សាលាក្តីនេះពិតជាមានសារសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជាក្នុងការយល់ដឹងអំពីប្រព័ន្ធយុត្តិធម៌និងសិទ្ធិមនុស្ស ជាពិសេសសិទ្ធិក្នុងការរស់រានមានជីវិត ។

រដ្ឋាភិបាលរបស់បណ្តាប្រទេសអាស៊ីមួយចំនួននៅតែយល់ឃើញថា សិទ្ធិមនុស្សគឺជាទ្រឹស្តីរបស់បស្ចិមប្រទេស ។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនេះប្រជាជនក្នុងបណ្តាប្រទេសនៅអាស៊ីបានយល់ថា សិទ្ធិមនុស្សគឺជាទស្សនៈសាកល ហើយដំណើរការដ៏ត្រឹមត្រូវនិងនីតិរដ្ឋគឺជាសមាសភាពយ៉ាងសំខាន់នៃដំណើរការប្រជាធិបតេយ្យ ។ នៅពេលដែលប្រទេសមួយចំនួននៅអាស៊ីនិងក្នុងបណ្តាប្រទេសដែលជាសមាជិកអាស៊ានកំពុងតែដើរតួនាទីយ៉ាងទូលំទូលាយអំពីនយោបាយពិភពលោកនិងសេដ្ឋកិច្ចអន្តរជាតិវាគឺជាការសំខាន់ណាស់ថាទង្វើនិងអាកប្បកិរិយារបស់ខ្លួនបានឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលធ្លាប់មាននិងកំពុងតែកើតមាននៅអាស៊ី ។ ទោះបីជាអាស៊ានខិតខំស្វះស្វែងជំរុញលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សនៅក្នុងតំបន់យ៉ាងណាក៏ដោយ ក៏គ្មានសមាជិករបស់អាស៊ានណាមួយបានផ្តល់មូលនិធិទៅកាន់អង្គជំនុំជម្រះវិសាមញ្ញនៅឡើយទេ ខណៈពេលដែលសាលាក្តីនេះជួបប្រទះនូវកង្វះខាតថវិកាដើម្បីដំណើរការងាររបស់ខ្លួន ។ អាស៊ានមានអាណត្តិនិងតួនាទីសំខាន់ជាងប្រទេសដែលបានផ្តល់ជំនួយដល់សាលាក្តីខ្មែរក្រហមនាពេលបច្ចុប្បន្នទៅទៀត ។ អាស៊ានមានកាតព្វកិច្ចដើម្បីធានាថាដំណើរការរបស់សាលាក្តីខ្មែរក្រហមអាចដំណើរការទៅមុខដោយអនុលោមតាមនីតិរដ្ឋដោយមិនត្រូវជួបខបសគ្គផ្នែកហិរញ្ញវត្ថុឡើយ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ដំណើរទស្សនកិច្ចរបស់លោក បាន គីមូន នឹងដាស់ស្មារតីព្រមទាំងលើកទឹកចិត្តដល់ប្រទេសដែលជាសមាជិកអាស៊ានទាំងអស់ក្នុងការបង្ហាញនូវការគាំទ្ររបស់ខ្លួនចំពោះសិទ្ធិមនុស្សនៅអាស៊ីដោយការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់សាលាក្តីខ្មែរក្រហមដែលកំពុងតែត្រូវការជាចាំបាច់ ។

**ឆាំង យុ**

# រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ហ៊ីលឡារី គ្លីនតុន ទស្សនកិច្ចសារមន្ទីរទួលស្លែង

*ខ្ញុំមានអារម្មណ៍រំជួលចិត្តឥតឧបមាពេលដែលខ្ញុំទៅទស្សនាសារមន្ទីរទួលស្លែង ។ ខ្ញុំបានសម្លឹងមើលទៅមុខមាត់របស់ក្មេងៗដែលជាជនជាតិខ្មែរទាំងនោះ ទាំងអ្នកដែលត្រូវបានសម្លាប់នៅកន្លែងមួយដែលពោរពេញទៅដោយភាពឈឺផ្សាផង និងអ្នកដែលបានប្រព្រឹត្តអំពើកាប់សម្លាប់ផង ។ អ្វីដែលជាចំណុចសំខាន់បំផុតនោះគឺថា ប្រជាជនកម្ពុជាខ្លួនឯងកំពុងតែអប់រំដល់ក្មេងជំនាន់ក្រោយអំពីទំព័រប្រវត្តិសាស្ត្រដ៏ខ្លោចផ្សាកាលពីអតីតកាលមួយនេះ ហើយប្រជាជនកម្ពុជាកំពុងតែរំឭកនិងគោរពដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ដោយខិតខំធ្វើការយ៉ាងសស្រាក់សស្រាំដើម្បីនាំមកនូវការទទួលខុសត្រូវខាងផ្លូវច្បាប់និងយុត្តិធម៌និងខិតខំដើម្បីឲ្យប្រទេសមានស្ថិរភាពនិងការបង្រួបបង្រួម ។*


លោកស្រី ហ៊ីលឡារី គ្លីនតុន ស្តាប់ការពន្យល់របស់លោក ឆាំង យុ នៅសារមន្ទីរទួលស្លែង

**ហ៊ីលឡារី គ្លីនតុន**

*ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ។*

# ខ្មែរក្រហម :
# ការកេណ្ឌទ័ពនិងការជ្រើសរើស ការបណ្តុះបណ្តាលនិងការអភិវឌ្ឍ

**(តចប់)**

ជនជាតិខ្មែរដែលទើបនឹងជ្រើសរើសឲ្យចូលបម្រើខ្មែរក្រហមមួយចំនួនត្រូវបង្ហាញភ័ស្តុតាងបញ្ជាក់ពីខ្លួនឯងថាហ៊ានកាត់ដោះស្ត្រីជនជាតិវៀតណាម ។ អ្នកផ្សេងទៀតប្រព្រឹត្តអំពើសាហាវមួយចំនួនដូចជា ការវះយកទារកដែលមិនទាន់កើតចេញពីស្ត្រីវៀតណាមមានផ្ទៃពោះដែលខ្មែរក្រហមចាត់ទុកជាសត្រូវ ហើយការធ្វើរបៀបនេះគឺអាចឲ្យកម្មាភិបាលបោកទារកដែលស្លាប់ទៅហើយនៅចំពីមុខស្ត្រីជាម្តាយ ដែលស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងនិស្សិតពេទ្យជនជាតិអាមេរិកាំងដែលបានទទួលការបណ្តុះបណ្តាលខាងផ្នែកវះកាត់សាកសពដែរ ។ ប៉ុន្តែកម្មាភិបាលខ្មែរក្រហមបានអនុវត្តការងាររបស់ខ្លួនយ៉ាងសាហាវព្រៃផ្សៃដោយប្រើទម្រង់ខ្លួនមនុស្សរស់តែម្តង។ សៀត គេង បានមើលឡើងវិញនូវហេតុការណ៍ជាក់លាក់មួយដែលធ្វើឲ្យកុមារភាពរបស់គាត់ផ្លាស់ប្តូរយ៉ាងខ្លាំង ។ គេង អះអាងថា មានពេលមួយនោះកុមារដែលឈប់សម្រាកពីសាលាឬការងារស្រែចម្ការគឺត្រូវទៅមើលការសម្លាប់មនុស្ស ។ គេង នៅចាំថ្ងៃមួយពេលដែលគាត់កំពុងដកស្មៅក្នុងសួនបន្លែសហករណ៍ ។ គាត់ឮសូរសំឡេងកណ្តឹងដែលតម្រូវឲ្យអ្នកធ្វើការងារទាំងក្មេងទាំងចាស់មានការប្រុងប្រយ័ត្ន ហើយអ្នកទាំងអស់នេះត្រូវត្រឡប់ទៅសហករណ៍ដើម្បីប្រជុំជាបន្ទាន់ដើម្បីមើលការដាក់ទណ្ឌកម្មដល់ជនក្បត់ ។ កុមារត្រូវបានដាក់ឲ្យនៅអង្គុយចំពីមុខជនរងគ្រោះដែលអាចមើលឃើញកាន់តែជិតនូវអ្វីដែលនឹងកើតឡើង ។ នៅចំកណ្តាលកន្លែងជួបជុំ គឺជាស្ត្រីម្នាក់ដែលដៃទាំងពីរត្រូវបានចងស្លាបសេកទៅក្រោយ ។ ស្ត្រីរូបនេះមានផ្ទៃពោះ ហើយពោះរបស់គាត់ឡើងប៉ោង ។ ឈរនៅចំហៀង គាត់ជាក្មេងប្រុសម្នាក់ដែលមានអាយុប្រាំមួយឆ្នាំកំពុងកាន់ពូថៅ ។ នៅក្នុងសំឡេងដ៏មុតស្រួច ក្មេងប្រុសនោះប្រាប់ឲ្យកុមារផ្សេងទៀតឲ្យប្រុងប្រៀបមើលនូវអ្វីដែលនឹងកើតឡើង ។ គេង បាននិយាយថា ក្មេងប្រុសនោះបានគំរាមថា ប្រសិនបើអ្នកទាំងអស់មិនព្រមមើល នោះនឹងទទួលរងទារុណកម្មស្រដៀងគ្នានេះដែរ ។ ក្នុងចិត្តរបស់គាត់ គេង និយាយអំពីក្មេងប្រុសនោះថា «ក្មេងប្រុសនោះដូចជាបិសាចមកពីឋាននរក ។ ភ្នែករបស់វាពណ៌ក្រហម ហើយមើលទៅហាក់ដូចជាមិនមែនជាមនុស្សទាល់តែសោះ» ។ ក្មេងប្រុសនោះយកខ្នងពូថៅវាយស្ត្រីដ៏កម្សត់នោះរហូតទាល់តែដួលទៅដី ហើយវាយដូច្នេះជាប់រហូតដល់ខ្លួនអស់កម្លាំងមិនអាចវាយតទៅទៀតបាន ។ នេះបង្ហាញឲ្យឃើញនូវប្រសិទ្ធភាពនៃវគ្គបំពាក់បំប៉នរបស់ខ្មែរក្រហមទៅលើកុមារក្មេងៗ ។

**ការប្រជុំជាសាធារណៈ**

លក្ខន្តិកៈជារឿយៗត្រូវបានបង្ហាញនៅទីនេះ ដូចជាកម្មាភិបាលបដិវត្តន៍ត្រូវបានរំពឹងថានឹងលើកសរសើរបដិវត្តន៍ព្រមទាំងកម្មាភិបាលថ្នាក់មូលដ្ឋានផង ។ នៅទីនេះ អ្នកចូលរួមនឹងច្រៀងចម្រៀងបដិវត្តន៍និងសូត្រពាក្យស្លោកទាំងអស់គ្នា ។ ចម្រៀងខ្មែរក្រហមដែលមានចំណងជើងថា «មាតុភូមិកម្ពុជា» បំផុសកំហឹងប្រជាជនទាំងនោះឲ្យស្អប់ចក្រពត្តិអាមេរិកនិងបរិវារ ។ បរិវាររបស់ចក្រពត្តិជំពាក់យើងនូវឈាមដែលក្តៅដូចភ្លើង ។ សង្គ្រាមកំហឹងនិងក្តៅគគុកធានាឲ្យប្រាកដថា កម្ពុជានឹងមិនភ្លេចសត្រូវរបស់ខ្លួនជាដាច់ខាត និងការគាបសង្កត់ដ៏ធ្ងន់ធ្ងរឡើយ ។ ចាប់កាន់កាំភ្លើងដើម្បីសម្លាប់សត្រូវភ្លាម ។

**ចម្រៀងខ្មែរក្រហម : «យើងខ្ញុំយុវជន យុវនារីប្តេជ្ញាដើរតាមអង្គការបដិវត្តន៍កម្ពុជារៀងរហូត»**

យូរលង់ពាន់ឆ្នាំកម្ពុជាឧត្តមទើបបានរំដោះ ជាតិខ្មៅ
ងងឹតប្រែភ្លឺថ្លាស្រស់ ប្រជាស្រីប្រុសរំដោះស្ថាពរ ។
ដោយមានអង្គការបដិវត្តន៍កម្ពុជារឹងប៉ឹងជំហរ ដឹកនាំ
យើងខ្ញុំតស៊ូឈ្នះវាយបនមេចោរចក្រពត្តិចង្រៃ ។
បំប៉នបំពាក់ជំហរទស្សនៈបដិវត្តន៍ប្រពៃ សតិអារម្មណ៍
នយោបាយអង្គការវិន័យចាត់តាំងមាំក្រៃគ្រប់ផ្នែក
គ្រប់ផ្លូវ ។ អង្គការបដិវត្តន៍បំភ្លឺប្រាកដឲ្យស្គាល់មិត្ត

សត្រូវ ស្គាល់ល្អអាក្រក់ស្គាល់ខុសស្គាល់ត្រូវ បដិវត្តន៍បង្ហាញផ្លូវរុងរឿងឧត្តម ។ ក្រៅពីនេះបដិវត្តន៍ដុតភ្លើងប្រយុទ្ធឲ្យឆេះក្តៅធំ វាយចោរចក្រពត្តិលុះត្រារលំបរិវារតូចធំវិនាសស្អាតរ ។ ខ្លាំងរលំគ្រេងជោគជ័យចិញ្ចែងអង្គការបន្តបំពាក់បំប៉នពង្រឹងជំហរបដិវត្តន៍នឹងនរសម្រួចប្រយុទ្ធ ។ ប្រយ័ត្នកុំឲ្យភ្លើតភ្លើនថ្លោះធ្លោយ ជំហរវណ្ណៈកម្មករក្រខ្សត់បំពាក់រហូតជានិច្ចគ្រប់ប្រាណ ។ អង្គការលើកមាគ៌ាឯករាជ្យម្ចាស់ការយ៉ាងល្អចំណាន ខ្លួនខត្តម្ចខ្លួននិងជាតិឲ្យបាន កិត្តិយសថ្កើនថ្កានដុតផ្ទាកខ្ញុំគេ ។ មាគ៌ាសេដ្ឋកិច្ចកសាងសម្រេចឲ្យបានច្រើនទៀត កសិកម្មមូលដ្ឋានសម្រុកស្រូវស្រែផលស្រូវធូរធារសាងកម្ពុជាថ្មី ។ អង្គការបដិវត្តន៍មាគ៌ាបរិសុទ្ធភ្លឺផ្លេកពណ្ណរាយ ស្រួលបំភ្លឺផ្លូវយើងខ្ញុំទាំងឡាយ លះបង់ជីវិតកាយដើម្បីបដិវត្តន៍ ។ យុវជនយុវនារីប្តេជ្ញាជារៀងរហូតដើរតាមអង្គការប្រជាជនក្រខ្សត់សម្រេចទិសដៅបដិវត្តន៍យុទ្ធសាស្ត្រថ្កើងថ្កាន ។ រួមរស់ការពារកសាងកម្ពុជាថ្មីសុខសាន្ត សម្បូរណ៍ថ្កើងថ្កានរុងរឿងនិរន្តន៍ ។

ជាទូទៅ ជនភៀសខ្លួនពិពណ៌នាការប្រជុំសហករណ៍ទាំងនេះថា ៖ «ជាការបូជាចំពោះកិច្ចការកសិកម្មដែលបានគ្រោងទុក ឬការនិយាយច្រំដែលលើគោលគំនិតទាក់ទងនឹងសន្តិសុខឬហេតុការណ៍ដែលបានធ្វើឲ្យប្រសើរឡើងទៅលើរបបសង្គមចាស់ ឬវិធីសាស្ត្រជាប្រព័ន្ធខ្លាំងឡើងសម្រាប់ការប្រជុំជារៀងរាល់ខែ ។ ការប្រមូលផ្តុំនេះដើម្បីស្តាប់កម្មាភិបាលមូលដ្ឋានដែលនិយាយសរសើរជោគជ័យបដិវត្តន៍ និងការឈានមុខរបស់កម្ពុជាប្រជាធិបតេយ្យក្រោមការដឹកនាំដ៏ជឿនលឿននិងមានសមត្ថភាពរបស់មជ្ឈិមបក្ស ។ មហាជនត្រូវបានរំពឹងថានឹងចូលរួមយ៉ាងពេញលេញ បើទោះជាមានការហេវហត់ដោយសារការងារពីថ្ងៃក៏ដោយ ក៏នៅតែខំប្រឹងទះដៃអបអរសាទរនូវរាល់ប្រយោគនីមួយៗរបស់កម្មាភិបាលដែរ ។ នេះជាសញ្ញាបញ្ជាក់ដល់កម្មាភិបាលដែលមើលមកលើហ្វូងមនុស្សដែលកំពុងយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នឲ្យទៅលើការប្រជុំ ដែលនេះអាចជួយកុំឲ្យនរណាម្នាក់ត្រូវបានចាត់ទុកជាសត្រូវ ។ ទាំងប្រជាជនចាស់និងថ្មីត្រូវបានតម្រូវឲ្យចូលរួមប្រជុំទាំងនេះជាញឹកញាប់ ។

អ្នកទាំងនេះគឺជាកម្មាភិបាលតំបន់ដោយប្រាប់មហាជនថា «គួរតែស្រឡាញ់បក្សនិងគោរពបក្សដោយមិនត្រូវសួរនាំអ្វីទេ» ។ ពេលខ្លះកម្មាភិបាលក្នុងសហករណ៍បានធ្វើការពិគ្រោះគ្នាពីរឿងប្រជាជនវៀតណាមនិងបំណងដែលចង់បានដីកម្ពុជា ។ កម្មាភិបាលនេះបានធ្វើការពិភាក្សាគ្នាពីរឿងសត្រូវរបស់ខ្លួនដែលនៅតែមានក្នុងចំណោមប្រជារាស្ត្រគឺជនកុម្មុយនីស្តវៀតណាមហាណូយឬជាក្រុមមន្ត្រីរដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ នល់ ។ ប្រធានភូមិជាច្រើននាក់បាននិយាយអំពីការងារដែលតម្រូវឲ្យកម្ចាត់សត្រូវរបស់បក្ស ។ កម្មាភិបាលថ្នាក់តំបន់ជាច្រើននាក់បានប្រើពេលវេលានោះជាមួយសហករណ៍របស់ខ្លួនដោយធ្វើការសាកសួរប្រជាជនថាតើបានទទួលអាហារគ្រប់គ្រាន់ឬទេ ពេលនោះគ្មាននរណាម្នាក់ហ៊ានត្អូញត្អែរឬតវ៉ាអ្វីឡើយ ។

ឆ្លៀតក្នុងឱកាសនោះដែរ កម្មាភិបាលទាំងនោះបានបង្កើនការគំរាមកំហែងទៅ


ក្រុមសិល្បៈសម័យខ្មែរក្រហម

លើប្រជាជនហើយប្រកាសស្លោកមួយឃ្លាថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។ ពាក្យស្លោកនេះបានធ្វើឲ្យប្រជាជនភ័យខ្លាច ហើយបានគោរពប្រណិប័តន៍អង្គការគ្រប់គ្នា ។ អ្នកខ្លះបានរៀបរាប់ថាអ្នកដែលចូលរួមក្នុងការប្រជុំនេះភាគច្រើនមានការភ័យខ្លាចយ៉ាងខ្លាំងរហូតមិនទាំងហ៊ានកម្រើកខ្លួនផង ។ នៅពេលដែលប្រជាជនកម្ពុជាមិនធ្វើស្រែឲ្យបានខ្លាំងពូកែគឺត្រូវកម្មាភិបាលខ្មែរក្រហមកសាង (ស្តីប្រដៅ) នៅពេល «ប្រជុំជីវភាព» ដែលធ្វើឡើងជាញឹកញាប់ ។ ខូវីន និយាយថា ការប្រជុំនេះធ្វើឡើងក្នុងគោលបំណង ៖ ទីមួយ ខ្មែរក្រហមបង្កើតឲ្យមានការប្រជុំឃោសនានៅតាមកន្លែងណាដែលអាចបញ្ចុះបញ្ចូលប្រជាជនពីឧត្តមគតិកុម្មុយនីស្តរបស់អង្គការ ។ ទីពីរ ការប្រជុំអស់នេះជាឱកាសឲ្យប្រជាជនសារភាពពីកំហុសនយោបាយនិងមនោគមន៍វិជ្ជាអំពីអតីតកាលរបស់ខ្លួនក៏ដូចជាដើម្បីកម្ចាត់ជនក្បត់នៅកម្ពុជា ។ អុង ថុងហឿង រំឭកថា «ជាអកុសលប្រជាជនកម្ពុជាជាច្រើនបានយល់ថាការប្រជុំជីវភាពទាំងនេះជាឱកាសមួយក្នុងការសារភាពកំហុសពីមុននឹងអាចជួយលុបលាងកំហុសទាំងនេះពីភ្នែកខ្មែរក្រហមគឺមិនខុសប្លែកអីពីការសារភាពកំហុសទៅកាន់បព្វជិតនៅក្នុងវិហារគ្រិស្តនោះទេ ។ ប្រសិនបើសារភាពនោះនឹងទទួលបានការទះដៃសាទរនិងការសរសើរ ហើយប្រហែលទទួលបានការឱបរឹតពីកម្មាភិបាលខ្មែរក្រហមដែលមានវត្តមាននៅទីនោះផង ។ សុខា បានប្រាប់ ប៊ុនស៊ូ នៅក្នុងកិច្ចសម្ភាសន៍ថា «បន្ទាប់ពីធ្វើការងាររួច យើងបានជួបជុំគ្នានៅក្នុងការប្រជុំមួយដើម្បីស្ទាបស្ទង់ពីដំណើរការនៃការងារ ។ សមមិត្តណាដែលមិនបានសម្រេចការងារត្រូវឡើងប្រាប់ពីមូលហេតុរបស់ខ្លួន ។ ក្នុងនាមជាប្រធានមួយរូប ខ្ញុំត្រូវតែសង្ខេបពីការពិភាក្សានៃការប្រជុំ ។ ឧទាហរណ៍ដូចជាថាសមមិត្តរូបនេះបានធ្វើការងារច្រើនថ្ងៃ ហើយបាននិយាយយ៉ាងគួរសមទៀត ដូចនេះគាត់ត្រូវបានទទួលពិន្ទុ ។ លើសពីនេះទៅទៀត ការប្រជុំនេះគឺដាក់ការងារថ្មីទៀតឲ្យគ្រប់គ្នាដូចជាការងារច្រូតស្រូវឬការងារផ្សេងទៀតដែលខ្មែរក្រហមប្រាប់ឲ្យខ្ញុំទៅប្រាប់អ្នកផ្សេងទៀត ។ យើងធ្វើតែការងារដដែលៗ តែប៉ុណ្ណឹងរាល់ថ្ងៃគ្មានអ្វីផ្សេងទៀតទេ» ។

**ទិតៀន និងស្វ័យទិតៀន**

មុននឹងចូលដល់កិច្ចការដែលទាក់ទងទៅនឹងការរិះគន់ខ្លួនឯងជាសាធារណៈនៅក្នុងសហករណ៍ កម្មាភិបាលម្នាក់ៗត្រូវបានជ្រើសរើសឲ្យឆ្លើយកម្រងសំណួរមួយស្តីពីជីវប្រវត្តិ ហើយដែលត្រូវផ្តល់នូវការយល់ដឹងច្បាស់លាស់ដំបូងមួយទៅលើថាតើ «ត្រូវធ្វើយ៉ាងណាដើម្បីឲ្យមនុស្សម្នាក់អាចពិចារណាគំនិតនិងឥរិយាបថរបស់ខ្លួនបាន» ដោយមានប្រសិទ្ធភាពនិងទៀងទាត់ ។ យោធាជំនិតម្នាក់របស់ អៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យបានរក្សាទុកសៀវភៅកំណត់ហេតុមួយក្បាលដែលគាត់ទុកសម្រាប់កត់ត្រាពីស្វ័យទិតៀនរបស់សមមិត្ត ឌួន «ដែលបានសារភាពពីចំណុចខ្វះខាតខាងស្មារតីរបស់គាត់» ដូចជានៅមានអារម្មណ៍និងចំណងជាមួយគ្រួសាររបស់គាត់និងចង់មានរបស់របរទុកជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ គាត់នៅតែមានឥរិយាបថដែលមិនសមស្របតាមខ្សែបក្សកុម្មុយនីស្តកម្ពុជាគឺដូចជាធ្វើមិនល្អនិងមិនគួរសមទៅលើអ្នកដទៃ ។ វាគឺជាការទទួលខុសត្រូវរបស់អ្នកសង្កេតក្នុងការវែកញែកនិងស្គាល់ថាគំនិតនិងការប្រព្រឹត្តរបស់អ្នកធ្វើស្វ័យទិតៀននោះជាការត្រឹមត្រូវឬមិនត្រឹមត្រូវនិងដើម្បីចង្អុលបង្ហាញឲ្យបានច្បាស់នៅពេលប្រជុំទិតៀន ។ កម្មាភិបាលថ្នាក់តំបន់នឹងមានការប្រុងប្រយ័ត្នចំពោះបុគ្គលណាដែលមានស្មារតីអន់ថយ ។

ឧទាហរណ៍ ដូចជានៅពេលដែលកម្មាភិបាលធ្វើស្វ័យទិតៀនខ្លួនឯងជាសាធារណៈ ។ ប្រសិនបើកម្មាភិបាលមានការពឹងផ្អែកទៅលើរឿងពីអតីត (នេះជាសញ្ញាសម្គាល់ថា អ្នកនិយាយនៅជាប់ឥរិយាបថមូលធន) ឬប្រសិនបើប្រើពាក្យបរទេស អ្នកស្តាប់អាចនឹងសន្និដ្ឋានថា (អ្នកនិយាយនោះមានការអប់រំតាមប្រព័ន្ធចក្រពត្តិ) ។ ឡូវ៉េង ពិច បានដដែកវែកញែកពីបញ្ហានេះតាមរយៈបទពិសោធន៍របស់លោកស្រីក្នុងការទិតៀនខ្លួនឯងដែលដើរតួបន្តជាសៃរៀននៃការអភិវឌ្ឍបដិវត្តន៍ និងការរីកចម្រើនអាចបង្ហាញទៅកាន់កម្មាភិបាលជាន់ខ្ពស់ទាំងនោះ ៖

> «ការប្រជុំទិតៀននេះមានការកើនឡើងរហូតដល់ពីរយប់ក្នុងមួយសប្តាហ៍ ។ នៅអំឡុងពេលប្រជុំនេះ វាហាក់បីដូចថាជារឿងរ៉ាវរបស់បុគ្គលម្នាក់ៗក្នុងពេលអតីតដែលមានភាពស្មុគស្មាញអាចកាត់បន្ថយមកត្រឹមការចោទប្រកាន់ថាក្បត់របស់បក្ស ។ ហេតុដែលធ្វើបែបនេះព្រោះយល់ថាមានតែអ្នកនយោបាយ

ជាន់ខ្ពស់សំខាន់ៗ ទេដែលអាចលើកលែងទោសឲ្យបាន ។ ភាពយឺតយ៉ាវក្នុងការសម្រេចកិច្ចការបានបង្ហាញពីស្មារតីដែលត្រូវបានបំផ្លិចបំផ្លាញ ។ ភាពខ្វះខ្វែងគឺជាសញ្ញាមួយយ៉ាងច្បាស់នៃការចង់បានអំណាច ។ គំនិតមានតម្លៃដូចជាសកម្មភាពដែរ ។ ដើម្បីឈរនៅលើភាពត្រឹមត្រូវបាន ម្នាក់ៗត្រូវតែជ្រួតជ្រាបនូវគំនិតរបស់បក្សដោយខ្លួនឯងដូចជារបៀបដែលចិត្តគំនិតត្រូវប្តូរផ្តាច់ដើម្បីបម្រើអង្គការជានិច្ចដោយគ្មានការស្ទាក់ស្ទើរនិងមិនខ្ជះខ្ជាយពេលវេលាដូចជាម៉ាស៊ីនអឺចីង ។ ចំណែកខាងវិន័យវិញ ខ្ញុំបានជួបប្រទះនូវឧបសគ្គមួយចំនួន ។ ខ្ញុំមិនបានស្តាប់ការផ្សព្វផ្សាយតាមវិទ្យុដោយយកចិត្តទុកដាក់ទេ ។ (ការស្តាប់វិទ្យុបានក្លាយជាកាតព្វកិច្ចមួយ យើងគ្រប់គ្នាត្រូវតែយកចិត្តទុកដាក់ទៅលើការផ្សាយទាំងឡាយដើម្បីធ្វើឲ្យយើងអាចធ្វើការអធិប្បាយបាននៅពេលក្រោយ) ។ ឬមួយក៏ ខ្ញុំបាននោមក្រៅកន្លែងដាក់ដី ។ ការស្តាប់រឿងរ៉ាវពិតនិងសំខាន់ទាំងនោះមនុស្សក៏បានរកឃើញនូវសញ្ញាណនៃចំណុចខ្សោយ ។ ភាសាក៏ត្រូវបានធ្វើការវិភាគដែរ ។ រាល់សកម្មភាពដែលជាកំហុសទាំងអស់ត្រូវបានយកមកបង្ហាញ ។

វ៉ែន យឿន បានរៀបរាប់ឡើងវិញនូវប្រវត្តិនៃជីវិតរបស់ជនដែលអង្គការគិតថានឹងក្បត់ជាមួយខ្លួន ។ ប៉ុន្តែសិក្សាស្តីពីការរិះគន់នេះវាមានលក្ខណៈកាន់តែពិបាកដោយសារតែប្រជាជនភាគច្រើនមិនបានដឹងថាតើនឹងមានអ្វីកើតឡើងមកលើខ្លួន និងមិនដឹងថាតើនឹងទទួលបានការទិតៀននេះដោយរបៀបណាទេ ។ ការទិតៀននេះត្រូវបានធ្វើឡើងជាចុងក្រោយ នៅបណ្តាតំបន់មួយចំនួនដែលត្រូវឃ្លាំមើលដើម្បីបង្ហាញខ្មែរក្រហមពីការយល់ដឹងពីមនោគមន៍វិជ្ជាខ្មែរក្រហមនិងធ្វើតាមគោលបំណងនៃការអនុវត្តដ៏ល្អរបស់ខ្មែរក្រហម ។ ស្វ័យទិតៀនដែលបានអនុវត្តយ៉ាងយកចិត្តទុកដាក់នោះបានក្លាយជាការបង្ហាញអំពីភាពគ្មានមេត្តាចំពោះអ្នកដែលធ្វើការទិតៀនពីចំណុចខ្សោយរបស់ខ្លួន ។ ការទិតៀននិងស្វ័យទិតៀនគឺជាសព្វាវុធនៃ ម៉ាស៊ីស្ស លេនីន ដែលធ្វើការដើម្បីផ្លាស់ប្តូរការអនុវត្តនិងភាពដឹកនាំល្អដោយបានធ្វេសប្រហែសនូវរឿងមួយចំនួន ។ ស្វ័យទិតៀននេះត្រូវបានបង្កើតឡើងដើម្បីហ្វឹកហ្វឺនខាងនយោបាយនិងយោធា និងការអភិវឌ្ឍខាងសម្ភារដើម្បីជួយដល់កម្មាភិបាលបក្សកុម្មុយនីស្តក្នុងការសិក្សាស្វែងយល់ពីគ្រោះថ្នាក់ជាអកុសលរបស់ខ្លួន ។ នៅថ្ងៃ៨ មករា ឆ្នាំ១៩៦៧ ម៉ៅ សេទុង បានបញ្ជាក់នៅក្នុងសារព័ត៌មានដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តចិន «ប្រជាជនប្រចាំឆ្នាំ» ជំរុញឲ្យគ្រប់ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាលធ្វើការក្រោកឈរឡើងដើម្បីស្វ័យទិតៀននិងធ្វើវិសុទ្ធកម្មទៅលើអ្នកឯទៀត ។

«ប្រសិនបើយើងមានចំណុចខ្វះខាតយើងមិនខ្លាចរាល់ការចង្អុលបង្ហាញឬទិតៀននោះទេព្រោះយើងបម្រើឲ្យប្រជាជន ។ នណាក៏ដោយក៏អាចចង្អុលប្រាប់ពីចំណុចខ្វះខាតរបស់យើងបានដែរ វាមិនជាបញ្ហានោះទេ ។ ប្រសិនបើការទិតៀននោះត្រឹមត្រូវ យើងនឹងធ្វើការកែតម្រូវតាម ។ ប៉ុន្តែប្រសិនបើវាផ្តល់ប្រយោជន៍ដល់ប្រជាជននោះ យើងនឹងធ្វើសកម្មភាពតាមដូចគ្នា ។ ដូចជាយើងបាននិយាយអឺចឹងថាធូលីនឹងកើនឡើង ដរាបណាយើងមិនធ្វើការសម្អាតបន្ទប់ឲ្យបានទៀងទាត់ ហើយមុខយើងនឹងកខ្វក់នៅពេលដែលយើងមិនបានលាងសម្អាតជាប្រចាំនោះ ។ ចិត្តគំនិតរបស់សមមិត្តយើងនិងបក្សប្រហែលជាប្រមូលធូលីនិងបោសសម្អាតឲ្យស្អាត ។ សុភាសិតមួយឃ្លាបានពោលថា «ទឹកមិនដែលកខ្វក់ ត្រចៀកទ្វារមិនដែលកណ្តៀរស៊ី» មានន័យថា ការការពារមាំមួនទប់ស្កាត់មិនឲ្យមានមេរោគចូលមកលុកលុយបាន ។ ការពិនិត្យការងារនិងដំណើរការរបស់យើងឲ្យបានទៀងទាត់នោះធ្វើឲ្យការងារលទ្ធិប្រជាធិបតេយ្យនឹងមានការរីកចម្រើន» ។

ស្វ័យទិតៀននៃរបបកុម្មុយនីស្តសង្គមនិយមបានដើរតួទាំងការអភិវឌ្ឍភាពជាអ្នកដឹកនាំនិងការទទួលខុសផ្សេងៗ ។ ឧទាហរណ៍ ម៉ៅ សេទុង បន្ទាប់ពីការបរាជ័យនូវមហាលោតផ្លោះមហាអស្ចារ្យ គាត់បានសរសេរបាយការណ៍ស្វ័យទិតៀនមួយ

នៅឆ្នាំ១៩៦២ដោយបន្ទាញពីកំហុសរបស់គាត់នៅក្នុងបញ្ហានោះ ។ «រឿងរ៉ាវនេះបណ្ដាលឲ្យមានបញ្ហាធំនិងខ្ញុំដែលជាអ្នកទទួលខុសត្រូវបញ្ហានេះ» ។ បញ្ហាចម្បងមួយរបស់ ម៉ៅ សេទុង ដោយមើលឃើញថា មហាលោតផ្លោះ មហាអស្ចារ្យនឹងទទួលបានជោគជ័យនោះគឺ «សមមិត្តម៉ៅ សេទុង ហើយនិងសមមិត្តដែលជាអ្នកដឹកនាំឯទៀតទាំងនៅមជ្ឈិមនិងតំបន់នានានោះគឺអត់ធ្មត់សម្រាប់លទ្ធផលភ្លាមៗ រួមជាមួយនឹងការធ្វើតាមគំនិតគេហួសហេតុពេកដែលវាជាការល្អ ហើយក៏អាចជាការអាក្រក់ផងដែរ ។ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៧៨ លោក ហួ គួហ្វុង ដែលជាប្រធានបក្សកុម្មុយនីស្ដក៏បានចូលរួមក្នុងស្វ័យទិតៀននេះនិងបានរិះគន់ពីគោលនយោបាយគាត់ផងដែរ ។ នេះគ្រាន់តែជាសេចក្ដីថ្លែងការណ៍ធំទូលាយមួយរបស់ គួហ្វុង ដោយបានអះអាងថា «យើងគាំទ្រនូវអ្វីដែលជាការសម្រេចចិត្តរបស់ប្រធាន ម៉ៅ សេទុង និងធ្វើតាមការណែនាំរបស់គាត់បានឲ្យ» ។

ចូសែហ្វ ស្តាលីន ជឿជាក់ថា ការធ្វើស្វ័យទិតៀនជាតម្រូវការមួយដ៏ចាំបាច់សម្រាប់អ្នកទាំងឡាយដែលទើបនឹងឡើងកាន់អំណាច ។ អ្នកដឹកនាំមួយចំនួនមិនបានចាប់អារម្មណ៍ចំពោះកំហុសនិងភាពទន់ខ្សោយរបស់ខ្លួនទេដែលបង្កឲ្យមានភាពងាយស្រួលដល់ខ្មាំងសត្រូវដោយមិនដឹងខ្លួន ។ ជាងនេះទៅទៀត គោលបំណងនៃការធ្វើស្វ័យទិតៀនគឺដើម្បី «លាតត្រដាងនិងបំបាត់ចោលនូវកំហុសនិងភាពទន់ខ្សោយរបស់យើង» ។ លេនីន បានសរសេររៀបរាប់នៅក្នុងកូនសៀវភៅរបស់គាត់ «កុម្មុយនីស្ដឆ្វេងនិយមភាពគ្មានសណ្ដាប់ធ្នាប់ដ៏ក្មេងខ្ចី» នៅខែមេសា និងឧសភា ឆ្នាំ១៩២០ យ៉ាងដូច្នេះថា «សរុបសេចក្ដីមក បើគ្មានស្វ័យទិតៀនទេនោះ បក្សវណ្ណៈ និងមហាជនទូទៅក៏មិនអាចនឹងមានការអប់រំដ៏សមរម្យមួយដែរ ហើយបើគ្មានការអប់រំដ៏សមរម្យមួយសម្រាប់បក្ស វណ្ណៈ និងមហាជនទេ នោះក៏មិនអាចនឹងមានជនកុម្មុយនីស្ដពិតប្រាកដដែរ» ។ អ្នកខ្លះបានធ្វើការសន្និដ្ឋានដោយប្រយោលថា បើមានស្វ័យទិតៀន នោះនឹងគ្មានត្រូវការការដឹកនាំតទៅទៀតទេ ហើយថាយើងនឹងបណ្ដោយឲ្យរឿងរ៉ាវកើតឡើងទៅតាមធម្មជាតិរបស់វា ។

ចំណែកឯ ស្តាលីន វិញបានបញ្ជាក់ថា «យើងត្រូវការស្វ័យទិតៀនមិនមែនដើម្បីបន្ធូរបន្ថយការដឹកនាំនោះទេ ថែមទាំងពង្រឹងការដឹកនាំឲ្យមានភាពខ្លាំងក្លាថែមទៀតក្នុងគោលបំណងកែប្រែការដឹកនាំដែលមានតែនៅលើក្រដាសនិងមានអំណាចតិចតួចទៅជាការដឹកនាំដែលមានលក្ខណៈរឹងមាំនិងពោរពេញទៅដោយអំណាច ។

យើងមិនអាចបដិសេធបានទេថាលទ្ធផលនៃការធ្វើស្វ័យទិតៀនធ្វើឲ្យកាន់តែមានភាពវៃឆ្លាតទ្បើង ហើយកាន់តែមានការប្រុងប្រយ័ត្នដើម្បីដោះស្រាយចំណោទក្នុងការដឹកនាំសេដ្ឋកិច្ចបានកាន់តែប្រសើរឡើងទេ ។ បក្សរបស់យើង សហភាពសូវៀត សហជីពកម្មកររួមទាំងបុគ្គលគ្រប់រូបផ្សេងទៀតកាន់តែមានភាពយោគយល់ អធ្យាស្រ័យ និងឆ្លើយតបភ្លាមៗទៅនឹងតម្រូវការរបស់មហាជន ។ ស្តាលីន ឆ្នាំ១៩៥៤ អះអាងថា តើវាមានការលំបាកក្នុងការយល់ថា យើងត្រូវការស្វ័យទិតៀនមិនមែនដើម្បីស្វែងរកកំហុសនិងដាក់ទណ្ឌកម្មកម្មាភិបាលផ្នែកសេដ្ឋកិច្ចរបស់យើងទេ ក៏ប៉ុន្តែដើម្បីជួយធ្វើឲ្យប្រសើរឡើង និងល្អឥតខ្ចោះរបស់កម្មាភិបាលទាំងនោះ ។

កម្មាភិបាលថ្មីត្រូវបានតម្រូវឲ្យអានឯកសារអំពី «ការតស៊ូផ្នែកវណ្ណៈ» និង «គំនុំរបស់បដិវត្តន៍» ។ កម្មាភិបាលថ្មីរំពឹងថានឹងចូលរួមនៅក្នុងវគ្គស្វ័យទិតៀន «ដែលជាកន្លែងអ្នកទាំងនោះត្រូវធ្វើការវាយតម្លៃទាក់ទងនឹងស្ថានភាពអារម្មណ៍និងស្មារតី» រួមទាំងការយល់ដឹងពីការអានឯកសារពីមុនមកផង ។ នៅឆ្នាំ ២០០១ ហ្សេលីម ឃីន និង វង្ស សុខេង បានធ្វើបទសម្ភាសន៍ជាមួយនឹងជនរងគ្រោះម្នាក់ដែលរួចរស់ជីវិតពីមន្ទីរកែប្រែអប់រំបឹងត្របែកនៅប្រទេសកម្ពុជា គឺសមាជិកព្រឹទ្ធសភា កែវ ប៊ុនធូក អំពីជីវិតនិងមរណៈនៅក្នុងមន្ទីរនេះ ។ ពេលដែលសួរគាត់ថាតើជីវិតនៅក្នុងមន្ទីរនោះមានសភាពយ៉ាងដូចម្ដេច គាត់ឆ្លើយថា «យើងត្រូវធ្វើការជាទម្ងន់និងមិនមានអាហារបរិភោគគ្រប់គ្រាន់នោះទេ នៅទីនោះមានវគ្គទិតៀននិងស្វ័យទិតៀនជារៀងរាល់ថ្ងៃ» ។ ការទិតៀនគឺជាផ្នែកមួយនៃរូបមន្តក្នុងការជម្រះកម្អែលចាស់របស់ពួកគហបតីនិងអ្នកទីក្រុង ។ អ្នកដឹកនាំថ្មីនិងអ្នកដឹកនាំដែលតំណាងឲ្យអ្នកចាស់ត្រូវបានបណ្ដុះបណ្ដាលឲ្យធ្វើការរិះគន់អ្នក

ផ្សេងរួមទាំងទិតៀនខ្លួនឯងផង ។

ធីតា ម៉ម បានរំឭកថា គាត់ធ្លាប់ជាមនុស្សនិយាយច្រើន និងជាអ្នកនិយាយដោយសេរី ។ ប៉ុន្តែក្រោយពីត្រូវបានបង្រ្កាបនៅក្នុងវគ្គទិតៀនរបស់ខ្មែរក្រហមរួចមក «ខ្ញុំក្លាយជាមនុស្សប្រយ័ត្នប្រយែង និងស្ងៀមស្ងាត់ ខ្ញុំតែងតែគិតក្នុងចិត្តជានិច្ចមុននឹងនិយាយអ្វីចេញមកក្រៅ ។ វិធីដែលល្អបំផុតគឺការធ្វើល្ងង់ខ្លៅ ។ ខ្ញុំមិនដែលធ្វើអ្វីឲ្យលេចមុខមាត់ក្រៅពីខំធ្វើការឲ្យខ្លាំងក្លានោះទេ ។ ពេលណាដែលកម្មាភិបាលសួរខ្ញុំ ខ្ញុំឆ្លើយថាមិនដឹង» ។ គ្រប់គ្នាខំប្រឹងរកកំហុសរបស់អ្នកដទៃដែលធ្វើឲ្យមនុស្សភាគច្រើនរស់នៅក្នុងភាពភ័យខ្លាចនិងព្រួយបារម្ភជានិច្ច ។ បដិវត្តន៍សង្គមនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យមានសភាពដូចទឹកជោរនិងទឹកនាចជាប្រចាំមិនទៀងទាត់ ។ ការវាយតម្លៃដែលមានលក្ខណៈវិជ្ជមានអាចធ្វើឲ្យអ្នកនោះទទួលបាននូវការដំឡើងឋានៈ តួនាទី ឬទទួលបាននូវអាហារបន្ថែមឬប្រយោជន៍ផ្សេងៗទៀត ។ យោធាតូចតាចអាចចរចាឋានៈរបស់ខ្លួនបានដោយការចូលរួមក្នុងវគ្គទិតៀន និងស្វ័យទិតៀន ។ យោងតាមលោក ហ៊ីនតុន «នៅពេលតែមួយដែលកម្មាភិបាលបានបង្ហាញពីការយកចិត្តទុកដាក់និងពីដំហរបដិវត្តន៍រុងរឿងរបស់ខ្លួន កម្មាភិបាលទាំងនោះក៏បានថ្លែងពីសិទ្ធិក្នុងការទទួលបាននូវមុខមាត់និងកិត្តិយសរបស់ខ្លួនដែរ ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថាក្នុងពេលធ្វើប្រវត្តិរូប ការទិតៀន និងការធ្វើស្វ័យទិតៀន ប្រធានបទមួយចំនួនក៏នឹងត្រូវលើកយកមកនិយាយដែរដូចជា ការបន្តបំពេញកិច្ចការប្រចាំថ្ងៃនិងការលះបង់ដើម្បីដើរតាមមាគ៌ាបក្សរបស់កម្ពុជាប្រជាធិបតេយ្យ ។ យើងអាចបង្កើតឬផ្លាស់ប្តូរប្រវត្តិរឿងរ៉ាវរបស់អ្នកណាម្នាក់បាន ប៉ុន្តែអ្វីដែលអាចគ្រោះថ្នាក់ជាងនេះគឺនៅពេលដែលធ្វើការទិតៀន និងស្វ័យទិតៀន ដោយសារថា អ្នកចូលរួមក្នុងវគ្គនេះមិនដឹងថាតើនឹងមានអ្នកណានិយាយអ្វីពីយើង ឬក៏ពាក្យសម្តីរបស់យើងមានផលប៉ះពាល់ ឬយល់យ៉ាងណាដល់អ្នកភូមិដូចគ្នា ។ ទោះបីជាបុគ្គលម្នាក់ៗទទួលស្គាល់នូវកំហុសរបស់ខ្លួនក៏ដោយ ក៏ការទិតៀនខ្លាំងអាចបណ្តាលឲ្យមានការអៀនខ្មាសនិងការបាក់មុខដែរ ។ ទាំងអស់គ្នាត្រូវបានរំពឹងទុកថានឹងចូលរួមការប្រជុំទិតៀននិងស្វ័យទិតៀន រួមទាំងអ្នកដែលមានឋានៈខ្ពស់ ឧទាហរណ៍ប្រធានមន្ទីរស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ឌុច ត្រូវបានសារភាពនៅខែមីនា ឆ្នាំ២០០៩ ថាជាអ្នកទទួលខុសត្រូវដោយមិនផ្ទាល់លើការសម្លាប់ប្រជាជនកម្ពុជា១៥.០០០នាក់ដែលបានចូលមកគុកទួលស្លែង ។ អតីតអ្នកយាមគុកដែលធ្លាប់ធ្វើការក្រោមបញ្ជា ឌុច បានប្រាប់តុលាការខក្រិដ្ឋកម្មសង្រ្គាមរបស់អង្គការសហប្រជាជាតិថា គាត់និងអ្នកយាមគុកដទៃទៀតត្រូវបានបង្ខំឲ្យចូលរួមប្រជុំស្វ័យទិតៀនដើម្បីបង្កើនប្រសិទ្ធភាពការងារនៅពេលធ្វើការឲ្យ ឌុច ។ អ្នកយាមម្នាក់ឈ្មោះ ចាន់ ខន បានិយាយថា គាត់ខ្លាច ឌុច ណាស់ គាត់ «មិនហ៊ានមើលមុខរបស់ ឌុច ទេ» នៅពេលដែលគាត់ធ្វើការនៅក្រោម ឌុច នៅឯមន្ទីរសន្តិសុខម-១៣ របស់ចលនាកុម្មុយនីស្តនៅដើមទសវត្សរ៍៧០ ។ ឌុច តែងតែព្រមានកម្មាភិបាលរបស់គាត់ថាប្រសិនបើកម្មាភិបាលទាំងនោះមិនសូវចូលរួមប្រជុំទិតៀន កម្មាភិបាលទាំងនោះនឹងត្រូវដាក់ទណ្ឌកម្មពីបទមិនគោរពតាមភារកិច្ចដែលកំណត់ឲ្យ ។ ខន បាននិយាយបន្ថែមទៅកាន់តុលាការខក្រិដ្ឋកម្មសង្រ្គាមថា «គ្មាននរណាម្នាក់ហ៊ានទិតៀន ឌុច នោះទេ ពីព្រោះ ឌុច គឺជាប្រធានមន្ទីរសន្តិសុខ នរណានឹងហ៊ានប្រថុយទិតៀនគាត់ វិសុទ្ធកម្មតែងតែធ្វើឡើងបន្ទាប់ពីការប្រជុំទិតៀនអំពីគោលនយោបាយរបស់មេដឹកនាំ ។ ការប្រជុំស្វ័យទិតៀនមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងជំងឺផ្លូវចិត្តដូចជា ការបាក់ទឹកចិត្ត ការញាំុមិនមានរបៀបរៀបរយនិងការថប់អារម្មណ៍ ។ ចំណុចនេះធ្វើឲ្យមានភាពជឿជាក់លើខ្លួនឯងមានកម្រិតទាប ។ យោងទៅតាម ឌីបូរ៉ា វ៉ នើ បានបញ្ជាក់ថា «គ្រប់ៗគ្នាមានគំនិតផ្ទាល់ខ្លួន ប៉ុន្តែការគិតអវិជ្ជមានអាចកំណត់ពីទង្វើរបស់យើង» ។ ភាគច្រើនការប្រជុំស្វ័យទិតៀនគឺជាកំហុសនិងឈ្នះលើខ្លួនឯង ។ ម៉ែនទូល ឡុនដុន លើកឡើងថា មេដឹកនាំដែលមានការវាយតម្លៃខ្ពស់នឹងចូលរួមនៅក្នុងការប្រជុំស្វ័យទិតៀនក្លាយជាចុះអន់ខ្សោយ ។ លទ្ធផលនៃការអនុវត្តរបស់អ្នកទាំងនេះមានការធ្លាក់ចុះយ៉ាងខ្លាំង ។ មេដឹកនាំទាំងនោះបានកំណត់កម្រិតខ្ពស់និងមានជំនឿជឿជាក់លើខ្លួនឯងជ្រុល ។ មេដឹកនាំទាំងនេះត្រូវបង្ហាត់និងឲ្យជំបូន្មានជាពិសេសនៅពេលដែលទទួលការទិតៀនមកវិញ ។ ជាចុងក្រោយ ស្វ័យទិតៀនត្រូវបានប្រើសម្រាប់ជួយកម្មាភិបាលឲ្យយល់អំពីការរៀបការដែលរៀបចំថ្មីៗ ។ ការរៀបការថ្មីៗនេះនឹងប្រាប់ទៅអ្នកដទៃ

អំពីទំនាក់ទំនងនេះប្រសិនបើមហាជនមិនយល់ព្រមទេនោះនឹងត្រូវបានប្រាប់ឲ្យលែងលះ ។

**ទង់បដិវត្តន៍ ៖ ទស្សនាវដ្ដីឃោសនា**




រូបគម្របមុខទស្សនាវដ្ដីទង់បដិវត្ត

ទង់បដិវត្តន៍ជាទស្សនាវដ្ដីមួយក្នុងចំណោមទស្សនាវដ្ដីបីដែលត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ខែនិងចែកចាយទូទាំងប្រទេស ។ ទស្សនាវដ្ដីនេះចាប់ផ្ដើមបោះពុម្ពផ្សាយនៅឆ្នាំ១៩៧៥ គឺរយៈពេលបួនខែមុនពេលឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ទស្សនាវដ្ដីមានចំណងជើងថា «យុទ្ធជននិងយុទ្ធនារីបដិវត្តន៍» បានផ្សព្វផ្សាយលេខទីមួយរបស់ខ្លួននៅខែមករា ឆ្នាំ១៩៧៤ ដោយបញ្ចប់ការផ្សព្វផ្សាយរបស់ខ្លួនពីរខែមុនការឈ្លានពានរបស់វៀតណាម ។ ទង់បដិវត្តន៍មិនដែលកំណត់ទំព័រជាអតិបរមាក្នុងការផ្សព្វផ្សាយទេ ទំព័ររបស់ទស្សនាវដ្ដីនីមួយៗខុសៗគ្នា ឧទាហរណ៍លេខខ្លះមានតែ២៩ទំព័រទេ ដែលចេញនៅខែមេសា ឆ្នាំ១៩៧៧ ហើយលេខខ្លះមាន១៣៣ទំព័រ ដែលចេញនៅខែកញ្ញា ឆ្នាំ១៩៧៧ ចំពោះបញ្ហាធម្មតាមាន៧៥ទំព័រ ។ ការសែតបដិវត្តន៍និងអត្ថបទផ្សព្វផ្សាយដទៃទៀតជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដែលបានប្រើដោយខ្មែរក្រហមដើម្បីបញ្ចុះបញ្ចូលប្រជាជនកម្ពុជាពីសារសំខាន់របស់ការបង្រួបបង្រួមនៅក្នុងបដិវត្តន៍ ដើម្បីបំបាត់ការតស៊ូវណ្ណៈ និងអ្វីដែលម៉ាក្សហៅថា «ការជិះជាន់ដែលព្រៃផ្សៃ» ។ ភាគច្រើនមានតែកម្មាភិបាលខ្មែរក្រហមទេបានទទួលទស្សនាវដ្ដីមួយច្បាប់នៃការផ្សព្វផ្សាយនោះ គឺមានតែឯកសារប៉ុណ្ណោះដែលអនុញ្ញាតឲ្យកម្មាភិបាលខ្មែរក្រហមអាន ។ អត្ថបទទាំងនោះបានរំឭកប្រវត្តិរបស់បក្សកម្មុយនីស្តកម្ពុជាដោយដកស្រង់សុន្ទរកថាពីមុនរបស់បក្សដែលនិយាយដោយកម្មាភិបាលជាន់ខ្ពស់របស់បក្ស និងផែនការសម្រាប់អនាគតដើម្បីអនុវត្តគោលនយោបាយនៅថ្ងៃក្រោយ ។

កូតានៃផលិតផលត្រូវបានពិភាក្សាយ៉ាងលម្អិតនៅក្នុងទស្សនាវដ្ដីនេះ ។ វោហាសាស្ត្របដិវត្តន៍ទាំងនេះបានបង្ហាញពីការលើកសរសើរកម្មាភិបាលទាំងនោះនិងការដឹកនាំដែលគួរឲ្យចង់គោរព ។ ឧទាហរណ៍ថាការដឹកនាំដោយមានការតាំងចិត្តយ៉ាងសាហាវព្រៃផ្សៃ និងខំប្រឹងធ្វើការដែលមានគោលបំណងចុងក្រោយដើម្បីចង់ឃើញភាពជោគជ័យរបស់បដិវត្តន៍ ។

**សាលាអភិវឌ្ឍភាពដឹកនាំ**

ហុង ចក ចាំថាខ្លួនធ្លាប់ជាបេក្ខជនពេញសិទ្ធិក្នុងចំណោមបេក្ខជនដទៃទៀតដែលត្រូវបានជ្រើសរើសឲ្យទៅសិក្សាភាពដឹកនាំនៅឯភ្នំពេញ ។ គាត់មានមោទនភាពខ្លាំងណាស់ដែលត្រូវបានគេជ្រើសរើសមកសិក្សាបែបនេះ ពីព្រោះថាក្លាយជាមេដឹកនាំគឺអ្វីដែលខ្មែរក្រហមនិយាយគ្រប់ពេលទៅកាន់ប្រជាជនក្រីក្រតាមរយៈយុទ្ធនាការឃោសនា ។ គាត់បានរំឭកថា «រៀនសូត្រមានការលំបាក» និងមានវិន័យជាច្រើន ។ មេដឹកនាំវ័យក្មេងទាំងនេះទាមទារឲ្យស្លៀកសម្លៀកបំពាក់ជាឯកសណ្ឋាន ហើយឲ្យមានភាពអត់ធន់និងចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនយោបាយឲ្យបានច្រើន ។ គ្រូបង្រៀនមេដឹកនាំទាំងនោះអំពីអង្គការនិងការធ្វើខុសដែលពាក់ព័ន្ធនឹងមូលធននិយម ។ ការពង្រឹងការអប់រំនេះជារឿងសំខាន់របស់បដិវត្តន៍និងរបៀបដែលបំណងរបស់កសិករក្នុងការបំបាត់ប្រព័ន្ធវណ្ណៈដើម្បីបង្កើតជាតិមួយដែលមានភាពស្មើគ្នា ។

ក្នុងនាមជាមេដឹកនាំថ្មី អ្នកទាំងនេះត្រូវមានទំនួលខុសត្រូវ

ដោយផ្ទាល់ដើម្បីជួយអង្គការក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងពួកអាក្រក់ បុគ្គលនិយមបញ្ញាជននិងជនក្បត់ ។ ក្នុងអំឡុងពេលប្រជុំបំពាក់បំប៉ននយោបាយ អ្នកទាំងនេះត្រូវបានបង្រៀនឲ្យចោទប្រកាន់ខ្លួនឯងនិងមិត្តភក្តិពីអ្វីដែលមិនគោរពតាមគោលការណ៍របស់អង្គការ ។ ក្នុងពេលប្រជុំទិតៀននេះ ចក បញ្ជាក់ថាអ្វីដែលល្អបំផុតដើម្បីធ្វើគឺក្រោកឈរឡើងឲ្យត្រង់ខ្លួនហើយសម្តែងភាពអាម៉ាស់ ហើយនិយាយទៅកាន់យោធាខ្មែរក្រហមថា «ខ្ញុំសារភាព» ។ ម្នាក់ៗត្រូវបានតម្រូវឲ្យធ្វើដូច្នេះទោះបីអ្នកជាជនស្លូតស្លំនៃការចោទប្រកាន់នេះក៏ដោយ ។ ចក និយាយថា មេដឹកនាំវ័យក្មេងទាំងនោះមិនបានចាប់អារម្មណ៍នឹងការពិតទេ «គេពេញចិត្តនឹងការចោទប្រកាន់នេះ» ។ វិន័យគឺតាមរយៈការអប់រំនិងស្វ័យទិតៀន ។ កម្មាភិបាលមុនបដិវត្តន៍ជាដំបូងត្រូវបានជឿថាគ្មានមនោសញ្ចេតនាអំពីជីវិតមនុស្សពីព្រោះគេអាចសម្លាប់មនុស្សដូចសម្លាប់មូស ។ អ្នកទាំងនេះមិនមានអារម្មណ៍អាណិតអាសូរពីជីវិតមនុស្សឡើយ ពីព្រោះអ្នកទាំងនេះត្រូវបានអប់រំឲ្យធ្វើតាមវិន័យទៅហើយ ។ សាលាប្រឡាច់បញ្ចូលជាមួយនឹងការផ្សារពីព្រោះមាគ៌ាបក្សបានគិតថាអ្នកណាដែលមានជំនាញមុខវិជ្ជានៅក្នុងការបណ្តុះឲ្យមានបញ្ញាជននិយម វរជននិយមដែលជាលទ្ធផលនៅក្នុងដំណោះស្រាយដោយទ្រឹស្តីនិងបទពិសោធន៍ជាក់ស្តែងចំពោះបញ្ហាពិតប្រាកដ ។

## សមាសភាពដែលជះឥទ្ធិពលដល់គុណភាពនៃការអប់រំ

ជាការពិតណាស់ថា បរិស្ថានជុំវិញនៅក្នុងការអប់រំត្រូវបានរៀបចំឡើងនោះអាចធ្វើឲ្យមានផលអាក្រក់ដល់អ្នកសិក្សា ។ តាមបទសម្ភាសន៍ខ្លះបានសប្បាយនឹងការអប់រំដែលបានទទួលពីរបបខ្មែរក្រហម ហើយនិងមិនត្អូញត្អែរនឹងស្ថានភាពជុំវិញឡើយ ។ អ៊ុង ប៊ុនហៀង ជាអ្នករស់រានមានជីវិតពីរបបនេះនិយាយថា សាលាដែលគាត់ទៅរៀននៅឯភ្នំអានដុង ខេត្តព្រៃវែង គឺមានគុណភាពអប់រំខ្ពស់ ។ ក្មេងៗចូលសាលាទៅរៀននៅពេលព្រឹកនៅក្នុងក្រោលគោ ។ មានភាពដូចគ្នានៃកម្រិតថ្នាក់ជាក់លាក់រវាងស្ថានភាពជុំវិញថ្នាក់តាមតំបន់ថ្នាក់រៀនធ្វើនៅក្នុងរោងសេះនិងរោងសហករណ៍ឬនៅក្នុងកន្លែងជាច្រើនទៀតគឺនៅខាងក្រោមដូច «នៅលើដីផ្ទាល់ ហើយដើមឈើចាស់ធ្វើជាដំបូល» ។ មិនតែប៉ុណ្ណោះ គ្រូបង្រៀនធ្វើឲ្យមានឥទ្ធិពលអាក្រក់ដល់ការសិក្សាអប់រំ ។ ជាទូទៅ គ្រូបង្រៀនត្រូវបានជ្រើសរើសដើម្បីឲ្យបង្រៀននៅក្នុងរបបខ្មែរក្រហមជាប្រជាជនមូលដ្ឋានដែលជាធម្មតាមានចំណេះដឹងតិចតួចឬគ្មានចំណេះដឹង គ្មានគរុកោសល្យបង្រៀនហើយមកពីជនបទ ។ ចំណុចមួយទៀតដែលជះឥទ្ធិពលដល់គុណភាពនៃប្រព័ន្ធអប់រំគឺកង្វះសម្ភារសិក្សាឲ្យសិស្ស ។ អ៊ុង ប៊ុនហេង ចាំថាសិស្សដែលបានចូលរៀន សរសេរនឹងក្រដាសផលិតពីបាវស៊ីម៉ង់ត៍ ។ ក្រសួងអប់រំបានផ្តល់ឲ្យសៀវភៅពុម្ពដែលមានចំនួនមានកំណត់សម្រាប់គ្រូបង្រៀន ប៉ុន្តែសិស្សដែលចូលរៀនគ្មានខ្មៅដៃ សៀវភៅពុម្ព ហើយត្រូវតែធ្វើដី-សធ្វើពីដីឥដ្ឋ ។ សិស្សទាំងអស់ត្រូវតែធ្វើសម្ភារសិក្សាសំខាន់ៗដោយខ្លួនឯងដែលប្រហែលធ្វើឲ្យបាក់ទឹកចិត្តរៀនសូត្រនៅក្នុងថ្នាក់រៀន ។ មេដឹកនាំបក្សបានកំពុងព្យាយាមធ្វើឲ្យសិស្សដល់ចំណុចមួយដែលម្ចាស់ការលើខ្លួនឯង ។ ទោះបីសិស្សបានទទួលអាហារូបត្ថម្ភបន្ថែមដើម្បីឲ្យបានចូលរៀនក៏ដោយ ក៏សិស្សទាំងនោះនៅតែទទួលអាហារមិនគ្រប់គ្រាន់ជាមួយនឹងការធ្វើការហួសកម្លាំងអស់រយៈពេលកន្លះថ្ងៃដែលធ្វើឲ្យសិស្សខ្សោយ ។



ការរៀនលេខនព្វន្ត នៅខែសីហា ឆ្នាំ១៩៧៨

កម្មវិធីរបស់សាលាភាគច្រើនគឺស្រដៀងគ្នានឹងធម្មជាតិដូចជាចម្រៀងបដិវត្តន៍ ការប្រើពាក្យស្លោកដើម្បីពង្រឹងគំនិតបដិវត្តន៍ឲ្យសិស្សម្នាក់ៗ ហើយនិងកម្មវិធីសិក្សាដែលផ្តោតលើអក្សរសាស្ត្រនិងលេខនព្វន្ធ ។ ជាទូទៅមានបួនកម្រិតសម្រាប់កុមារដែលត្រូវបង្រៀនទីមួយក្មេងគឺរៀនពីរបៀបអាននិងសរសេរទោះបីប្រព័ន្ធអប់រំមានភាពយឺតយ៉ាវជាងប្រព័ន្ធអប់រំរបស់បស្ចិមប្រទេសក៏ដោយ ។ ទីពីរ សិស្សត្រូវបានបង្រៀនពីមូលដ្ឋានគ្រឹះរបស់គណិតវិទ្យា ។ ទីបី ការអប់រំសិក្សាមានការបង្រៀនចម្រៀងបដិវត្តន៍ដែលជាទូទៅចម្រៀងដែលនិយាយអំពីការប្តេជ្ញាចំពោះអង្គការ» ។ ចុងក្រោយសិស្សទាំងអស់ត្រូវបានបង្រៀនយ៉ាងហ្មត់ចត់អំពីមនោគមន៍វិជ្ជាសង្គមនិយមនិងសមភាពនិយម ។ ផ្នែកខ្លះនៃកម្រិតចុងក្រោយនេះ សិស្សត្រូវបានបង្រៀនអំពីតម្រូវការនិងសារសំខាន់នៃការខំប្រឹងប្រែងធ្វើការអ្វីដែលផ្តល់ប្រយោជន៍ដល់អង្គការនិងទាំងអស់គ្នានិងពីគ្រោះថ្នាក់ដោយប្រទេសជិតខាងវៀតណាម ។ សៀវភៅពុម្ពភូមិវិទ្យាមួយបានប្រើប្រព័ន្ធអប់រំរបស់របបសម្តេចព្រះនរោត្តម សីហនុ គឺស្រដៀងគ្នានឹងសៀវភៅពុម្ពភូមិវិទ្យារបស់របបកម្ពុជាប្រជាធិបតេយ្យដែលបោះពុម្ពនៅឆ្នាំ១៩៥៧មានចំណងជើងថា «ភូមិវិទ្យារបស់ប្រទេសកម្ពុជានិងខ្យល់មូសុងរបស់ទ្វីបអាស៊ី» ដែលបានបញ្ជាក់ថា អង្ករគឺជាដំណាំមូលដ្ឋានរបស់ប្រទេស ដូច្នេះអង្ករគួរតែជាមូលធនសម្រាប់កសាងនិងការពារប្រទេសកម្ពុជា ។ សៀវភៅពុម្ពកម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់ពាក្យបដិវត្តន៍យ៉ាងមានប្រសិទ្ធភាពតាមរយៈសៀវភៅពុម្ពនេះ ឧទាហរណ៍អង្ករមានសារសំខាន់សម្រាប់កសាងនិងការពារសត្រូវពីខាងក្រៅយ៉ាងមានប្រសិទ្ធភាពដែលសត្រូវត្រូវបានចាត់ទុកភាគច្រើនថាជាវៀតណាមនិងរួមទាំងសហរដ្ឋអាមេរិកផង ។ មេដឹកនាំខ្មែរក្រហមមានបំណងបញ្ចុះបញ្ចូលសិស្សថាជនជាតិវៀតណាមសាហាវព្រៃផ្សៃនិងផ្តាច់ការដោយថានរណាដែលធ្លាប់ទៅប្រទេសវៀតណាមឬថៃគឺជាសត្រូវរបស់បក្ស ។

## ខ្មែរក្រហម ៖ ដំឡើងឋានៈ និងឃុំខ្លួនកម្មាភិបាល

អ្នកដែលចូលយោធាបានឡើងឋានៈតាមរយៈគុណូបការៈនិងចូលអង្គការបក្សដោយសារការអប់រំនេះបានដាស់សតិអារម្មណ៍នយោបាយ ។ ការអនុវត្តការងារជួយដល់ការជ្រើសរើសសម្រាប់អង្គភាពស្នូលជំហានទីមួយដើម្បីក្លាយជាបក្សជនត្រៀម ។ ការដំឡើងមុខតំណែងសម្រាប់កម្មាភិបាលថ្នាក់ក្រោមចាប់ផ្តើមតាមរយៈភាពស្មោះត្រង់មុនសម័យបដិវត្តន៍ ។ នោះគឺភាពស្មោះត្រង់ចំពោះបក្សនិងរបៀបដែលកម្មាភិបាលថ្នាក់ក្រោមបង្ហាញពីភាពស្មោះត្រង់ចំពោះបក្សគឺជាកត្តាសំខាន់ក្នុងការដំឡើងឋានៈក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៨ ។ បេក្ខជនដែលមានសមត្ថភាពសម្រាប់ការដំឡើងឋានៈត្រូវមានប្រវត្តិរូបស្អាតស្អំ ។ លើសពីនេះទៅទៀតនៅខែកក្កដាឆ្នាំ១៩៧៧ កម្មាភិបាលជាន់ខ្ពស់របស់បក្សបានពិភាក្សាគ្នានៅភូមិភាគបស្ចិមថា «ការពង្រឹងបក្សជាដំបូងពឹងផ្អែកលើការពិនិត្យលើប្រវត្តិរូបដើម្បីបែងចែកកម្មាភិបាលល្អចេញពីកម្មាភិបាលអាក្រក់» ។ ក្រោយមកការសម្រេចនេះបានផ្លាស់ប្តូរបន្តិចបន្តួចពីព្រោះកម្មាភិបាលជាន់ខ្ពស់របស់បក្សចាប់ផ្តើមជឿថា «ប្រវត្តិរូបកាលមុនមិនជឿជាក់បាននោះទេ ដើម្បីកសាងសមាជិកបក្សថ្មី» ។ អ្នកទាំងអស់គ្នាត្រូវបានដំឡើងឋានៈនៅក្នុងជួរដឹកនាំបក្សរួមទាំងក្នុងភូមិភាគ ផ្នែកក្រសួង ការិយាល័យ និងយោធាផង» ។ គ្មានការលើកទឹកចិត្តជាសម្ភារសម្រាប់បំពេញការងារច្រើនជាងការបរិច្ចាគនិងការខិតខំប្រឹងប្រែងចំពោះការងារឡើយ ។ នៅក្នុងប្រព័ន្ធការងារពលកម្ម ម្នាក់ៗត្រូវធ្វើតាមបទបញ្ជា ។ ការលើកទឹកចិត្តមួយគឺថាប្រសិនបើកម្មាភិបាលបង្ហាញពីភាពខិតខំប្រឹងប្រែងអស់រយៈពេលយូរ នោះនឹងទទួលបានឋានៈជាប្រជាជនមូលដ្ឋានដែលត្រូវបានដំឡើងឲ្យមានឋានៈខ្ពស់ ។ ការដំឡើងនេះមិនត្រឹមតែបានឋានៈដូចប្រជាជនមូលដ្ឋានទេ ថែមទាំងមិនត្រូវបានយកទៅសម្លាប់ទៀតផង ទោះបីជាយ៉ាងណាក៏ដោយ ក៏ការដំឡើងឋានៈនៅក្នុងតំបន់នោះនឹងធ្វើឲ្យមានវិសុទ្ធកម្មច្រើន ។ មេដឹកនាំដែលមិនផ្តល់រង្វាន់ឬការលើកទឹកចិត្តសម្រាប់ការងារដែលបានបំពេញដោយអ្នកក្រោមឱវាទគឺពិតជាមិនមែនមានសីលធម៌ការងារខ្ពស់នោះទេ ។ មានការលុបបំបាត់ចោលនូវការលើកទឹកចិត្តជាបុគ្គលតាមការស្នើដោយកម្មាភិបាលបក្សជាន់ខ្ពស់ ។ ការលុបបំបាត់នេះមានភាពស្រដៀងគ្នានឹងវាងបដិវត្តន៍របស់ ម៉ៅ និង ប៉ុល ពត ដែលជាការបំបាត់ចោលនូវការលើកទឹកចិត្តជាបុគ្គលនិងការប្រើប្រាស់លុយ ។ រង្វាន់ត្រូវបានដឹងថានឹងធ្វើឲ្យមានចំណង់និយមដែលមិនត្រូវនឹងសង្គមនិយម ។ ការផ្លាស់ប្តូរសង្គមគឺជាគំនិតរបស់ ម៉ៅ ដែលអាច

ឲ្យកសិករនិងប្រជាជនថ្មីខំធ្វើការនិងកាន់តែមានប្រសិទ្ធភាព ។ ជាមួយនឹងការលុបបំបាត់លុយធ្វើឲ្យមានផលប៉ះពាល់អាក្រក់ដល់សេដ្ឋកិច្ចកម្ពុជា ។ ការបង្កើតឲ្យមានបរិស្ថានការងារមានភាពដូចគ្នានឹងមានន័យថាប្រជាជនកម្ពុជាគ្មានផ្លូវបង្កើតឲ្យមានសម្ភារមានតម្លៃទេ ។

រង្វាន់លើកទឹកចិត្តមួយសម្រាប់កម្មាភិបាលនិងប្រជាជនធម្មតាគឺមានសិទ្ធិរស់នៅក្នុងប្រពន្ធ័សង្គមនិយម ។ មនុស្សមួយចំនួនបានទទួលការលើកទឹកចិត្តឲ្យមានឱកាសចូលរួមហ៊ឹកហ៊ឺននៅសាលាបច្ចេកទេស ។ ភ័ស្តុតាងតាមរយៈសក្ខីកម្មបានអះអាងថា ខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនមូលដ្ឋានស្នើដើម្បីបានចូលសាលាបច្ចេកទេសនេះ ។ អ៊ឹង វុធ បន្ទាប់ពីត្រូវបានបង្ខំឲ្យរៀបការជាមួយនឹងកម្មាភិបាលខ្មែរក្រហមម្នាក់ភ្លាមបានស្នើឲ្យចូលរួមក្នុងការហ៊ឹកហ៊ឺនបច្ចេកទេសស្តីការពន្ធុតកូននៅឯមន្ទីរពេទ្យ១៧មេសារយៈពេលមួយឆ្នាំ» ។ ញ៉ែម អេន ត្រូវបានដំឡើងតំណែង ហើយត្រូវបានបញ្ជូនមកភ្នំពេញ ។ នៅភ្នំពេញ គាត់កាន់តែមានសមត្ថភាព ។ ញ៉ែម អេន ត្រូវបានបញ្ជូនឲ្យមកសិក្សាវិទ្យាសាស្ត្រនយោបាយនិងយុទ្ធសាស្ត្រយោធានៅឯសាលាបច្ចេកទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ញ៉ែម អេន ត្រូវបានដំឡើងជាកងយុវជនឆ្នើមម្នាក់ ហើយបញ្ជូនឲ្យទៅហ៊ឹកហ៊ឺននៅប្រទេសចិននៅចុងឆ្នាំ ១៩៧៦ នៅពេលគាត់មានអាយុ១៥ឆ្នាំ ។ នៅពេលដែលក្រុមឆ្នើមនេះទៅដល់ទីក្រុងប៉េកាំង អ្នកទាំងនោះត្រូវបានបែងចែកដោយមួយចំនួនបញ្ជូនទៅហ៊ឹកហ៊ឺនខាងយោធាជើងគោកនិងជើងទឹកមួយចំនួនទៅនៅខស្សរាហកម្ម ឬក៏កសិកម្ម ។ ញ៉ែម អេន ត្រូវបានជ្រើសរើសឲ្យទៅរៀនខាងថតរូប ។ នៅពេលត្រឡប់មកទីក្រុងភ្នំពេញវិញ ញ៉ែម អេន ត្រូវបានចាត់តាំងឲ្យទៅនៅមន្ទីរ៨៧០ នៅក្រសួងការពារជាតិក្រោមបញ្ជារបស់ ប៉ុល ពត ដែលជាតំណែងមួយដ៏មានកិត្តិយស ។ កម្មករនៅតំបន់តាបាំងត្រូវបានលើកទឹកចិត្តសម្រាប់ការងាររបស់ខ្លួនដោយគិតទៅលើគោលនយោបាយរបស់ខ្មែរក្រហមក្នុងការលើកទឹកចិត្ត ។ ប្រជាជនមិត្តថ្មីជាទូទៅត្រូវបានលើកទឹកចិត្តឲ្យសម្រាកនិងបន្ថែមអាហារសម្រាប់ការបំពេញការងារលំបាកទាន់ពេលវេលា ។ យឹមស៊ុត និយាយថាគាត់បានឡើងទម្ងន់ម្តងទៀតហើយ ហើយមានសុខភាពល្អទៀត ។ ទោះបីឈប់សម្រាក មិនបានពេញមួយថ្ងៃក៏ដោយ ក៏យឹមស៊ុត គិតថាគាត់មានពេលសម្រាកច្រើននៅក្នុងខ្ទមរបស់គាត់នៅក្នុងតំបន់តាបាំងជាងកន្លែងផ្សេងទៀតក្នុងរយៈពេលពីឆ្នាំចុងក្រោយ ។ **ហ្វ្រីហ្គារី ប្រូកណូ**



អ្នកភូមិ និងនិស្សិតទស្សនកិច្ចសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

# វេទិកាពិភាក្សាបញ្ហាតុលាការខ្មែរក្រហមនៅភ្នំវល្លិ៍

ភ្នំវល្លិ៍ គឺជាតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៩៥ ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ អាជ្ញាធរនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរាយការណ៍ជាប្រចាំអំពីការវាយប្រហាររថភ្លើងកំពតភ្នំពេញនៅក្នុងតំបន់នេះនិងការស្លាប់របស់អ្នកដំណើរជាច្រើននាក់ ។ យោងតាមកំណត់ហេតុប្រជុំរបស់មន្ទីរគណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្តកំពតបានឲ្យដឹងថា កាលពីមុនខែមិថុនាឆ្នាំ១៩៨១ ប៉ែត (នួន ប៉ែត) បានរៀបចំមូលដ្ឋានទ័ពនៅភ្នំវល្លិ៍ដែលមានសមាជិកចំនួន១២នាក់ ។ ជាទូទៅ តំបន់នេះមានអតីតខ្មែរក្រហមប្រមាណជា៧០នាក់ដែលមានសកម្មភាពចូលបន្លំខ្លួនជាមួយនឹងអ្នកស្រុកប្រឈមមុខគ្នានឹងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងសកម្មភាពប្លន់និងកេណ្ឌអ្នកស្រុកឲ្យចូលរួមបុ



ផ្លូវរថភ្លើងជាកន្លែងដែលជនបរទេសបីនាក់ត្រូវខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៩៤

ទិញគ្រឿងឧបភោគ បរិភោគពីអ្នកស្រុក ។

មកដល់ឆ្នាំ១៩៩៤ ខ្មែរក្រហមនៅក្នុងតំបន់នេះបានធ្វើការពង្រីកសកម្មភាពរបស់ខ្លួនដើម្បីប្លន់និងចាប់ជម្រិតអ្នកទេសចរបរទេស ។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៤ អ្នកដំណើរជនជាតិអាមេរិកកាំងឈ្មោះ មេលីសា ហ៊ីមស៍ ត្រូវបានចាប់ជម្រិតដោយកងកម្លាំងរបស់ខ្មែរក្រហមនៅជិតភ្នំវល្លិ៍ ហើយត្រូវបានដោះលែងមកវិញនៅខែឧសភាជាថ្នូរនឹងទឹកប្រាក់៥០០០ដុល្លារ និងម្ហូបអាហារនិងគ្រឿងសំណង់ពេញមួយរថយន្តធំដែលចំនួននេះជាការកាត់បន្ថយពីការទាមទារដំបូង ។ ដំបូងឡើយ កងកម្លាំងខ្មែរក្រហមទាមទារប្រាក់ចំនួនដល់ទៅប្រាំម៉ឺនដុល្លារ ។ ឆ្ងាយពីកន្លែងដែលមេលីសា ហ៊ីមស៍ ត្រូវបានចាប់ខ្លួនអ្នកទេសចរជនជាតិអូស្ត្រាលីខែលី វីលឃីនសុន និងអ្នករួមដំណើរជនជាតិអង់គ្លេសពីរនាក់ទៀតត្រូវបានចាប់ខ្លួននិងសម្លាប់នៅថ្ងៃទី១១ខែមេសាឆ្នាំដដែលនោះ ។ បន្ទាប់មក នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៤ កងកម្លាំងខ្មែរក្រហមដែលមានមូលដ្ឋាននៅភ្នំវល្លិ៍បានស្ទាក់វាយប្រហារទៅលើរថភ្លើងដឹកទំនិញពីភ្នំពេញទៅក្រុងព្រះសីហនុធ្វើឲ្យជនជាតិខ្មែរស្លាប់១៣នាក់ ។ ខ្មែរក្រហមបានស្ទាក់ប្លន់ចាប់ជម្រិតអ្នកដំណើរជនជាតិអូស្ត្រាលី ដេវីដ វីលសុន ជនជាតិបារាំង ហ្សង់ មីសែលប្រាកែត និងជនជាតិអង់គ្លេស ម៉ាកស្លែតធ័រ ។ អ្នកទេសចរទាំងបីនាក់ត្រូវបានចាប់ទុកដើម្បីធ្វើជាថ្នូរនឹងទឹកប្រាក់ចំនួន១៥ម៉ឺនដុល្លារ ក្រោយពីការចរចាគ្នាអស់រយៈពេលជិតពីរខែ ។ នៅពេលដែលរដ្ឋាភិបាលកម្ពុជាបានបើកការបង្ក្រាបផ្នែកយោធាទៅលើភ្នំវល្លិ៍ខ្មែរក្រហមម្នាក់ (ទោះជាមិនមានព័ត៌មានច្បាស់ការថាជាអ្នកណាប្រាកដក៏ដោយ) បានសម្រេចចិត្តសម្លាប់ជនបរទេសទាំងបី ។ របាយការណ៍តាមកាសែតបានបញ្ជាក់ថា អ្នកទាំងបីត្រូវបានបញ្ជាឲ្យជីករណ្តៅដោយខ្លួនឯងនិងវាយរហូតដល់ស្លាប់ដែលហេតុការណ៍នេះប្រហែលជាកើតឡើងនៅថ្ងៃទី២៨ខែកញ្ញា ។ ព័ត៌មានបន្ថែមអំពីប្រវត្តិសាស្ត្រនៅក្នុងតំបន់នេះនិងទស្សនៈផ្សេងៗអំពីការសម្លាប់ជនបរទេសនៅឆ្នាំ១៩៩៤ នឹងមានបង្ហាញនៅក្នុងបទសម្ភាសន៍ខាងក្រោម ។

ការទទួលខុសត្រូវចំពោះការសម្លាប់នេះ អតីតកម្មាភិបាលខ្មែរក្រហមបីនាក់ត្រូវបានកាត់ទោសឲ្យជាប់គុកមួយជីវិតទោះបីជា



កងទ័ពរដ្ឋាភិបាលវាយប្រហារ និងសម្លាប់ទាហានខ្មែរក្រហមនៅឆ្នាំ១៩៨៣

ពីរនាក់ក្នុងចំណោមអ្នកទាំងបីមានសិទ្ធិទទួលបាននូវការលើកលែងទោសពីការចោទប្រកាន់ដោយសារតែគាត់បានចុះចូលជាមួយរដ្ឋាភិបាលក្រោយពីការស្ទាក់វាយប្រហារបន្តិចក៏ដោយ លោកឧត្តមសេនីយ៍ នួន ប៉ែត ជាអតីតមេបញ្ជាការកងពល៤០៥ របស់ខ្មែរក្រហមនិងជាមេបញ្ជាការមូលដ្ឋានទ័ពនៅភ្នំវល្លិ៍ត្រូវបានចាប់ខ្លួននិងដាក់ទោសឲ្យជាប់គុកមួយជីវិតនៅឆ្នាំ១៩៩៩ ពីបទបញ្ជាឲ្យមានការសម្លាប់ជនបរទេសទាំងបី ។ មេបញ្ជាការពីរនាក់ទៀតដែលធ្លាប់ទទួលតំណែងជាមន្ត្រីជាន់ខ្ពស់នៅក្នុងកងយោធពលខេមរភូមិន្ទក្រោយពីផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលត្រូវបាននាំយកទៅកាត់ទោសរយៈពេលពីរបីឆ្នាំក្រោយមក ។ សំ ប៊ិត ដែលជាមេបញ្ជាការទ័ពជាន់ខ្ពស់នៅភូមិភាគនិរតីហើយដែលត្រូវបានរកឃើញថាជាអ្នករៀបចំផែនការចាប់ខ្លួននិងបញ្ជាឲ្យសម្លាប់ ត្រូវបានកាត់ទោសឲ្យជាប់គុកនៅឆ្នាំ២០០២និងស្លាប់នៅឆ្នាំ២០០៨ ។ សំ ប៊ិត បដិសេធការចោទប្រកាន់ដោយធ្វើការបញ្ជាក់ថាគាត់ត្រូវបានផ្លាស់ចេញពីតំបន់នេះរួចទៅហើយមុនពេលដែលមានការចាប់ខ្លួនជនបរទេសទាំងបីនាក់ ។ ប៉ុន្តែ នួន ប៉ែត បានផ្តល់កសិណសាក្សីថា ប៊ិត បានបញ្ជាឲ្យមានការសម្លាប់ ។ វរសេនីយឯក ឈូក រិន ដែលត្រូវបានឲ្យដឹងថាជាអ្នកដែលបានរៀបផែនការវាយប្រហាររថភ្លើងត្រូវបានកាត់ទោសនៅឆ្នាំ២០០២ ប៉ុន្តែនៅមានសេរីភាពក្នុងពេលប្តឹងឧទ្ធរណ៍រហូតដល់ឆ្នាំ២០០៥ ។ ឈូក រិន បានអះអាងបញ្ជាក់ថា គាត់មានបំណងចរចាដើម្បីដោះលែងជនបរទេសទាំងបីនោះនៅពេលដែលគាត់បានចុះចូលជាមួយរដ្ឋាភិបាលនៅខែតុលាឆ្នាំ១៩៩៤ ប្រហែលជានៅក្រោយពេលដែលជនបរទេសនោះបានស្លាប់ទៅហើយ ។

សព្វថ្ងៃនេះ តំបន់ភ្នំវល្លិ៍មានដង់ស៊ីតេប្រជាជនទាប ហ៊ុំព័ទ្ធទៅដោយទីវាលល្ហល្ហេវ បើទោះជាផ្លូវនេះជាផ្លូវដាំដុះក៏ដោយ ។ ផ្លូវរថភ្លើងដែលជាកន្លែងជនបរទេសបីនាក់ត្រូវបានចាប់ខ្លួនមានទីតាំងស្ថិតនៅក្បែរភូមិដែលជាកន្លែងរំពុកដល់ឧក្រិដ្ឋកម្មហើយនិងផលប៉ះពាល់របស់ឧក្រិដ្ឋកម្មទាំងនោះទៅលើអ្នកស្រុក ។ បន្ថែមពីលើអតីតកម្មាភិបាលខ្មែរក្រហមដែលបានរស់នៅទីនោះប្រជាជនចំណូលថ្មីរួមបញ្ចូលទាំងជនរងគ្រោះរបស់ខ្មែរក្រហមផងបានផ្លាស់ទៅរស់នៅតំបន់នោះ ។ ទោះបីជាឃុំនេះមានចម្ងាយត្រឹមតែម្ភៃនាទីពីក្រុងទេសចរណ៍កែបដ៏មានប្រជាប្រិយក៏ដោយគ្រួសារមួយចំនួនមិនអាចរស់នៅដោយការប្រកបរបរកសិកម្មនិងការធ្វើជំនួញកំប៉ិកកំប៉ុកបានឡើយ ហើយគ្រួសារមួយចំនួនបានផ្លាស់ចេញទៅរស់នៅតំបន់



ទាហានខ្មែរក្រហមដែលរដ្ឋាភិបាលចាប់ខ្លួននៅឆ្នាំ១៩៨៣

ផ្សេងកាលពីរបីឆ្នាំមុន ។ អ្នកភូមិមួយចំនួនទៀតក៏មានបំណងចាកចេញពីតំបន់នេះក្នុងពេលឆាប់ៗនេះដែរ ។

### វេទិកាពិភាក្សានៅភ្នំវល្លិ៍

វេទិកាពិភាក្សានេះត្រូវបានប្រារព្ធឡើងនៅក្នុងបរិវេណនៃមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈសហគមន៍ភូមិចម្ការបី ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ នៅពេលដែលវេទិកានេះចាប់ផ្ដើមមានប្រជាជនប្រមាណ២០០នាក់និងកុមារមួយចំនួនធំចូលរួមមានប្រជាជនចាមមូស្លីមចំនួន២២នាក់មកពីភូមិថ្មីនិងភូមិស្បូវ (អ៊ីមាំរបស់ខេត្តកែប ហាកឹម ទូន និងស្ត្រី) លោកគ្រូអ្នកគ្រូ២០នាក់ដែលធ្លាប់មកចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលក្នុងគម្រោងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ដោយហេតុថាតំបន់នេះពុំមានអគារធំល្មមដើម្បីរៀបចំការប្រជុំនិងបញ្ចាំងខ្សែភាពយន្ត វេទិកាពិភាក្សានេះត្រូវបានរៀបចំធ្វើឡើងនៅទីវាល ។


ឡុង ដានី និងក្រុមប្រឹក្សាឃុំពងទឹក ជុំ នួង

ជុំ នួង សមាជិកក្រុមប្រឹក្សាឃុំបានធ្វើការស្វាគមន៍អ្នកភូមិដែលបានមកចូលរួម ។ នួង បានផ្ដាំផ្ញើដល់អ្នកចូលរួមទាំងអស់ឲ្យធ្វើការពិចារណាចំពោះខ្សែភាពយន្តនេះនិងបញ្ចេញទស្សនៈរបស់ខ្លួន ។ នួង មានប្រសាសន៍ថា នេះជាឱកាសដ៏កម្រមួយដែល អ្នកភូមិជាច្រើនបានមកជួបជុំគ្នាហើយអ្នកភូមិត្រូវទទួលបាននូវការស្វាគមន៍និងគោរព ។ នៅពេលដែល ជុំ នួង កំពុងថ្លែងទៅកាន់អ្នកចូលរួមលោកមេភូមិ សារឿន បានប្រាប់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាថា នួង គឺជាអតីតទាហានខ្មែរក្រហម ។ បន្ទាប់មកលោកមេភូមិ សារឿន បានមានប្រសាសន៍ថា ការប្រជុំនេះបានផ្ដល់នូវឱកាសដ៏មានតម្លៃក្នុងការបង្កើនចំណេះដឹងរបស់អ្នកស្រុកអំពីតុលាការខ្មែរក្រហមព្រមទាំងផ្ដល់ឱកាសដល់អ្នកស្រុកឲ្យបញ្ចេញទស្សនៈផ្ទាល់ខ្លួនដែរ ។

លោក វីលៀម ស្មីត សហព្រះរាជអាជ្ញារងអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានថ្លែងទៅកាន់អ្នកចូលរួមទាំងអស់ថា តុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដើម្បីនាំយកអ្នកដែលទទួលខុសត្រូវក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំទៅកាត់ទោសនិងបង្កើតឲ្យមានសង្គមមួយដែលមានសុវត្ថិភាពដើម្បីការអភិវឌ្ឍកម្ពុជានៅថ្ងៃអនាគត ។ លោកសហព្រះរាជ


សហព្រះរាជអាជ្ញារងលោក វីលៀម ស្មីត នៅក្នុងវេទិកាពិភាក្សា

អាជ្ញារងបានធ្វើការប្រៀបធៀបអំពើឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យទៅនឹងអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅប្រទេសអាល្លឺម៉ង់នៅអំឡុងសង្គ្រាមលោកលើកទីពីរ ឧក្រិដ្ឋកម្មនៅបូស្នៀនៅពាក់កណ្ដាលទសវត្សរ៍៩០និងឧក្រិដ្ឋកម្មនៅប្រទេសរ៉ាន់ដាឆ្នាំ១៩៩៤ ។ លោកសហព្រះរាជអាជ្ញារងបានមានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានសម្រេចចិត្តបង្កើតតុលាការនេះឡើងដើម្បីបញ្ជាក់ថាអំពើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបែបនេះនឹងមិនកើតឡើងសាជាថ្មីម្ដងទៀតទេ ។ ទោះបីជាតុលាការនេះមិនអាចនាំយកមនុស្សប្រព្រឹត្តខុសទាំងអស់ទៅកាត់ទោសបានក៏ដោយ ប៉ុន្តែអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនិងមេដឹកនាំជាន់ខ្ពស់នឹងត្រូវនាំយកទៅកាត់ទោសដែរ ហើយទង្វើនេះនឹងនាំទៅដល់ការបង្ហាញនិងការគោរពដល់ជនរងគ្រោះផង ។ លោកព្រះរាជអាជ្ញារងក៏បានលើកទឹកចិត្តឲ្យអ្នកចូលរួមសួរសំណួរដោយផ្ដល់ហេតុផលថា

ការិយាល័យសហព្រះរាជអាជ្ញាជាតំណាងឲ្យសង្គមកម្ពុជា ដូច្នេះ ការិយាល័យនេះចង់ដឹងពីទស្សនៈរបស់សាធារណជនដើម្បីយកទៅពិចារណា ។ អ្នកចូលរួមភាគច្រើនមិនដែលធ្លាប់ឮពីមន្ទីរឃុំឃាំង ស-២១ឡើយ ហើយក៏មានអ្នកចូលរួមពីរបីនាក់បានសួរសំណួរមួយចំនួនព្រោះគាត់ធ្លាប់បានទៅធ្វើទស្សនកិច្ចនៅតុលាការខ្មែរក្រហមក្រោមការរៀបចំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយសារសវនាការនេះនឹងកាត់ក្តីទៅលើជនជាប់ចោទទាំងបួនរូប ព្រមទាំងនិងពិភាក្សាទៅលើទីតាំងឧក្រិដ្ឋកម្មនៅពាសពេញផ្ទៃប្រទេស សវនាការអាចនឹងប្រើប្រាស់រយៈពេលប្រមាណជាមួយឆ្នាំកន្លះ ។ គាត់បានបញ្ជាក់ថា នៅពេលដែលមនុស្សគ្រប់រូបទទួលស្គាល់ថាសវនាការនេះត្រូវពន្លឿនដំណើរការរបស់ខ្លួនតាមដែលអាចធ្វើទៅបាន ជាពិសេសដោយសារតែជនជាប់ចោទទាំងអស់នោះ


អ្នកចូលរួមក្នុងវេទិកាពិភាក្សា



បុរសម្នាក់ដែលធ្លាប់បានចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងបានទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាតជើងឯក បានសួរសំណួរថា តើការកាត់ក្តីមេដឹកនាំខ្មែរក្រហមដែលនៅរស់នោះនឹងត្រូវចាប់ផ្តើមនៅពេលណា? លោក វីលៀម ស្មីត បានមានប្រសាសន៍ថា សវនាការរំពឹងថានឹងចាប់ផ្តើមនៅខែមេសាហើយ មានអាយុកាន់តែច្រើនទៅហើយ តុលាការនេះក៏ត្រូវតែផ្តល់នូវយុត្តិធម៌ដល់មនុស្សគ្រប់រូបផងដែរ ។ លោក វីលៀម ស្មីត បានមានប្រសាសន៍ថា «ប្រសិនបើជនជាប់ចោទទាំងនោះគ្រាន់តែត្រូវចាប់ខ្លួនមកហើយស្លាប់ទៅវិញ តុលាការនេះមានតួនាទីមិនខុសពីខ្មែរក្រហមទេ» ។


សហព្រះរាជអាជ្ញារង វីលៀម ស្មីត និយាយទៅកាន់អ្នកចូលរួម

ស្ត្រីម្នាក់ដែលបានចូលរួមក្នុងការប្រជុំនេះធ្លាប់បានទៅធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងទីតាំងបូជនីយដ្ឋានផ្សេងៗ បានចោទសួរថា តើមេដឹកនាំខ្មែរក្រហមទាំងបួនរូបនោះអាចនឹងទទួលទោសធំបំផុតបែបណា ។ លោកព្រះរាជអាជ្ញារង វីលៀម ស្មីត បានបញ្ជាក់ថាទាំងភាគីកម្ពុជានិងភាគីអង្គការសហប្រជាជាតិមិនគាំទ្រចំពោះការដាក់ទោសប្រហារជីវិតទេ ហេតុនេះទោសធំបំផុតចំពោះតុលាការនេះគឺការជាប់គុកអស់មួយជីវិត ។ នៅពេលដែលអ្នកស្រុកបន្តចោទសួរថាតើមានការចោទប្រកាន់ទៅលើមេដឹកនាំណាផ្សេងទៀតលើស

ពីជនជាប់ចោទទាំងបួនរូបនោះទេ។ លោក វីលៀម ស្មីត បានបញ្ជាក់ថានៅមានការស៊ើបអង្កេតបន្តទៅលើជនសង្ស័យចំនួនប្រាំរូបទៀតដែលសរុបទាំងអស់មានជនជាប់ចោទ១០រូបដែលត្រូវនាំយកមកកាត់ទោស។ ការិយាល័យសហព្រះរាជអាជ្ញាជឿជាក់ថាតួលេខនេះមានភាពស៊ីគ្នាជាមួយនឹងអាជ្ញាយុកាលរបស់តុលាការ ហើយការិយាល័យនឹងមិនធ្វើការចោទប្រកាន់បន្តទៀតទេ។ មានសំណួរមួយទៀតសួរថា ប្រសិនបើមេដឹកនាំទាំងនោះស្លាប់នៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន តើតុលាការនឹងធ្វើយ៉ាងដូចម្តេច។ លោក វីលៀម ស្មីត មានប្រសាសន៍ថាសវនាការនឹងនៅតែបន្តដំណើរការរបស់ខ្លួនជាមួយជនជាប់ចោទដែលនៅរស់ បើសិនជាមានជនជាប់ចោទណាម្នាក់ស្លាប់។ ជនជាប់ចោទទាំងអស់ត្រូវបានចាត់ទុកថាមិនមានទោសរហូតទាល់តែរកឃើញថាមានមិនកំហុស។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារបានដាក់បញ្ចាំងខ្សែភាពយន្ត «ទួលស្លែង ឆ្នាំ១៩៧៩» ជាខ្សែវីដេអូដើមថតដោយក្រុមខ្សែភាពយន្តរបស់វៀតណាមនៅពេលដែលក្រុមកងទ័ពវៀតណាមបានរកឃើញទីតាំងមន្ទីរសន្តិសុខនេះដំបូង ប៉ុន្តែការបញ្ចាំងនេះត្រូវផ្អាកទៅវិញដោយសារតែមានពន្លឺចាំងខ្លាំងនៅលើផ្ទាំងសំពត់ស ជាហេតុនាំឲ្យអ្នកទស្សនាមិនអាចមើលរូបភាពឃើញ។ ក្រុមការងារក៏មិនបញ្ចាំងខ្សែភាពយន្ត «នៅក្រោយជញ្ជាំងនៃមន្ទីរស-២១ដែរ» ដោយសារមូលហេតុដូចគ្នានេះ។ ជាអកុសល ការបញ្ចាំងនេះមិនអាចដំណើរការទៅបានដោយហេតុថាអតីតឆ្មាំគុកទួលស្លែង ហ៊ីម ហ៊ុយ ក៏មានវត្តមានក្នុងឱកាសនោះដែរ។ ហ៊ីម ហ៊ុយ ត្រូវបានធ្វើបទសម្ភាសន៍នៅក្នុងខ្សែភាពយន្តឯកសារនោះហើយវត្តមានរបស់គាត់អាចនឹងមានអត្ថន័យជាងនេះចំពោះអ្នកចូលរួមប្រសិនបើពួកគាត់អាចមើលឃើញ ហ៊ីម ហ៊ុយ និងជនរងគ្រោះនៃមន្ទីរស-២១ ធ្វើការពិភាក្សាគ្នាពីមន្ទីរឃុំឃាំងនេះនៅក្នុងខ្សែភាពយន្ត។

ទោះបីជាយ៉ាងនេះក៏ដោយ ខ្សែវីដេអូខ្លីអំពី ឌុច ធ្វើការអភ័យទោសនិងខ្សែវីដេអូអំពីការអានសាលក្រមត្រូវបានបញ្ចាំងឲ្យអ្នកចូលរួមទស្សនា។

បន្ទាប់ពីការបញ្ចាំងខ្សែវីដេអូ ហ៊ីម ហ៊ុយ និងកុមាររងគ្រោះនៅមន្ទីរស-២១ នង ចាន់ផល បានឡើងថ្លែងការណ៍នៅចំពោះមុខអ្នកចូលរួមទាំងអស់។ ហ៊ុយ បានឡើងរៀបរាប់អំពីប្រវត្តិការងាររបស់គាត់នៅក្រោមរបបខ្មែរក្រហមនិងពីមូលហេតុដែលគាត់ត្រូវមកធ្វើជាកងការពារនៅមន្ទីរស-២១។ គាត់បានបញ្ជាក់ថាប្អូនប្រុសរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅទីនោះដែរ។ ហ៊ុយ មានចិត្តសប្បាយរីករាយចំពោះការសម្រេចសាលក្រមក្នុងករណី ឌុច។ គាត់រំឭកថា ភាពភ័យខ្លាចដែលគាត់មាននៅពេលនោះប្រសិនបើគាត់នៅជាមួយ ឌុច យូរជាងនេះទៀតគាត់ក៏នឹងត្រូវគេសម្លាប់ដែរ។ ក្នុងទស្សនៈរបស់គាត់ ឌុច គឺជាអ្នកធ្វើសេចក្តីសម្រេចនៅមន្ទីរឃុំឃាំង ស-២១។

ចាន់ផល ឡើងថ្លែងអំពីហេតុការណ៍ដែលឪពុកគាត់ត្រូវខ្មែរក្រហមចាប់បញ្ជូនមកមន្ទីរស-២១និងអំពីពេលដែលម្តាយគាត់និងប្អូនប្រុសគាត់ត្រូវគេបញ្ជូនទៅស-២១ក្នុងរយៈពេល៣ខែ


ហ៊ីម ហ៊ុយ និយាយទៅកាន់អ្នកចូលរួម


នង ចាន់ផល និយាយទៅកាន់អ្នកចូលរួម

ក្រោយមក ។ អ្នកចូលរួមទាំងអស់ស្ងៀងស្តាប់ ចាន់ផល យ៉ាង ស្ងៀមស្ងាត់ ខណៈដែល ចាន់ផល រៀបរាប់ពីពេលដែលគាត់បាន ឃើញខ្មែរក្រហមធ្វើបាបម្តាយគាត់ ហើយនិងពេលដែលគាត់ ត្រូវរស់រហូតដល់ពេលដែលកងទ័ពវៀតណាមចូលមកដល់ ។ ចាន់ផល ទទួលការឈឺចាប់ក្នុងរយៈពេលយ៉ាងយូរ ប៉ុន្តែការងាររក ស៊ីប្រចាំថ្ងៃធ្វើឲ្យគាត់អាចបំភ្លេចរឿងរ៉ាវនេះបានខ្លះដែរ ។ ដោយ សារតែមានតុលាការ ចាន់ផល អាចរកឃើញនូវឃាតករដែល សម្លាប់ឪពុកម្តាយគាត់ហើយគាត់ក៏មានឱកាស ដាក់ពាក្យបណ្តឹងទៅតុលាការដែរ ។ នៅពេលដែល សាលក្រម ឌុច បានប្រកាសនៅថ្ងៃទី២៦ខែកក្កដា ចាន់ផល មានអារម្មណ៍សប្បាយរីករាយដែលបានចូល រួមនៅក្នុងសវនាការនោះ ។ ទោះបីជា ចាន់ផល មិន ជឿពាក្យសម្តី ឌុច សារភាព១០០ភាគរយក៏ដោយ ក៏ការឆ្លើយសារភាពនិងសំណូមពររបស់ ឌុច ឲ្យទុក ទ្វារសុំទោសបើកចំហមានសារសំខាន់ណាស់ចំពោះ ចាន់ផល ។


ស៊ីរ៉ិ សាវីណា កំពុងពិភាក្សាជាមួយអាជ្ញាធរដែនដី

ប្រធានគម្រោងឯកសាររស់ ស៊ីរ៉ិ សាវីណា បានចោទសួរអំពីទស្សនៈរបស់អ្នកចូលរួមចំពោះការមកចូលរួម របស់ ហ៊ឹម ហ៊ុយ និង នង ចាន់ផល ក្នុងវេទិកាពិភាក្សាជាមួយគ្នា ។ តើរឿងនេះអាចបញ្ជាក់បានថា អតីតកម្មាភិបាលនិងជនរងគ្រោះ អាចរស់នៅជាមួយគ្នានិងផ្សះផ្សាគ្នាបានដែរឬទេ? អ្នកចូលរួម ទាំង៦នាក់ដែលបានឡើងបញ្ចេញយោបល់ឆ្លើយវិជ្ជមានទៅនឹង សំណួរនេះ ។ ស្ត្រីអ្នកចូលរួមម្នាក់បានបញ្ជាក់ថា ហ៊ឹម ហ៊ុយ មិនមែនធ្វើជាឆ្មាំគុកតាមចិត្តរបស់គាត់ទេ ប៉ុន្តែគាត់គ្រាន់តែធ្វើទៅ តាមបញ្ជាគេប៉ុណ្ណោះ ។ ស្ត្រីអ្នកចូលរួមម្នាក់ទៀតបានគូសបញ្ជាក់ ថា ហ៊ុយ មិនមែនជាមេដឹកនាំកំពូលទេ ហើយ ចាន់ផល ក៏មិនមែន នាំមកទូលស្នែងដោយសារតែគាត់ដែរ ។ ស្ត្រីដែលឡើងមាន យោបល់ទីបី គិតថាពួកគាត់អាចរស់នៅជាមួយគ្នាបានទោះបីជា អ្នកទាំងពីរនៅមានរឿងជូរចត់ពីអតីតកាលក៏ដោយ ។ ប្រសិនបើ ពួកគាត់រស់នៅជាមួយគ្នាពួកគាត់នឹងត្រូវបន្តរំពុករឿងរ៉ាវឈឺចាប់ ពីអតីតកាល ប៉ុន្តែប្រសិនបើពួកគាត់រស់នៅទីទៃពីគ្នា ពួកគាត់ ប្រហែលជាអាចបំភ្លេចបាន ។ អ្នកភូមិម្នាក់ទៀតមានប្រសាសន៍ ថាគាត់ក៏ជាជនរងគ្រោះម្នាក់ដែរគាត់មានសមាជិកគ្រួសារបាត់បង់ នៅក្នុងរបបនោះ ។ ចំពោះគាត់ ការសងសឹកគ្មានទីបញ្ចប់ទេ ។ មនុស្សអាចរស់នៅជាមួយគ្នាបាន ប្រសិនបើមនុស្ស មានចំណេះដឹង មនុស្សអាចរស់នៅជាមួយគ្នាបាន ដើម្បីកសាងអនាគតទាំងអស់គ្នា ។ ចុងក្រោយស្ត្រី អ្នកចូលរួមទីប្រាំដែលជាប្រពន្ធរបស់អតីតគណៈឃុំ ក្នុងរបបខ្មែរក្រហមមានយោបល់ថា អ្នកទាំងពីរមាន ការឈឺចាប់ដូចគ្នា លើកលែងតែ នង ចាន់ផល ដែលបានបាត់បង់ក្រុមគ្រួសារទាំងមូល ។ គាត់ជឿ ជាក់ថា ប្រសិនបើមនុស្សអាចគិតពិចារណាឲ្យបាន ល្អិតល្អន់នោះពួកគាត់នឹងមិនសងសឹកគ្នាទៅវិញទៅ មកនោះទេ ។ មនុស្សគ្រប់គ្នាសុទ្ធតែមានការឈឺចាប់


អ្នកចូលរួមក្នុងវេទិកាពិភាក្សា

គ្រាន់តែទំហំនៃការឈឺចាប់មានកម្រិតខុសគ្នាប៉ុណ្ណោះ ទាក់ទងនឹងសាលក្រម ឌុច អ្នកចូលរួមម្នាក់មានប្រសាសន៍ថា គាត់សង្ឃឹមថាតុលាការនេះនឹងរកយុត្តិធម៌ដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គាត់មិនសប្បាយចិត្តចំពោះការកាត់បន្ថយទោស ឌុច ពី៣៥ឆ្នាំឲ្យនៅត្រឹម១៩ឆ្នាំទេ ។ បើ ឌុច ត្រូវដាក់ទោស៣៥ឆ្នាំពេញ នោះគាត់នឹងពេញចិត្តជាងនេះ ពីព្រោះ ឌុច នឹងមានអាយុលើសពី១០០ឆ្នាំ ទម្រាំនឹងដល់ពេលចេញមកវិញ ប៉ុន្តែគាត់អាចនឹងមានជីវិតរួចចេញពីគុកវិញ ប្រសិនបើទោសរបស់គាត់ត្រូវបានកាត់បន្ថយ ។ ក្នុងទស្សនៈរបស់គាត់តុលាការនេះត្រូវតែគោរពទៅតាមនីតិវិធី ទម្រាំនឹងសម្រេចឲ្យគាត់ជាប់ទោស១៩ឆ្នាំ ។ ដូច្នេះបើទោះជាគាត់ចង់បានការកាត់ទោសឲ្យយូរជាងនេះក៏ដោយ ក៏គាត់គាំទ្រតុលាការនេះដែរពីព្រោះគាត់ជឿជាក់ថាតុលាការនេះមានឯករាជ្យ និងយុត្តិធម៌ ។ គាត់ធ្លាប់មានទស្សនៈថាគ្មានតុលាការណាអាចរកយុត្តិធម៌ឲ្យរូបគាត់បានទេ ប៉ុន្តែតុលាការខ្មែរក្រហមនេះគឺពិតជាតុលាការដ៏ល្អជាងគេនៅក្នុងប្រទេសកម្ពុជា ។ ចាន់ ផល និយាយថាគាត់មានការធូរស្បើយចិត្តច្រើន បច្ចុប្បន្ននេះដោយសារតែគាត់បានកសាងគ្រួសារឡើងវិញប៉ុន្តែ តុលាការនេះអាចធ្វើឲ្យគាត់មានការធូរស្បើយជាងមុនមួយកម្រិតទៀត ។ អ្នកចូលរួមក្នុងវេទិកាពិភាក្សាបានទទួលសៀវភៅបោះពុម្ពផ្សាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «សេចក្តីសង្ខេបសាលក្រម ឌុច» សៀវភៅផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា «អំពើប្រល័យពូជសាសន៍សារសំខាន់នៃសំណុំរឿង០០២» ទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅសិក្សា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ។

## ទស្សនៈបន្ថែម

## ញ៉ែម ធឿន ភេទប្រុសអាយុ៥៦ឆ្នាំ

ញ៉ែម ធឿន អាយុ៥៦ឆ្នាំរស់នៅភូមិចម្ការបី ប៉ុន្តែមានស្រុកកំណើតនៅស្រុកបន្ទាយមាស ខេត្តកំពត ។ នៅឆ្នាំ១៩៧០ ធឿន បានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ក្រោយពីមានការអំពាវនាវពីសម្តេចព្រះនរោត្តម សីហនុ ឲ្យជួយដណ្តើមអំណាចទ្រង់ត្រឡប់មកវិញ ។ នៅពេលនោះវៀតណាមបានជួយចលនាខ្មែរក្រហមវាយដណ្តើមយកតំបន់គ្រប់គ្រងរបស់ លន់ នល់ បានជាច្រើន ។ ធឿន ធ្វើការជាមួយនឹងកងទ័ពវៀតណាមរហូតដល់ឆ្នាំ១៩៧១ពេលដែលចលនាខ្មែរក្រហមមានឯករាជ្យម្ចាស់ការដោយខ្លួនឯង ។ ក្រោយមក គាត់បានប្រែក្លាយទៅជាទាហានបម្រើឲ្យខ្មែរក្រហមដែលនៅពេលនោះត្រូវបានហៅថា កងទ័ពបដិវត្តន៍ ។ ធឿន ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅវាយជាមួយនឹងទាហាន លន់ នល់ នៅតាមទីតាំងនានាពេញទាំងខេត្តកំពត ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ ធឿន ត្រូវបានបញ្ជូនឲ្យទៅព្រំដែនភាគនិរតីដើម្បីការពារទប់ទល់នឹងការឈ្លានពានរបស់វៀតណាម ។ នៅពេលនោះ ធឿន ធ្វើការបម្រើនៅក្នុងកងពលលេខ២៣០ ។ ធឿន បានរៀបការជាមួយប្រពន្ធគាត់ឈ្មោះ ហែម ជី នៅឆ្នាំ១៩៧៦នៅក្នុងពិធីរៀបការមួយដែលរៀបចំដោយខ្មែរក្រហម ។ ពួកគាត់បានរៀបការនៅក្នុងមូលដ្ឋានទ័ពរបស់ ធឿន ដោយមានវត្តមានមេបញ្ជាការកងពលនិងមិត្តរួមការងារទាំងអស់របស់គាត់ ។ ក្នុងពិធីរៀបការនោះ ខ្មែរក្រហមបានរៀបចំឲ្យមានពិធីជប់លៀងបន្តិចបន្តួចដើម្បីអបអរដល់គូស្វាមីភរិយាថ្មីនៅឆ្នាំ១៩៧៧ ធឿន ត្រូវបានដំឡើងឲ្យធ្វើជាមេបញ្ជាការនៃកងវរសេនាពិសេសក្នុងកងពល៧០៣ដោយសារតែគាត់មានបទពិសោធន៍នៅលើសមរភូមិនានានិងត្រូវបានបញ្ជូនឲ្យទៅវាយជាមួយវៀតណាមនៅខេត្តតៃនិញប្រទេសវៀតណាម ។


អនុប្រធានភូមិ ញ៉ែម ធឿន

នៅឆ្នាំ១៩៧៨ វៀតណាមបានវាយបង្ក្រាបលើកងទ័ពខ្មែរក្រហមទាំងអស់ ។ ទាហាននៅក្នុងកងរបស់គាត់បានរត់ខ្ចាត់ខ្ចាយត្រឡប់មកទឹកដីកម្ពុជាវិញ រួចគាត់ក៏ធ្វើដំណើរតម្រង់ទៅរក

ភ្នំស្រង់ខេត្តកំពង់ស្ពឺជាមួយមិត្តភក្តិរបស់គាត់ជាច្រើននាក់ ។ នៅតាមផ្លូវគាត់ជួបនឹងគ្រោះថ្នាក់ធ្វើឲ្យគាត់របួសជើង ។ សរុបមកគាត់ធ្លាប់មានរបួសចំនួនប្រាំដងរួចមកហើយ ដោយសារតែគ្រាប់បែកនិងគ្រាប់មីន ។ បច្ចុប្បន្ន ធឿន នៅមានបំណែកគ្រាប់បែកនៅក្នុងសាច់ជើងខាងឆ្វេងរបស់គាត់នៅឡើយនិងមានស្នាមរបួសពេញទាំងប្រាណ ។ នៅតាមផ្លូវទៅកំពតជាមួយនឹងខ្មែរក្រហម គាត់បានជួបជាមួយនឹងសាច់ញាតិដែលធ្វើដំណើរមកពីស្រុកកំណើត ហើយបាននិយាយប្រាប់គាត់ពីការស្លាប់នៃសមាជិកក្រុមគ្រួសារគាត់ ។ ប្អូនប្រុសគាត់ពីរនាក់និងបងប្អូនជីដូនមួយរបស់គាត់ម្នាក់ត្រូវខ្មែរក្រហមសម្លាប់ ។ ធឿន មិនដែលបានត្រឡប់ទៅលេងផ្ទះទាល់តែសោះតាំងពីពេលដែលគាត់ចាកចេញទៅបម្រើបដិវត្តន៍មក ។ នៅពេលដែលបានស្តាប់ការរៀបរាប់ពីសាច់ញាតិរបស់គាត់ គាត់មានអារម្មណ៍សោកសៅហើយដឹងខ្លួនថាអ្វីៗដែលគាត់បានលះបង់កន្លងមក ដើម្បីបម្រើខ្មែរក្រហមមិនមានន័យអ្វីទាំងអស់ ។ នៅពេលគាត់កំពុងប្រយុទ្ធ ខ្មែរក្រហមបានសម្លាប់សមាជិកក្រុមគ្រួសាររបស់គាត់ ។ នៅឆ្នាំ១៩៧៩ គាត់សម្រេចចិត្តថានឹងធ្វើការចុះចូលជាមួយរដ្ឋាភិបាលហើយត្រឡប់ទៅកាន់ស្រុកកំណើតរបស់គាត់នៅស្រុកបន្ទាយមាសខេត្តកំពតវិញ ។ ទោះបីជាគាត់មិនមានដីស្រែចម្ការច្រើនដើម្បីប្រកបរបរក៏ដោយក៏គាត់ធ្វើស្រែបន្តិចបន្តួចដើម្បីចិញ្ចឹមគ្រួសារដែរ ។

ធឿន បានផ្លាស់ទៅរស់នៅភូមិចម្ការបីនៅពេលដែល ឈូក រិន (ក្រោយមកត្រូវបានកាត់ទោសពីបទសម្លាប់ជនជាតិបរទេសនៅឆ្នាំ១៩៩៨) សុំឲ្យគាត់ត្រឡប់មករស់នៅភ្នំវល្លិ៍ដើម្បីជួយគាត់ក្នុងការវាយបំបែកពួកខ្មែរក្រហមដែលមិនទាន់បានចុះចូល ។

ធឿន និង ឈូក រិន ធ្លាប់បម្រើទ័ពនៅក្នុងកងពលតែមួយចាប់ពីឆ្នាំ១៩៧៦រហូតដល់ឆ្នាំ១៩៧៨ពេលដែលកងទ័ពវៀតណាមបានចូលមកដល់ ។ ទោះបីជា ធឿន មានឋានៈតូចជាងគាត់ក៏ដោយ ក៏ពួកគាត់ខស្បូរាហ៍និយាយប្រាស្រ័យទាក់ទងគ្នាធ្វើឲ្យអ្នកទាំងពីរស្គាល់គ្នាកាន់តែច្បាស់ ។ នៅពេល ឈូក រិន បានដឹងពីទីកន្លែងស្នាក់នៅរបស់ ធឿន គាត់បានសុំឲ្យ ធឿន ផ្លាស់មកនៅភ្នំវល្លិ៍ដើម្បីជួយកងទ័ពរដ្ឋាភិបាលក្នុងការវាយបំបាក់ពួកខ្មែរក្រហមដែលមិនទាន់បានចុះចូល ។ ខ្មែរក្រហមផ្តាច់ខ្លួនបានជួយកងទ័ពរដ្ឋាភិបាលបំបែកតំបន់រឹងមាំរបស់ខ្មែរក្រហម ។ ក្រោយមក ឈូក រិន បានប្រគល់ដីមួយចំនួនទៅឲ្យ ធឿន ដើម្បីសង់ផ្ទះនិងដាំដំណាំ ។ រិន បានប្រាប់ទៅ ធឿន ថាគាត់បានចូលមករស់នៅក្នុងតំបន់ភ្នំវល្លិ៍នេះតាំងពីបែកពី ធឿន នៅឆ្នាំ១៩៧៨ ។

នៅពេលដែល ឈូក រិន នៅជាមួយទ័ពខ្មែរក្រហមនៅឡើយ គាត់បានគ្រប់គ្រងលើតំបន់មួយដែលមានឈ្មោះបច្ចុប្បន្នថាជាភូមិចម្ការបី ។ នៅពេលនោះ គ្រួសាររបស់ខ្មែរក្រហមមួយចំនួនបានប្រកបរបរធ្វើស្រែចម្ការដើម្បីទ្រទ្រង់ជីវភាព ។ ចម្ការបីគឺជាទីតាំងចម្បងគេរបស់កងទ័ពខ្មែរក្រហម ។ ក្រោយពី ឈូក រិន បានផ្តាច់ខ្លួនជាមួយទាហានរបស់គាត់ប្រមាណជា៣០នាក់ទៀត រដ្ឋាភិបាលបានសង់ផ្ទះឲ្យពួកគាត់ស្នាក់នៅក្នុងតំបន់ភ្នំវល្លិ៍នោះ ។ ឈូក រិន ចង់ចុះចូលជាមួយរដ្ឋាភិបាលព្រោះថាកាលនោះគាត់មានទំនាក់ទំនងខ្លះៗជាមួយរដ្ឋាភិបាល ហើយក៏ចាប់ផ្តើមមានគំនិតថារស់នៅជាមួយខ្មែរក្រហមតទៅទៀតគឺគ្មានប្រយោជន៍អ្វីទាល់តែសោះ ។

យោងតាមការរៀបរាប់របស់ ធឿន នៅពេលដែល ឈូក រិន ផ្តាច់ខ្លួនគាត់ចង់នាំយកកងទ័ពរដ្ឋាភិបាលទៅវាយបំបាក់ខ្មែរក្រហមដែលនៅសេសសល់និងដាក់សម្ពាធលើខ្មែរក្រហមឯទៀតដើម្បីឲ្យដោះលែងជនបរទេសទាំងបីនាក់ដែរ ។ ក៏ប៉ុន្តែជនបរទេសទាំងនោះត្រូវខ្មែរក្រហមសម្លាប់បាត់ទៅហើយ មុនពេលដែលកងទ័ពរដ្ឋាភិបាលមកដល់ ។ ឈូក រិន បានប្រាប់គាត់ថានៅពេលដែលខ្មែរក្រហមចាប់បានអ្នកទាំងបី ឈូក រិន ត្រូវរបួសនិងព្យាបាលនៅមន្ទីរពេទ្យឯណោះ ហេតុនេះគាត់មិនបានដឹងពីការចាប់ខ្លួននោះទេ ។

នួន ប៉ែត ចូលមកគ្រប់គ្រងតំបន់ទាំងមូលចាប់ពីផ្នែកខាងកើតនៃភ្នំទៅផ្នែកមួយទៀតនៅក្នុងស្រុកដងទង់ខេត្តកំពត ។ នួន ប៉ែត ធ្លាប់ជាមេកងចល័តក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងមិនធ្លាប់មានបទពិសោធន៍យោធាទេ ។ ក្រោយមក គាត់ត្រូវបានតែងតាំងជាមេបញ្ជាការកងទ័ពនៅភ្នំវល្លិ៍ ។ ធឿន បានជួយ ឈូក រិន វាយបំបាក់ នួន ប៉ែត ដោយប្រើប្រាស់ទាំងយុទ្ធសាស្ត្រ «ក្តៅ» និង «ត្រជាក់» ។ ជាដំបូង ធឿន បានធ្វើការចរចាជាមួយនឹង នួន ប៉ែត ដោយប្រើប្រាស់វិទ្យុទាក់ទង ។ ដោយសារតែ ធឿន និង ប៉ែត

ធ្លាប់បានស្គាល់គ្នាពីមុនមក ប៉ែត បានយល់ព្រមនឹងសំណើរបស់ ធឿន ទៅជួបគ្នានៅកន្លែងកំណត់មួយ ។ នៅពេលដែល ធឿន និង ក្រុមរបស់ខ្លួនវាយប្រហារទៅលើ នួន ប៉ែត ធឿន ពេលនោះ ដណ្តើមបានការកាន់កាប់តំបន់របស់ ប៉ែន ។ ពេលដែល នួន ប៉ែត បរាជ័យគាត់បានរត់គេចខ្លួនទៅកោះស្លា ។ ឈូក រិន និង ធឿន បន្តវាយប្រយុទ្ធនៅកោះស្លាទៀតរហូតគាត់ទទួលបានជ័យជម្នះទាំងស្រុងហើយនាំខ្មែរក្រហមទាំងនោះឲ្យចុះចូលជាមួយរដ្ឋាភិបាល ។

ក្រោយពី នួន ប៉ែត បានចុះចូលជាមួយរដ្ឋាភិបាលគាត់បានផ្លាស់ទៅរស់នៅប៉ៃលិន ។ សរុបមកមានខ្មែរក្រហមប្រមាណជា៩០គ្រួសារនៅភ្នំវល្លិ៍បានចុះចូលជាមួយនឹងរាជរដ្ឋាភិបាល ។ នៅភ្នំវល្លិ៍មានកម្មាភិបាលជាន់ខ្ពស់ប្រមាណជា២-៣នាក់ដែល ធឿន ស្គាល់ឈ្មោះ ។ ក្នុងនោះរួមមាន ណាក់ សព្វថ្ងៃរស់នៅកោះស្លា ជុំ នួន តាម៉ៅ ប្រាក់ ជី និង ស្រី សំ សព្វថ្ងៃរស់នៅភូមិចម្ការបី ។ ធឿន មិនច្បាស់ថាអ្នកទាំងអស់នោះមានមុខនាទីពិតប្រាកដយ៉ាងដូចម្តេចខ្លះទេ ។ បច្ចុប្បន្នមានគ្រួសារខ្មែរក្រហមប្រមាណតែ៩០គ្រួសារប៉ុណ្ណោះដែលបន្តរស់នៅក្នុងភូមិចម្ការបី ។ អតីតខ្មែរក្រហមភាគច្រើននៅភ្នំវល្លិ៍មកពីខេត្តកំពត តាកែវ និងមួយចំនួនមកពីខេត្តផ្សេងៗ ។ បន្តិចម្តងៗ ពួកគាត់បានលក់ដីធ្លីរួចផ្លាស់ចេញពីភូមិចម្ការបីដើម្បីទៅទិញដីនៅកោះស្លាដែលមានតម្លៃថោកជាងនេះ ។ អតីតខ្មែរក្រហមខ្លះទៀត បានត្រឡប់ទៅរស់នៅស្រុកកំណើតរបស់ខ្លួនវិញ ។

ក្នុងជីវិតរបស់គាត់ជាទាហានខ្មែរក្រហមម្នាក់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែល ធឿន ធ្លាប់ជួបគឺ តាម៉ុក ជាលេខាភូមិភាគនិរតី ។ ធឿន ជួប តាម៉ុក ក្នុងពេលដែលមានការប្រជុំនៅមូលដ្ឋានតំបន់និងពេលខ្លះទៀត នៅពេលដែល តាម៉ុក កំពុងតែត្រួតទ័ព ។ ធឿន ត្រូវបានរំសាយចេញពីទ័ពកាលពីឆ្នាំមុនរួច ក៏ត្រូវបោះឆ្នោតឲ្យធ្វើជាអនុប្រធានភូមិ ។ រំឭករឿងរ៉ាវកាលពីអតីតកាលធ្វើឲ្យ ធឿន មានការសោកស្តាយជាខ្លាំងដោយសារតែគាត់បានបម្រើឲ្យខ្មែរក្រហមដែលរបបនេះធ្វើឲ្យមានមនុស្សស្លាប់បាត់បង់ជីវិតជាច្រើននាក់ដែលក្នុងនោះរួមទាំងសមាជិកក្រុមគ្រួសាររបស់ ធឿន ផងដែរ ។ ធឿន មានអារម្មណ៍សប្បាយរីករាយណាស់ដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមួយត្រូវបានបង្កើតឡើង ។ គាត់ជឿជាក់ថាអ្នកដែលធ្វើតាមបញ្ជាគេមិនមានកំហុសនោះទេ ។


ជុំ នួន

## ជុំ នួន ភេទប្រុស អាយុ៦៩ឆ្នាំ

ជុំ នួន អាយុ៦៩ឆ្នាំជាសមាជិកក្រុមប្រឹក្សាឃុំពងទឹកមានទីលំនៅនៅភូមិចម្ការបី ។ នួន មានស្រុកកំណើតនៅភូមិព្រានទុំ ឃុំស្រែជាខាងជើង ស្រុកដងទង់ ខេត្តកំពត ។ ភរិយារបស់ នួន ឈ្មោះ ហ៊ិន នួន មានអាយុ៦០ឆ្នាំ ក៏មានស្រុកកំណើតនៅទីនោះដែរ ។ នួន មានកូន៥នាក់ ប្រុសបីនាក់និងស្រី២នាក់ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ធ្វើជាប្រធានភូមិម្ទិះដែលបច្ចុប្បន្នស្ថិតក្នុងភូមិអង្គរជ័យឃុំស្រែជា ។ នួន ត្រូវបានតែងតាំងឲ្យធ្វើជាមេភូមិនៅទីនោះ ក្រោយពីគណៈស្រុកឈ្មោះ សៀន ត្រូវថ្នាក់លើបញ្ជូនឲ្យទៅកាន់តំណែងថ្មីក្នុងភូមិភាគបូព៌ាឆ្នាំ១៩៧៨ ។

នួន បានរៀបរាប់ថា កាលនោះមាន (ប្រជាជនថ្មីប្រជាជនដែលត្រូវខ្មែរក្រហមជម្លៀសពីទីក្រុង) ជាច្រើននាក់ត្រូវបានបញ្ជូនឲ្យមករស់នៅភូមិរបស់គាត់ ។ កាលនោះ ប្រជាជនថ្មីស្ទើរតែទាំងអស់តម្រូវឲ្យទៅរស់នៅភូមិថ្មី ។ តាមការពិត ទាហានខ្មែរ

ក្រហមបញ្ជូនប្រជាជនថ្មីទាំងនោះទៅសម្លាប់នៅក្នុងព្រៃសោះ ។ នួន រំឭករឿងនេះទាំងសោកស្តាយថា ក្នុងចំណោមប្រជាជនថ្មីទាំងអស់នោះមានគ្រួសាររបស់បងប្អូនចិញ្ចឹមរបស់គាត់ដែលជាឧត្តមសេនីយ៍នៅជំនាន់ លន់ នល់ ដែរ ។ គ្រួសារគាត់ ត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញមករស់នៅភូមិម្ទិះនេះ ។ នៅពេលខ្មែរក្រហមប្រាប់ថា នឹងយកគ្រួសាររបស់បងចិញ្ចឹមរបស់ នួន ទៅភូមិថ្មីបងចិញ្ចឹមរបស់គាត់បានឲ្យគាត់ជួយរក្សាមាសមួយកញ្ចប់និងត្បូងថ្មមានតម្លៃមួយចំនួនទៀត ។ បងចិញ្ចឹមគាត់ប្រាប់គាត់ថាប្រសិនបើគ្រួសារគាត់បានជួបនឹង នួន ម្តងទៀតគ្រួសារគាត់នឹងចែករំលែកមាសកន្លះកញ្ចប់ឲ្យមក នួន ។ ប៉ុន្តែ ប្រសិនបើ គ្រួសាររបស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅភូមិថ្មីនោះគាត់ចង់ឲ្យ នួន ជួយធ្វើបុណ្យតាមទំនៀមទម្លាប់ខ្មែរឲ្យគាត់ផង ។ ពីរបីខែក្រោយមកដោយប្រពន្ធ នួន ភ័យខ្លាចថាអង្គការនឹងដឹងថាគាត់មានមាសនិងត្បូងថ្មមានតម្លៃគាត់ក៏បានយករបស់ទាំងនោះទៅឲ្យខ្មែរក្រហមនៅឃុំស្រែជា ។ នួន មានប្រសាសន៍ថា គាត់ធ្លាប់ជួយប្រជាជនមួយចំនួនឲ្យភៀសខ្លួនទៅវៀតណាម នៅពេលគាត់ដឹងថាអ្នកទាំងនោះត្រូវខ្មែរក្រហមយកទៅសម្លាប់នៅស្រុកកំពង់ត្រាច ។

នៅពេលកងទ័ពវៀតណាមចូលមកដល់ភ្នំពេញក្នុងឆ្នាំ១៩៧៩ គ្រួសាររបស់ នួន បានគេចខ្លួនទៅរស់នៅភ្នំវល្លិ៍ ។ នៅពេលនោះមានប្រជាជនប្រមាណជាមួយរយនាក់ (ទាហាន៣០នាក់អាជ្ញាធរស្រុកភូមិនិងជនស៊ីវិល៧០នាក់) ។ ឈ្មោះ ភឿន គឺជាមេបញ្ជាការជំបូងបង្អស់នៅភ្នំវល្លិ៍ ។ គាត់ត្រូវទាហានវៀតណាមសម្លាប់នៅឆ្នាំ១៩៨០ ។ បន្ទាប់ពីនោះមក គាដុន គឺជាអ្នកមើលការខុសត្រូវផ្នែកស៊ីវិលនិង សុខ ជាមេបញ្ជាការកងទ័ពនៅភ្នំវល្លិ៍ ។ នៅឆ្នាំ១៩៨៣-១៩៨៤ គាដុន និង សុខ ត្រូវបានបញ្ជូនទៅកោះស្លាឲ្យធ្វើការជាមួយ សំ បិត ដែលជាមេភូមិភាគលេខ៤ (ភូមិភាគនិរតី) ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៨៤ ភ្នំវល្លិ៍ត្រូវបានប្តូរទៅគ្រប់គ្រងដោយសមមិត្ត សាត និង នួន ប៉ែត វិញ ។ នៅរវាងឆ្នាំ១៩៨៥ និង១៩៩៥ នួន ប៉ែត និង យុង វន គឺជាមេបញ្ជាការនៅក្នុងតំបន់នេះ ។ ឈូក រិន ដែលជាមេបញ្ជាការទទួលបន្ទុកវាយប្រយុទ្ធនៅសមរភូមិកំពង់ត្រាច ។ សិទ្ធិគ្រប់គ្រងខេត្តកំពតរួមទាំង (ស្រុកទឹកឈូ) រឹង ស្វាយ ថាត ត្រួតត្រាផ្លូវជាតិលេខ៣ ។

នៅឆ្នាំ១៩៩៤ ក្រុមរបស់ ឈូក រិន បានចាប់ជនបរទេសចំនួនបីនាក់នៅក្នុងការវាយប្រហាររថភ្លើងមួយ ហើយនាំយកជនបរទេសទាំងបីនាក់នោះទៅទុកនៅទីតាំងខ្មែរក្រហមនៅភ្នំវល្លិ៍ ។ យុង វន និង អូក ប៉ុន បានសម្លាប់ជនបរទេសទាំងបីនាក់នៅស្នាចព្រៃខាងលិចវត្តស្រែជា ។ ក្រោយមក យុង វន ត្រូវអ្នកក្រោមបង្គាប់គាត់សម្លាប់នៅឆ្នាំ១៩៩៥ ពេលដែលខ្មែរក្រហមមួយចំនួនបានធ្វើសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាលនិងមួយចំនួនទៀតបដិសេធមិនចូលរួម ។ អូក ប៉ុន ត្រូវឪពុករបស់គាត់សម្លាប់នៅឆ្នាំ១៩៩៥ ។ នៅរវាងឆ្នាំ១៩៨៣ដល់ឆ្នាំ១៩៩៥ នួន គឺអនុប្រធានទីពីរនៃផ្នែកដឹកជញ្ជូនភូមិភាគនិរតី ។ ក្រោយពេលធ្វើសមាហរណកម្ម នួន ត្រូវបានតែងតាំងឲ្យធ្វើជាប្រធានភូមិចម្ការបីនិងជាមេបញ្ជាការកងវរសេនាធំទី១ នៅចម្ការដូងខេត្តកែប ។

ចាប់ពីឆ្នាំ២០០២មកទល់បច្ចុប្បន្ន នួន ត្រូវបានអ្នកភូមិបោះឆ្នោតឲ្យធ្វើជាសមាជិកនៃក្រុមប្រឹក្សាឃុំពងទឹក ។ នួន មានប្រសាសន៍ថា គាត់គាំទ្រការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គាត់សង្ឃឹមថាប្រជាជនកម្ពុជាជាពិសេសក្មេងជំនាន់ក្រោយនឹងអាចរៀនសូត្រពីការកាត់ទោសនេះនិងពីរបបកម្ពុជាប្រជាធិបតេយ្យ ។

**នាក់ ភូ ភេទស្រី អាយុ៥១ឆ្នាំ**




នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នាក់ ភូ រស់នៅក្នុងស្រុកឈូកខេត្តកំពត ហើយធ្វើការនៅក្នុងកងយុវជន ។ គាត់លាក់

អត្តសញ្ញាណរបស់ខ្លួនដោយសារតែឪពុកគាត់ធ្លាប់ធ្វើជាប៉ូលិស ។

ម្យ៉ាងទៀត ខ្មែរក្រហមបានចោទប្រកាន់គ្រួសារគាត់ថាជាអ្នកសក្តិភូមិ ។ ប៉ុន្តែគាត់មិនអាចលាក់ជាមួយនឹងអ្នកភូមិបានទេ ។ ខ្មែរក្រហមបានសម្លាប់បងប្រុសរបស់គាត់ ដោយសារតែគេដឹងថាបងប្រុសគាត់មានចំណេះដឹងជ្រៅជ្រះ ។ គ្រួសាររបស់គាត់អាចរួចជីវិតពីរបបខ្មែរក្រហមបានដោយសារតែគាត់ខំប្រឹងធ្វើការជាទម្ងន់ដូចអ្នកភូមិដទៃទៀតដែរ ។ នៅឆ្នាំ១៩៩២ម្តាយ ប្អូនប្រុសនិងប្អូនថ្លៃ ភូ បានផ្លាស់ពីកំពតមករស់នៅភ្នំវល្លិ៍ ប៉ុន្តែនៅឆ្នាំ១៩៩៦ប្អូនរបស់គាត់បានស្លាប់នៅក្នុងការប្រយុទ្ធគ្នាជាមួយនឹងកងទ័ពរដ្ឋាភិបាល រីឯប្រពន្ធគាត់ស្លាប់ដោយសារតែជំងឺ ។ ភូ ផ្លាស់មករស់នៅភូមិចម្ការបីនៅឆ្នាំ១៩៩៥ ក្រោយពីខ្មែរក្រហមបានធ្វើសមាហរណកម្មជាមួយនឹងរដ្ឋាភិបាលដោយសារតែគ្រួសាររបស់គាត់ត្រូវការដីដើម្បីដាំដុះ ។

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩កម្មាភិបាល ខ្មែរក្រហមបានផ្តុំមករស់នៅភ្នំវល្លិ៍ដោយសារពួកគាត់ខ្លាចកងទ័ពវៀតណាមដែលនឹងចូលមកកាន់កាប់តំបន់ផ្សេងៗក្បែរនោះ ។ នៅឆ្នាំ១៩៧៩ នួន ប៉ែត ធ្លាប់ជាគណៈនៅក្នុងខេត្តកំពត ឈូក រិន គឺជាគណៈនៅស្រុកកំពង់ត្រាច ឈួន សិទ្ធិ (សព្វថ្ងៃស្លាប់) គឺជាប្រធានកងនៅស្រុកកំពត វន គណៈស្រុកឈូក និង នួង ទទួលខុសត្រូវខាងដឹកជញ្ជូន ។ ក្រុមគ្រួសារអតីតខ្មែរក្រហមមានប្រមាណជា២០០ គ្រួសារដែលរស់នៅក្នុងតំបន់ភ្នំវល្លិ៍ ។ នៅក្នុងរបបខ្មែរក្រហម នួន ប៉ែត គឺជាប្រធានវរសេនាតូច ហើយ ឈូក រិន ជាប្រធានកងក្នុងស្រុកទូកមាសខេត្តកំពត ។ តំបន់ភ្នំវល្លិ៍ មានការបែងចែកជាកងទ័ពក្រុមប៉ូលិសនិងប្រព័ន្ធរដ្ឋបាលស្រុកដោយឡែកពីគ្នា ។ ប្រជាជនរស់នៅក្នុងតំបន់នោះមិនហ៊ានទិញស្បៀងពីខាងក្រៅទេ ហេតុនេះខ្មែរក្រហមតែងតែទិញស្បៀងនិងគ្រឿងបរិក្ខារផ្សេងៗទុកឲ្យអ្នកស្រុកជានិច្ច ។ ស្ថានភាពនៅក្នុងភូមិមិនសូវជាស្ថិតស្ថេរទេ ដោយសារខ្មែរក្រហមតែងតែវាយប្រយុទ្ធជាមួយនឹងទាហានរដ្ឋាភិបាលជានិច្ច ។ ភូ បានប្រាប់ឲ្យដឹងថា ខ្មែរក្រហមទិញគ្រឿងសព្វាវុធមកពីតាមព្រំដែនតែគាត់មិនដឹងថាជាព្រំដែនមួយណាទេ ។

យោងតាមសម្តី ភូ ថា ឈូក រិន គឺជាអ្នកដែលបញ្ជាឲ្យមានការចាប់ជនជាតិបរទេសនៅផ្លូវរថភ្លើង ។ ពេល ភូ ធ្វើដំណើរទៅលេងម្តាយ ភូ ជួបនឹងជនបរទេសទាំងបីនាក់ដែលជាប់ឃុំនៅក្នុងផ្ទះមួយហើយអ្នកទាំងបីត្រូវបានដាក់ឲ្យធ្វើការងារជាមួយនឹងអ្នកភូមិ ។ ខ្មែរក្រហមចង់ឲ្យរដ្ឋាភិបាលធ្វើការដោះដូរជនបរទេសទាំងបីនាក់នោះជាមួយស្បៀងនិងប្រាក់ ប៉ុន្តែរដ្ឋាភិបាលមិនយល់ព្រមរួចក៏វាយបកទៅខ្មែរក្រហមវិញ ហេតុនេះហើយទើបជនបរទេសទាំងបីនាក់ត្រូវខ្មែរក្រហមបញ្ជូនទៅ នួន ប៉ែត ដើម្បីសម្លាប់ ។ ប្រហែលជាមួយខែក្រោយមក ឈូក រិន គឺជាមេដឹកនាំដំបូងដែលបានចុះចូលជាមួយរដ្ឋាភិបាលដោយសារតែក្រុមគាត់មិនអាចតស៊ូជាមួយកងទ័ពរដ្ឋាភិបាលបាន ។ ឈូក រិន ស្នើសុំឲ្យក្រុមផ្សេងៗដែលរស់នៅកោះស្លានិងកំពតចុះចូលជាមួយរដ្ឋាភិបាលដែរ ប៉ុន្តែ នួន ប៉ែត និងទ័ពខ្មែរក្រហមប៉ុន្មាននាក់ទៀតបដិសេធមិនចូលរួម ។ នៅឆ្នាំ១៩៩៦ខ្មែរក្រហមបានវាយជាមួយ ឈូក រិន និងទ័ពរបស់រដ្ឋាភិបាល ។ ក្រោយមក រដ្ឋាភិបាលបានតែងតាំងមន្ត្រីថ្មីជំនួសកន្លែងរបស់ខ្មែរក្រហម ប៉ុន្តែអតីតខ្មែរក្រហមមួយចំនួននៅធ្វើជាមេភូមិដដែល ។

## សេន ហាន ភេទស្រី អាយុ៥៥ឆ្នាំ

សេន ហាន ជាអតីតប្រធានកងទ័ពនារីរបស់ខ្មែរក្រហម ។ ប្តីរបស់គាត់ជាមន្ត្រីនៃគណៈកម្មាធិការឃុំ នៅឃុំដូនយ៉យស្រុកឈូកនៅក្នុងរបបខ្មែរក្រហម ហើយទើបនឹងស្លាប់នៅឆ្នាំ២០០៦ ។ សេន ហាន កើតនៅភូមិច្រកកែស ឃុំដងទង់ ស្រុកដងទង់ ខេត្តកំពត ។ ក្រោយពីមានការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុនៅឆ្នាំ១៩៧០មក ហាន បានសម្រេចចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅភូមិស្រែចែងដោយមូលហេតុច្រើនយ៉ាង ។ ទីមួយ ដោយសារតែគាត់ទើបមានអាយុបាន១៨ឆ្នាំគាត់មានការព្រួយបារម្ភចំពោះសុវត្ថិភាពផ្ទាល់ខ្លួនខ្លាចពេលដែលកងទ័ព លន់ នល់ ចូលមកក្នុងភូមិធ្វើបាបគាត់ ។ ស្រីៗនៅក្នុងភូមិគាត់មួយចំនួនត្រូវកងទ័ព លន់ នល់ ចាប់យកទៅធ្វើឲ្យគាត់មានការភ័យខ្លាច ។ ទីពីរ គាត់មិនអាចទ្រាំទ្រនឹងការបំផ្លិចបំផ្លាញពីការប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និងទ័ពខ្មែរក្រហម ។ យោងតាមសម្តីរបស់ ហាន ស្ត្រី៥នាក់ទៀតដែលរស់នៅក្នុងភូមិជាមួយគ្នាក៏ត្រូវបានបង្ខំឲ្យចូលបម្រើបដិវត្តន៍ជាមួយនឹងបុរសជាច្រើននាក់ទៀតដែរ ។ ហាន ទៅប្រយុទ្ធស្ទើរតែគ្រប់ទីកន្លែងទាំងអស់ ។ ដំបូង ខ្មែរក្រហមបញ្ជូនគាត់ទៅខេត្ត

កំពង់ស្ពឺដើម្បីធ្វើការផ្សារបន្តុបង្កើនផលក្រោមការដឹកនាំរបស់ តា ស៊ុន ។ ក្រោយមក ហាន ត្រូវបានខ្មែរក្រហមដំឡើងឋានៈធ្វើជាប្រធានក្រុមកងទ័ពនារីមានកូនចៅពីបីទៅប្រាំនាក់ ។ ហាន ជឿជាក់ថាគាត់បានឡើងឋានៈក៏ដោយសារគាត់ខំប្រឹងប្រែងធ្វើការងារដែរ ។ បន្ទាប់ពីធ្វើការនៅខេត្តកំពង់ស្ពឺ ហាន ត្រូវបានគេបញ្ជូនឲ្យទៅធ្វើនៅស្រុកឈូក ។ នៅឈូកខ្មែរក្រហមបានរៀបចំគាត់ឲ្យរៀបការជាមួយឈ្មោះ សួន សិទ្ធិ ។ គាត់បានយល់ព្រមចំពោះសំណើនោះ ។ ក្រោយពីពិធីមង្គលការបានបញ្ចប់ទៅ គាត់ត្រូវរស់នៅបែកពីប្តីប្រមាណជា៣ខែ ប៉ុន្តែបន្ទាប់ពីនោះមកគាត់អាចរស់លំបិនជាទីបំផុតដោយសារតែគាត់ត្រូវធ្វើការធ្ងន់ ហើយរស់នៅក្នុងភាពភ័យខ្លាច ។ ពេលនិយាយពីគាត់និងប្តីគាត់អ្នកស្រុកបានបញ្ជាក់ថា «អាហារក្រៀមៗស្ទើរតែអស់ទៅហើយ ដូច្នេះយើងត្រូវរកផ្លែឈើថ្មីនិងស្រស់វិញ» ។ ឃ្លានេះចង់មានន័យថាគាត់គួរតែស្លាប់ដូចអ្នកដទៃទៀតដែលមកភូមិភាគនិរតីដែរដោយសារតែពួកគាត់ត្រូវធ្វើដំណើរមកខាងជើង ។ ទោះបីជា ប្តីគាត់ស្នើថាគាត់គួរតែធ្វើដំណើរបែកគ្នាដើម្បីជួយសមាជិកគ្រួសារពីការចោទប្រកាន់និងសម្លាប់ ហាន បដិសេធ ហើយព្យាយាមស្វែងរកផ្លូវមួយទៀត ។ ហាន ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅបឹងពន្លៃខេត្តពោធិ៍សាត់ ។



សេន ហាន ឡើងសួរសំណួរទៅកាន់សហព្រះរាជអាជ្ញារង

នៅជាមួយប្តីគាត់រៀងរហូត ។ សិទ្ធិ ធ្លាប់បួសជាព្រះសង្ឃនៅវត្តខណ្ឌលោម ។ គាត់មានស្រុកកំណើតនៅស្រុកជុំគិរីខេត្តកំពត ។ ហាន បានបង្កើតកូនស្រីម្នាក់ឈ្មោះ សេន ចាន់ថា នៅឆ្នាំ ១៩៧៦ ។ កូនស្រីគាត់រស់នៅក្បែរគាត់ជារៀងរហូតមក ។

នៅឆ្នាំ១៩៧៧-១៩៧៨ ហាន បានផ្លាស់ទៅរស់នៅខេត្តបាត់ដំបងពេលដែលទាហានវៀតណាមចូលមកដល់ ។ នៅតាមផ្លូវទៅបាត់ដំបង ហាន ត្រូវបានប្រជាជននៅភូមិភាគពាយ័ព្យហៅថាជាជនដៃដល់ ។ ហាន បញ្ជាក់ថា ជីវិតគាត់មានសភាពលំបាកអ្នកភូមិខ្លះនៅទួលពន្លៃចង់សងសឹកចំពោះប្តីគាត់ព្រោះគាត់ធ្លាប់ជាសមាជិកនៃគណៈឃុំ រីឯអ្នកខ្លះទៀតមិនចង់សម្លាប់គាត់ទេ ថែមទាំងចង់ការពារគាត់ទៀតផង ។ ហាន ខំប្រឹងការពារប្តីគាត់និងសុំឲ្យគេដោះលែងគាត់មកវិញ ។ ហាន គិតថាខ្លួនឯងគឺជាជនរងគ្រោះ ។

បន្ទាប់ពីខ្មែរក្រហមបានដួលរលំទៅ ហាន សម្រេចចិត្តធ្វើដំណើរត្រឡប់មកផ្ទះវិញ ដោយពកូនដែលទើបនឹងកើតនិងស្តាយអង្ករខ្លះទៀតផង ។ ប្តីរបស់គាត់ក៏ត្រឡប់មកភូមិវិញដែរតែដើរតាមផ្លូវផ្សេងទៀតដើម្បីកុំឲ្យកងទ័ពវៀតណាមចំណាំគាត់ថាជាខ្មែរ

ក្រហម ។ នៅពេលដែលសួរគាត់ថា ហេតុអ្វីបានជាគាត់សម្រេចចិត្តត្រឡប់មកស្រុកកំណើតវិញ ហាន ឆ្លើយថាគាត់គ្មានអ្វីដែលគួរឲ្យខ្លាចទេព្រោះគាត់មិនបានធ្វើអ្វីខុស ។ អ្នកស្រុកស្វាគមន៍ចំពោះគាត់ថែមទាំងឲ្យម្ហូបគាត់ទៀតផង ។ ទោះបីជាយ៉ាងនេះក៏ដោយជីវិតរបស់គាត់នៅជួបការលំបាកដដែលដោយសារខ្វះខាតម្ហូបអាហារនិងសម្ភារៈចាំបាច់មួយចំនួន ។ ដោយសារតែភ័យខ្លាចអំពីសុវត្ថិភាពប្តី ហាន បានរត់ទៅរស់នៅភ្នំវល្លិ៍ដើម្បីលាក់ខ្លួនពីរដ្ឋាភិបាលដែលគាំទ្រដោយវៀតណាម ។ ក្រោយពីដឹងដំណឹងថា ប្តីគាត់ធ្លាក់ខ្លួនឈឺធ្ងន់គាត់បានដើរប្រមូលថ្នាំបុរាណដើម្បីមកយកដាំឲ្យប្តីគាត់នៅលើភ្នំ ។ ក្រោយមក គាត់ក៏សម្រេចចិត្តទៅរស់នៅជាមួយប្តីគាត់នៅទីនោះដែរដោយទុកកូនពីរនាក់របស់គាត់ឲ្យតាយាយជួយមើលថែទាំ ។

ភ្នំវល្លិ៍ត្រូវបានបែងចែកជាតំបន់ ហើយគ្រប់គ្រងដោយអតីតកម្មាភិបាលខ្មែរក្រហមបីបួននាក់ ។ មេខ្មែរក្រហមដែលមានអំណាចជាងគេបំផុតគឺ នួន ប៉ែត ។ នៅពេលសម្ភាសន៍ ហាន មិនបានលាតត្រដាងថា ប្តីគាត់ធ្លាប់ជាគណៈស្រុកគ្រប់គ្រងតំបន់ខ្លះនៅភ្នំនេះទេ ប៉ុន្តែក្រុមការងារបានទទួលព័ត៌មានពីអ្នកភូមិផ្សេងទៀត ។ ហាន បានចុះចូលជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៨និងរស់នៅចម្ការដូងក្នុងស្រុកដំណាក់ចង្អើរ ។ បន្ទាប់មកគាត់បានផ្លាស់មករស់នៅភូមិចម្ការបីដែលជាទីលំនៅរបស់គាត់បច្ចុប្បន្ន ។

ហាន មានប្រសាសន៍ថា របបខ្មែរក្រហមមិនមែនជារបបមួយល្អទេពីព្រោះរបបនេះបានសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃ ។ ហាន រំឭកឡើងវិញពីរឿងរ៉ាវពូរបស់គាត់ដែលត្រូវខ្មែរក្រហមបាញ់សម្លាប់ ។ អ្នកភូមិម្នាក់បានមកសុំខ្ចីក្បឿងរបស់ពូគាត់នៅមុនរបបខ្មែរក្រហម ។ ពេលដែលអ្នកភូមិនោះយកក្បឿងមកសងវិញប្រភេទក្បឿងនោះមិនដូចទៅនឹងក្បឿងដែលពូគាត់បានឲ្យខ្ចីទេ ។ ហេតុនេះគាត់មិនទទួលយកក្បឿងនោះឡើយ ។ អ្នកភូមិម្នាក់នោះបានចោទពូរបស់គាត់ថា ជាអ្នកស៊ើបការណ៍ ក៏បាញ់គាត់រហូតដល់ស្លាប់ ។

ហាន ធ្លាប់បានទៅទស្សនកិច្ចនៅតុលាការខ្មែរក្រហម គុកទួលស្លែងនិងវាលពិឃាតជើងឯកកាលពីប៉ុន្មានឆ្នាំមុន ។ គាត់គិតថាតុលាការខ្មែរក្រហមគឺត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជានិងជាមធ្យោបាយក្នុងការទប់ស្កាត់របបនេះកុំឲ្យកើតមានសាជាថ្មីម្តងទៀត ។ គាត់យល់ព្រមនឹងការកាត់ទោសឲ្យ ឌុច ជាប់គុក៣៥ឆ្នាំ «ប្រសិនបើយើងបានប្រព្រឹត្តខុស យើងត្រូវតែទទួលខុសត្រូវចំពោះកំហុសនោះ»

ហាន មិនបានដឹងពីការចាប់ជម្រិតជនបរទេសទាំងបីនាក់នោះទេនៅឆ្នាំ១៩៩០ ។ ហាន និយាយថាគាត់គ្រាន់តែធ្លាប់ឮពីរឿងនេះ ។ គាត់មិនបានចងចាំពីកាលប្បវត្តិរបស់រឿងរ៉ាវនោះច្បាស់លាស់ទេ ។ ពេលរំឭករឿងរ៉ាវរបស់គាត់ ពេលខ្លះគាត់មានការច្របូកច្របល់ចំពោះឆ្នាំដូចដែលគាត់បានសារភាពដែរ ។ ហាន តែងតែយំនៅពេលរំឭកពីបទពិសោធន៍របស់គាត់តាមផ្លូវពីបាត់ដំបងមកស្រុកកំណើតវិញ ហើយគាត់ច្រើនតែបញ្ជាក់ពីជីវិតរបស់គាត់នៅចន្លោះឆ្នាំ១៩៧៨និងឆ្នាំ១៩៨៣នៅភ្នំវល្លិ៍ជាជាងបញ្ជាក់ពីតួនាទីនិងការងាររបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ បច្ចុប្បន្នអ្នកភូមិគាត់ច្រើនមើលមកគាត់ថា ជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ។

## ហ៊ឹម ហ៊ុយ ភេទប្រុស អាយុ៥៣ឆ្នាំ



ហ៊ឹម ហ៊ុយ និង នង ចាន់ផល ស្តាប់ការរៀបរាប់របស់លោក វីលៀម ស្មីត

ហ៊ឹម ហ៊ុយ ដែលជាអតីតប្រធានសន្តិសុខនៅមន្ទីរស-២១ បានចូលបដិវត្តន៍នៅអាយុ១២ឆ្នាំ ហើយត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅគុកទួលស្លែងនៅអាយុ១៨ឆ្នាំ ។ គាត់ទទួលខុសត្រូវក្នុងការដឹកអ្នកទោស២០នាក់ឬច្រើនជាងនេះតាមឡានជារៀងរាល់យប់ទៅជើងឯកកន្លែងដែលគាត់ធ្វើការត្រួតពិនិត្យអត្តសញ្ញាណរបស់អ្នកទោសមុនពេលបញ្ជូនទៅតាមរណ្តៅនៅខាងក្រៅដើម្បី

សម្លាប់ដោយវាយនឹងដំបង ។ ក្នុងចំណោមអ្នកទោសប្រមាណ ១៨០០០នាក់ដែលស្លាប់នៅទីនោះគាត់បានអះអាងថាគាត់សម្លាប់ផ្ទាល់ដៃតែចំនួន៥នាក់ប៉ុណ្ណោះដើម្បីជាការបញ្ជាក់ពីភាពស្មោះត្រង់របស់គាត់ចំពោះមេរបស់គាត់ ។

បន្ទាប់ពីបានចូលរួមក្នុងវេទិកាពិភាក្សា ហ៊ឹម ហ៊ុយ បានបញ្ចេញការពិតជាលើកទីមួយអំពីអ្នកជិតខាងរបស់គាត់ដែលធ្លាប់ធ្វើជាអ្នកយាមនៅគុកទួលស្លែងដូចគាត់ដែរ ។ មកដល់បច្ចុប្បន្ននេះឪពុកម្តាយរបស់អ្នកយាមនោះមិនចូលចិត្ត ហ៊ុយ ទេ ហើយថែមទាំងដាក់បន្ទុកឲ្យគាត់ទទួលខុសត្រូវចំពោះការស្លាប់កូនទីពីរដែលបានបាត់ខ្លួននៅក្នុងសម័យនោះដែរ ។ បើទោះបីជាកូនគាត់ត្រឡប់មកវិញ ហើយឲ្យដំណឹងថា គាត់បានទៅរស់នៅយ៉ាងសុខស្រួលនៅប្រទេសជប៉ុនយ៉ាងណាក៏ដោយ ក៏ពួកគាត់នៅតែមិនចូលចិត្ត ហ៊ុយ ដដែល ។ ហ៊ុយ ដែលមានប្អូនប្រុសស្លាប់នៅទួលស្លែងដោយសារ ឌុច ដែរនោះ បានពោលទាំងឈឺចាប់ថាគ្រួសារអ្នកជិតខាងគាត់ជាជនជាតិវៀតណាម ហេតុនេះ ហ៊ុយ អាចធ្វើឲ្យកូនគាត់ស្លាប់បានគ្រប់ពេលវេលា ប្រសិនបើគាត់ទម្លាយរឿងនេះប្រាប់ ឌុច ។ នេះជាលើកទីមួយ ហើយដែលព័ត៌មានអំពីអ្នកយាមជាជនជាតិវៀតណាមធ្វើការនៅគុកទួលស្លែងត្រូវបានទម្លាយចេញ ។

***សេចក្តីសន្និដ្ឋាន***

ភាពចាំបាច់ក្នុងការបញ្ចាំងខ្សែភាពយន្តនៅខាងក្រៅ ដោយសារតែមិនមានអគារទំហំធំគ្រប់គ្រាន់ដើម្បីដាក់មនុស្សច្រើនជាង២០នាក់ គឺជាឧបសគ្គមួយដែលមិនអាចឲ្យខ្សែភាពយន្តដំណើរការទៅបានបណ្តាលឲ្យមានលទ្ធផលមិនសូវជាគាប់ប្រសើរប៉ុន្មានទេ ។ ទីតាំងសម្រាប់ឲ្យអ្នកស្រុកអង្គុយមានសភាពក្តៅដោយសារតែពន្លឺថ្ងៃឡើងកាន់តែក្តៅខ្លាំងធ្វើឲ្យម្ចប់កាន់តែតិចទៅ ។ ដោយសារតែមូលហេតុទាំងអស់នេះធ្វើឲ្យមនុស្សជាច្រើនក្រោកឈរនៅពេលកំពុងបញ្ចាំងភាពយន្ត ហើយចាកចេញទៅជាមួយកូនតូចៗរបស់គាត់មុនពេលដែលការប្រជុំបញ្ចប់ ។ ទោះជាយ៉ាងនេះក៏ដោយ ចំនួនមនុស្សដែលចូលរួមក្នុងព្រឹត្តិការណ៍នេះមានចំនួនច្រើនគួរឲ្យចាប់អារម្មណ៍បើគិតអំពីចម្ងាយផ្លូវនិងទំហំដីតូចរបស់ភូមិ ។ អ្នកចូលរួមបានដឹងពីការបង្កើតតុលាការខ្មែរក្រហមទោះជាមិនលម្អិតណាស់ណាក៏ដោយ ហេតុនេះវេទិកានេះផ្តល់ឱកាសឲ្យពួកគាត់បានរៀនសូត្រពីករណី០០១និងចាប់ផ្តើមពិចារណាពីសវនាការលើកក្រោយទៀត ។ ការចូលរួមជាវាគ្មិនកិត្តិយសរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត លោក ហ៊ឹម ហ៊ុយ លោក នង ចាន់ផល បានបង្កើនឥទ្ធិពលនៃការពិភាក្សានិងជួយឲ្យអ្នកស្តាប់ផ្តោតទៅលើបញ្ហានៃការផ្សះផ្សាគ្នារវាងជនរងគ្រោះនិងជនដៃដល់ ។ ក្រុមការងារក៏បានប្រមូលព័ត៌មានថ្មីៗអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងតំបន់ព្រមទាំងប្រមូលឈ្មោះនិងទីតាំងផ្សេងៗរបស់អតីតកម្មាភិបាលដើម្បីទុកទំនាក់ទំនងនៅពេលក្រោយៗទៀត ។ **អាន ហេនឌុល**

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីសង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**

# តើការអត់ឱនទោសអាចធ្វើបានដែរឬទេ?

នៅពេលព្រឹក ខ្ញុំនិងក្រុមគម្រោងបានទៅដល់ម៉ាស្ជិតមួយ ឈ្មោះថា មូដារ៉ាក ស្ថិតនៅក្នុងភូមិអូរត្រាវ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានចម្ងាយប្រហែលជា១០០ ម៉ែត្រពីច្រកចូល ។ ម៉ាស្ជិតនេះត្រូវបានសាងសង់នៅឆ្នាំ១៩៦៣ ដោយលោក គឹម យូណុះ ដែលទីតាំងរបស់ម៉ាស្ជិតនេះមានទេសភាពយ៉ាងស្រស់ស្អាតនិងអាចមើលឃើញភ្នំផង ។ ដោយសារតែដីនៅក្នុងបរិវេណម៉ាស្ជិតនេះមានលក្ខណៈទាប ដូច្នេះហើយជនជាតិចាមទាំងអស់បានទាំគ្នាជីកស្រះទឹកពីរទៀតដើម្បីយកដីចាក់ធ្វើខឿនម៉ាស្ជិតនេះបន្ថែមឲ្យបានខ្ពស់ ដែលសព្វថ្ងៃស្រះទឹកមួយត្រូវបានជនជាតិអ៊ីស្លាមយកទឹកមកប្រើប្រាស់ និងមួយទៀតត្រូវបានលុបបំពេញដើម្បីសាងសង់សាលារៀនថ្មីមួយខ្នងទៀត ។ នៅឆ្នាំ១៩៧៣ ម៉ាស្ជិតនេះត្រូវបានបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកចំដំបូលម៉ាស្ជិតនេះតែម្តង ដែលធ្វើឲ្យជញ្ជាំងម៉ាស្ជិតនេះទទួលការប្រេះស្រាំខ្លះៗដែរ ។ លើសពីនេះទៅទៀត ដោយសារស្ថានភាពច្របូកច្របល់បែបនេះ ទាហានលន់ នល់ ក៏បានគាស់យកបង្អួច ទ្វារ និងបង្កាន់ដៃចេញ ដែលធ្វើឲ្យម៉ាស្ជិតនេះមានសភាពខូចខាតកាន់តែធ្ងន់ធ្ងរថែមទៀត ។

នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់កាប់អំណាច ខ្មែរក្រហមបានយកម៉ាស្ជិតនេះទៅធ្វើជាមន្ទីរពេទ្យ និងជាឃ្លាំងស្តុកអំបិល ចំណែកសាលារៀនធ្វើជារោងបាយសហករណ៍ ។ ដោយសារតែខ្វះការថែរក្សានិងការយកចិត្តទុកដាក់បានធ្វើឲ្យម៉ាស្ជិតនិងសាលារៀននេះមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ។ នៅឆ្នាំ១៩៧៩ ពេលដែលរបបនេះដួលរលំទៅ ទើបម៉ាស្ជិតនេះត្រូវបានជួសជុលជាបណ្តើរៗ ឯសាលារៀនក៏ត្រូវបានសង់ថ្មីមួយខ្នងទៀតនៅឆ្នាំ១៩៩៣ ពីព្រោះតែសាលារៀនមុនមានលក្ខណៈចាស់ខ្លាំងដែលមិនអាចឲ្យសិស្សចូលរៀនបាន ។

ដោយសារតែខ្មែរក្រហមបានបំផ្លាញម៉ាស្ជិតនៅទីនេះ រួមទាំងម៉ាស្ជិតនៅកន្លែងផ្សេងៗទៀត បានធ្វើឲ្យម៉ាស្ជិតមួយចំនួនទទួលរងនូវភាពប្រេះស្រាំនិងខ្លះទៀតមានលក្ខណៈចាស់ទ្រុឌទ្រោមខ្លាំងដែលស្ទើរតែរលំបាត់រូបរាង ។ លើសពីនេះ ខ្មែរក្រហមបានប្រព្រឹត្តទៅលើជនជាតិចាមយ៉ាងសាហាវឃោរឃៅថែមទៀត ដែលធ្វើឲ្យជនជាតិចាមឬក៏ខ្មែរតែងតែយល់ថា ការអត់ឱនទោសឲ្យមេដឹកនាំទាំងនេះគឺជារឿងពិបាកដែលអាចធ្វើទៅបានណាស់ ។

ជាការពិតណាស់ មនុស្សម្នាក់អាចអត់ឱនទោសឲ្យមនុស្សម្នាក់ទៀតបានគឺអាស្រ័យទៅចិត្តគំនិតរបស់បុគ្គលនោះ ព្រមទាំងទៅលើការជះឥទ្ធិពល ឬការទទួលរងដែលគាត់បានជួបប្រទះផង ។ ហើយបើជនរងគ្រោះមិនអាចអត់ឱនឲ្យជនដៃដល់បានអាចដោយសារតែស្ថានភាពនោះមានសភាពធ្ងន់ធ្ងរពេក និងមិនអាចធ្វើការបំភ្លេចបានទេ ។

ម៉ាត់ សេន អាយុ៦៨ឆ្នាំ រស់នៅភូមិទួលទទឹង ឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានរៀបរាប់ថា ក្រោយពីរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ចេញពីតំណែង នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានចាប់ផ្តើមចូលមកកាន់កាប់ភូមិនេះ ។ បន្ទាប់មក គ្រួសាររបស់គាត់ត្រូវបានជម្លៀសឲ្យទៅរស់នៅស្រុកទូកមាស ខេត្តកំពត ។ តាមផ្លូវធ្វើដំណើរគាត់បានឃើញទាហាន លន់ នល់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនយកទៅឃុំនៅក្នុងព្រះវិហារកំពង់នង់ ។ ក្រោយពីប្រារព្ធធ្វើពិធីជប់លៀងចប់ ខ្មែរក្រហមបានប្រកាសថា បងប្អូនណាដែលមានពាក់ស័ក្តិធំត្រូវបញ្ជូនទៅខេត្តកំពត ។ បន្ទាប់មកមានឡានប្រហែលជា១០គ្រឿងបានមកដឹកពួកគាត់យកទៅដោយមានទាំងជនជាតិខ្មែរនិងអ៊ីស្លាមផងដែរយកទៅសម្លាប់ចោលនៅភ្នំបូកគោ ។ គាត់បន្តថា ក្នុងចំណោមអ្នកទាំងនេះមាន មនុស្ស តែ៣-៤នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។

នៅឆ្នាំ១៩៧៧ គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅស្រុកកំពង់ត្រាច ។ នៅទីនោះ គាត់បានឃើញឈ្លបខ្មែរក្រហមម្នាក់ឈ្មោះ សាន ចាប់នារីម្នាក់ឈ្មោះ មាស សៅ (កូនស័ក្តិ៥នៅខេត្តកំពត) យកទៅរំលោភ រួចចងដាក់ឈើឆ្កាងមួយដោយស្រាតខោអាវរបស់នាងចេញទាំងអស់ ដោយសារតែនាងបដិសេធមិន

ព្រមស្រឡាញ់។ បន្ទាប់មក សេន បានឃើញដោយផ្ទាល់ភ្នែកពេលដែល សាន យកកាំបិតវះពោះនារីនោះទាំងរស់រហូតដល់ស្លាប់។ បន្ទាប់មក សាន បាន លូកទាញយកថ្លើមរបស់នាងឲ្យឈ្លបពីរនាក់ទៀតឈ្មោះ រិន និង ខ្មៅ យកទៅឆាស៊ី។ លើសពីនេះទៀត គាត់បានដឹងថាខ្មែរក្រហមបានសម្លាប់មនុស្សជាច្រើននាក់ដាក់ក្នុងស្រះរណ្ដៅគ្រាប់បែកបេ-៥២មួយយ៉ាងធំក្នុងព្រៃ ដោយមានចាក់មីក្រូៗដើម្បីបន្លប់កុំឲ្យប្រជាជនដឹង ខណៈពេលដែលខ្លួនកំពុងសម្លាប់មនុស្ស។ សេន រំឭកហេតុការណ៍នោះថា គាត់បានឃើញឈ្លបខ្មែរក្រហមចងស្លាបសេកប្រជាជនឲ្យឈរនៅមុខស្រះនោះ រួចឈ្លប៧នាក់ទៀតយកដំបងវាយឬផ្អាងត្នោតអារ-ក ទម្លាក់ចូលរណ្ដៅនោះតែម្ដង។ ចំណែកក្មេងៗវិញគឺបោះឡើងទៅលើ រួចយកកាំបិតចំពុះទុងចាក់សម្លាប់។ រយៈពេល៥ថ្ងៃទើបខ្មែរក្រហមបញ្ឈប់សកម្មភាពសម្លាប់មនុស្សនេះ។

សេន បានរៀបរាប់ឲ្យដឹងថា បងប្អូនជីទួតមួយរបស់គាត់ក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលដែរ (ពីរគ្រួសារ)។ ចំណែកឪពុកដែលមានមុខងារជាគ្រូបង្រៀនវិញក៏ត្រូវខ្មែរក្រហមសម្លាប់ដែរ ដោយពីរ-បីថ្ងៃក្រោយមក យាយតាពីរនាក់បានមកប្រាប់កូននោះថា «ឪពុករបស់អូនឯង ខ្មែរក្រហមចងយកទៅសម្លាប់នៅភ្នំល្អាងហើយ»។ បន្ទាប់មក កូននោះបានសុំខ្មែរក្រហមទៅមើលឪពុករបស់ខ្លួន។ គាត់បន្តថា គាត់បានទៅមើលទីតាំងសម្លាប់នៅក្នុងភ្នំល្អាងនោះដែរដោយឃើញមានស្នាមចាក់នឹងកាំបិត។ ចំណែកគ្រួសារបងប្រុសរបស់គាត់ឈ្មោះ សារ៉ស់ (សមាជិក៥នាក់) និងប្អូនស្រីឈ្មោះ អាមីណាស់ (សមាជិក៨នាក់) ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅក្នុងភ្នំល្អាងដែរ។

ដោយសារតែ សេន បានឃើញហេតុការណ៍ជាច្រើនដែលខ្មែរក្រហមបានសម្លាប់មនុស្ស រួមទាំងបងប្អូនរបស់គាត់យ៉ាងសាហាវឃោរឃៅបែបនេះ សេន យល់ថា ទោះបីជាមេដឹកនាំខ្មែរក្រហមកំពុងតែត្រូវបានកាត់ទោសក៏ដោយ ក៏គាត់មិនអាចអត់ឱនទោសឲ្យមេដឹកនាំទាំងនោះដែរ។ សេន រៀបរាប់ថា «សម្លាប់មនុស្សហើយមកសុំទោសក្រោយ នរណាក៏អាចធ្វើបានដែរ។ ប៉ុន្តែ ការសុំទោសនេះ គឺហួសពេលទៅហើយ»។ គាត់បានបន្តថា «បើគាត់មានកូនរៀនជាមួយកូនខ្មែរក្រហម ក៏គាត់មិនឲ្យរៀនជាមួយដែរ»។ ដូច្នេះ គាត់យល់ថា ការកាត់ទោស ឌុច ឲ្យជាប់គុកតែរយៈពេល៣៥ឆ្នាំនោះ គឺមិនសូវពេញចិត្តទេ លុះត្រាតែជាប់គុកមួយជីវិត។

ខុសប្លែកពី សេន ឈ្មោះ វ៉ាន់ សើ អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរជ្រៅ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុបានរៀបរាប់ថា នៅឆ្នាំ១៩៧១ សើ បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហម។ ក្រោយពីត្រូវបានចាត់តាំងឲ្យទៅប្រយុទ្ធជាច្រើនកន្លែងនៅសមរភូមិខេត្តកំពតនៅឆ្នាំ១៩៧៣ គាត់ក៏ត្រូវរបួសជង្គង់ ស្នាទាំងសងខាង ភ្លៅ និងខ្នង។ បន្ទាប់មក សើ ត្រូវបានបញ្ជូនមកសមរភូមិក្រោយដើម្បីព្យាបាលរបួស។ ក្រោយពីជាសះស្បើយពីជំងឺ ខ្មែរក្រហមម្នាក់ដែលសព្វថ្ងៃរស់នៅក្នុងភូមិជាមួយគាត់ដែរ (សូមមិនបញ្ចេញឈ្មោះ) បានចោទប្រកាន់គាត់ថា គេងកម្ទាំងពលកម្មរបស់ប្រជាជន រួចចាប់ចងស្លាបសេកយកទៅដាក់គុកនៅវាលរេញរយៈពេលបីថ្ងៃ។ គាត់បានបន្តថា ការចោទប្រកាន់នេះគឺដោយសារតែគំនុំ ដោយបានចាប់ទាំងបងថ្លៃប្រុសរបស់គាត់ឈ្មោះ ឡើ សាន់ និងបងប្រុសបង្កើតឈ្មោះ វ៉ាន់ អេង ទៅផង (សព្វថ្ងៃអ្នកទាំងពីរស្លាប់)។ ក្រោយមក សើ ត្រូវបានបញ្ជូនយកទៅដាក់ឃុំនៅជំរំអប់រំកែប្រែខ្លួន៧៥ រយៈពេលពីរខែទៀត។ នៅទីនោះ គាត់និងអ្នកទោសប្រហែលមួយពាន់នាក់ ដែលភាគច្រើនជាទាហានខ្មែរក្រហមដែរត្រូវបានចាត់តាំងឲ្យកាប់ឆ្ការព្រៃដើម្បីធ្វើស្រែចម្ការចាប់ពីព្រឹកព្រលឹមរហូតដល់ម៉ោង៦ល្ងាច ទើបអនុញ្ញាតឲ្យឈប់សម្រាកហូបបាយ។ ដោយសារតែគាត់គោរពវិន័យបានល្អ នៅឆ្នាំ១៩៧៣ គាត់ត្រូវបានផ្លាស់ឲ្យទៅធ្វើជាជាងឈើជាមួយសមាជិក៦នាក់ទៀតនៅ គុក៦៥ ដើម្បីលត់ដំខ្លួនក្រោមការគ្រប់គ្រងរបស់ប្រធានគុកឈ្មោះ ខេន។ នៅទីនោះ សើ បានដឹងថា គុកនោះមានបណ្ដោយប្រហែល៣០ម៉ែត្រ ដោយបែងចែកអ្នកទោសជាពីរកម្រិត គឺកម្រិតស្រាល (ឃុំនៅខាងលើផ្ទះ) និងកម្រិតធ្ងន់ (ឃុំនៅខាងក្រោមផ្ទះ) ដែលអ្នកទោសត្រូវបានដាក់ខ្នោះជើងទាំងអស់។ វ៉ាន់ សើ បន្តថា ពេលឃើញអ្នកទោសច្រើនបែបនេះ គាត់មានអារម្មណ៍ភ័យខ្លាចជាខ្លាំង ជាពិសេសឃើញឈ្លបបណ្ដើរមនុស្សយកទៅសម្លាប់ជារៀងរាល់ថ្ងៃ។ ដាក់ ស្តែង មិត្តភក្តិរបស់គាត់ឈ្មោះ អាង ក៏ត្រូវជាប់គុកនៅទីនោះ

ដែរ ។ ក្រោយមក អ្នកទោសទាំងនេះត្រូវបញ្ជូនទៅសំឡូតនិងតាឡីទៀតផង ។ ដោយសារការអនុវត្តវិន័យបានល្អ រយៈពេល ៧ខែក្រោយមក គាត់ត្រូវបានដោះលែងឲ្យមករស់នៅភូមិជើងគោ ឃុំជើងគោវិញ ។ នៅទីនោះ គាត់ត្រូវបានបង្ខំឲ្យធ្វើស្រែ និងហូបចុកដូចប្រជាជនធម្មតាដែរ ។

នៅឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមករំដោះ មិត្តភក្តិរបស់ សើ ដែលមានតួនាទីជាប្រធានឃុំនិងមិត្តភក្តិផ្សេងទៀតជំរុញឲ្យគាត់ធ្វើការសងសឹកចំពោះអ្នកដែលចោទប្រកាន់យកគាត់ទៅដាក់គុក ដោយឲ្យកាំបិតខ្វែវមួយទៅគាត់ ។ ប៉ុន្តែទោះជាមានការជំរុញយ៉ាងណាក៏ដោយ ក៏គាត់មិនធ្វើបែបនេះដែរ ដោយគាត់ជ្រើសរើសយកពាក្យសុភាសិតមួយថា «ពៀររម្ងាប់ដោយការមិនចងពៀរ» ។ សើ មិនចង់ចងកម្មចងពៀរនឹងគ្នាទៀតទេ ។ ដោយសារ សើ យកទ្រឹស្តីខាងលើនេះមកអនុវត្ត ដូច្នេះគាត់ព្រមអត់ឱនទោសឲ្យ ឌុច ទោះបីជា ឌុច បានសម្លាប់មនុស្សអស់ប្រហែល ១៤០០០នាក់នៅគុកទួលស្លែងក៏ដោយ ។ ម្យ៉ាងទៀតគឺថាតុលាការបានកាត់ទោស ឌុច ឲ្យជាប់គុករយៈពេល១៩ឆ្នាំដែលវាជាការគ្រប់គ្រាន់ហើយសម្រាប់ ឌុច ។

លេស ម៉ី អាយុ៧២ឆ្នាំ រស់នៅភូមិអូរត្រាវ ឃុំអណ្តូងថ្មស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានរៀបរាប់ថា គាត់បានរៀបការនៅឆ្នាំ១៩៥៤ ។ នៅពេលខ្មែរក្រហមចូលមកកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ គ្រួសាររបស់គាត់ដែលមានកូន១០នាក់និងឪពុកម្តាយរបស់គាត់ត្រូវបានជម្លៀសឲ្យទៅរស់នៅជាច្រើនកន្លែងរហូតដល់ស្រុកកោះកុង ។ បន្ទាប់មក ទាហានខ្មែរក្រហមបានបំបែកសមាជិកគ្រួសាររបស់គាត់ឲ្យទៅធ្វើការនៅតាមកងផ្សេងៗ ។ គាត់បន្ថែមថា ខ្មែរក្រហមមិនត្រឹមតែបង្ខំឲ្យគាត់ហូបសាច់ជ្រូកប៉ុណ្ណោះទេ ថែមទាំងបញ្ជាឲ្យគាត់ធ្វើការរហូតដល់យប់ទៀតផង ។ លើសពីនេះទៅទៀត នៅពេលដែលគាត់ធ្វើការ គាត់តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់គាត់និងកូនគាត់ជានិច្ច ពីព្រោះគាត់បានឃើញខ្មែរក្រហមសម្លាប់មនុស្សស្ទើរតែរៀងរាល់ថ្ងៃ ។ ធ្វើការបានប៉ុន្មានខែក្រោយមក គាត់បានទទួលដំណឹងថា កូនរបស់គាត់ពីរនាក់ដែលមានវ័យជំទង់និងរស់នៅភូមិត្របែកព្រៃត្រូវបានខ្មែរក្រហមសម្លាប់ហើយ ។ បន្ទាប់មក កូនរបស់គាត់៥នាក់ទៀតក៏ត្រូវស្លាប់ជាបន្តបន្ទាប់ដែរ ពីព្រោះតែខ្មែរក្រហមមិនផ្តល់អាហារឲ្យហូបគ្រប់គ្រាន់ និងបង្ខំឲ្យធ្វើការជាទម្ងន់ ។ ចំណែកប្រពន្ធ និង-ម្តាយ របស់គាត់ដែលធ្វើការនៅកងផ្សេងក៏ស្លាប់ដែរ ។

បន្ទាប់ពីរបបនេះដួលរលំទៅ កូនរបស់គាត់តែបីនាក់ប៉ុណ្ណោះដែលមានជីវិតត្រឡប់មកស្រុកកំណើតវិញ ។ នៅពេលនោះ ម៉ី ពិបាកចិត្តជាខ្លាំង ។ ក្រោយមកទៀត គាត់បានចាប់ផ្តើមគិតថា មិនមែនមានតែគ្រួសាររបស់គាត់ទេដែលបានស្លាប់ពីព្រោះគ្រួសារខ្មែរដទៃទៀតក៏អ៊ីចឹងដែរ ។ ដូច្នេះហើយ គាត់បានសម្រេចចិត្តថា គាត់មិនធ្វើការសងសឹកទេ ។ គាត់បន្តថា «វាគ្មានប្រយោជន៍ ពីព្រោះកូនរបស់គាត់ស្លាប់បាត់ទៅហើយ ។ លើសពីនេះទៅទៀត វាមិនអាចឲ្យកូនរបស់គាត់រស់រានមានជីវិតមកវិញទេ ទោះបីជាយើងសម្លាប់មេដឹកនាំទាំងអស់នោះចោលក៏ដោយ ។ យើងមិនត្រូវសងសឹកវិញទេ ។ ព្រះនឹងកាត់ទោសពួកគេ ។ ម្យ៉ាងទៀត មេដឹកនាំខ្មែរក្រហមនឹងស្លាប់នៅក្នុងគុកដោយសារវ័យចំណាស់របស់ពួកគេ» ។

ដូច្នេះហើយ ការអត់ឱនទោសនេះគឺអាស្រ័យទៅលើការយល់ឃើញរបស់បុគ្គលម្នាក់ៗ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីអភិវឌ្ឍសង្គមឲ្យរីកចម្រើន ប្រជាជនទាំងអស់គួរតែចាប់ផ្តើមធ្វើការផ្សះផ្សារបួសផ្លូវចិត្តរបស់ខ្លួនតាមរយៈការចែករំលែករឿងរ៉ាវដែលខ្លួនធ្លាប់ជួបប្រទះដល់ក្មេងជំនាន់ក្រោយ ក៏ដូចជាអ្នកដែលមិនធ្លាប់ឆ្លងកាត់របបនោះដោយផ្ទាល់ដែរ ។

**តាត លក្ខិណា**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

# ការចោទប្រកាន់អំពីការអនុវត្តផ្នែកសុខាភិបាល របស់ខ្មែរក្រហមថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

***(តពីលេខមុន)***

*ការបណ្តុះបណ្តាលដ៏ខ្លីនិងភាពមិនចេះអក្សររបស់បុគ្គលិកពេទ្យបានបន្តឲ្យមានលទ្ធផលដ៏អាក្រក់ ។ ទោះបីជាពេទ្យខ្លះហាក់បីដូចជាចង់ជួយអ្នកជំងឺនិងអ្នករងរបួសក៏ដោយ ក៏ការទទួលការបណ្តុះបណ្តាលដ៏តិចតួចបានបណ្តាលឲ្យអ្នកទាំងនោះធ្វើឲ្យអ្នកជំងឺស្លាប់ជាច្រើន ។ អ្នកជំងឺត្រូវបានផ្តល់ថ្នាំ និងប្រាប់ពីចំនួនដងនៃការលេបថ្នាំដូចគ្នាដោយមិនគិតពីប្រភេទជំងឺឡើយ ។ ការចាក់ថ្នាំក៏មានលក្ខណៈមិនត្រឹមត្រូវដែរពីព្រោះវារួមផ្សំដោយការព្យាបាលមិនត្រឹមត្រូវ និងសារធាតុរាវដែលត្រូវបានគេប្រឡំថាជាថ្នាំព្យាបាល ។ ដោយសារពេទ្យខ្មែរក្រហមមិនដែលទទួលបានការណែនាំឲ្យស្គាល់ពីរោគសញ្ញានៃជំងឺផ្សេងៗគ្នា ឬសម្ភារៈបច្ចេកទេសដើម្បីពិនិត្យសុខភាពអ្នកទាំងនោះបានត្រឹមតែអាចព្យាបាលនិងសម្គាល់ជំងឺជាក់លាក់មួយចំនួនប៉ុណ្ណោះ ដូចជា របួស រាករូស ជំងឺអាសន្នរោគ និងជំងឺគ្រុនក្តៅខ្លួនធម្មតា ។ ជំងឺ «កំបាំង» ដែលពាក់ព័ន្ធនឹងសួត ពោះវៀន និងក្រពះ ដែលមិនអាចសម្គាល់បានតាមរយៈដៃ ឬឃើញនឹងភ្នែកមិនអាចត្រូវបានរកឃើញទេ ដូច្នេះអ្នកជំងឺដែលបង្ហាញថាខ្លួនមានជំងឺនឹងត្រូវចោទប្រកាន់ថាធ្វើជាឈឺ ឬមានជំងឺ «សតិអារម្មណ៍» ។ អ្នកជំងឺដែលឈឺធ្ងន់មិនអាចព្យាបាលបានត្រូវខ្មែរក្រហមទុកចោលឲ្យស្លាប់តែម្តង ។*

***ក) ការពឹងផ្អែកទៅលើថ្នាំដែលផលិតក្នុងស្រុក***

*បដិវត្តន៍ផ្នែកសុខាភិបាលរបស់ខ្មែរក្រហមក៏មានរួមបញ្ចូលទាំងការដាក់កំហិតមិនឲ្យបុគ្គលិកពេទ្យប្រើប្រាស់ថ្នាំដែលត្រូវបានពិសោធន៍តាមបែបវិទ្យាសាស្ត្រដើម្បីព្យាបាលអ្នកជំងឺនិងរបួសដែរ ។ អង្គការបានប្រកាសថា «យើងមិនពឹងផ្អែកទៅលើបច្ចេកវិទ្យាទេ ។ យើងអភិវឌ្ឍប្រទេសយើងតាមរយៈឥរិយាបថបដិវត្ត ។ អ្វីដែលមិនមែនជាបដិវត្តន៍នឹងមិនត្រូវយកមកប្រើប្រាស់ទេ ។ បុគ្គលិកពេទ្យសង្គមនិយមត្រូវតែបោសសម្អាតកាកសំណល់របស់សង្គមចាស់និងថ្នាំទំនើបចោល» ។ ដូចការអះអាងរបស់គណៈមជ្ឈិមបក្សទៅលើការពឹងផ្អែកលើខ្លួនឯងដែរ ប៉ុល ពត បាននិយាយជាផ្លូវការថាថ្នាំទាំងអស់ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសគួរតែជាថ្នាំដែលផលិតដោយកម្មាភិបាលខ្មែរក្រហមសម្រាប់ឱសថស្ថាននិងមន្ទីរពេទ្យនៅក្នុងប្រទេស ។ «យើងត្រូវតែបង្កើតក្រុមស្រាវជ្រាវមួយ និងដឹកនាំការពិសោធទៅលើថ្នាំបុរាណ ។ ទោះបីជាយើងមិនមានរូបមន្តត្រឹមត្រូវ យើងនៅតែអាចផលិតវាបាន ។ យើងកំពុងតែអនុវត្តការពឹងផ្អែកលើខ្លួនឯងផ្នែកថ្នាំពេទ្យ» ។*

*ក្រសួងសុខាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យបានដឹកនាំវគ្គបណ្តុះបណ្តាលកម្មាភិបាលពេទ្យខ្មែរក្រហមដែលភាគច្រើនជាស្ត្រីដើម្បីអប់រំពីមធ្យោបាយផលិតថ្នាំសម្រាប់ព្យាបាល*



*ពេទ្យខ្មែរក្រហមកំពុងលាយថ្នាំ ខែសីហា ឆ្នាំ១៩៧៨*

ជំងឺទូទៅដូចជា ក្តៅខ្លួន ឈឺក្បាល ឈឺក្រពះនិងជំងឺសន្លប់ ។ «ថ្នាំ» ដែលផលិតក្នុងស្រុករួមមានឬសឈើ សំបកឈើ រុក្ខជាតិនៅតំបន់ត្រូពិចនិងសារធាតុ «ធម្មជាតិ» ផ្សេងៗ ។ វាត្រូវបានគេហៅថាថ្នាំ «អាចម៍ទន្សាយ» ដោយសារតែរូបរាង និងភាពគ្មានប្រសិទ្ធភាពរបស់វា ។ ដោយត្រូវបានផលិតឡើងដោយគ្មានការពិសោធតាមបែបវិទ្យាសាស្ត្រ ថ្នាំអាចម៍ទន្សាយអាចសម្លាប់អ្នកជំងឺ ឬធ្វើឲ្យអ្នកជំងឺឈឺកាន់តែធ្ងន់ ពីព្រោះវាត្រូវបានចែកដល់អ្នកជំងឺគ្រប់គ្នាដោយមិនគិតពីរោគសញ្ញារបស់អ្នកទាំងនោះឡើយ ។

បុគ្គលិកពេទ្យដែលត្រូវបានជ្រើសរើសឲ្យផលិតថ្នាំដឹងថាថ្នាំនោះមិនមានប្រសិទ្ធភាពទេ ប៉ុន្តែអ្នកទាំងនោះត្រូវតែបង្ខំចិត្តធ្វើតាមបញ្ជារបស់អង្គការ ។ ស្រដៀងគ្នានេះដែរ អ្នកជំងឺជាច្រើនដែលបានលេបថ្នាំអាចម៍ទន្សាយដឹងថាថ្នាំនេះមិនមានប្រសិទ្ធភាព ឬអាចបង្កគ្រោះថ្នាក់ដល់ជីវិត ប៉ុន្តែអ្នកទាំងនោះមិនអាចមិនលេបវាបានទេ ។ អ្នកខ្លះឃ្លានខ្លាំងពេករហូតលេបថ្នាំអាចម៍ទន្សាយសម្រាប់បង្កើនសារធាតុអាហារ ទោះបីជាដឹងថាថ្នាំនោះអាចប៉ះពាល់ដល់សុខភាពក៏ដោយ ។

បន្ថែមទៅលើការផលិតថ្នាំអាចម៍ទន្សាយ ខ្មែរក្រហមបានផលិតសារធាតុរាវសម្រាប់ចាក់ឲ្យអ្នកជំងឺដែលមានរបួសនិងមានជំងឺថែមទៀត ។ សារធាតុ «ធម្មជាតិ» ដែលមាននៅក្នុងថ្នាំអាចម៍ទន្សាយត្រូវបានប្រែក្លាយជាសារធាតុរាវ ហើយបន្ទាប់មកយកទៅចាក់បញ្ចូលតាមសរសៃឈាម និងត្រគាករបស់អ្នកជំងឺ ។ អតីតពេទ្យខ្មែរក្រហមម្នាក់បានរំឭកថា «ខ្មែរក្រហមក៏មានសេរ៉ូមទឹកប្រៃនិងផ្អែម ដែលរក្សានៅក្នុងដបនិងខ្ចប់ដោយកញ្ចប់ប្លាស្ទិកសម្រាប់ចាក់ដែរ ។ ទឹកសេរ៉ូមនោះបានធ្វើឲ្យខ្ញុំមានភាពតក់ស្លុតពីព្រោះវាជាទឹកដូង» ។ អតីតពេទ្យម្នាក់ទៀតបាននិយាយថា ទឹកដូងស្រស់ប្រភេទខ្លះអាចព្យាបាលអ្នកជំងឺនៅពេលបន្ទាន់ ប៉ុន្តែពេទ្យខ្មែរក្រហមមិនត្រូវបានអប់រំឲ្យដឹងថា ដូងណាអាចប្រើប្រាស់ជាថ្នាំ ដូងណាជាដូងស្រស់ ឬថាតើត្រូវកាប់ដូងដោយរបៀបណាដើម្បីកុំឲ្យទឹកដូងក្លាយជាពុល ។ ដូច្នេះការចាក់ថ្នាំដោយប្រើទឹកដូងអាចធ្វើឲ្យអ្នកជំងឺស្លាប់ ។ ដោយសារតែពេទ្យខ្មែរក្រហមជាច្រើនមិនចេះអក្សរ វាមានបញ្ហាបន្ថែមមួយចំនួនទាក់ទងនឹងការចាក់ថ្នាំអ្នកជំងឺដោយប្រើថ្នាំដែលខ្លួនយល់ថាវាផលិតដោយខ្លួនឯង ប៉ុន្តែតាមពិតវាជាសារធាតុរាវដែលមិនជាប់ពាក់ព័ន្ធ ។ អាស្រ័យហេតុនេះ អ្នកជំងឺខ្លះ ត្រូវបានចាក់ដោយវត្ថុធាតុរាវដូចជា ទឹក ស៊ុបមាន់ និងទឹកត្នោត ។

ការរួចរស់ពីជំងឺនិងការស្លាប់បន្ទាប់ពីការចាក់ថ្នាំគឺអាស្រ័យទៅលើវិធីសាស្ត្រនៃការចាក់ថ្នាំ ។ ដោយមិនមានការផ្គត់ផ្គង់សម្ភារវេជ្ជសាស្ត្រទំនើប សារធាតុរាវដែលជាថ្នាំការពារត្រូវបានយកទៅដាក់នៅក្នុងដបសូដាដែលមិនត្រូវបានកម្ចាត់មេរោគអស់ ។ ពេទ្យខ្មែរក្រហមបានប្រើប្រាស់សឺរ៉ាំងចាក់ថ្នាំ និងម្ជុលដែលមិនស្រួច ហើយសឺរ៉ាំងនោះត្រូវប្រើប្រាស់ដដែលៗ ។ មុនពេលចាក់ថ្នាំ គិលានុបដ្ឋាយិកាបាន «សម្អាត» ម្ជុលចាក់ថ្នាំដោយម្រាមដៃដ៏កខ្វក់របស់ខ្លួន ។ នៅពេលខ្លះ ម្ជុលត្រូវបានប្រើប្រាស់ជាច្រើនដងមុនពេល «យកទៅសម្អាត» ។ ជាលទ្ធផល អត្រានៃការឆ្លងជំងឺបន្ទាប់ពីទទួលការចាក់ថ្នាំមានកម្រិតដល់ទៅ៩០ភាគរយ នៅក្នុងភូមិដាច់ស្រយាលមួយចំនួន ហើយអ្នកជំងឺមានភាពភ័យខ្លាចចំពោះការចាក់ថ្នាំណាស់ ។

## ឃ) ថ្នាំបរទេសដែលមានប្រើប្រាស់សម្រាប់កម្មាភិបាលក្នុងជួរថ្នាក់ដឹកនាំខ្មែរក្រហម

ខណៈពេលដែលប្រជាជនកម្ពុជាភាគច្រើនដែលរស់នៅក្នុងរបបខ្មែរក្រហមទទួលរងគ្រោះ និងស្លាប់ដោយសារជំងឺព្រោះមិនបានទទួលការព្យាបាលត្រឹមត្រូវ មេដឹកនាំនិងកម្មាភិបាលខ្មែរក្រហមអាចប្រើប្រាស់ថ្នាំដែលមានការពិសោធតាមបែបវិទ្យាសាស្ត្រនិងបច្ចេកទេសទំនើប ។ វាទំនងជាមានការថែទាំសុខភាពបីកម្រិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅកម្រិតខ្ពស់បំផុតគឺគណៈមជ្ឈិមបក្ស និងកម្មាភិបាលជាន់ខ្ពស់អាចទទួលបានការថែទាំសុខភាពតាមបែបបស្ចិមប្រទេសនៅទីក្រុង ។ មន្ទីរពេទ្យព-១៧ នៅភ្នំពេញមានឧបករណ៍និងសម្ភារៈព្យាបាលទំនើបដែលនាំចូលពីបរទេស ។ អៀង ធីរិទ្ធ និងស្វាមីរបស់ខ្លួនទទួលការពិនិត្យសុខភាពនិងព្យាបាលនៅទីនោះ ហើយពីឆ្នាំ១៩៧៧-១៩៧៨ ខៀវ សំផន និង នួន ជា ក៏បានទៅធ្វើទស្សនកិច្ចនៅមន្ទីរពេទ្យនោះជាច្រើនដងដែរ ។ នៅក្រៅទីក្រុងដែលមិនមានឧបករណ៍ទំនើបបែបនេះក៏មានថ្នាំវិទ្យាសាស្ត្រល្អសម្រាប់ទុកព្យាបាលកម្មាភិបាលថ្នាក់ខ្ពស់ដែរ ។ ថ្នាំដែលផលិតនៅប្រទេសចិនដូចជា អាស្ពីរីន ថ្នាំការពារជំងឺគ្រុន

ចាញ់ ថ្នាំក្លូរ៉ូមេផេនីកុល និងតេត្រាស៊ីឃ្លីន ជាដើមសម្រាប់ផ្តល់ឲ្យកម្មាភិបាលទាំងនោះ ។

នៅកម្រិតបន្ទាប់ កម្មាភិបាលថ្នាក់ក្រោម និង «ប្រជាជនចាស់» «ប្រជាជនមូលដ្ឋាន» អាចស្វែងរកការព្យាបាលនៅមន្ទីរពេទ្យយោធា និងមន្ទីរពេទ្យតំបន់ដែលអាចមានថ្នាំវិទ្យាសាស្ត្រ និងមានបុគ្គលិកពេទ្យដែលធ្លាប់ទទួលការបណ្តុះបណ្តាលមុនពេលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ។ ប្រជាជនចាស់អាចចៀសផុតពីជំងឺធ្ងន់ធ្ងរនិងការស្លាប់ច្រើនជាងប្រជាជនថ្មី ពីព្រោះប្រជាជនចាស់ធ្លាប់បានចូលរួមរាយជាមួយខ្មែរក្រហមនៅអំឡុងសង្គ្រាមស៊ីវិលដែលធ្វើឲ្យអង្គការពេញចិត្ត ។ ពេទ្យខ្មែរក្រហមដែលជាប្រជាជនចាស់តែងតែផ្តល់ការព្យាបាលឲ្យប្រជាជនមូលដ្ឋានល្អជាង ហើយមានទុកថ្នាំវិទ្យាសាស្ត្រសម្រាប់ឲ្យអ្នកទាំងនោះនិងកម្មាភិបាលខ្មែរក្រហមប្រើប្រាស់ទៀតផង ។

«ប្រជាជនថ្មី» និងកម្មករ-កសិករផ្សេងទៀតត្រូវទៅទទួលការព្យាបាលនៅមន្ទីរពេទ្យដែលមានបុគ្គលិកពេទ្យក្មេងៗ ធ្វើការនិងទទួលថ្នាំអាចម៍ទន្សាយដែលផលិតដោយខ្លួនឯង និងការចាក់ថ្នាំ ។ ដោយសារតែប្រជាជនថ្មីមិនទម្លាប់នឹងការងាររកសិកម្ម និងទទួលរបបអាហារតិចតួច អ្នកទាំងនោះចាប់ផ្តើមមានជំងឺ និងឆាប់ខ្សោយជាងប្រជាជនចាស់ ។ ប៉ុន្តែនាមជាប្រជាជនថ្មី ធ្វើឲ្យអ្នកទាំងនោះ «មិនអាចមានថ្នាំដែលអាចព្យាបាលខ្លួនបានទេ ដូច្នេះអ្នកទាំងនោះក៏ស្លាប់ដោយជំងឺរាក គ្រុនចាញ់ និងគ្រុនពោះវៀន» ។ ប្រជាជនថ្មីតែងតែត្រូវបានចោទប្រកាន់ថាមាន «ជំងឺសតិអារម្មណ៍» ជាងមានជំងឺពិតប្រាកដ ដោយសារតែជំងឺរបស់អ្នកទាំងនោះមិនអាចមើលឃើញដោយភ្នែកទទេ ដូច្នេះពេទ្យក្មេងៗ (មិនអាចរកឃើញថាឈឺអ្វីឡើយ) ជាលទ្ធផលអ្នកទាំងនោះមិនអាចទទួលការព្យាបាលទេ ។ ជាពិសេស ស្ត្រីមិនត្រូវបានអនុញ្ញាតឲ្យទៅមន្ទីរពេទ្យទេ លើកលែងមានការសន្លប់សិន ។ នៅពេលដែលប្រជាជនថ្មីទទួលបានឱកាសដ៏តិចតួចទៅព្យាបាលជំងឺនៅមន្ទីរពេទ្យ អ្នកទាំងនោះទទួលបានការព្យាបាលមិនល្អដូចជាប្រជាជនចាស់ និងកម្មាភិបាលខ្មែរក្រហមទេ ។ ពេទ្យខ្មែរក្រហមម្នាក់នៅមន្ទីរពេទ្យព-១ បានអះអាងថា មន្ទីរពេទ្យព្យាបាលទាំងកូនរបស់កម្មាភិបាល និងកូនរបស់ប្រជាជនថ្មី ។ ពេទ្យនោះបាននិយាយថាកូនរបស់ «ប្រជាជន១៧មេសា» មិនដែលទទួលបានការព្យាបាលឲ្យបានប្រសើរទេ ហើយក្មេងជាច្រើននាក់នោះត្រូវស្លាប់ដោយសារជំងឺដែលអាចព្យាបាលបានដូចជា គេគាណូស កញ្ជ្រឹល អ៊ុតស្វាយ ជំងឺខាន់លឿង របេង គ្រុនក្តៅនិងរាកជាដើម ។ ភាគច្រើននៃជំងឺទាំងនេះកើតឡើងដោយសារតែការធ្វេសប្រហែស និងខ្វះអនាម័យរបស់ពេទ្យ ។ ប្រព័ន្ធសុខាភិបាលគឺជាភ័ស្តុតាងបញ្ជាក់ថា គណៈមជ្ឈិមបក្សដឹងថាសេវាសុខាភិបាលដែលខ្លួនផ្តល់ឲ្យប្រជាជនកម្ពុជាភាគច្រើនគឺមានភាពខ្វះខាតជាខ្លាំង ។ វាក៏អាចបញ្ជាក់ពីភាពមិនពិតនៃការប្តេជ្ញាចិត្តរបស់បក្សដែលចង់ធ្វើឲ្យមានភាពម្ចាស់ការលើផ្នែកសុខាភិបាលពីព្រោះការព្យាបាលតាមបែបបស្ចិមប្រទេសមិនអាចយកទៅព្យាបាលបុគ្គលដែលត្រូវបានគេហាមឃាត់មិនឲ្យប្រើប្រាស់ដើម្បីប្រយោជន៍បដិវត្តន៍ ។

## ៥) សារសំខាន់នៃថ្នាំរបស់បស្ចិមប្រទេស

ផលវិបាកដ៏ធ្ងន់ធ្ងរបំផុតពីការជំរុញឲ្យមានភាពឯករាជ្យម្ចាស់ការរបស់ខ្មែរក្រហមគឺការផ្តាច់ខ្លួនចេញពីសហគមន៍សេដ្ឋកិច្ចអន្តរជាតិ ។ ការបិទផ្សារលក់ទំនិញ ការហាមប្រាមមិនឲ្យប្រើប្រាស់ក្រដាសប្រាក់ និងការដាក់កំហិតមិនឲ្យធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃ បានបណ្តាលឲ្យមានយុគសម័យដ៏អាក្រក់មួយដែលជះឥទ្ធិពលអវិជ្ជមានដល់ចិត្តរបស់ «ប្រជាជនថ្មី» និងកម្មករកសិករ ។ នៅឆ្នាំ១៩៧៧ នៅពេលដែលប្រជាជនកំពុងជួបស្ថានភាពលំបាក ហើយប្រទេសកំពុងជួបប្រទះសង្គ្រាមទ្រង់ទ្រាយធំជាមួយវៀតណាម គណៈមជ្ឈិមបក្សបានបង្កើនការស្វែងរកការគាំទ្រពីប្រទេសសង្គមនិយមនានាដើម្បីផ្តល់សម្ភារមូលដ្ឋានដែលខ្លួនមិនអាចផលិតបានដូចជាថ្នាំពេទ្យ ចំណីអាហារ និងគ្រឿងសព្វាវុធ ។

ជាឧទាហរណ៍ នៅរយៈពេលបីខែដំបូង ប្រទេសកម្ពុជាបានចំណាយ១៦លានដុល្លារហុងកុង (៣.៥លានដុល្លារអាមេរិក) ទៅលើទំនិញរបស់ហុងកុងដែលបានមកពីប្រទេសអង់គ្លេស បារាំង និងសហរដ្ឋអាមេរិក បើប្រៀបធៀបទៅឆ្នាំ១៩៧៦ កម្ពុជាចំណាយត្រឹមតែ១១លានដុល្លារហុងកុងប៉ុណ្ណោះ ។ ក្នុងការចំណាយនេះ ប្រាក់ចំនួន១.១៧២.៣៤៦ដុល្លារហុងកុង ត្រូវបានចំណាយទៅលើថ្នាំដែលផលិតនៅបរទេស បើប្រៀបធៀបទៅឆ្នាំ១៩៧៦

កម្ពុជាបានចំណាយត្រឹមតែ១.៦៣៥.៤៥៥ដុល្លារហុងកុង ប៉ុណ្ណោះក្នុងរយៈពេលពេញមួយឆ្នាំ ។ ថ្នាំភាគច្រើនគឺសម្រាប់ ព្យាបាលជំងឺគ្រុនចាញ់ ដែលតាមប្រភពព័ត៌មានកម្ពុជាផ្លូវការបាន ប្រកាសថានៅឆ្នាំ១៩៧៧ ជំងឺគ្រុនចាញ់បានជះឥទ្ធិពលយ៉ាងខ្លាំង ទៅលើលទ្ធភាពធ្វើស្រែចម្ការរបស់ប្រជាជន ។ បន្ទាប់ពីការរីក រាលដាលនៃជំងឺគ្រុនចាញ់ «មេដឹកនាំកម្ពុជាបានបញ្ឈប់ការប្តេជ្ញា ចិត្តពឹងផ្អែកទៅលើថ្នាំបុរាណដែលផលិតដោយខ្លួនឯងទៀត ហើយ» ។ នៅចុងឆ្នាំ១៩៧៧ កម្ពុជាបាននាំចូលថ្នាំសម្លាប់សត្វ ល្អិតចំនួន២២៧គោនពីសហរដ្ឋអាមេរិក និង១២៥០គោនពី ក្រុមហ៊ុនរបស់អង់គ្លេសដែលមានមូលដ្ឋាននៅហុងកុង ។ សូម្បីតែ នៅឆ្នាំ១៩៧៦ កម្ពុជាបានធ្វើរបាយការណ៍ថាខ្លួនបានទិញថ្នាំ សម្លាប់សត្វល្អិតដែលមានតម្លៃ១.៦លានដុល្លារអាមេរិក ហើយ បានទទួលអំណោយជាថ្នាំការពារជំងឺគ្រុនចាញ់ពីអង្គការប្រឆាំង នឹងអំពើហិង្សារបស់សហរដ្ឋអាមេរិកទៀតផង ។

### ៣) ការបដិសេធមិនផ្តល់ការថែទាំសុខភាព ៖ អ្វីដែលមជ្ឈិមបក្សដឹង

មានភ័ស្តុតាងបញ្ជាក់ថាមេដឹកនាំដែលកំពុងរង់ចាំការជំនុំ ជម្រះនៅ អ.វ.ត.ក ដឹងពីផលប៉ះពាល់ដែលបង្កឡើងដោយគោល នយោបាយបដិវត្តន៍ផ្នែកសុខាភិបាលរបស់ប្រទេសជាពិសេស សេចក្តីសម្រេចក្នុងការផ្លាស់ប្តូរបុគ្គលិកពេទ្យដែលមានការបណ្តុះ បណ្តាលដោយដាក់ពេទ្យបដិវត្តន៍វ័យក្មេងដែលមិនចេះអក្សរមក ជំនួសវិញ ។ នៅក្នុងកិច្ចប្រជុំគណៈមជ្ឈិមបក្សដែលចូលរួមដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រធានពេទ្យឈ្មោះ ស៊ឹម លាងហាក់ ហៅ សី មានការអះអាងថា មានករណីជាច្រើន ដែលពេទ្យអាចផ្តល់ថ្នាំខុសឲ្យអ្នកជំងឺដែលមកសម្រាកព្យាបាលនៅ មន្ទីរពេទ្យខ្មែរក្រហម ពីព្រោះពេទ្យទាំងនោះមិនចេះអក្សរ ។ អៀង ធីរិទ្ធ បានអះអាងនៅពេលប្រជុំនោះថា ពេទ្យមានការលំបាកក្នុង ការព្យាបាលអ្នកជំងឺពីព្រោះអ្នកទាំងនោះមិនចេះអក្សរ ហើយបាន ទទួលការបណ្តុះបណ្តាលជំនាញវេជ្ជសាស្ត្រពីពេទ្យចិនដែលមិនចេះ ភាសាខ្មែរ ។

អៀង ធីរិទ្ធ ក៏ដឹងថានៅមន្ទីរពេទ្យ១៧មេសា កម្មាភិបាល ខ្មែរក្រហមរាប់រយនាក់ត្រូវបានដាក់គុក និងសម្លាប់ដោយទោស កំហុសតូចតាច ព្រោះតែប្រឆាំងនឹងបក្ស (ដូចជាខ្វះសីលធម៌និងខ្វះ ការទទួលខុសត្រូវក្នុងការនិយាយស្តី) ហើយអ្នកខ្លះទៀតត្រូវបាន ចាប់ខ្លួនដោយត្រូវចោទប្រកាន់ថាមិនបានផ្តល់ការព្យាបាលត្រឹម ត្រូវធ្វើឲ្យអ្នកជំងឺស្លាប់ ។ ការចាប់ខ្លួនទាំងនេះមិនមែនដើម្បីដោះ ស្រាយនូវការព្យាបាលមិនត្រឹមត្រូវនៅក្នុងប្រទេសទេ ប៉ុន្តែគឺដើម្បី បង្ហាញគណៈមជ្ឈិមបក្សថា ការងារទាំងអស់ដំណើរការទៅបាន ត្រឹមត្រូវហើយ ។ អៀង ធីរិទ្ធ បានចូលរួមក្នុងការប្រជុំដែលមាន ការចាប់ខ្លួនបុគ្គលិកពេទ្យទាំងនេះ បានបញ្ជាក់ថាគាត់ដឹងពីការ ព្យាបាលមិនត្រឹមត្រូវដែលបណ្តាលឲ្យអ្នកជំងឺស្លាប់ដែរ ។ ទោះបីជា អៀង ធីរិទ្ធ អាចប្រហែលជាដឹងពីគោល នយោបាយផ្នែកសុខាភិបាលរបស់គណៈ មជ្ឈិមបក្សដែលធ្វើឲ្យពេទ្យដែលគ្មានការ បណ្តុះបណ្តាលសម្លាប់អ្នកជំងឺដោយចៃដន្យ ក៏ដោយ ក៏ អៀង ធីរិទ្ធ មិនបានធ្វើអ្វីដើម្បី ទប់ស្កាត់ការចាប់ខ្លួនបុគ្គលិកពេទ្យ ឬការ ព្យាបាលមិនត្រឹមត្រូវនៅមន្ទីរពេទ្យដែរ ។ នៅក្នុងរបបខ្មែរក្រហមមិនមានការបណ្តុះ បណ្តាលពេទ្យ ឬគិលានុបដ្ឋាកសាជាថ្មីទេ ។



រោងចក្រផលិតឱសថនៅកំពង់ចាម ខែសីហា ឆ្នាំ១៩៧៨

គណៈមជ្ឈិមបក្សក៏ដឹងពីភាពគ្មាន ប្រសិទ្ធភាព និងការស្លាប់បណ្តាលមកពីថ្នាំ ដែលផលិតក្នុងស្រុកដែរ ។ នៅក្នុងកិច្ចប្រជុំ

គណៈអចិន្ត្រៃយ៍បក្ស អៀង ធីរិទ្ធ បានរាយការណ៍ពីភាពគ្មានប្រសិទ្ធភាពនៃថ្នាំជាច្រើនមុខរបស់ខ្មែរក្រហម ។ ប៉ុន្តែ ប៉ុល ពត នៅតែជំរុញឲ្យប្រើប្រាស់ថ្នាំនោះដដែល ដោយអះអាងថា «ប្រសិទ្ធភាព ឬគ្មានប្រសិទ្ធភាព យើងត្រូវតែប្រើប្រាស់ថ្នាំនេះដើម្បីសិក្សាពីវា» ។ ភស្តុតាងបន្ថែមដែលបញ្ជាក់ថាគណៈមជ្ឈិមបក្សក៏ដឹងពីរឿងថ្នាំគ្មានប្រសិទ្ធភាពនេះដែរ គឺតាមរយៈការចាត់តាំងរបស់ ប៉ុល ពត នៅឆ្នាំ១៩៧៦ ដោយឲ្យ អៀង ធីរិទ្ធ ទៅធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យដើម្បីស៊ើបអង្កេតអំពីការគ្រប់គ្រងទៅលើសុខភាព របបអាហារ និងការស្នាក់នៅរបស់កម្មករ កសិករ ។ អៀង ធីរិទ្ធ បានរកឃើញភស្តុតាងនៃ «បញ្ហា» ជាច្រើន ៖

*«ស្ថានភាពនៅទីនោះមានសភាពចម្លែក ។ នៅបាត់ដំបង ខ្ញុំបានឃើញកម្មាភិបាលបង្ខំឲ្យប្រជាជនទាំងអស់ធ្វើស្រែ ។ វាលស្រែស្ថិតនៅឆ្ងាយពីភូមិខ្លាំងណាស់ ។ ប្រជាជនមិនមានផ្ទះសម្បែង ហើយមានជំងឺ ។ ខ្ញុំដឹងថា បទបញ្ជារបស់នាយករដ្ឋមន្ត្រី ប៉ុល ពត គឺមិនអនុញ្ញាតឲ្យមានមនុស្សចាស់ ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅកូន ឬក្មេងតូចៗទៅធ្វើការនៅវាលស្រែទេ ។ ប៉ុន្តែខ្ញុំបែរជាឃើញអ្នកទាំងអស់គ្នាធ្វើការនៅវាលស្រែហាលខ្យល់ ហាលថ្ងៃទៅវិញ ហើយអ្នកខ្លះមានជំងឺរាក និងគ្រុនចាញ់ទៀតផង» ។*

នៅក្នុងរបាយការណ៍ផ្ញើទៅឲ្យគណៈមជ្ឈិមបក្សស្តីពីការធ្វើទស្សនកិច្ចរបស់គាត់ អៀង ធីរិទ្ធ បានបន្ទោស «ភ្នាក់ងារសត្រូវ» ចំពោះស្ថានភាពមិនល្អដែលគាត់បានឃើញជាជាងគោលនយោបាយសុខាភិបាលរបស់បក្សឬការជម្លៀសប្រជាជនប្រាំបីសែននាក់ទៅភូមិភាគពាយ័ព្យនោះទេ ។ អៀង ធីរិទ្ធ បានរាយការណ៍ថា «ភ្នាក់ងារនោះបានចូលមកក្នុងបក្សយើង ហើយបានឡើងកាន់អំណាចខ្ពស់ជាងគេទៀត ។ ភ្នាក់ងារនោះគោងតែបង្ហាញមុខពីរ ធ្វើដូចខ្លួនកំពុងតែដើរតាមមាគ៌ារបស់យើងដូច្នោះដែរ» ។

អៀង ធិរិទ្ធ មិនមែនជាមេដឹកនាំខ្មែរក្រហមតែម្នាក់ដែលបានរាយការណ៍ទៅគណៈមជ្ឈិមបក្សអំពីស្ថានភាពរស់នៅដ៏អាក្រក់ដែលប្រជាជនកម្ពុជាភាគច្រើនបានជួបប្រទះទេ ។ នៅក្នុងរបាយការណ៍ខែមិថុនា ឆ្នាំ១៩៧៧ ផ្ញើទៅមន្ទីរ៨៧០ (ការិយាល័យរបស់គណៈមជ្ឈិមបក្ស) កម្មាភិបាលភូមិភាគនិរតីបាននិយាយពីស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងស្រុកផ្សេងៗដែលខ្លួនបានគ្រប់គ្រងថា ៖

*(តំបន់២៥) ៖ ស្ថានភាពរស់នៅរបស់ប្រជាជន ៖ បច្ចុប្បន្នស្ថានភាពរស់នៅរបស់ប្រជាជនហាក់ដូចជាធម្មតា ។ ទោះបីជាស្ថានភាពរស់នៅរបស់ប្រជាជននៅស្រុកកៀនស្វាយ និងលើកដែកបានជួបប្រទះនឹងបញ្ហាក៏ដោយ បច្ចុប្បន្នស្ថានភាពបានប្រសើរឡើងហើយ ។ នៅតំបន់៣៣ ស្ថានភាពរស់នៅរបស់ប្រជាជនហាក់ដូចជាធម្មតាដែរ ប៉ុន្តែប្រសិនបើមានបញ្ហា វាកើតនៅតែមូលដ្ឋានប៉ុណ្ណោះ ។ យើងអាចនិយាយបានថា យើងអាចដោះស្រាយបញ្ហានេះបាន ។ ស្ថានភាពរស់នៅ និងសុខភាពរបស់ប្រជាជននៅតំបន់ទាំងបួនៈ បច្ចុប្បន្ន នៅខេត្តកំពត កំពង់ស្ពឺ និង តាកែវ ប្រជាជនមានជំងឺអាសន្នរោគ ហើយប្រជាជនខ្លះបានស្លាប់ ។*

រស់ ញឹម អនុប្រធានទីពីរនៃគណៈប្រធានរដ្ឋ ក៏បានផ្ញើរបាយការណ៍ជាប្រចាំទៅមន្ទីរ៨៧០ ដែលរៀបរាប់ព័ត៌មានអំពីស្ថានភាពរបស់ប្រជាជនដែរ ។ នៅក្នុងរបាយការណ៍ថ្ងៃទី១៦ និង១៧ ខែឧសភា ឆ្នាំ១៩៧៨ រស់ ញឹម បានសង្ខេបពីស្ថានភាពរស់នៅដ៏លំបាកដែលកើតមាននៅគ្រប់តំបន់នៃប្រទេស ហើយបន្ទាប់មក រស់ ញឹម បានរៀបរាប់ពីបញ្ហាផ្ទាល់របស់គាត់ជាមួយនឹងការខ្វះខាតនៃផ្នែកសុខាភិបាលរបស់ខ្លួននៅក្នុងប្រទេស ៖

*ខ្ញុំបានទទួលសារតាមទូរលេខដែលនិយាយថា ខ្ញុំអាចស្នាក់នៅមន្ទីរពេទ្យ ។ ខ្ញុំមានជំងឺដោយសារការផ្លាស់ប្តូរនៃសម្ពាធឈាម ។ បច្ចុប្បន្ន ជំងឺនេះបានរីករាលដាល ដែលធ្វើឲ្យខ្ញុំមិនអាចដើរ ឬអង្គុយពីរទៅបីថ្ងៃ ។ ខ្ញុំមានជំងឺដោយសារតែការធ្វើការច្រើន និងហួសកម្លាំង ។ មិនមានពេទ្យព្យាបាលខ្ញុំទេ ។ មានតែបុគ្គលិកពេទ្យក្មេង ប៉ុន្តែបុគ្គលិកនោះទើបតែត្រូវបានបង្រៀនពីការវាស់សម្ពាធឈាម និងឲ្យថ្នាំ ។ ចំពោះជំងឺខ្ញុំ ខ្ញុំនឹងទៅព្យាបាលនៅពេលដែលខ្ញុំឈឺធ្ងន់ ពីព្រោះបច្ចុប្បន្នខ្ញុំ មានការងារជាច្រើនត្រូវធ្វើ ជាពិសេសទាក់ទងនឹងស្ថានភាពរស់នៅ ។*

**(នៅមានត)**

**ឡុង ឌីលីម**

# លទ្ធភាពនៃការចោទប្រកាន់អំពើប្រល័យពូជសាសន៍ ដែលខ្មែរក្រហមបានធ្វើទៅលើខ្មែរក្រោម

**(តចប់)**

*ក) ក្រុមដែលទទួលបានការការពារដែលមិនជាប់ពាក់ព័ន្ធនឹងក្រុមណាមួយនៃក្រុមទាំងបួនដែលបានកំណត់*

ដើម្បីដោះស្រាយបញ្ហានៃការកំណត់ជនជាតិហ៊ូទូ និងទុតស៊ី នៅក្នុងករណី អាកាយេស៊ូ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានពឹងផ្អែកទៅលើកំណត់ហេតុរបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍ដែលបានចែងថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានចោទប្រកាន់ថាជាអំពើដែលប្រព្រឹត្តតែទៅលើក្រុម «ស្ថិរភាព» គឺមិនមែនក្រុម «ចល័ត» ទេ ។ ជាលទ្ធផល ចៅក្រមបានរកឃើញថា ជនជាតិទុតស៊ីគឺជាក្រុមអចិន្ត្រៃយ៍និងស្ថិរភាព ដែលសមស្របនឹងទទួលបានការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍ ទោះបីជាប្រជាជនទុតស៊ីមិនមានភាសាខ្លួនឯង ឬវប្បធម៌ខុសប្លែកពីប្រជាជនរ៉្វាន់ដាដទៃទៀតក៏ដោយ ។ អត្តសញ្ញាណក្រុមដែលកំណត់ដោយលក្ខណៈវិនិច្ឆ័យអចិន្ត្រៃយ៍ មិនត្រូវបានអនុម័តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាភ្លាមៗនោះទេ ។ ខណៈពេលដែលតុលាការបានប្រើប្រាស់ចំណុចខ្លះដើម្បីដាក់កំហិតទៅលើទំហំនៃការការពារក្រុមអចិន្ត្រៃយ៍ និងស្ថិរភាព មិនមានសេចក្តីសម្រេចក្រោយៗមកបានព្យាយាមពង្រីកក្រុមដែលទទួលបានការការពារចេញពីក្រុមទាំងបួន ឬអនុម័តនិយមន័យដ៏ទូលំទូលាយនៃក្រុមដែលទទួលបានការការពារទេ ។ នៅក្នុងការពិភាក្សា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបែងចែកក្រុមជនរងគ្រោះជាក្រុមមួយដែលស្ថិតនៅក្នុងក្រុមទាំងបួន ។

ស្រដៀងនឹងយុត្តិសាស្ត្រដែលប្រើប្រាស់នៅក្នុងករណី អាកាយេស៊ូ នៅក្នុងករណី ក្រាទីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានអះអាងថា «ការងារពីមុនរបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍បង្ហាញថា ការកំណត់ក្រុមបែបនេះត្រូវបានគេពង្រីកឲ្យកាន់តែទូលាយដើម្បីបកស្រាយទៅលើបញ្ហាមួយដែលស្របនឹងក្រុមជនជាតិភាគតិចជាជាងក្រុមមនុស្សជាក់លាក់មួយចំនួន ។ អាស្រ័យហេតុនេះ វានឹងមិនមានលក្ខណៈស្របនឹងគោលដៅនៃអនុសញ្ញាអំពើប្រល័យពូជសាសន៍ក្នុងការ «ព្យាយាមបែងចែកក្រុមមនុស្សដោយយោងទៅតាមគោលការណ៍លក្ខណៈវិនិច្ឆ័យតាមគោលការណ៍វិទ្យាសាស្ត្រ» ។ អាស្រ័យហេតុនេះ នៅក្នុងករណី ក្រាទីក តុលាការមិនបានពង្រីកក្រុមទាំងបួននេះទេ ។ ប៉ុន្តែ តុលាការបានអះអាងថា ក្រុមដែលទទួលបានការការពារមិនចាំបាច់ត្រូវតែជាក្រុមទាំងបួន ប៉ុន្តែវាត្រូវតែមានលក្ខណៈដូច នឹងផ្នែកណាមួយនៃក្រុមទាំងបួន ។ ដូច្នេះ តុលាការមិនបានបែងចែកក្រុមមូស្លីមនៅប៊ូស្នៀថាជាក្រុមសាសនា ជាតិ ពូជសាសន៍ ឬជាតិពន្ធុទេ ។ ប៉ុន្តែ តុលាការបានអះអាងថា ប្រជាជនមូស្លីមនៅប៊ូស្នៀអាចបង្កើតជាក្រុមដែលទទួលបានការការពារ» ។

*៦) បទដ្ឋានតុលាការពិសេសក្នុងការកំណត់ក្រុមដែលទទួលបានការការពារដើម្បីកាត់ទោសអំពើប្រល័យពូជសាសន៍បានប្រើប្រាស់ទម្រង់នៃយុត្តិសាស្ត្រ «សត្យានុម័ត» «អត្តនោម័ត» និង «ចម្រុះ» ។*

ដើម្បីបញ្ជាក់ថា ក្រុមមួយត្រូវបានការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍ តុលាការពិសេសបានបែងចែកការកំណត់តម្រូវការជាពីរដំណាក់ ។ ទីមួយ តុលាការត្រូវកំណត់ថាក្រុមនោះស្ថិតនៅក្រោមអនុសញ្ញាអំពើប្រល័យពូជសាសន៍ ហើយទីពីរ តុលាការត្រូវតែកំណត់ភាពជាសមាជិករបស់ក្រុមនោះ ។ នៅក្នុង

ដំណាក់កាលនៃការវិភាគទាំងពីរ តុលាការជាច្រើនបានប្រើប្រាស់ការរួមបញ្ចូលគ្នានៃកត្តាសត្យានុម័ត និងអត្តនោម័ត ។

### ក) យុត្តិសាស្ត្រ «សត្យានុម័ត»

យុត្តិសាស្ត្រ «សត្យានុម័ត» គឺជាយុត្តិសាស្ត្រដំបូងគេដែលប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាដើម្បីកំណត់ក្រុមជនរងគ្រោះនិងសមាជិករបស់ក្រុមនោះ ។ ការប្រើប្រាស់ពាក្យថា «សត្យានុម័ត» គឺមិនសូវជាត្រឹមត្រូវ ។ មិនមានតុលាការណាបានដើរតាមយុត្តិសាស្ត្រសត្យានុម័តទាំងស្រុងទេគឺថាតុលាការនោះតែងតែមើលទៅលើកត្តាអត្តនោម័តផ្សេងៗដូចជាការយល់ឃើញទៅលើក្រុមជនរងគ្រោះ ។ ធាតុសំខាន់នៃយុត្តិសាស្ត្រសត្យានុម័តគឺ ក្រុមជនរងគ្រោះត្រូវបានបែងចែកឬកំណត់ឲ្យទៅជាក្រុមទទួលបានការការពារដោយប្រើប្រាស់ភ័ស្តុតាងសត្យានុម័តដូចគ្នាដែលអាចបង្ហាញពីភាពជាសមាជិករបស់ក្រុមនោះ ។ លក្ខណៈវិនិច្ឆ័យសមាជិកនៃក្រុម និងការកំណត់ស្ថានភាពនៃក្រុមកើតឡើងនៅពេលជាមួយគ្នា ។ តាមការពិត យុត្តិសាស្ត្រសត្យានុម័តបានមើលទៅស្ថានភាពសមាជិកក្រុមដើម្បីកំណត់ថាតើសមាជិកនោះស្ថិតក្នុងសមជាក្រុមដែលទទួលបានការការពារឬទេ ។

ជាឧទាហរណ៍ ដើម្បីកំណត់អត្តសញ្ញាណក្រុម នៅក្នុងករណី អាកាយេស៊ូ តុលាការបានប្រើប្រាស់យុត្តិសាស្ត្រសត្យានុម័តដើម្បីកំណត់ក្រុមនោះ ។ តុលាការបានអះអាងថា ហ៊ូទូ និងទុតស៊ីមិនស្ថិតនៅក្នុងក្រុមដែលបានរៀបរាប់ណាមួយទេ ពីព្រោះហ៊ូទូនិងទុតស៊ី មានវប្បធម៌ ភាសា សាសនា និងអត្តសញ្ញាណជាតិដូចគ្នា ។ ប៉ុន្តែ តុលាការបានកំណត់ថា «គោលបំណងរបស់អ្នកព្រាងច្បាប់អនុសញ្ញាប្រល័យពូជសាសន៍ គឺដើម្បីការពារក្រុមអចិន្ត្រៃយ៍និងស្ថិរភាព» ។ អាស្រ័យហេតុនេះ តុលាការត្រូវតែបង្ហាញដោយសត្យានុម័តថាទុតស៊ីអាចជាផ្នែកមួយក្រុមអចិន្ត្រៃយ៍និងស្ថិរភាព ។ តាមពិត តុលាការបានពិនិត្យមើលទៅលើទាំងភ័ស្តុតាងសត្យានុម័ត និងអត្តនោម័ត ។ ប៉ុន្តែ តុលាការបានសម្អាងយ៉ាងខ្លាំងទៅលើយុត្តិសាស្ត្រចាស់ដែលដាក់ឲ្យប្រើប្រាស់ដោយអាណានិគម បែលហ្ស៊ិក និងប្រើប្រាស់ដោយរដ្ឋាភិបាលរ៉ាន់ដា ។ ជាឧទាហរណ៍ នៅក្នុងករណីខ្លះ «ប័ណ្ណសម្គាល់ខ្លួនរបស់ប្រជាជនមានបញ្ជាក់ពីជនជាតិភាគតិចនៅគីនយ៉ាវ៉ាន់ដាដើម្បីសម្គាល់ជនជាតិហ៊ូទូ ឬទុតស៊ី ។ តុលាការបានអះអាងថា «សាក្សីបានឆ្លើយនឹងសំណួររបស់ព្រះរាជអាជ្ញាទាក់ទងនឹងអត្តសញ្ញាណរបស់ជនជាតិហ៊ូទូ ឬទុតស៊ីយ៉ាងលឿននិងមិនមានភាពស្ទាក់ស្ទើរឡើយ ។ ទស្សនៈរបស់សហគមន៍ទាក់ទងនឹងអត្តសញ្ញាណនៃជនជាតិត្រូវបានគេចាត់ទុកថាជាភ័ស្តុតាងអត្តនោម័ត ។ នៅក្នុងករណី អាកាយេស៊ូ តុលាការបានព្យាយាមពិចារណាទៅលើការកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន ដោយអត្តនោម័តនៅក្នុងមធ្យោបាយសត្យានុម័ត និងមិនផ្តោតទៅលើទស្សនៈរបស់រ៉ាន់ដា តែបែរជាផ្តោតទៅលើការកំណត់អត្តសញ្ញាណ «ភ្លាមៗ» ដែលតុលាការបានសង្កេតដោយសត្យានុម័ត ។ អាស្រ័យហេតុនេះ តុលាការបានបង្ហាញពីភ័ស្តុតាងដូចជាការសិក្សារបស់អ្នកអង្កេតដែលមិនផ្តោតទៅលើអ្វីដែលសាក្សីបាននិយាយ ប៉ុន្តែផ្តោតទៅលើរបៀបនៃការនិយាយរបស់សាក្សី ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺថា តុលាការមិនបាននិយាយថា ទុតស៊ីគឺជាជនជាតិភាគតិចទេ ។ តុលាការបែរជាកំណត់ថា «ទុតស៊ីបានបង្កើតជាក្រុមជនជាតិមួយក្រុម» ។ នៅទីបញ្ចប់ តុលាការបានសម្រេចថា «ទុតស៊ីគឺជាក្រុមអចិន្ត្រៃយ៍ និងស្ថិរភាព» ។

នៅក្នុងករណីកាយីហ្ស៊ីម៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាបានពិចារណាម្តងទៀតថាតើទុតស៊ីគឺជាក្រុមដែលទទួលការការពារឬទេ ។ នៅក្នុងករណីកាយីហ្ស៊ីម៉ា តុលាការបានពង្រីកអត្ថន័យក្រុមជនជាតិដើម្បីអនុញ្ញាតឲ្យមានការពិចារណាទៅលើអត្តសញ្ញាណដែលត្រូវបានគេកំណត់ដោយអត្តនោម័ត ។ តុលាការបានសម្រេចថាក្រុមជនជាតិដែលត្រូវបានការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍អាចជាក្រុមមួយដែលខុសប្លែកពីគេ (មានអត្តសញ្ញាណផ្ទាល់ខ្លួន) ឬក្រុមត្រូវបានអ្នកដទៃដែលរួមមានជនប្រព្រឹត្តឧក្រិដ្ឋកម្មស្គាល់អត្តសញ្ញាណ ។ ខណៈពេលដែលហាក់ដូចជាយល់ស្របនឹងយុត្តិសាស្ត្រអត្តនោម័តនិងបន្សល់ទុកនូវលទ្ធភាពសម្រាប់កំណត់អត្តសញ្ញាណរបស់ក្រុមដោយកត្តាអត្តនោម័ត តាមការពិត តុលាការបានពិចារណាទៅលើភ័ស្តុតាងប្រភេទផ្សេងៗគ្នាដូចជានៅក្នុងករណី អាកាយេស៊ូ ដែរ ។ ភ័ស្តុតាងនេះរួមមានភ័ស្តុតាងដែលជាទូទៅត្រូវបានគេចាត់ទុកថាជាសត្យានុម័ត ។ ជាក់ស្តែង នៅក្នុងករណី កាយីហ្ស៊ីម៉ា តុលាការបាន

ពឹងផ្អែកទៅលើប័ណ្ណសម្គាល់ខ្លួនដែលចេញដោយរដ្ឋាភិបាលដែលបានបញ្ជាក់ពីអត្តសញ្ញាណជនជាតិ និងពឹងផ្អែកតែទៅលើការពិតដែលប្រជាជនភាគច្រើនទៅលើខ្លួនឯងទាក់ទងនឹងជនជាតិ ។

ធាតុទីពីរសម្រាប់កំណត់ក្រុមដែលទទួលបានការការពារគឺស្វែងរកថា ក្រុមណាជាអ្នកបង្កើតឲ្យមានសមាជិករបស់ខ្លួន ។ ចរិតលក្ខណៈកំណត់នៃយុត្តិសាស្ត្រសត្យានុម័តដែលប្រើប្រាស់នៅក្នុងករណី អាកាយេស៊ូ និង កាយីហ្សីម៉ា គឺតុលាការស្វែងរកភ័ស្តុតាងសត្យានុម័តដើម្បីកំណត់ភាពជាសមាជិករបស់ក្រុម ។ នៅក្នុងករណី អាកាយេស៊ូ តុលាការបានកំណត់ថា «លក្ខណៈវិនិច្ឆ័យទូទៅនៅក្នុងប្រភេទទាំងបួននៃក្រុមដែលទទួលបានការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍គឺភាពជាសមាជិករបស់ក្រុមបែបនេះនឹងមិនប៉ះពាល់ដល់ភាពជាសមាជិកដែលមានពីកំណើតទេ ។ ជាឧទាហរណ៍ ខណៈពេលដែលប័ណ្ណសម្គាល់ខ្លួនអាចបញ្ជាក់ពីក្រុមដែលទទួលបានការការពារ វាក៏អាចបង្ហាញពីបុគ្គលដែលជាសមាជិករបស់ក្រុមនោះដែរ ។

## ៧) យុត្តិសាស្ត្រ «អត្តនោម័ត»

យុត្តិសាស្ត្រអត្តនោម័តមានភាពស្រដៀងគ្នានឹងយុត្តិសាស្ត្រសត្យានុម័ត ពីព្រោះតុលាការសុទ្ធតែប្រើវាដើម្បីកំណត់អត្តសញ្ញាណរបស់ក្រុមដែលត្រូវទទួលបានការការពារដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចគ្នា ។ ប៉ុន្តែតាមរយៈយុត្តិសាស្ត្រនេះ ទស្សនៈរបស់សង្គមទៅលើក្រុមទាំងពីរអាចកំណត់ពីភាពជាសមាជិករបស់បុគ្គលនិងកំណត់ថា តើក្រុមនោះអាចបង្កើតជាក្រុមទទួលបានការការពារឬទេ ។ ចំពោះបញ្ហានៃការកំណត់ក្រុមដែលទទួលការការពារនៅក្នុងករណី ជេលីស៊ីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានផ្តោតសំខាន់ទៅលើលទ្ធភាពដែលជនដៃដល់សម្រេចថាជននោះជាជនរងគ្រោះ ។ តុលាការបានអះអាងថា «ទោះបីជាយើងអាចកំណត់ក្រុមសាសនាតាមយុត្តិសាស្ត្រសត្យានុម័តវាមានភាពសមរម្យជាងក្នុងការវាយតម្លៃឋានៈរបស់ក្រុមជាតិ ជាតិពន្ធុ ឬពូជសាសន៍ តាមទស្សនៈរបស់ជនដៃដល់» ។ តុលាការបានសម្អាងថា ក្រុមជនរងគ្រោះត្រូវបានក្រុមជនដៃដល់មើលឃើញថា ជាក្រុមជាតិ ជាតិពន្ធុ ឬពូជសាសន៍មួយដែលសហគមន៍មិនទទួលស្គាល់ដែលបណ្តាលឲ្យក្រុមនោះក្លាយជាគោលដៅ ។

នៅក្នុងករណី ជេលីស៊ីក តុលាការបានធ្វើសេចក្តីសម្រេចដោយអត្តនោម័តបំផុតគឺពឹងផ្អែកទៅលើការកំណត់ថាជនជាតិម៉ូស្លីមនៅបូស្នៀគឺជាក្រុមដែលទទួលបានការការពារដោយសារតែក្រុមនោះត្រូវជនដៃដល់មិនទទួលស្គាល់ ។ ទោះបីជាយ៉ាងណាក៏ដោយតុលាការ ក៏បានទទួលស្គាល់ថា ការកំណត់ក្រុមជនរងគ្រោះគួរតែមានវិសាលភាពត្រឹមក្រុមទាំងបួនដែលត្រូវបានកំណត់ដោយសត្យានុម័តដោយអនុសញ្ញាប្រល័យពូជសាសន៍ ។ សេចក្តីសម្រេចបានបង្ហាញថាក្រុមដែលទទួលបានការការពារត្រូវតែឆ្លើយតបនឹងក្រុមណាមួយក្នុងចំណោមក្រុមទាំងបួនដែលត្រូវបានកំណត់ដោយសត្យានុម័ត ។ តុលាការយល់ស្របយ៉ាងតិចតួចទៅលើសេចក្តីសម្រេចនិងភ័ស្តុតាងដែលជារឿងរ៉ាវផ្ទាល់ខ្លួនដែលថាជនរងគ្រោះគឺជាម៉ូស្លីម ។ ខណៈពេលដែលករណី ជេលីស៊ីក បានកំណត់ស្ថានភាពនៃក្រុមដោយពឹងផ្អែកទៅលើភ័ស្តុតាងអត្តនោម័តវាមិនមានភាពច្បាស់លាស់ថា តើមានការស្នើថា ក្រុមជនរងគ្រោះអាចត្រូវបានកំណត់ដោយតែតាមយុត្តិសាស្ត្រអត្តនោម័តតែមួយដែរឬទេ ។ របាយការណ៍នៅក្នុងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ចំពោះករណី ស្តាទីក បានបង្ហាញយ៉ាងច្បាស់ថាវាគឺយុត្តិសាស្ត្រដែលមិនមានការយល់ស្រប ។

នៅក្នុងករណី ក្រាទីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានប្រើប្រាស់ការសម្អាងនៅក្នុងករណី ជេលីស៊ីក ដែលបណ្តាលឲ្យមានការពន្យល់បន្ថែមពីការកំណត់ដោយអត្តនោម័តដើម្បីរួមបញ្ចូលក្រុមសាសនា ។ តុលាការបានអះអាងថា «លក្ខណៈវប្បធម៌ សាសនា ជាតិពន្ធុ ឬជាតិរបស់ក្រុមត្រូវតែយកមកកំណត់ជាមួយនឹងបរិបទសង្គមប្រវត្តិសាស្ត្ររបស់វា ។ តុលាការបានកំណត់ក្រុមដែលជាប់ពាក់ព័ន្ធដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលក្រុមជនដៃដល់មើលទៅក្រុមជនរងគ្រោះ ។ ខណៈពេលដែលករណី ក្រាទីក បានរួមបញ្ចូលទស្សនៈអត្តនោម័តរបស់ជនដៃដល់ថាជាកត្តាមួយ នៅក្នុងការកំណត់ក្រុមតុលាការមិនបានពឹងផ្អែកទៅលើភ័ស្តុតាងសត្យានុម័តដែលថាក្រុមត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ដោយរដ្ឋធម្មនុញ្ញប្រទេសសឺបៀ ។

អាស្រ័យហេតុនេះ ខណៈពេលដែលនៅក្នុងករណី ក្រាទីក

តុលាការហាក់ដូចជាទុកចំហនូវចំណុចថា តើក្រុមនោះត្រូវបានកំណត់ដោយទស្សនៈអត្តនោម័តរបស់ក្រុមជនដៃដល់និងសមាជិកក្រុមផ្ទាល់ឬទេ តាមជាក់ស្តែងតុលាការបានប្រើប្រាស់យុត្តិសាស្ត្រចម្រុះដែលរួមមានទាំងភ័ស្តុតាងអត្តនោម័តនិងសត្យានុម័ត ។ ការព្យាយាមបែងចែកក្រុមមួយដែលពឹងផ្អែកតែទៅលើទស្សនៈអត្តនោម័តរបស់ជនដៃដល់ឬចរិតលក្ខណៈអត្តនោម័តផ្សេងទៀតមិនត្រូវគេប្រកាសហាមឃាត់មិនឲ្យប្រើប្រាស់ ប៉ុន្តែ នៅក្នុងករណី ស្តាទីក តុលាការបានបដិសេធមិនយល់ស្របនឹងការកំណត់នោះ ។

នៅក្នុងករណី ស្តាទីក តុលាការបានអះអាងថា ករណី ក្រាទីក និង រូតាហ្គាន់ដា មិនបានបញ្ជាក់ថាក្រុមមួយអាចត្រូវបានគេកំណត់ដោយអត្តនោម័តតែមួយនោះទេ ។ តុលាការមិនបានសម្រេចប្រើប្រាស់បទដ្ឋានសមរម្យណាមួយទេគឺគ្រាន់តែអះអាងថាសេចក្តីសម្រេចលើករណីមុនមិនបានបញ្ជាក់ថា ក្រុមជនរងគ្រោះមិនអាចត្រូវបានកំណត់ដោយទស្សនៈអត្តនោម័តរបស់ជនដៃដល់តែម្នាងទេ ។

## ក) យុត្តិសាស្ត្រចម្រុះ

យុត្តិសាស្ត្រចម្រុះក៏បានពិនិត្យមើលទៅលើទាំងភ័ស្តុតាងអត្តនោម័តនិងសត្យានុម័ត ។ ភាពពិសេសរបស់យុត្តិសាស្ត្រនេះគឺជាភ័ស្តុតាងដែលគេយកមកប្រើប្រាស់ដើម្បីកំណត់ឋានៈរបស់ក្រុមដែលត្រូវទទួលបានការការពារដែលមិនជាប់ពាក់នឹងភាពជាសមាជិកនៃក្រុម ។ យុត្តិសាស្ត្រនេះបានបែងចែកការវិភាគទៅលើការការពារក្រុមនិងការវិភាគទៅលើលក្ខណៈវិនិច្ឆ័យទៅលើភាពជាសមាជិករបស់ក្រុម ។ តាមរយៈយុត្តិសាស្ត្រនេះតុលាការអាចកំណត់ក្រុមមួយថា ទទួលបានការពារដោយប្រើប្រាស់ទាំងភ័ស្តុតាងសត្យានុម័តនិងអត្តនោម័តនៅពេលដែលតុលាការនោះកំពុងតែកំណត់សមាជិករបស់ក្រុមនោះដោយប្រើប្រាស់ទស្សនៈអត្តនោម័តរបស់ជនដៃដល់ ។ ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានអះអាងថា ការកំណត់ដ៏ត្រឹមត្រូវទៅលើក្រុមដែលទទួលបានការការពារត្រូវតែធ្វើឡើងទៅតាមមូលដ្ឋាននៃករណីពីមួយទៅមួយដែលរួមមានទាំងលក្ខណៈវិនិច្ឆ័យ ដោយសត្យានុម័តនិងអត្តនោម័ត ។ ប៉ុន្តែ នៅក្នុងករណី ប្រាជានីន តុលាការក៏បានអះអាងថាសមាជិកនៃ «ក្រុមដែលទទួលបានការការពារអាចត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យអត្តនោម័តដែលជនដៃដល់យល់ទៅលើក្រុមនោះដោយផ្អែកទៅលើជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា» ។ នៅក្នុងករណីខ្លះជនរងគ្រោះប្រហែលជាយល់ថាខ្លួនឯងគឺជាក្រុមដែលបានរៀបរាប់ខាងលើ ។ នេះបង្ហាញថាយ៉ាងហោចណាស់ ក៏មានតុលាការព្យាយាមចង់ប្រើប្រាស់បទល្មើសប្រល័យពូជសាសន៍មកចោទប្រកាន់ដោយសម្អាងទៅលើទស្សនៈអត្តនោម័តតែមួយដែលជនដៃដល់កំណត់និងដាក់គោលដៅទៅលើជនរងគ្រោះ ។ ការព្យាយាមនេះប្រហែលជាកើតឡើងទោះបីជាជនរងគ្រោះជាបុគ្គលមិនមែនជាផ្នែកមួយនៃក្រុមហើយ ក៏មិនបានចាត់ទុកខ្លួនឯងថាជាផ្នែកមួយនៃក្រុមនោះដែរ ។

ស្រដៀងគ្នានេះដែរ នៅក្នុងករណី បេងគីសស៊ីម៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានអះអាងថាលក្ខណៈវិនិច្ឆ័យសម្គាល់ភាពជាសមាជិកតាមការកំណត់របស់ជនដៃដល់មានសារសំខាន់ជាងចំណុចផ្សេងទៀតនៅពេលដែលយើងធ្វើការកំណត់ភាពជាសមាជិករបស់ក្រុម ។ ប៉ុន្តែ តុលាការខ្លះបានអះអាងថាទស្សនៈអត្តនោម័តមិនគ្រប់គ្រាន់សម្រាប់ធ្វើការកំណត់ក្រុមទេ ។ នៅពេលដែលក្រុមមួយត្រូវបានកំណត់ដោយសត្យានុម័តភាពជាសមាជិករបស់ក្រុមនោះគួរតែត្រូវបានយកមកវិភាគដោយអត្តនោម័ត ។ យុត្តិសាស្ត្រនេះបានទទួលស្គាល់ថា ប្រជាជនដែលត្រូវបានគេកំណត់គោលដៅប្រហែលជាមិនមែនតាមចរិតលក្ខណៈរបស់ក្រុមនោះទេ ប៉ុន្តែគឺដោយសារជនដៃដល់យល់ថាបុគ្គលនោះស្ថិតនៅក្នុងក្រុមនោះ ។ នៅក្នុងករណី បេងគីសស៊ីម៉ា តុលាការបានសម្អាងថា «ជនដៃដល់ដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រហែលជាកំណត់ក្រុមគោលដៅដោយមិនឆ្លើយតបនឹងលក្ខណៈពេញលេញរបស់ក្រុមឬយោងតាមផ្នែកខ្លះនៃសង្គមនោះទេ ។ នៅក្នុងករណីបែបនេះ ប្រសិនបើជនដៃដល់មើលឃើញថាជនរងគ្រោះជាក្រុមដែលត្រូវទទួលបានការការពារនោះតុលាការក៏គិតថាជនរងគ្រោះនោះគឺជាក្រុមដែលត្រូវទទួលបានការការពារដែរ» ។ យុត្តិសាស្ត្រនេះបានទទួលស្គាល់ភាពលំបាកជាក់ស្តែងក្នុងការកំណត់ក្រុមមួយនិងការមិនជាប់ពាក់ព័ន្ធរវាងអ្វីដែលជនដៃដល់គិតនិងអ្វីដែលជនរងគ្រោះឬសហគមន៍ទាំងមូលយល់ ។

យុត្តិសាស្ត្រនេះបានសន្និដ្ឋានថាការវិភាគដើម្បីកំណត់វត្តមាននៃក្រុមមិនគួរដូចនឹងយុត្តិសាស្ត្រដែលប្រើសម្រាប់កំណត់ភាពជាសមាជិកក្រុមទេ ។ នៅក្នុងករណី រូតាហ្គាន់ដា តុលាការបានអះអាងថា «ភាពជាសមាជិករបស់ក្រុមគឺជាទស្សនៈអត្តនោម័តជាជាងសត្យានុម័ត ។ ជនរងគ្រោះត្រូវបានជនដៃដល់ដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍យល់ថាជាក្រុមដែលត្រូវកម្ចាត់ ។ ប៉ុន្តែតុលាការអះអាងថា ការប្រើប្រាស់និយមន័យអត្តនោម័តតែមួយគឺមិនគ្រប់គ្រាន់សម្រាប់កំណត់ក្រុមជនរងគ្រោះទេ» ។

ជាក់ស្តែង នៅក្នុងករណី បេឌីស៊ីម៉ា និង រូតាហ្គាន់ដា តុលាការបានពឹងផ្អែកទៅលើភស្តុតាងសត្យានុម័តដែលរួមមានការបែងចែកច្បាប់នៅក្នុងរដ្ឋធម្មនុញ្ញដែលត្រូវបានគេទទួលស្គាល់ ។ អាស្រ័យហេតុនេះភាពខុសគ្នាដំបូងរវាងយុត្តិសាស្ត្រនេះនិង «យុត្តិសាស្ត្រសត្យានុម័ត» គឺពាក់ព័ន្ធនឹងរបៀបនៃការរៀបចំភស្តុតាង ។ តាមរយៈយុត្តិសាស្ត្រសត្យានុម័តភស្តុតាងត្រូវបានយកទៅកំណត់ក្រុមនិងកំណត់គន្លឹះសម្រាប់កំណត់ភាពជាសមាជិករបស់ក្រុម ។ តាមរយៈយុត្តិសាស្ត្រចម្រុះភស្តុតាងសត្យានុម័តជាភស្តុតាងបន្ថែមហើយវាត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថាមានក្រុមនិងសមាជិកក្រុមច្បាស់លាស់មួយ ។

នៅក្នុងករណី ឌីនដាបាហ៊ីហ្ស៊ី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានផ្តល់ឧទាហរណ៍ដ៏ច្បាស់លាស់មួយទៅលើករណីមួយដែលពឹងផ្អែកតែទៅលើទស្សនៈអត្តនោម័តរបស់ជនដៃដល់ក្នុងការកំណត់ជនរងគ្រោះដែលជាក្រុមត្រូវទទួលបានការការពារដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ នៅក្នុងករណីនោះជនរងគ្រោះនោះមានឪពុកជនជាតិប៊ែលហ្ស៊ិកនិងម្តាយជនជាតិរ៉្វាន់ដា ។ យោងទៅតាមច្បាប់របស់រដ្ឋាភិបាលជនរងគ្រោះនោះត្រូវមានសញ្ជាតិប៊ែលហ្ស៊ិក ។ ដោយពឹងផ្អែកទៅលើករណី បេឌីស៊ីម៉ា តុលាការបានអះអាងថា នៅពេលដែលកំណត់ភាពជាសមាជិករបស់ក្រុមដែលត្រូវទទួលបានការការពារ «គោលបំណងអត្តនោម័តរបស់ជនដៃដល់គឺជាចំណុចសំខាន់ជាងគេដែលត្រូវយកមកពិចារណា» ។ តុលាការបានរកឃើញថាជនរងគ្រោះត្រូវគេសម្លាប់ដោយសារតែ «ជននោះត្រូវបានជនដៃដល់យល់ថាជាជនជាតិទុតស៊ី» ។ ភស្តុតាងនៃការរកឃើញនេះគឺសំអាងតែទៅលើទស្សនៈរបស់ជនដៃដល់ដែលបង្ហាញចេញតាមរយៈសក្ខីកម្ម ។ នៅក្នុងករណីនេះមិនមានការប្រើប្រាស់ភស្តុតាងអត្តនោម័តដូចជាប័ណ្ណសម្គាល់ខ្លួនដើម្បីបង្ហាញថាជនរងគ្រោះគឺជាជនជាតិហ៊ូទូឬទុតស៊ីទេ ។ តុលាការគ្រាន់តែស្តាប់សក្ខីកម្មរបស់ជនដៃដល់ដែលថាជនរងគ្រោះមានចំណុចខ្លះដែលត្រូវចាត់ទុកជាជនជាតិទុតស៊ីប៉ុណ្ណោះ ។ ដូច្នេះ ជននោះត្រូវបានចាត់ទុកថាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍តាមទស្សនៈរបស់ជនដៃដល់ ។ តុលាការបានរកឃើញថាការកំណត់របស់ជនដៃដល់ទៅលើភាពជាសមាជិករបស់ក្រុមជនរងគ្រោះមិនត្រឹមតែតុលាការអាចទទួលយកបានទេ វាថែមទាំងជាប្រភពសំខាន់ទៀតផង ។

## ៧) មូលហេតុដែលខ្មែរក្រោមត្រូវបានគេកំណត់គោលដៅនិងលទ្ធផលនៃការបែងចែកក្រុម

នៅក្នុងការបែងចែកក្រុមខ្មែរក្រោមបញ្ហាចម្បងដែលត្រូវដោះស្រាយគឺមូលហេតុដែលជំរុញឲ្យមានការកំណត់គោលដៅ ។ វាមានលទ្ធភាពបី ៖ អ្នកទាំងនោះត្រូវបានគេកំណត់គោលដៅដោយសារតែនយោបាយបដិវត្តន៍សមភាគីវត្តមានជាក្រុមជនជាតិភាគតិចឬដោយសារតែអ្នកទាំងនោះត្រូវបានគេចាត់ទុកថាជនជាតិវៀតណាម ។ មានទ្រឹស្តីមួយថាអ្នកទាំងនោះត្រូវបានគេដាក់គោលដៅដោយសារអ្នកទាំងនោះធ្លាប់មានទំនាក់ទំនងជាមួយខ្មែរសេរីដែលប្រឆាំងជនកុម្មុយនីស្តនៅក្នុងសង្គ្រាមស៊ីវិលនៅមុនពេលខ្មែរក្រហមឡើងកាន់អំណាច ឬដោយសារតែអ្នកទាំងនោះបានចូលរួមក្នុងសង្គ្រាមវៀតណាមដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ តាមទស្សនៈនេះ អ្នកទាំងនោះត្រូវបានគេកំណត់គោលដៅដោយសារការចូលរួមក្នុងនយោបាយ ។ ដូច្នេះមានអ្នកខ្លះជឿថាបទល្មើសប្រល័យពូជសាសន៍មិនគួរយកមកប្រើប្រាស់ទេ ពីព្រោះក្រុមនយោបាយមិនមែនជាក្រុមដែលត្រូវទទួលបានការការពារដោយអនុសញ្ញាប្រល័យពូជសាសន៍ទេ ។ ប៉ុន្តែដូចដែលបានរៀបរាប់ខាងលើនយោបាយ និងពូជសាសន៍តែងតែមានទំនាក់ទំនងយ៉ាងស្អិតរមួតនឹងគ្នា ។ ប៊ែន ឃៀរនិន បាននិយាយថា «ការធ្វើបាបខ្មែរក្រោមគឺដោយសារតែពូជសាសន៍របស់អ្នកទាំងនោះ» ។ ដូច្នេះ «មនោគមន៍វិជ្ជាពូជសាសន៍បានបង្ហាញពីការសង្ស័យផ្នែកនយោបាយ ។ ដើម្បីចោទប្រកាន់អំពើប្រល័យពូជសាសន៍ដែលបាន

ធ្វើទៅលើខ្មែរក្រោម អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែកំណត់ថាអ្នកទាំងនោះត្រូវបានគេកំណត់គោលដៅដោយសារតែភាពជាសមាជិកជាខ្មែរក្រោម ។ រាល់ការកំណត់នយោបាយត្រូវតែយកមកបង្ហាញឲ្យជាប់ពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ក្រុមនោះ ។ ទស្សនៈនយោបាយរបស់បុគ្គលនឹងត្រូវបានសន្មតទៅតាមមូលដ្ឋាននៃភាពជាសមាជិករបស់ក្រុម ។ ការគំរាមកំហែងនៃការប្រឆាំងនយោបាយ ប្រហែលជាមូលហេតុមួយប៉ុន្តែវាត្រូវតែមានជាប់ពាក់ព័ន្ធនឹងជាតិពន្ធុ ។ នៅក្នុងករណី ណាហ្គីម៉ាណា តុលាការបាននិយាយថាហេតុផលនៅពីក្រោយដើម្បីកំណត់គោលដៅទៅលើក្រុមមួយមិនអាចបន្ថយចេតនាប្រល័យពូជសាសន៍ប៉ុន្តែការដាក់គោលដៅទៅលើក្រុមដែលត្រូវទទួលបានការការពារដោយសារតែភ្នាក់ងារនយោបាយបែរជាធ្វើឲ្យចេតនាប្រល័យពូជសាសាន៍កាន់តែធ្ងន់ឡើងទៅវិញ ។ អាស្រ័យហេតុនេះ ប្រសិនបើខ្មែរក្រោមត្រូវបានកំណត់ថាជាក្រុមដែលត្រូវទទួលបានការការពារដោយសារតែក្រុមនោះផ្ទាល់ឬដោយសារតែអ្នកទាំងនោះជាផ្នែកមួយនៃជនជាតិវៀតណាមនោះ មូលហេតុនយោបាយសម្រាប់បំផ្លាញនឹងមិនអាចបន្ថយចេតនាប្រល័ពូជសាសន៍បានឡើយ ។

ម្យ៉ាងវិញទៀត ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថាសមាជិករបស់ខ្មែរក្រោមត្រូវបានគេកំណត់គោលដៅមិនមែនដោយសារតែអ្នកទាំងនោះជាខ្មែរក្រោម ប៉ុន្តែដោយសារតែអ្នកទាំងនោះមានសម្ព័ន្ធភាពនយោបាយ នោះតុលាការមិនអាចធ្វើការចោទប្រកាន់បទល្មើសប្រល័យពូជសាសន៍បានឡើយ ។ នៅក្នុងករណីនោះ ជនរងគ្រោះមិនមែនត្រូវបានគេកំណត់គោលដៅដោយសារតែជាតិពន្ធុទេ ដូច្នេះបទល្មើសប្រឆាំងមនុស្សជាតិចំពោះការធ្វើទុក្ខបុកម្នេញលើក្រុមនយោបាយស័ក្តិសមនឹងយកមកចោទប្រកាន់ជាង ។

### ៨) លទ្ធភាពនៃការកំណត់ថាខ្មែរក្រោមគឺជាក្រុមជនជាតិភាគតិចដែលត្រូវបានការការពារអនុសញ្ញាប្រល័យពូជសាសន៍

ខណៈពេលដែលខ្មែរក្រោមមានសញ្ជាតិដូចជាខ្មែរ យើងអាចធ្វើការកំណត់ថាអ្នកទាំងនោះគឺជាក្រុមជនជាតិច្បាស់លាស់មួយដែលស្រដៀងនឹងការបែងចែករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាថាទុតស៊ីគឺជាក្រុមជនជាតិមួយ ។ នៅក្នុងករណីអាកាយេស៊ូ អង្គហេតុបួនដែលរួមមានភស្តុតាងអត្តនោម័ត និងសត្យានុម័តបានធ្វើឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដារកឃើញថាមានភស្តុតាងគ្រប់គ្រាន់បង្ហាញថាទុតស៊ីត្រូវបានគេកំណត់គោលដៅដោយសារតែជាតិពន្ធុរបស់ក្រុមនោះ ។ ក៏មានកត្តាស្រដៀងគ្នាដែលធ្វើឲ្យតុលាការអាចកំណត់ខ្មែរក្រោមដែរ ។ ទីមួយ ក្នុងបញ្ហាបិទផ្លូវនៅទូទាំងប្រទេសបន្ទាប់ពីការផ្ទុះយន្តហោះរបស់ប្រធានាធិបតីនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៤ ទុតស៊ីត្រូវបានគេបំបែកចេញពីហ៊ូទូតាមរយៈប័ណ្ណសម្គាល់ខ្លួននិងមុខមាត់ បន្ទាប់មកសម្លាប់ ។ ស្រដៀងគ្នានេះដែរ នៅក្នុងតំបន់បាទីនៃប្រទេសកម្ពុជាខ្មែរក្រោមត្រូវបានបំបែកពីប្រជាជនខ្មែរដោយផ្អែកទៅលើមរតករបស់ឪពុកម្តាយ បន្ទាប់មកត្រូវបានសម្លាប់ ។ ទោះបីជាខ្មែរក្រោមមិនមានប័ណ្ណសម្គាល់ខ្លួនដែលចេញដោយរដ្ឋាភិបាលក៏ដោយ ក៏អ្នកទាំងនោះត្រូវបានសម្គាល់ដោយកត្តាសត្យានុម័តជាច្រើនដូចជា សកម្មភាព សម្លៀកបំពាក់ និងគោត្តនាម ។

ទីពីរ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានពិចារណាភស្តុតាងនៃយុទ្ធនាការឃោសនាតាមវិទ្យុនិងឯកសារសារព័ត៌មានដែលស្នើឲ្យសម្លាប់ទុតស៊ីដែលជាអ្នកត្រូវបានចាត់ទុកថាបានចូលរួមជាមួយរណសិរ្សនយោបាយរបស់រ៉្វាន់ដានិងត្រូវចោទប្រកាន់ថាបានធ្វើការដោយសម្ងាត់ដើម្បីដណ្តើមអំណាចនៅអំឡុងបដិវត្តន៍ឆ្នាំ១៩៥៩ ។ នៅប្រទេសកម្ពុជាមានយុទ្ធនាការឃោសនាប្រឆាំងនឹងវៀតណាមដូចជា ៖ «វិទ្យុភ្នំពេញបានចោទប្រកាន់ថាអ្នកជំនាន់ក្រោយរបស់វៀតណាមទាំងអស់និងមានផែនការសម្លាប់ប្រជាជនកម្ពុជាដូច្នេះត្រូវសម្លាប់ផុតពូជអ្នកទាំងនោះ ។ នៅក្នុងករណីជាច្រើនខ្មែរក្រោមត្រូវបានគេកំណត់គោលដៅពីព្រោះអ្នកទាំងនោះត្រូវបានគេចាត់ទុកថាជាឈ្លបយកការណ៍របស់វៀតណាម ។ នៅក្នុងសៀវភៅរបស់ បេន គៀរនិន គាត់បានអះអាងថានៅឆ្នាំ១៩៧៨មានបែងចែកជនជាតិភាគតិចវៀតណាមនិងខ្មែរក្រោមដើម្បីសម្លាប់ ។

ទីបី ហ៊ូទូ និងទុតស៊ីត្រូវបានគេសម្គាល់តាមរយៈប័ណ្ណសម្គាល់ខ្លួនដែលចេញដោយរដ្ឋាភិបាល ។ នៅប្រទេសកម្ពុជាបញ្ញត្តិនៅទួលស្លែងដែលថាអ្នកដែលមានទំនាក់ទំនងជាមួយកម្ពុជា

ក្រោមត្រូវបានចាត់ទុកថាជាជនក្បត់អាចបង្ហាញពីការទទួលស្គាល់របស់រដ្ឋាភិបាលថាខ្មែរក្រោមគឺជាក្រុមដាច់ពីគ្នា ។ ទីបួន ប្រជាជនវៀតណាមអាចចាត់ទុកខ្លួនឯងថាជាហ៊្វូ ឬទុតស៊ី ។ រីឯនៅកម្ពុជា ខ្មែរក្រោមចាត់ទុកថាខ្លួនឯងថាជាខ្មែរក្រោមតែម្តង ។ ជាងនេះទៅទៀត ខ្មែរក្រោមមានប្រវត្តិសាស្ត្រទាក់ទងនឹងដីសណ្តទន្លេមេគង្គ ។ អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិធ្លាប់បានប្រើប្រាស់ប្រវត្តិជាប់ពាក់ព័ន្ធនឹងទឹកដីជាភស្តុតាងសម្រាប់សម្គាល់សញ្ជាតិ ។ ជាសរុប តុលាការអាចធ្វើការកំណត់ថាខ្មែរក្រោមគឺជាក្រុមជាតិពន្ធុមួយតាមនិយមន័យអនុសញ្ញាប្រល័យពូជសាសន៍ដោយប្រើប្រាស់ភស្តុតាងសត្យានុម័តនិងអត្តនោម័តដែលស្រដៀងគ្នានិងត្រូវបានប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដាដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ វាក៏មានព្រំដែនកំណត់ជាក់ស្តែងក្នុងការកំណត់ថាខ្មែរក្រោមគឺជាក្រុមជាតិពន្ធុដើម្បីចោទប្រកាន់អំពើប្រល័យពូជសាសន៍ក្នុងករណី០០២នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។ ខ្មែរក្រោមមិនត្រូវបានបញ្ចូលទៅក្នុងដីកាដែលសហព្រះរាជអាជ្ញាបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតឡើយ ។ ការធ្វើបែបនេះបានកំណត់នូវទំហំនៃការស៊ើបអង្កេត ។ ភស្តុតាងបន្ថែមទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមអាចត្រូវបានយកមកបង្ហាញ ប៉ុន្តែ មិនមែនយកមកចោទប្រកាន់បទល្មើសប្រល័យពូជសាសន៍ក្នុងនាមអ្នកទាំងនោះជាក្រុមដែលទទួលបានការការពារឡើយ ។

## ៩) ការកំណត់ថាខ្មែរក្រោមមានជាតិនិងជាតិពន្ធុជាវៀតណាម ដោយយោងទៅតាមទស្សនៈអត្តនោម័តរបស់ខ្មែរក្រហម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាអាចស្វែងរកថាខ្មែរក្រោមខ្លះត្រូវបានខ្មែរក្រហមកំណត់គោលដៅដោយសារតែអ្នកទាំងនោះគឺជាវៀតណាម ។ ដើម្បីធ្វើបែបនេះតុលាការត្រូវតែអនុម័តយុត្តិសាស្ត្រចម្រុះដែលប្រើប្រាស់ដោយតុលាការពិសេស ។ ដំបូងតុលាការត្រូវតែកំណត់ថាវៀតណាមគឺជាក្រុមដែលទទួលបានការការពារ ។ វាទំនងជាមានការលំបាកបន្តិចបន្តួចក្នុងការធ្វើបែបនេះ ។ ទីពីរ សហព្រះរាជអាជ្ញាត្រូវតែបញ្ជាក់ថាជនរងគ្រោះខ្មែរក្រោមត្រូវបានកំណត់គោលដៅដោយសារតែអ្នកទាំងនោះត្រូវបានយល់ឃើញថាមានជាតិពន្ធុឬពូជសាសន៍វៀតណាម ។ ដូច្នេះ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញពីទំនាក់ទំនងរវាងជនរងគ្រោះនិងក្រុមវៀតណាម ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវស្វែងរកថាខ្មែរក្រោមមិនមែនត្រូវខ្មែរក្រហមធ្វើបាបដោយហេតុផលនយោបាយវៀតណាមទេ ប៉ុន្តែដោយខ្មែរក្រហមយល់ថាអ្នកទាំងនោះគឺជាវៀតណាមតែម្តង ។

ដូចដែលបានរៀបរាប់ខាងលើ យើងអាចបញ្ជាក់នូវចំណុចខាងលើ ។ ជាឧទាហរណ៍ នៅស្រុកបាទីនៅឆ្នាំ១៩៧៦ គ្រួសាររបស់ខ្មែរក្រោមទាំងអស់ត្រូវបានសម្លាប់រង្គាលពីព្រោះខ្មែរក្រហមបានប្រកាសថាអ្នកទាំងនោះចេះនិយាយវៀតណាម ។ ខ្មែរក្រោមម្នាក់ដែលជាឈ្លើយសឹកបន្ទាប់ពីផ្តាច់ខ្លួនចេញពីវៀតណាមបានរំឭកថា នៅពេលដែលខ្មែរក្រហមសួរថាយើងចេះនិយាយវៀតណាមឬទេ «យើងទាំងអស់គ្នាសុទ្ធតែបដិសេធថាមិនចេះនិយាយវៀតណាមទេ» ។ ប្រសិនបើយើងឆ្លើយថាចេះ ខ្មែរក្រហមនឹងសម្លាប់យើង ។ យើងទាំងអស់គ្នាសុទ្ធតែត្រូវធ្វើប្រវត្តិរូបគ្រួសារ ។ ប្រសិនបើយើងនិយាយថា យើងនៅមានបងប្អូនរស់នៅវៀតណាម ខ្មែរក្រហមនឹងសម្លាប់យើង» ។ របបខ្មែរក្រហមចង់សងសឹកនឹងកម្ពុជាក្រោម និងកម្ចាត់ចោលនូវគ្រប់ពូជសាសន៍វៀតណាម ។ របាយការណ៍បញ្ជាក់ថា នៅចុងឆ្នាំ១៩៧៨ នៅតំបន់១៣នៃស្រុកត្រាំកក់មានកម្មាភិបាលក្នុងតំបន់និយាយថា «ប្រសិនបើវៀតណាមបាត់ខ្លួនអស់នោះខ្មែរនឹងនៅរស់ ។ តែប្រសិនបើខ្មែរបាត់ខ្លួនអស់ វៀតណាមនឹងនៅរស់» ។ ការឃោសនានេះបានបង្ហាញពីអត្ថន័យដែលមិនមានការយល់ស្របគ្នាដែលនាំឲ្យមានការគំរាមកំហែងសម្លាប់វៀតណាម ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវស្វែងរកថាខ្មែរក្រោមត្រូវបានគេកំណត់គោលដៅដោយសារតែអ្នកទាំងនោះមិនមែនជាផ្នែករីករាលដាលនៃការគំរាមកំហែង ប៉ុន្តែគឺជាគោលដៅនៃការគំរាមកំហែងទាក់ទងជនជាតិវៀតណាមតែម្តង ។

## ១០) យុត្តិសាស្ត្រទីបី ការប្រើប្រាស់ភស្តុតាងវាយប្រហារទៅលើខ្មែរក្រោមដើម្បីបង្ហាញពីចេតនាប្រល័យពូជសាសន៍វៀតណាម

យុត្តិសាស្ត្រទីបីគឺជាការប្រើប្រាស់ភស្តុតាងនៃអំពើ

សាហាវឃោរឃៅដែលខ្មែរក្រហមធ្វើទៅលើខ្មែរក្រោមដើម្បីបញ្ជាក់ពីចេតនាប្រល័យពូជសាសន៍វៀតណាម ។ វាស្រដៀងនឹងយុត្តិសាស្រ្តដែលប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានប្រើប្រាស់ភ័ស្តុតាងឧក្រិដ្ឋកម្មដែលហ៊ូទូមិនជ្រុលនិយមត្រូវបានហ៊ូទូជ្រុលនិយមធ្វើបាបដើម្បីបង្ហាញពីចេតនាប្រល័យពូជសាសន៍ទុតស៊ី ។ សម្រាប់តុលាការ វាគឺជាជម្រើសធម្មតាបំផុត ។ ទោះបីជាយ៉ាងណាក៏ដោយ វាអាចជួយដល់ការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមអំពីបទល្មើសប្រល័យពូជសាសន៍ប្រឆាំងនឹងវៀតណាម ។ ប្រវត្តិវិទូជាច្រើនបានសម្លឹងមើលទៅក្រោយ ហើយបានលើកឡើងថាមិនមានការចោទប្រកាន់បទល្មើសបែបនេះទៅលើហ៊ូទូដែលបានធ្វើបាបហ៊ូទូមិនជ្រុលនិយមទេ ។ ទស្សនៈប្រវត្តិសាស្រ្តស្រដៀងគ្នាប្រហែលជាអាចកើតមាននៅពេលអនាគតប្រសិនបើតុលាការមិនស្វែងរកយុត្តិធម៌ដល់ខ្មែរក្រោម ។

## ១១) ផលវិបាកនយោបាយបន្ទាប់ពីធ្វើការចោទប្រកាន់អំពើប្រល័យពូជសាសន៍

ដូចបណ្ឌិត ចន ឆរឆីអារី បាននិយាយថា «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានភារកិច្ចនាំយកយុត្តិធម៌ដល់ជនរងគ្រោះ ប៉ុន្តែអង្គជំនុំជម្រះក៏មានភារកិច្ចសំខាន់ក្នុងការជំរុញនូវអ្វីដែលមន្រ្តីតុលាការជឿថាពិតដែរ ។ ចំណុចនេះបានចោទជាសំណួរថាតើតុលាការគួរតែចោទប្រកាន់បទល្មើសប្រល័យពូជសាសន៍ដែលខ្មែរក្រហមធ្វើទៅលើខ្មែរក្រោមដោយរបៀបណា ។ ដើម្បីធ្វើបែបនេះដំបូងសហចៅក្រមស៊ើបអង្កេតត្រូវសម្រេចថាតើខ្មែរក្រោមដោយសារតែអ្នកទាំងនោះគឺជាខ្មែរក្រោមឬដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យចង់បំផ្លាញក្រុមនោះតែម្តង ។

ទោះបីជាតុលាការអាចចោទប្រកាន់បទល្មើសប្រល័យពូជសាសន៍ដែលខ្មែរក្រហមធ្វើទៅលើខ្មែរក្រោម ក៏វានៅតែមិនមានភាពច្បាស់លាស់ថាតើខ្មែរក្រោមចង់ឲ្យគេទទួលស្គាល់ខ្លួនថាជាក្រុមដែលមានជាតិពន្ធុផ្សេងគ្នាឬទេ ។ ខ្មែរក្រោមនៅកម្ពុជាអាចត្រូវបានគេចាត់ទុកថាជាខ្មែរឬខ្មែរក្រោម ។ វានៅតែមិនទាន់ច្បាស់ថាតើការទទួលស្គាល់ជាផ្លូវការរបស់តុលាការថាខ្មែរក្រោមគឺជាក្រុមដែលមានជាតិពន្ធុផ្សេងគ្នាអាចផ្លាស់ប្តូរទស្សនៈរបស់សាធារណជនឬប៉ះពាល់ដល់ទំនាក់ទំនងរវាងខ្មែរ និងខ្មែរក្រោមឬទេ ។

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងចោទប្រកាន់បទល្មើសប្រល័យពូជសាសន៍ទៅលើខ្មែរក្រហមបានធ្វើទៅលើខ្មែរក្រោមដោយនិយាយថាអ្នកទាំងនោះគឺជាវៀតណាមដោយផ្អែកទៅលើទស្សនៈអត្តនោម័ត នោះវានឹងធ្វើឲ្យទស្សនៈដែលថាខ្មែរក្រោមគឺជាវៀតណាមនៅមានបន្ត ។ ការហៅខ្មែរក្រោមគឺជាវៀតណាមអាចផ្តល់ប្រយោជន៍ខ្លះដល់ខ្មែរក្រោមដែលរស់នៅវៀតណាមដែលចង់ឲ្យមានសមភាពសង្គមនិងនយោបាយ ។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចអាចផ្តល់ផលប៉ះពាល់អវិជ្ជមានដល់សហគមន៍ដែលរស់នៅប្រទេសកម្ពុជា ។ កម្ពុជានិងវៀតណាធ្លាប់មានប្រវត្តិមិនជឿជាក់គ្នា ដោយហៅខ្មែរក្រោមថាជាវៀតណាមអាចប៉ះពាល់ដល់ស្ថានភាពរស់នៅកម្ពុជា ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានឥទ្ធិពលខ្លាំងដល់សាធារណជនទេ ប៉ុន្តែវាក៏អាចប៉ះពាល់បន្តិចបន្តួចដែរ ។

ជាទីបញ្ចប់ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រើប្រាស់ភ័ស្តុតាងដែលខ្មែរក្រហមបានធ្វើទៅលើខ្មែរក្រោមគ្រាន់តែដើម្បីបញ្ជាក់ពីបទល្មើសដែលខ្មែរក្រហមធ្វើទៅលើវៀតណាម នោះខ្មែរក្រោមប្រហែលជាយល់ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនដោះស្រាយនូវឧក្រិដ្ឋកម្មដែលខ្មែរក្រហមធ្វើទៅលើខ្មែរក្រោមទេ ។ ដោយនិយាយអំពីការដែលសហព្រះរាជអាជ្ញាមិនបានស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមជាក្រុម មាន ចាន់ថន ដែលជាជនរងគ្រោះ ខ្មែរក្រោមបាននិយាយថា «យោងទៅតាមច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទទួលស្គាល់ការស្លាប់របស់ប្រជាជនចាមនិងវៀតណាម ។ ប៉ុន្តែហេតុអ្វីបានជាមិនទទួលស្គាល់ការបកស្រាយរបស់យើងទាំងអស់គ្នា?

ជាសរុប អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែដោះស្រាយនូវបញ្ហាទាំងនេះនិងព្យាយាមកំណត់ក្រុមខ្មែរក្រោមដោយសត្យានុម័តនិងអត្តនោម័តដើម្បីយុត្តិធម៌ ។

**ជេមស៍ ស៊ី. រ៉ូប៊ីត**

# រូបថតជនរងគ្រោះនៅមន្ទីរស-២១

នៅក្នុងដំណើរទស្សនកិច្ចនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានអ្នកទោសស្លូតត្រង់ប្រមាណជាង ១៨.០០០នាក់ បានស្លាប់បាត់បង់ជីវិត។ លោកស្រី ហ៊ីលឡារី គ្លីនតុន រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក បានឈរមើលរូបថតជនរងគ្រោះ ចាន់ គឹមស្រ៊ុន បីកូនប្រុស និងស្តាប់ការពន្យល់ពីលោក ឆាំង យុ ទាក់ទងនឹងប្រវត្តិនៃរូបថតនេះយ៉ាងស្ងៀមស្ងាត់។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាន់ គឹមស្រ៊ុន ហៅ សាង មានតួនាទីជាប្រធានរោងចក្រតម្បាញតំបន់២៥ ចំណែកប្តីគាត់ឈ្មោះ សេក ប្រាក់ ជាលេខាតំបន់២៥។ នៅខែឧសភា ឆ្នាំ១៩៧៨ ចាន់ គឹមស្រ៊ុន ប្តី ព្រមទាំងកូនប្រុសអាយុមិនដល់មួយឆ្នាំត្រូវអង្គការចាប់មកឃុំឃាំង សួរចម្លើយ និងសម្លាប់ចោលនៅគុកទួលស្លែងឬមន្ទីរស-២១ ដោយចោទថាក្បត់។ ចំណែកកូនស្រីច្បងឈ្មោះ សេក សាយ ឬ សេក សុធី បានរួចរស់ជីវិតដោយមូលហេតុបានចេញទៅធ្វើការក្នុងកងផលិតឱសថនៅមន្ទីរពេទ្យសំប៉ាន។ ចាប់តាំងពីពេលនោះមក សាយ បាត់ដំណឹងពីឪពុកម្តាយនិងបងប្អូនរហូត ហើយគាត់ក៏មករស់នៅជាមួយម្តាយចិញ្ចឹមនៅខេត្តកំពង់ស្ពឺវិញ។

បន្ទាប់ពីស្តាប់ និងដើរមើលរូបថត និងទិដ្ឋភាពនៅក្នុងសារមន្ទីរនេះរួចមក លោកស្រីបានសរសេរពីយោបល់ផ្ទាល់ខ្លួន និងសោកនាដកម្មរបស់ជនរងគ្រោះដែលបានស្លាប់ និងជំរុញឲ្យមានការទទួលខុស ត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនេះ។ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១០ ក្រោយពីទស្សនកិច្ចនេះ លោក ញាណ សុជាតិ បានយករូបថតដែលមានលោកស្រី ហ៊ីលឡារី គ្លីនតុន លោក ឆាំង យុ និង ចាន់ គឹមស្រ៊ុន ជនរងគ្រោះដែលស្លាប់នៅទួលស្លែងទៅប្រគល់ឲ្យកូនស្រីឈ្មោះ សេក សាយ រស់នៅភូមិព្រៃនួប ឃុំខ្នង ក្រពើស្រុក គងពិសី ខេត្តកំពង់ស្ពឺ។

សេក សាយ បច្ចុប្បន្នមានកូនបីនាក់និយាយទាំងទឹកមុខស្រងូតស្រងាត់ថា «រូបថតនេះពិតជាមានតម្លៃសម្រាប់គាត់ណាស់ ហើយព្រលឹងរបស់ម្តាយគាត់នឹងបានទៅកាន់សុគតិភព»។

លោក ឆាំង យុ ដែលបានចូលរួមដំណើរជាមួយលោកស្រី ហ៊ីលឡារី គ្លីនតុន នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងមានប្រសាសន៍ថា «ជីវិតមនុស្សម្នាក់ៗពិតជាមានតម្លៃខ្លាំងណាស់»។ លោក ឆាំង យុ បន្តទៀតថា គាត់មានកិត្តិយសខ្លាំងណាស់ដែលបាននិយាយពីប្រវត្តិរបស់ជនរងគ្រោះប្រាប់មេដឹកនាំសហរដ្ឋអាមេរិក ដែលគាំទ្រការរកយុត្តិធម៌ដល់ជនរងគ្រោះ។

ទោះបីជនរងគ្រោះស្លាប់ទៅអស់រយៈពេលជាង៣០ឆ្នាំមកហើយក្តី ក៏នៅមានអ្នកឈឺឆ្អាល យកចិត្តទុកដាក់ និងជំរុញឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់នេះដែរ។ **សោម ប៊ុនថន**


លោកស្រី ហ៊ីលឡារី គ្លីនតុន សំឡឹងមើលរូបថតអ្នកទោស ចាន់ គឹមស្រ៊ុន


សេក សាយ អតីតកូនជនរងគ្រោះនៅមន្ទីរស-២១

# រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោកស្រី ហ៊ីលឡារី គ្លីនតុន ជួបសំណេះសំណាលជាមួយយុវជនកម្ពុជានៅសាលចតុមុខ

***ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០***

***លោកស្រី គ្លីនតុន*** ៖ *ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយឥតឧបមាដែលបានជួបជាមួយអ្នកទាំងអស់គ្នានៅទីនេះ ហើយខ្ញុំសូមថ្លែងអំណរគុណដែលបានមកចូលរួមក្នុងថ្ងៃនេះដែលជាថ្ងៃឈប់សម្រាកផង ។ អរគុណ កល្យាណ ដែលបានធ្វើកិច្ចការបានយ៉ាងល្អ ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តមមន្ត្រីក្រសួងអប់រំដែលបាននៅទីនេះជាមួយយើងដែរ និងសូមអរគុណដល់លោកស្រីអគ្គរាជទូតសហរដ្ឋអាមេរិក ។ នេះគឺជាលើកទីមួយហើយដែលខ្ញុំបានធ្វើដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា ។ ប្រទេសកម្ពុជាគឺជាគោលដៅដែលខ្ញុំតែងតែចង់មកធ្វើដំណើរទស្សនកិច្ចជាយូរមកហើយ ។ ជាពិសេស នាងខ្ញុំមានអារម្មណ៍រំភើបតាមរយៈរបាយការណ៍របស់ស្វាមីខ្ញុំ ប៊ីល គ្លីនតុន កាលពីពេលដែលគាត់ធ្វើដំណើរមកកាន់ប្រទេសកម្ពុជានៅឆ្នាំ២០០៦ ហើយគាត់បានត្រឡប់មកផ្ទះវិញដោយនាំមកជាមួយនូវរឿងរ៉ាវជាច្រើនទាក់ទងនឹងការវិវឌ្ឍទៅមុខដែលកំពុងតែកើតមានឡើងសព្វថ្ងៃនេះនៅប្រទេសកម្ពុជា ហើយខ្ញុំពិតជាចង់ឃើញដោយភ្នែករបស់ខ្ញុំផ្ទាល់ ។*

*ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំងដែលនៅឆ្នាំ២០១០ នេះយើងមានឱកាសនិយាយជាមួយគ្នាជាលក្ខណៈបើកចំហមិនមែនតែពីអនាគតរបស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ជាពិសេសអំពីយុវជនដូចអ្នកទាំងអស់គ្នានេះ តែយើងនិយាយអំពីកិច្ចសហការគ្នារវាងប្រទេសកម្ពុជានិងសហរដ្ឋអាមេរិក ។ នៅឯប្រទេសរបស់ខ្ញុំ យើងទាំងអស់គ្នាខំប្រឹងប្រែងធ្វើការជាមួយអ្នកទាំងអស់គ្នាដោយផ្តល់ឱកាសបន្ថែមទៀតដល់យុវជនជំនាន់ក្រោយសម្រាប់កម្មវិធីដំណើរការទស្សនកិច្ចសម្រាប់និស្សិត ឬក៏អាហារូបករណ៍ ហ្វូលប្រាយនិងអាហារូបករណ៍សម្រាប់ការស្រាវជ្រាវដែលទាំងនេះគឺជាឱកាសមួយសម្រាប់យុវជនជំនាន់ក្រោយបានទៅសិក្សានៅសហរដ្ឋអាមេរិក ហើយយើងនឹងលើកទឹកចិត្តពលរដ្ឋអាមេរិកឲ្យមកបានឃើញពីភាពកក់ក្តៅនិងភាពទន់ភ្លន់របស់ប្រជាជនកម្ពុជាដោយផ្ទាល់ ។*


លោកស្រី ហ៊ីលឡារី គ្លីនតុន និងលោក ឆាំង យុ ទស្សនកិច្ចសារមន្ទីរទួលស្លែង

*ជាមួយគ្នានេះ ខ្ញុំសង្ឃឹមថាយើងអាចនឹងទទួលបានយោបល់ខ្លះៗពីអ្នកទាំងអស់គ្នាទាក់ទងនឹងការរំពឹងចង់ឃើញពីការរីកចម្រើននៃការសហការជាដៃគូរវាងប្រទេសកម្ពុជានិងសហរដ្ឋអាមេរិក នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខនេះ ។ នៅពេលដែលខ្ញុំសម្លឹងមើលអ្នកទាំងអស់គ្នាដែលមានវត្តមាននៅទីនេះ ខ្ញុំដឹងថាភាគច្រើនប្អូនៗមិនបានកើតទាន់សម័យដែលខ្ញុំនៅរៀន និងនៅពេលដែលប្រទេសរបស់ប្អូនៗបានជាប់គាំងដោយសារតែសង្គ្រាមស៊ីវិលនោះទេ ។ ប្អូនៗទាំងអស់គ្នានៅទីនេះមានឱកាសសរសេរ*

ឡើងវិញពីអនាគតរបស់ប្រទេសកម្ពុជាដែលខ្ញុំគិតថាវាពិតជាមានសារសំខាន់សម្រាប់អ្វីដែលកំពុងតែកើតមានឡើងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ។ ប្រវត្តិសាស្ត្រ វប្បធម៌ សិល្បៈដ៏រុងរឿងនិងទឹកចិត្តសប្បុរសរបស់ប្រជាជនកម្ពុជាគឺជាអ្វីដែលអ្នកទាំងអស់គ្នាត្រូវតែប្រកាន់ខ្ជាប់ក្នុងខ្លួនជានិច្ច ។ ប៉ុន្តែទាំងអស់នេះគឺពឹងផ្អែកលើយុវជនជំនាន់ក្រោយទាំងស្រុងដែលត្រូវធ្វើការសម្រេចចិត្តរៀបចំអនាគតថ្មីរបស់ប្រទេសកម្ពុជា ។

សព្វថ្ងៃនេះ ប្រទេសកម្ពុជាគឺស្ថិតនៅក្នុងដំណើរការនៃការផ្លាស់ប្តូរ ។ សន្តិភាពកើតមានសេដ្ឋកិច្ចរីកចម្រើនយ៉ាងឆាប់រហ័សក្នុងអំឡុងមួយទសវត្សរ៍នេះ ជំនួញនិងការវិនិយោគទុនក្រៅប្រទេសកំពុងតែកើនឡើង ការងារជាច្រើនត្រូវបានបង្កើតឡើង ហើយផ្លូវដែលមិនអាចធ្វើដំណើរបានឥឡូវត្រូវបានស្ថាបនាសាឡើងវិញ ។ តុលាការដែលត្រូវបានបង្កើតឡើងដោយប្រទេសកម្ពុជា អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិកំពុងតែនាំជនដែលបង្កភាពឈឺចាប់និងសេចក្តីវិនាសអន្តរាយមកកាត់ទោស ។ នេះគឺជាកិច្ចការដ៏សំខាន់ដើម្បីធានាឲ្យបាននូវសន្តិភាពដ៏យូរអង្វែង បើទោះបីជាខ្ញុំដឹងថាដំណើរការរបស់តុលាការនេះនាំមកនូវភាពឈឺចាប់ក៏ដោយ ។ ហើយខ្ញុំសូមថ្លែងអំណរគុណដល់អ្នកដែលបានគាំទ្រកិច្ចការនេះ ។

ដំណើរការវិវឌ្ឍនេះគឺជាឆន្ទៈខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់ប្រជាជនកម្ពុជាទាំងអស់ ដូចជាប្អូនៗ ឪពុកម្តាយ ជីដូនជីតាអ្នកជាតិខាងនិងមិត្តភក្តិរបស់ប្អូនៗ ហើយសហរដ្ឋអាមេរិកចង់ជួយប្អូនៗបន្តដំណើរការវិវឌ្ឍទៅមុខទៀត ។ យើងគិតថាប្រទេសកម្ពុជានឹងមានអនាគតត្រចះត្រចង់មិនមែនត្រឹមតែក្នុងប្រទេសនោះទេ ប៉ុន្តែថែមទាំងជាប្រទេសដែលរីកចម្រើននិងលូតលាស់នៅក្នុងតំបន់ទៀតផង ។ ប៉ុន្តែប្រទេសកម្ពុជានឹងនៅតែប្រឈមមុខជាមួយនឹងបញ្ហាមួយចំនួនទៀតដែលជាក់ស្តែង ការផ្លាស់ប្តូរអាកាសធាតុការសាងសង់ទំនប់ទឹកគឺកំពុងតែបង្កបញ្ហាដល់ការហូរនិងការលូតលាស់ទៅមុខរបស់ទន្លេមេគង្គ ។ នេះគឺគ្រាន់តែជាបញ្ហាមួយដែលរដ្ឋាភិបាលកម្ពុជានិងរួមទាំងយុវជនជំនាន់ប្អូនៗចាំបាច់ត្រូវតែដោះស្រាយ ។

យើងចង់ជួយប្រទេសកម្ពុជាក្នុងការបង្កើតជាឱកាសថ្មីមួយដើម្បីកុំឲ្យប្អូនៗខ្វាចអនាគតរបស់ខ្លួន ។ ប្អូនៗត្រូវតែសម្លឹងរកមើលអនាគតល្អស្វែងរកការងារល្អអភិវឌ្ឍន៍ទេពកោសល្យរបស់ខ្លួន ហើយជួយដល់ប្រទេសជាតិរបស់ប្អូនៗ ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានវិនិយោគទុនប្រមាណ៧០លានដុល្លារក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅឆ្នាំនេះ ។ ជាមួយគ្នានេះ យើងក៏កំពុងតែសហការជាមួយប្រទេសកម្ពុជានៅក្នុងវិស័យផ្សេងៗទៀតដែរ ។ អ្នកជំនាញផ្នែកសុខភាពរបស់យើងកំពុងតែធ្វើការ (មិនឮសំឡេង) ដើម្បីពង្រីកការទទួលបាននូវសេវាថែទាំសុខភាពដ៏សំខាន់ដល់ប្រជាជន រួមមានវិធីសាស្ត្រ ការពារព្យាបាល និងថែទាំដល់អ្នកជំងឺអេសដ៍ ។ ក្រុមអ្នកជំនាញផ្នែកច្បាប់របស់យើងកំពុងតែបំពេញការងារដើម្បីបង្ក្រាបការជួញដូរមនុស្សនិងទេសចរណ៍ផ្លូវភេទលើកុមារ ។ កាលពីម្សិលមិញ ខ្ញុំបានទៅទស្សនាអង្គការមួយនៅខេត្តសៀមរាបដែលដំណើរការដោយមិត្តភក្តិរបស់ខ្ញុំម្នាក់គឺ ម៉ម សុម៉ាលី ដែលជាស្ត្រីខ្មែរម្នាក់ដែលធ្លាប់ក្លាយជាទាសករផ្លូវភេទ ហើយបានរត់គេចពីទីកន្លែងនោះ ហើយបច្ចុប្បន្ននេះ សុម៉ាលី បានខិតខំប្រឹងប្រែងជួយស្ត្រីនិងក្មេងស្រីៗឲ្យរួចផុតពីការរងគ្រោះ ។

សហរដ្ឋអាមេរិកពិតជាមានមោទនភាពដែលយើងបានធ្វើការស្តារសម្បត្តិវប្បធម៌ និងប្រាសាទបុរាណជាច្រើនរបស់ប្រទេសកម្ពុជា ពីព្រោះសម្បត្តិអស់ទាំងនេះបង្ហាញពីប្រវត្តិសាស្ត្រដ៏អស្ចារ្យរបស់ប្រជាជនកម្ពុជា ហើយនាំមកនូវភ្ញៀវទេសចរដែលជាប្រភពចំណូលដ៏ល្អសម្រាប់ប្រទេសកម្ពុជា ។

ដូច្នេះ ខ្ញុំមានវត្តមាននៅទីនេះដោយសារតែខ្ញុំមិនចង់អានពីរឿងរ៉ាវរបស់ប្រទេសកម្ពុជាទេ ។ ខ្ញុំមិនចង់ឲ្យគេប្រាប់ខ្ញុំថាតើយុវជនកម្ពុជាជំនាន់ក្រោយកំពុងគិតនិងធ្វើអ្វីនោះទេ ។ ខ្ញុំចង់ឮពីប្អូនៗទាំងអស់គ្នាផ្ទាល់តែម្តង ។ ហើយខ្ញុំសង្ឃឹមថាក្រោយពីការជួបសំណេះសំណាលគ្នានៅក្នុងសាលនេះមក ប្អូនៗនឹងបន្តធ្វើការទាក់ទងជាមួយនឹងស្ថានទូតអាមេរិក ជំនួញរបស់សហរដ្ឋអាមេរិក អង្គការក្រៅរដ្ឋាភិបាល សកលវិទ្យាល័យដែលមាននៅក្នុងប្រទេសកម្ពុជា ពីព្រោះយើងមិនចង់មានត្រឹមតែការសហការជាដៃគូរវាងរដ្ឋាភិបាល

តែប៉ុណ្ណោះទេ ប៉ុន្តែការសហការរវាងប្រជាជនរបស់ប្រទេសទាំងពីរដែរ ។



អ្នកទោសនៅមន្ទីរស-២១

កាលពីព្រឹកមិញនេះ ខ្ញុំរួមទាំងសហការីរបស់ខ្ញុំបានធ្វើដំណើរទស្សនកិច្ចនៅសារមន្ទីរទួលស្លែងដែលជាអតីតសាលារៀនមួយ ។ នេះគឺជាបទពិសោធន៍ដ៏ជូរចត់បំផុតរបស់ប្រជាជនកម្ពុជា ។ ហើយរូបថតរបស់ក្មេងៗដែលត្រូវគេសម្លាប់ និងរូបថតរបស់អ្នកដែលប្រព្រឹត្តការសម្លាប់ពិតជាពោរពេញទៅដោយភាពឈឺចាប់ ។ ប៉ុន្តែខ្ញុំពិតជាសូមកោតសរសើរដល់ប្រទេសកម្ពុជាដែលអាចប្រឈមមុខដោះស្រាយជាមួយនឹងរឿងអតីតកាលរបស់ខ្លួន (មិនឮសំឡេង) ។ ខ្ញុំធ្វើដំណើរទស្សនកិច្ចទូទាំងពិភពលោក ។ ខ្ញុំចូលចិត្តការចូលទៅទស្សនាកន្លែងបែបនេះដែលគ្មានការតាក់តែងនិងរៀបចំទុកជាមុន ក៏ដូចជាការចូលជួបសំណេះសំណាលជាមួយនឹងមន្ត្រីរាជការផងដែរ ។ ខ្ញុំទើបតែបានជួបព្រះមហាក្សត្រ ហើយខ្ញុំនឹងជួបសំណេះសំណាលពីបញ្ហានេះជាមួយនឹងលោកនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងលោកមន្ត្រីក្រសួងការបរទេសដោយផ្ទាល់ ។ ដូច្នេះខ្ញុំនឹងបានស្តាប់ឮដោយផ្ទាល់នូវអ្វីដែលប្រទេសផ្សេងទៀតធ្លាប់ប្រាប់ខ្ញុំ ហើយខ្ញុំនឹងតាមដានមើលថាតើប្រទេសទាំងនោះកំពុងធ្វើអ្វី ។ ប្រទេសដែលកាត់ទោសជនដៃដល់ឲ្យទទួលស្គាល់ពីអតីតកាលរបស់ខ្លួននឹងមិនអាចបែកបាក់សាមគ្គីភាពគ្នាទេ ហើយប្រទេសនេះនឹងកសាងអនាគតដ៏ល្អសម្រាប់ក្មេងៗជំនាន់ក្រោយ ។ ដូច្នេះខ្ញុំពិតជាមានមោទនភាពណាស់ ដែលបានឃើញឆន្ទៈរបស់ប្រទេសកម្ពុជាក្នុងការប្រឈមមុខដោះស្រាយបញ្ហាអតីតកាលរបស់ខ្លួនដោយភាពក្លាហាននិងស្មោះត្រង់ ។

ហើយឥឡូវនេះខ្ញុំមានវត្តមានជាមួយនឹងប្អូនទាំងអស់គ្នាដែលជាក្មេងៗជំនាន់ក្រោយដែលបានរស់នៅដោយសន្តិភាព ទទួលបានឱកាសពង្រឹងទេពកោសល្យ កម្លាំង និងសេរីភាពដើម្បីសម្រេចក្តីសុបិនរបស់ខ្លួន ។ ប្អូនទាំងអស់គ្នានៅទីនេះគឺជាភ័ស្តុតាងដ៏ល្អសម្រាប់អនាគតនិងបច្ចុប្បន្នកាលរបស់ប្រទេសកម្ពុជា ។ ប្អូនៗពិតជាតំណាងឲ្យក្តីសង្ឃឹមដ៏ល្អបំផុតដូចយុវជននៅប្រទេសផ្សេងៗទៀតដែរ ។ ហើយខ្ញុំរំពឹងចាំមើលថាតើរដ្ឋាភិបាលនិងប្រជាជនអាមេរិកអាចក្លាយជាដៃគូដែលជួយឲ្យប្អូនៗស្គាល់ក្តីស្រមៃរបស់ខ្លួន ហើយដែលសំខាន់ជាងនេះនោះគឺជួយប្រទេសរបស់ប្អូនៗទទួលបាននូវអនាគតមួយដែលប្រកបដោយសន្តិភាព លទ្ធិប្រជាធិបតេយ្យស្ថិរភាព និងវិបុលភាពរហូតទៅ ។ សូមអរគុណ (សំឡេងទះដៃ)

អ្វីដែលយើងនឹងធ្វើនៅពេលនេះគឺសូមឲ្យអ្នកទាំងអស់គ្នាលើកដៃហើយខ្ញុំនឹងហៅអ្នកឲ្យសួរសំណួរ ។ ខ្ញុំនឹងព្យាយាមឲ្យអ្នកទាំងអស់គ្នានៅក្នុងសាលនេះបានសួរសំណួរ ។ នៅពេលដែលលើកដៃហើយ ប្អូនៗនឹងទទួលបានមីក្រូហ្វូន ហើយក្រោកឈរណែនាំខ្លួននិងសួរសំណួរ ។ ហើយខ្ញុំក៏មានប្រដាប់ស្តាប់សំឡេងដែរ ប្រសិនបើអ្នកមិនអាចនិយាយភាសាអង់គ្លេសបាន ខ្ញុំនឹងស្តាប់ការបកប្រែ ហើយធ្វើការឆ្លើយតបនឹងសំណួររបស់ប្អូនៗ ។

នរណាចង់សួរមុនគេ? តើយើងគួរតែឲ្យខាងណាសួរមុន? អូ! ពិតជាអស្ចារ្យមែនៗ ។ ខ្ញុំឃើញក្មេងស្រីម្នាក់លើកដៃនៅកន្លែងនោះ ។ មិនមែនម្នាក់នេះទេនោះគឺក្មេងស្រីម្នាក់ដែលកំពុងតែងាកចុះឡើងនោះ ។ នោះគឺក្មេងស្រីម្នាក់នោះ ។ ចាស៎! គឺម្នាក់ហ្នឹងហើយ ។ ខ្ញុំនឹងឲ្យប្អូនសួរសំណួរមុន ហើយខ្ញុំនឹងឲ្យប្អូនស្រីម្នាក់ទៀតសួរ បន្ទាប់មកយើងនឹងឲ្យអ្នកនៅម្ខាងទៀតសួរម្តង ។

**សំណួរ** : អរុណសួស្តីលោកស្រីរដ្ឋមន្ត្រី ។ នាងខ្ញុំឈ្មោះ លីតា មកពីផ្នែកសារព័ត៌មាននិងអប់រំនៃសាកលវិទ្យាល័យ (មិនឮសំឡេង)

ហើយនាងខ្ញុំសូមសួរសំណួរមួយទៅកាន់លោកស្រី ។ លោកស្រីគឺជាស្ត្រីដែលមានឥទ្ធិពលម្នាក់នៅក្នុងពិភពលោក ដូច្នេះខ្ញុំចង់ដឹងថាតើបញ្ហាយេនឌ័របានចោទជាបញ្ហាដល់លោកស្រីក្នុងការបំពេញការងារនយោបាយរបស់លោកស្រីដែរឬទេ? សូមអរគុណ (សំឡេងទះដៃ) ។

***លោកស្រី គ្លីនតុន*** ៖ ចម្លើយគឺថាបញ្ហាយេនឌ័របានចោទជាបញ្ហាដល់ការបំពេញការងាររបស់ខ្ញុំ ។ ប៉ុន្តែមិនសូវជាញឹកញាប់ ហើយក៏មិនបានរារាំងខ្ញុំមិនឲ្យបំពេញការងារនិងចំណាប់អារម្មណ៍ និងកាតព្វកិច្ចរបស់ខ្ញុំបានឡើយ ។ ប៉ុន្តែខ្ញុំគិតថាវាសមហេតុផលក្នុងការនិយាយថាសូម្បីតែនៅប្រទេសរបស់ខ្ញុំក៏រឿងនេះបានចោទជាបញ្ហាដល់ស្ត្រីក្នុងការ (មិនឮសំឡេង) ការិយាល័យសាធារណៈ នៅក្នុងស្ថានភាពផ្សេងៗគ្នាជាងបុរស ។ បញ្ហានេះបានការវិឌ្ឍទៅមុខច្រើនហើយៗ វាប្រសើរជាងមុនច្រើនណាស់ ។ ប៉ុន្តែវានៅតែជាបញ្ហាមួយដែលស្ត្រីនៅតែប្រឈមមុខ ហើយស្ត្រីទាំងអស់គ្នាត្រូវតែសហការគ្នាដើម្បីជម្នះបញ្ហានេះ ។ ប្អូនៗប្រាកដជាមិនភ្ញាក់ផ្អើលប៉ុន្មានទេ (មិនឮសំឡេង) ដែលខ្ញុំនិយាយថា ខ្ញុំគឺជាអ្នកគាំទ្រសិទ្ធិ និងឱកាសរបស់ស្ត្រី និងក្មេងស្រី ពីព្រោះខ្ញុំជឿថាប្រទេសណាដែលមិនបានប្រើប្រាស់ទេពកោសល្យរបស់ប្រជាជនខ្លួនទាំងអស់ រួមទាំងស្ត្រីនិងក្មេងស្រីនេះនឹងបាត់បង់ឱកាសក្នុងការរីកចម្រើន ។ ហើយខ្ញុំពិតជាចង់ឃើញស្ត្រី ក្មេងៗជាច្រើនទៀតបន្តធ្វើការងារផ្នែកនយោបាយនៅក្នុងជួររដ្ឋាភិបាល បក្ស នយោបាយនៅក្នុងការគ្រប់គ្រងការិយាល័យនិងទទួលបានតំណែងខ្ពស់ៗ ។ ហើយខ្ញុំក៏ចង់ឃើញស្ត្រីក្មេងៗទាញយកផលប្រយោជន៍ពីការងារធ្វើជំនួញ សិក្សា និងមុខងាររបស់ខ្លួនដែរ ។ ដូច្នេះប្រសិនបើប្អូនៗខិតខំប្រឹងប្រែងរៀនសូត្រនិងរៀបចំខ្លួនរួចជាស្រេចនោះប្អូនៗគួរតែអាចទទួលការងារមួយដែលថ្លៃថ្នូរ ។ ហើយនៅពេលអនាគត យើងនឹងអាចវិនិច្ឆ័យអត្តចរិតនិងសមត្ថភាពរបស់មនុស្សបានតាមរយៈការងារដែលកំពុងតែព្យាយាមធ្វើដូចដែលលោកបណ្ឌិត ម៉ាទីន ឡូធឺ ឃីង បាននិយាយដូច្នោះដែរ ។ ដូច្នេះខ្ញុំធ្លាប់ឆ្លងកាត់បញ្ហាខ្លះៗ ប៉ុន្តែមិនច្រើនប៉ុន្មានទេ តែគ្រប់គ្រាន់ដែលអាចធ្វើឲ្យខ្ញុំដឹងថាវានៅតែជាការ


In memory of the tragic suffering of the people of Cambodia and in hope that there will be a future of peace, prosperity and greater awareness of all that needs to be done to move the country forward, including trials, accountability, and reconciliation. May God bless all who lost their lives and their families and all Cambodians who want to make a difference for the next generation.

Hillary Rodham Clinton

11/1/10

## ខ្លឹមសារជាភាសាខ្មែរ

នៅក្នុងការចងចាំនៃសោកនាដកម្មដ៏ឈឺចាប់របស់ប្រជាជនកម្ពុជា ហើយនៅក្នុងក្តីសង្ឃឹមថានៅថ្ងៃអនាគតនឹងអាចមានសន្តិភាព ភាពរុងរឿង និងការយល់ដឹងឲ្យកាន់តែច្បាស់លាស់ចំពោះអ្វីៗទាំងអស់ដែលចាំបាច់ត្រូវតែសម្រេចឲ្យបាន ដែលរួមមានទាំងសាលាក្តី ការទទួលខុសត្រូវ ក្នុងការផ្សះផ្សា ក្នុងគោលបំណងដើម្បីធ្វើឲ្យប្រទេសនេះឆ្ពោះទៅមុខ ។ សូមឲ្យទេវតាប្រសិទ្ធិពរជូនដល់អ្នកដែលបានបាត់បង់ជីវិត និងសាច់ញាតិទាំងឡាយ ក៏ដូចជាជូនដល់ប្រជាជនកម្ពុជាទាំងអស់ដែលចង់ធ្វើឲ្យមានភាពខុសប្លែកមួយជូនដល់អ្នកជំនាន់ក្រោយ ។

***លោកស្រី ហ៊ីលឡារី គ្លីនតុន, ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០***


លោកស្រី ហ៊ីលឡារី គ្លីនតុន អង្គុយសរសេរយោបល់ផ្ទាល់ខ្លួន នៅសារមន្ទីរទួលស្លែង

ចោទបញ្ហាដដែល ។ ហើយយើងទាំងអស់គ្នាត្រូវតែធ្វើការសម្រាប់សង្គមរបស់យើងទាំងអស់គ្នាដើម្បីព្យាយាមបើក (មិនឮសំឡេង) ឱកាសនេះហើយ បន្ទាប់មកជួយស្ត្រីក្មេងៗដើរចាប់យកឱកាសទាំងនេះ និងទាញយកផលប្រយោជន៍ពីការខិតខំព្យាយាមការប្តេជ្ញាចិត្តរបស់គេដើម្បីទទួលបានជោគជ័យមិនមែនសម្រាប់តែខ្លួនឯងប៉ុណ្ណោះទេ ថែមទាំងសម្រាប់សង្គមរបស់គេផងដែរ ។

ឥឡូវនេះមានក្មេងស្រីម្នាក់ទៀតដែលក្រោកឈរនៅពេលតែមួយនឹងប្អូនស្រីមុន ដូច្នេះខ្ញុំនឹងឲ្យគាត់សួរសំណួរហើយយើងនឹងបន្តទៅអ្នកផ្សេងទៀត ។

***សំណួរ*** ៖ *អស្ចារ្យមែន ខ្ញុំពិតជារំភើបមែនទែន ។ អរុណសួស្តី សាយ័ន្តសួស្តី (សំឡេងសើច) ខ្ញុំចង់ស្តាប់ពីបទពិសោធន៍របស់លោកស្រី ពីព្រោះលោកស្រី (មិនឮសំឡេង) ថាតើធ្វើយ៉ាងណាទើបអាចទទួលបានជោគជ័យ និងក្លាយជាមនុស្សមានឥទ្ធិពលដូចលោកស្រី ពីព្រោះថាលោកស្រីគឺជាវរនារីគំរូរបស់ខ្ញុំ ។ (សំឡេងទះដៃ)*

***លោកស្រី គ្លីនតុន*** ៖ *អរគុណប្អូន ។ ខ្ញុំនឹងនិយាយឲ្យប្អូនដឹងពីជីវិតរបស់ខ្ញុំបន្តិចចុះ ពីព្រោះថាគ្រប់គ្នាសុទ្ធតែមានរឿងរ៉ាវជីវិតខុសៗគ្នាដែលនេះគឺជាសេចក្តីសុខមួយក្នុងនាមកើតមកជាមនុស្សពីព្រោះវាមានភាពខុសប្លែកគ្នានិងការប្រែប្រួលច្រើនណាស់នៅក្នុងការកំណត់ថាតើយើងជានរណា និងថាតើយើងមកពីកន្លែងណា ។ ខ្ញុំគឺជាកូនច្បងនៅក្នុងចំណោមបងប្អូនបីនាក់ ។ ខ្ញុំមានប្អូនប្រុសពីរនាក់ ។*

*ម្តាយរបស់ខ្ញុំមិនបានរៀនដល់ថ្នាក់មហាវិទ្យាល័យទេ ពីព្រោះគាត់មិនដែលមានឱកាសរៀនដល់ថ្នាក់ខ្ពស់បែបនេះឡើយ ។ គាត់ជួបប្រទះនឹងជីវិតដ៏លំបាក ហើយត្រូវធ្វើការតាំងពីគាត់មានអាយុ១៣ឆ្នាំ ប៉ុន្តែម្តាយខ្ញុំគាត់បានរៀនចប់ថ្នាក់វិទ្យាល័យដែរ ។ ឪពុករបស់ខ្ញុំគឺជាកងទ័ពជើងទឹកនៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។*

*នៅពេលដែលអ្នកទាំងពីរបានរៀបការជាមួយគ្នា អ្នកទាំងពីរបានខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនៗ ហើយបានបញ្ជូនកូនៗទៅរៀន ហើយអ្នកទាំងពីរមិនដែលចាត់ទុកថាខ្ញុំខុសពីបងប្អូនប្រុសរបស់ខ្ញុំឡើយ ។ គាត់ទាំងពីរមានសេចក្តីរំពឹងពីយើងទាំងបីនាក់ដូចៗគ្នា ។ ឪពុករបស់ខ្ញុំគាត់កាចបន្តិចក្នុងការចិញ្ចឹមបីបាច់យើង ហើយគាត់តែងតែប្រាប់ខ្ញុំឲ្យព្យាយាមឲ្យអស់ពីសមត្ថភាព ហើយគាត់រំពឹងចង់ឲ្យខ្ញុំខំប្រឹងប្រែងរៀនសូត្រ ហើយរៀនឲ្យបានពូកែតាមសមត្ថភាពរបស់ខ្ញុំ ។*

*ដូច្នេះពេលដែលខ្ញុំរៀនដល់ថ្នាក់មហាវិទ្យាល័យ នោះគឺជាដំណាក់កាលមួយដ៏សំខាន់សម្រាប់ខ្ញុំ និងជាពិសេសសម្រាប់ម្តាយរបស់ខ្ញុំពីព្រោះគាត់មិនមានឱកាសនេះទេ ។ ហើយខ្ញុំតែងតែមានអារម្មណ៍ថាវាគឺជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការរៀនឲ្យបានពូកែនិងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ។ ជាលទ្ធផល ខ្ញុំក៏បានបញ្ចប់មហាវិទ្យាល័យហើយខ្ញុំបានបន្តទៅរៀននៅសាលាច្បាប់ដែលមិនសូវមាននិស្សិតស្រីៗរៀនប៉ុន្មានទេ ប៉ុន្តែខ្ញុំចូលចិត្តរៀនពីកិច្ចការដែលធ្វើនៅក្នុងជួររដ្ឋាភិបាល និងនៅក្នុងសង្គម ហើយការដែលបានក្លាយជាមេធាវីបានធ្វើឲ្យខ្ញុំទទួលបាននូវព័ត៌មាននិងការយល់ដឹងជាច្រើនទាក់ទងនឹងរដ្ឋាភិបាល និងសង្គម ។*

*នៅពេលកំពុងរៀននៅសាលាច្បាប់ ខ្ញុំបានជួបបុរសម្នាក់ឈ្មោះ ប៊ីល គ្លីនតុន ហើយយើងបានណាត់ដើរលេងជាមួយគ្នា ។ យើងទាំងពីរនាក់បានបញ្ចប់ផ្នែកច្បាប់ជាមួយគ្នា ហើយទាំងពីរនាក់បានក្លាយជាមេធាវី ។ យើងបានរៀបការជាមួយគ្នានៅឆ្នាំ១៩៧៥ ហើយយើងទើបតែនឹងអបអរសាទរពិធីគម្រប់ខួបអាពាហ៍ពិពាហ៍លើកទី៣៥របស់យើងនាពេលថ្មីៗនេះ ។ ស្វាមីរបស់ខ្ញុំតែងតែខិតខំប្រឹងប្រែងធ្វើការ ហើយគាត់តែងតែគាំទ្រកិច្ចការដែលខ្ញុំបានធ្វើ ។ ដូច្នេះខ្ញុំមានឪពុកនិងស្វាមីដែលចាំគាំទ្រខ្ញុំជានិច្ច ។ ដំបូន្មានដែលខ្ញុំមានសម្រាប់ប្អូនគឺថាប្អូនត្រូវតែរកស្វាមីដែលចេះគាំទ្រប្អូន (សំឡេងសើច) ក្នុងនាមជាស្ត្រីវ័យក្មេងដែលចង់ធ្វើកិច្ចការដែលជួយឲ្យប្អូនប្រើប្រាស់ចំណេះដឹងដើម្បីសម្រេចក្តីស្រមៃរបស់ប្អូនបាន ។ ប៉ុន្តែខ្ញុំក៏មានអារម្មណ៍ស្រឡាញ់តួនាទីជាម្តាយនិងចូលចិត្តការចិញ្ចឹមបីបាច់ថែរក្សាកូនស្រីរបស់ខ្ញុំណាស់ដែលនេះគឺជាកិច្ចការដ៏សំខាន់ដែលខ្ញុំបានធ្វើកន្លងមក ។ ហើយខ្ញុំគិតថា ប្អូនអាចបញ្ចូលនិងធ្វើឲ្យក្តីសង្ឃឹមរបស់ប្អូនមានតុល្យភាពជាមួយនឹងមុខងារនិងការចូលរួមរបស់ប្អូននៅក្នុងទីសាធារណៈបាន ។ ហើយខ្ញុំសង្ឃឹមថាប្អូនៗទាំងអស់គ្នាទាំងប្រុសទាំងស្រីនឹងទទួលបានបទពិសោធន៍ជីវិតដែលនឹងធ្វើឲ្យប្អូនយល់ថាប្អូនបានបំពេញការងារ និងចូលរួមក្នុងសង្គមបានយ៉ាង*

អស់ពីសមត្ថភាព ។ វាមិនមានភាពងាយស្រួលទេ ប៉ុន្តែវាមានតម្លៃ ។ អរគុណសម្រាប់ពាក្យពេចន៍ដ៏ល្អរបស់ប្អូន ហើយខ្ញុំជូនពរប្អូនមានសំណាងល្អ ។ (សំឡេងទះដៃ)

ចាស៎! គឺប្អូនប្រុសម្នាក់នោះហើយ ។ សូមយកមីក្រូហ្វូន ។

***សំណួរ*** ៖ សាយន្តសួស្តី លោកស្រីរដ្ឋមន្ត្រីក្រសួងការបរទេស ហ៊ីលឡារី គ្លីនតុន ហើយ (មិនឮសំឡេង) យើងនិយាយទៅកាន់លោកស្រីកាលពីព្រឹកមិញនេះ ។ ហើយសំណួររបស់ខ្ញុំមិត្តភក្តិខ្ញុំ (មិនឮសំឡេង) យើងប្រាថ្នាចង់និយាយនិងសន្ទនាជាមួយគាត់ដូចដែរ គឺទៅកាន់លោក អូបាម៉ា ដែលយើងអាចធ្វើបាន ។ គាត់គឺជាវីរបុរសរបស់ខ្ញុំ ។

***លោកស្រី គ្លីនតុន*** ៖ អូ! ប្រសើរណាស់ ខ្ញុំនឹងនិយាយប្រាប់គាត់ពីរឿងនេះ ។

***សំណួរ***៖ សំណួររបស់ខ្ញុំគឺដូចដែលលោកស្រីបានដឹងហើយថា ប្រទេសចិនគឺ (មិនឮសំឡេង) ហើយមានឥទ្ធិពលមកលើកម្ពុជា ហើយអ្វីទៅជាលទ្ធផលនៃឥទ្ធិពលនេះលើការទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិក និង (មិនឮសំឡេង) ប្រជាធិបតេយ្យ និង (មិនឮសំឡេង) ប្រទេសកម្ពុជាផ្ទាល់?

***លោកស្រី គ្លីនតុន*** ៖ អរគុណ អរគុណ ។ (សំឡេងទះដៃ) ។ រឿងនេះប្រាកដជាសម្រេចទៅលើប្រទេសកម្ពុជា រដ្ឋាភិបាលរបស់ប្អូននិងប្រជាជនរបស់ប្អូនក្នុងការកំណត់ទំនាក់ទំនងជាមួយប្រទេសនានា ។ ប៉ុន្តែខ្ញុំគិតថា បើប្រទេសកម្ពុជាឆ្លាត គួរតែរាប់អានជាមួយប្រទេសផ្សេងៗ ហើយនិងស្វែងរកឱកាសសហការជាមួយប្រទេសផ្សេងទៀត ។ ខ្ញុំគិតថាប្រទេសនានាចង់គាំទ្រប្រទេសកម្ពុជានិងអនាគតរបស់ប្អូន ។ ប្រទេសនានាកំពុងតែចូលរួមជាមួយកម្ពុជាខាងផ្នែក សិល្បៈ វប្បធម៌ សុខភាព និងតាមរយៈវិធីសាស្ត្រជាច្រើន ។

ដូច្នេះវាដូចតែទំនាក់ទំនងរវាងប្រទេសយើងជាមួយប្រទេសដទៃផ្សេងទៀតដែរ ។ យើងស្វែងរកតុល្យភាព យើងមិនចង់ឲ្យមានការពឹងផ្អែកតែលើប្រទេសតែមួយទេ ។ អ្នកចង់មានទំនាក់ទំនងដែលរំលងខ្សែបន្ទាត់ភូមិសាស្ត្រ ។ ប្រទេសចិនជាប្រទេសដ៏អស្ចារ្យ និងមានអនាគតភ្លឺស្វាងនៅថ្ងៃខាងមុខ ។ ហើយមានហេតុផលជាក់លាក់ជាច្រើនដែលធ្វើឲ្យកម្ពុជាមានទំនាក់ទំនងល្អជាមួយចិន ។

ឧទាហរណ៍ ដូចជាខ្ញុំរៀបរាប់ពីទន្លេមេគង្គ ។ ចំណុចផ្តួចផ្តើមមួយដែលសហរដ្ឋអាមេរិកកំពុងតែធ្វើការនោះគឺនាំឲ្យប្រទេសវៀតណាម ឡាវ កម្ពុជា និងប្រទេសថៃមកជុំគ្នាធ្វើការសម្រាប់ការការពារទន្លេមេគង្គខ្សែទឹកខាងក្រោម ។ ហើយអ្វីដែលជាបញ្ហាប្រឈមនោះគឺការធ្វើទំនប់នៅខាងទន្លេមេគង្គខ្សែទឹកខាងលើ ដូច្នេះត្រូវតែមានការចរចា និងជជែកពិភាក្សាគ្នាជាច្រើនក្នុងចំណោមមិត្តអំពីថាតើត្រូវការពារធនធានដ៏អស្ចារ្យនេះសម្រាប់អ្នកទាំងអស់គ្នា ដូចម្តេច?

ដូច្នេះ ខ្ញុំគិតថាមិនមែនជារឿងសម្រាប់សហរដ្ឋអាមេរិកត្រូវប្រាប់កម្ពុជាថា ត្រូវគ្រប់គ្រងចាត់ចែងទំនាក់ទំនងរបស់កម្ពុជានោះទេ ប៉ុន្តែតាមការអង្កេតជាប្រវត្តិសាស្ត្រ ការមានទំនាក់ទំនងជាមួយប្រទេសច្រើនដែលអាចធ្វើទៅបាននោះ អ្នកអាចស្វែងរកវិធីនានាដើម្បីធ្វើការជាមួយប្រទេសទាំងនោះ និងដើម្បីឲ្យមានការសន្ទនាយ៉ាងទូលំទូលាយដែលអាចដោះស្រាយបញ្ហានានាបាន ។ យើងមិនត្រូវមានទំនាក់ទំនងជាមួយគ្នា ហើយមកបង្កើតជាបញ្ហាផ្សេងៗរវាងគ្នានិងគ្នាទេ ។ ខ្ញុំគិតថា នេះជាផ្លូវដ៏ល្អក្នុងការឆ្ពោះទៅមុខ ។ ដូចនេះខ្ញុំសង្ឃឹមថាអ្វីទាំងនេះ ហើយដែលកម្ពុជានឹងជ្រើសរើសអនុវត្តទៅពេលអនាគត ។ (សំឡេងទះដៃ) ។ អូ! ព្រះអើយៗ លើកដៃច្រើនណាស់តែយើងមានពេលវេលាខ្លីពេក ។ ក្មេងប្រុសដែលពាក់វ៉ែនតា នៅត្រង់នោះពាក់អាវពណ៌សនោះ ។

***សំណួរ*** ៖ លោកស្រីរដ្ឋមន្ត្រី អរគុណនូវវត្តមានរបស់លោកស្រីនៅថ្ងៃនេះ ។ ខ្ញុំទើបតែបានអានអត្ថបទដែលលោកស្រីសរសេរទាក់ទងនឹងកិច្ចការអន្តរជាតិនៅប៉ុន្មានថ្ងៃនេះ ហើយអ្វីដែលធ្វើឲ្យខ្ញុំយល់ច្បាស់នោះគឺលក្ខខណ្ឌនានានៃប្រជាជននៅប្រទេសផ្សេងៗគ្នាមានឥទ្ធិពលផ្ទាល់ទៅលើសារប្រយោជន៍សន្តិសុខ ស្ថិរភាពនិងភាពសុខដុមរបស់សហរដ្ឋអាមេរិក ។ ឥឡូវនេះ លោកស្រីប្រហែលជាបានដឹងហើយថាមុនពេលដែលលោកស្រីមកទស្សនកិច្ចនៅទីនេះ ការសន្ទនាពិភាក្សានានានៅកម្ពុជាតែងតែឆ្ពោះទៅសហរដ្ឋអាមេរិកទាមទារឲ្យកម្ពុជាសងនូវបំណុលជាង៤០០លានដុល្លារអាមេរិកដែលជំពាក់នៅក្នុងអំឡុងដើមទសវត្សរ៍៧០ ។ យើងជាប្រទេសដែល

មិនមានលទ្ធភាពក្នុងការសងបំណុល៤០០លានដុល្លារ ដែលវាប្រហែលជាស្មើនឹង៥ភាគរយនៃកំណើនផលិតផលសរុបប្រចាំឆ្នាំរបស់យើង ។ យើងអាចមានលទ្ធភាពសងដរាបណាមិនចំណាយទៅលើសុខុមាលភាពនិងអភិវឌ្ឍន៍នៃប្រជាជនកម្ពុជារាប់លាននាក់ ។ ដូច្នេះសំណួររបស់ខ្ញុំគឺថា តើលោកស្រីយល់ស្របថាដំណោះស្រាយដ៏ល្អលើបញ្ហានេះគឺប្រហែលជាការចាប់ផ្ដើមចរចាលុបបំណុលនោះភ្លាមៗទេ? សូមអរគុណ ។

***លោកស្រី គ្លីនតុន*** ៖ *សូមអរគុណ ។ ដំបូងខ្ញុំសូមអរគុណដែលបានអានអត្ថបទពីកិច្ចការងារទំនាក់ទំនងអន្តរជាតិ ។ ខ្ញុំសូមកោតសរសើរយ៉ាងខ្លាំង ។ ខ្ញុំនឹងធ្វើការលើកអំពីរឿងនេះឡើងពិភាក្សាជាមួយទាំងឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងលោកនាយករដ្ឋមន្ត្រី ។ ការសង្ឃឹមទុករបស់ខ្ញុំគឺថា យើងអាចបន្តពិភាក្សាថាតើត្រូវដោះស្រាយបំណុលដ៏ចំណាស់នេះដោយវិធីណា ។ នៅពេលដែលអ្នកមានបំណុលបែបនេះគឺថាវិលទៅរកទសវត្សរ៍៧០នៃរបប លន់ នល់ ក្រោយមកអ្នកនឹងដឹងថានេះជារឿងមិនមែនជាប់ទាក់ទងតែផ្នែកប្រាក់កាសទេតែក៏ជាប់ទាក់ទងទៅនឹងនយោបាយផងដែរ ។ ហើយខ្ញុំនឹងផ្ញើប្រសិនបើរដ្ឋាភិបាលកម្ពុជាមានបំណង ខ្ញុំនឹងបញ្ចូលក្រុមការងារជំនាញ ហើយយើងនឹងស្វែងរកវិធីផ្សេងៗដើម្បីដោះស្រាយបញ្ហានេះដោយការរួមបញ្ចូលគ្នានូវចំណុចមួយក្នុងចំណោមមធ្យោបាយផ្សេងៗ ។ អ្នកអាចសង់ខ្លះ ដូចនេះអ្នកអាចមានបំណុលដោយសារបញ្ហាធម្មជាតិអ្នកអាចមានបំណុលដោយសារបញ្ហាអប់រំ ។ មានកិច្ចការជាច្រើនដែលរដ្ឋាភិបាលកម្ពុជាអាចធ្វើដែលអាចបំពេញនូវសេចក្ដីត្រូវការដើម្បីបង្ហាញពីភាពទទួលខុសត្រូវ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺការដាក់ទុនទៅលើតម្រូវការរបស់ប្រជាជនកម្ពុជា ។ ដូចនេះ ខ្ញុំគិតថាយើងមានវិធីនឹងស្វែងរកការដោះស្រាយបញ្ហានេះ ។ មានវិធានផ្សេងក្នុងនានាក្នុងការដំណើរការរឿងនេះដូចដែលអ្នកបានដឹងរួចមកហើយ ។ ដូចនូវអ្វីដែលគេហៅថា ក្រុមទីក្រុងប៉ារីសបានកំណត់នូវការរំពឹងទុកយ៉ាងប្រាកដនានា ។ ប៉ុន្តែខ្ញុំប្រាកដណាស់នឹងដោះស្រាយបញ្ហានេះ ។ ខ្ញុំនឹងចែករំលែកការព្រួយបារម្ភរបស់អ្នកនៅជាប់នៅទីនោះ ហើយវាត្រូវតែដោះស្រាយ ហើយខ្ញុំចង់ចាប់ដើមដោះស្រាយឲ្យបានកាន់តែឆាប់កាន់តែល្អ ។ ដូចនេះ សូមអរគុណដែលបានសួរសំណួរនេះ នេះជាសំណួរដ៏ល្អ ។ (សំឡេងទះដៃ)*

*សូមឲ្យប្អូនស្រីនៅខាងនោះម្ដង ។*

***សំណួរ*** ៖ *តើអ្នកសុខសប្បាយជាទេ លោកស្រី ហ៊ីលឡារី គ្លីនតុន? ខ្ញុំមកពី (មិនឮសំឡេង) ដោយសារគ្រូរបស់ខ្ញុំ (មិនឮសំឡេង) មុខវិជ្ជាដែលខ្ញុំសិក្សា....នៅ (មិនឮសំឡេង) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ខ្ញុំចង់ដឹងប្រសិនតើកម្ពុជាមានទេសចរណ៍ផ្លូវភេទដែរឬអត់ តើលោកស្រីគិតយ៉ាងដូចម្ដេច? ហើយចំណុចមួយទៀតគឺថា តើធ្វើយ៉ាងដូចម្ដេចដើម្បីឲ្យកម្ពុជាក្លាយជាប្រទេសឯករាជ្យពិតប្រាកដ ។*

***លោកស្រី គ្លីនតុន*** ៖ *ដើម្បីក្លាយជាប្រទេសឯករាជ្យជាងនេះ?*

***សំណួរ*** ៖ *ចាស៎! ។*

***លោកស្រី គ្លីនតុន*** ៖ *សម្រាប់ប្រជាជនក្លាយជាមានឯករាជ្យជាងនេះ?*

***សំណួរ*** ៖ *ចាស៎! ។*

***លោកស្រី គ្លីនតុន*** ៖ *ខ្ញុំគិតថាការអភិវឌ្ឍវិស័យអប់រំ និង សេដ្ឋកិច្ច ការបង្កើនឱកាសដល់ប្រជាជនទាំងអស់ ជាពិសេសកូនប្រជាជនក្រីក្រឲ្យអាចចូលរៀនសូត្រហេដ្ឋារចនាសម្ព័ន្ធល្អដែលអាចឲ្យប្រជាជននាំយកផលិតផលរបស់គាត់ទៅលក់នៅតាមទីផ្សារនានា ។ ខ្ញុំដឹងថាប្រទេសកម្ពុជាជាប្រទេសសេដ្ឋកិច្ចពឹងលើវិស័យកសិកម្ម ហើយត្រូវធ្វើយ៉ាងណាបង្កើតឲ្យមានមធ្យោបាយក្នុងការផលិតកសិកម្ម ប្រព័ន្ធដែលអាចឲ្យផលិតផលទាំងនោះឈានទៅរកទីផ្សារ ដូចនេះកសិករអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធទាំងនោះ ។ ដូចនេះ ខ្ញុំគិតថាមានការអនុវត្តនានាដែលកំពុងតែអនុវត្តនៅកន្លែងផ្សេងៗនៅលើពិភពលោកដែលប្រទេសកម្ពុជាអាចទាញយកប្រយោជន៍បាន ។ ចំណុចគន្លឹះឆ្ពោះទៅរកសេរីភាពរបស់ប្រទេសគឺធ្វើឲ្យប្រព័ន្ធនយោបាយនិងកំណើនសេដ្ឋកិច្ចមួយដែលមានស្ថិរភាព ដូច្នេះ*

ផលប្រយោជន៍នៃកំណើនសេដ្ឋកិច្ចនេះនឹងមិនធ្លាក់ទៅក្នុងដៃប្រជាជនមួយចំនួនតូចនោះទេ ប៉ុន្តែវានឹងធ្លាក់ទៅក្នុងដៃប្រជាជនទូទៅ ដូច្នេះប្រជាជនម្នាក់ៗមានអារម្មណ៍ថាខ្លួនមានឱកាសមួយដែលកូនរបស់គាត់អាចមានជីវិតភាពរស់នៅប្រសើរមួយ ហើយដែលការខិតខំប្រឹងប្រែងរបស់គាត់នឹងទទួលបានផលប្រយោជន៍ត្រឡប់មកវិញ ។

យើងដឹងហើយតាមរយៈការមើលទៅលើប្រវត្តិសាស្ត្រនៅពេលដែលសេដ្ឋកិច្ចកាន់តែរីកចម្រើន កាន់តែមានស្ថិរភាព នោះនឹងនាំឲ្យប្រទេសកាន់តែសុខដុមរមនា និងមានសេរីភាព ដូច្នេះមានភាពផ្សំជាច្រើនដូចជានៅពេលដែលមានសេរីភាពផ្នែកនយោបាយ ការគោរពសិទ្ធិមនុស្ស ហើយសិទ្ធិត្រូវបានដឹងច្បាស់នៅពេលដែលប្រជាជនមានសិទ្ធិក្នុងការប្រកួតប្រជែងក្នុងការបោះឆ្នោត ប្រព័ន្ធតុលាការឯករាជ្យ និងសេរីភាពខាងសារព័ត៌មាន ។ សមាសភាពនានានៃសេរីភាពខាងនយោបាយ មានសារសំខាន់ជាពិសេសនៅពេលដែលអ្នកធ្វើឲ្យលទ្ធិប្រជាធិបតេយ្យមានការលូតលាស់និងស្ថិរភាព និងកំណើនសេដ្ឋកិច្ច ដូច្នេះធ្វើឲ្យប្រជាជនយល់ថាប្រជាធិបតេយ្យកំពុងតែត្រូវបានផ្តល់ឲ្យប្រជាជននោះពិតជាមានសារសំខាន់ណាស់ ។

ដូច្នេះមានការលំបាកណាស់នៅក្នុងការផ្តោតតែលើមួយចំណុច ។ អ្នកត្រូវតែក្រឡេកមើលទៅលើមូលដ្ឋានទាំងមូលដែលនាំឲ្យសង្គមមានការអភិវឌ្ឍប្រកបដោយស្ថិរភាព ភាពសុខដុមរមនា សេរីភាព និងប្រជាធិបតេយ្យ ។ ប៉ុន្តែ ខ្ញុំមានមោទនភាពចំពោះការអភិវឌ្ឍរបស់កម្ពុជាសព្វថ្ងៃ ប៉ុន្តែត្រូវតែបន្តអភិវឌ្ឍបន្ថែមទៀត ។ វាមានការលំបាកណាស់ ។ សំណួរអំពី... សំណួរមួយក្នុងចំណោមសំណួរជាច្រើនដំបូងបំផុតនោះគឺពីសកម្មភាពនយោបាយរបស់ខ្ញុំជាស្ត្រី ខ្ញុំក៏ត្រូវបានគេរិះគន់ពីជំនឿនយោបាយរបស់ខ្ញុំនិងជំហររបស់ខ្ញុំ ។ ហើយនៅក្នុងប្រទេសយើងយើងមានការជជែកវែកញែកខាងនយោបាយយ៉ាងតឹងតែងមួយ ។ ជាការពិតអ្នកខ្លះនៅទីនេះអាចនឹងដឹង ហើយថាយើងមានការបោះឆ្នោតមួយនៅថ្ងៃស្អែកនេះ ។ ហើយវាគឺជាប្រព័ន្ធបោះឆ្នោតមួយដែលរឹងមាំនិងមិនចុះម្រុងគ្នាដែលមិនគួរឲ្យជឿ ប៉ុន្តែយើងគិតថាវាជាប្រព័ន្ធដែលល្អមួយពីព្រោះប្រជាជនអាចបញ្ចេញយោបល់ផ្សេងៗរបស់ខ្លួនហើយពលរដ្ឋម្នាក់ៗអាចនិយាយថាខ្ញុំមិនជឿលើនេះឬលើនោះ ។ បើតាមប្រវត្តិសាស្ត្ររបស់យើង នេះជាការបន្តប្រជាធិបតេយ្យចំណាស់ជាងគេនៅក្នុងពិភពលោកសព្វថ្ងៃដែលត្រូវបានបញ្ជាក់ថាមានការរឹងមាំនិងជោគជ័យ ។

ដូច្នេះភាពស្មើគ្នានៃសេរីភាពរវាងគណបក្សនយោបាយមានសារសំខាន់ណាស់ដូចគ្នាផងដែរខាងផ្នែកសេដ្ឋកិច្ច ដូចនេះប្រជាជនមើលឃើញថាជីវិតភាពរបស់គាត់មានភាពប្រសើរឡើង ។ ដូច្នេះយើងត្រូវសាមគ្គីគ្នា ។ សូមអ្នកនៅខាងនោះ ។

***សំណួរ*** ៖ សូមអរគុណច្រើនដែលអនុញ្ញាតឲ្យខ្ញុំមានឱកាសសួរសំណួរ ។ ក្នុងនាមប្រជាជនកម្ពុជានិង (មិនច្បាស់សំឡេង) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាខ្ញុំសូមស្វាគមន៍ការអញ្ជើញមកប្រទេសកម្ពុជា ។ ខ្ញុំជា (មិនច្បាស់សំឡេង) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាហើយខ្ញុំសូម (មិនច្បាស់សំឡេង) ថាធាតុផ្សំសំខាន់នៃសិទ្ធិមនុស្ស និងសេរីភាពខាងនយោបាយគឺមានសារសំខាន់ណាស់សម្រាប់និរន្តរភាពរបស់កម្ពុជា ដូចនេះខ្ញុំចង់ដឹងថាលោកស្រីនិងរដ្ឋការរបស់លោកអូបាម៉ាតើគិតយ៉ាងណា ចំពោះការដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើឲ្យបិទការិយាល័យអគ្គការសហប្រជាជាតិ ។ ហើយខ្ញុំយល់ថា សព្វថ្ងៃរដ្ឋាភិបាលរបស់លោក អូបាម៉ា កំពុងតែពង្រឹងទំនាក់ទំនងជាមួយប្រទេសកម្ពុជានិងក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ដូចនេះតើ (មិនច្បាស់សំឡេង) ថ្មីនេះនឹងមានការប៉ះពាល់សិទ្ធិមនុស្សនៅកម្ពុជាឬទេ? សូមអរគុណ ។

***លោកស្រី គ្លីនតុន*** ៖ សហរដ្ឋអាមេរិកប្រាកដជាប្តេជ្ញាគាំទ្រការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា ។ នៅពេលដែលអ្នកគិតពីប្រវត្តិសាស្ត្រប្រទេសអាមេរិកពីដើមមក ហើយនិងការបង្កើតសាធារណរដ្ឋមួយ ប្រសិនបើអ្នកអានសេចក្តីប្រកាសឯករាជ្យនិងរដ្ឋធម្មនុញ្ញរបស់យើង យើងជាប្រទេសដែលបង្កើតឡើងដោយក្តីជំនឿថាមនុស្សម្នាក់មានសិទ្ធិស្មើៗគ្នាមានសិទ្ធិរស់នៅក្នុងសេរីភាពសេចក្តីសុខ និងមានសិទ្ធិប្រាកដរាល់ពលរដ្ឋអាមេរិកទាំងអស់មានសិទ្ធិប្រឆាំងនឹងរដ្ឋាភិបាលមានសិទ្ធិក្នុងការបញ្ចេញមតិមានសិទ្ធិគោរពបូជាតាមជម្រើសរៀងៗខ្លួន ។ល ។ ដូច្នេះយើងមានជំនឿខ្លាំងណាស់ទៅលើសិទ្ធិមនុស្ស ហើយវាជាផ្នែកមួយរបស់ពលរដ្ឋអាមេរិក

ទាំងអស់ ។ ហើយយើងចង់ឃើញប្រទេសនានាការពារសិទ្ធិប្រជាជន ។ ដូចនេះ យើងតែងលើកបញ្ហានេះនៅគ្រប់ការពិភាក្សារបស់យើង ពេលដែលជួបជាមួយរាល់មេដឹកនាំប្រទេសទាំងអស់នៅជុំវិញពិភពលោក ។ ឥឡូវវប្បធម៌ផ្សេងៗគ្នាប្រវត្តិសាស្ត្រផ្សេងៗគ្នា និងបទពិសោធន៍ផ្សេងៗគ្នាត្រូវតែមានការយកចិត្តទុកដាក់ ហើយខ្ញុំមានការគោរពលើរឿងនេះណាស់ ។ បទពិសោធន៍របស់សហរដ្ឋអាមេរិក មិនមែនជាបទពិសោធន៍របស់កម្ពុជា ប្រទេសចិន ឥណ្ឌាទេ ។ ដូចនេះអ្នកបានដឹងអំពីភាពខុសគ្នានេះ ។

ប៉ុន្តែយើងម្នាក់ៗមានជំនឿថា មនុស្សជាតិគ្រប់រូបមានសិទ្ធិពិតប្រាកដ ហើយម្នាក់ៗជឿថាសិទ្ធិជាសាកលគួរតែគោរព ។ ប៉ុន្តែសង្គមនានានឹងអាចមានផ្លូវផ្សេងៗក្នុងការសម្រេចការងារនេះ ។ ដូច្នេះទើបយើងតែងតែជំរុញឲ្យមានសេរីភាពកាន់តែច្រើន ការគោរពសិទ្ធិមនុស្សឲ្យបានច្រើនហើយយើងគិតថាយើងកំពុងតែរួមគ្នាជាមួយប្រទេសនានានិងជាដៃគូរបស់ប្រទេសដែលមានបញ្ហានេះនេះជាវិធីល្អក្នុងការរក្សាការជជែកពិភាក្សានេះបន្តទៀត ។ ដូចនេះទោះជាយើងមិនពេញចិត្តទៅនឹងសកម្មភាពរបស់រដ្ឋាភិបាលណាមួយ ប្រទេសណាមួយក៏ដោយ ក៏យើងមិនបញ្ឈប់ការជជែកពិភាក្សាហើយយើងមិនបញ្ឈប់ការធ្វើការជាមួយគ្នា ហើយយើងមិនបញ្ឈប់ស្វែងរកចំណុចព្រមព្រៀងគ្នាទេ ។ ពីព្រោះវាមានសារសំខាន់ណាស់ក្នុងការបន្តទំនាក់ទំនង ហើយខ្ញុំគិតថានេះជាអ្វីដែលយើងកំពុងតែអនុវត្តនៅក្នុងតំបន់នេះនិងនៅលើពិភពលោកទាំងមូល ។

ដូចនេះយើងតែងតែជួបនូវបញ្ហាទាំងនេះ ប៉ុន្តែមានចំណុចសំខាន់ច្រើនទៀតដែលយើងនឹងធ្វើការពិភាក្សា ។ ហើយយើងសង្ឃឹមថាស្ថាប័នប្រជាធិបតេយ្យនានានឹងកាន់តែរឹងមាំនៅប្រទេសកម្ពុជាហើយ ទំហំនៃការបញ្ចេញមតិខាងនយោបាយនឹងមានគម្លាតធំដែលប្រជាជនមានសិទ្ធិក្នុងការរិះគន់រដ្ឋាភិបាលដែលអ្នកទាំងអស់គ្នាដឹងថាគាត់ជាស្វាមីរបស់ខ្ញុំក្នុងពេលដែលគាត់កំពុងកាន់តំណែងជាប្រធានាធិបតីមានពលរដ្ឋអាមេរិករាប់លាននាក់រិះគន់គាត់ ។ ឥឡូវលោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា ដែលបង្កើតឲ្យមានសេចក្តីសង្ឃឹមយ៉ាងខ្លាំងនិងជាសញ្ញាណដ៏អស្ចារ្យនៃការរីកចម្រើនរបស់ពិភពលោកនោះគាត់ក៏កំពុងត្រូវបានរិះគន់ដែរ ។ ដែលនេះជាប្រពន្ធ័នយោបាយរបស់ប្រទេសយើង ។ ហើយយើងមិនគិតថាវាធ្វើឲ្យយើងទន់ខ្សោយនោះទេ ។ យើងគិតថាវាធ្វើឲ្យយើងកាន់តែរឹងមាំ ។ ដូចនេះយើងសង្ឃឹមថា យើងអាចបញ្ចុះបញ្ចូលឲ្យប្រទេសនានាធ្វើតាមការអនុវត្តនេះ ។

អូ! ម្ចាស់ថ្លៃអើយ! សូមយុវតីម្នាក់ពាក់អាវពណ៌ផ្កា ឈូកនោះ ។

***សំណួរ*** ៖ ខ្ញុំចង់សួរលោកស្រីអំពីដំណើរការនៃការបោះឆ្នោតនៅសហរដ្ឋអាមេរិកជាពិសេសទាក់ទងនឹងលោកស្រី និង លោក បារ៉ាក់ អូបាម៉ា ព្រមទាំងស្វាមីរបស់លោកស្រីដែលជាគណបក្សប្រជាធិបតេយ្យ ។ អ្នកទាំងពីរប្រហែលជាធ្លាប់ប្រជែងគ្នាដើម្បីក្លាយជាអ្នកដឹកនាំកំពូលនៅក្នុងជួររដ្ឋាភិបាល ។ ខ្ញុំឆ្ងល់ថា ដំបូងលោកស្រីគឺជាអ្នកប្រឆាំងប៉ុន្តែនៅទីបញ្ចប់លោកស្រីគឺជាអ្នកគាំទ្ររដ្ឋាភិបាល អូបាម៉ា ទៅវិញ ។

**លោកស្រី គ្លីនតុន** ៖ នេះគឺជាសំណួរដ៏សំខាន់មួយ ដូច្នេះខ្ញុំនឹងធ្វើការបកស្រាយវា ។ ខ្ញុំធ្លាប់បានប្រឆាំងនឹង អូបាម៉ា ចំពោះការបោះឆ្នោតធ្វើជាប្រធានាធិបតីដោយប្រើលទ្ធិប្រជាធិបតេយ្យ ។ ខ្ញុំបានព្យាយាមយ៉ាងខ្លាំង ហើយខ្ញុំបានចំណាយអស់ជាង ២០០លានដុល្លារសហរដ្ឋអាមេរិក ។ ខ្ញុំបានព្យាយាមក្អាល់ជាមួយគាត់ ។ នៅទីបញ្ចប់ អូបាម៉ា គឺជាអ្នកឈ្នះ ហើយខ្ញុំគឺជាអ្នកចាញ់ ។

ហើយនៅពេលដែល អូបាម៉ា ស្នើឲ្យខ្ញុំធ្វើការឲ្យរដ្ឋាភិបាលរបស់គាត់ ខ្ញុំក៏មានការភ្ញាក់ផ្អើលដែរ ។ ប៉ុន្តែយើងបានពិភាក្សាជាមួយគ្នា យើងចង់បង្ហាញថាមនុស្សពីរនាក់អាចប្រឆាំងគ្នា បន្ទាប់មកក៏អាចធ្វើការជាមួយគ្នាដើម្បីប្រទេសដែរ ។ ខ្ញុំជឿជាក់ថា នៅត្រង់ចំណុចអភិវឌ្ឍន៍នយោបាយជាក់ស្តែងមួយចំនួនអ្នកមិនអាចធ្វើឲ្យបញ្ហានយោបាយ ក្លាយជាបញ្ហាផ្ទាល់ខ្លួនបានទេ ហើយអ្នកក៏មិនអាចធ្វើឲ្យបញ្ហានយោបាយជ្រៀតជ្រែកដល់ប្រទេសយើងបានដែរ ។ ខ្ញុំពិតជាមានមោទនភាពដែលបានក្លាយទៅជារដ្ឋមន្ត្រីក្រសួងការបរទេសតំណាងឲ្យសហរដ្ឋអាមេរិកនិងប្រធានាធិបតីនៅពេលដែលខ្ញុំទៅធ្វើទស្សនកិច្ចនៅប្រទេសដូចជាប្រទេសកម្ពុជាជាដើម ។

ប្រជាជនជាច្រើននៅលើពិភពលោកមិនអាចយល់បានទេ ។ នៅពេលដែលខ្ញុំចាប់ផ្តើមដំណើរទស្សនកិច្ចម្តងៗមានមនុស្សជា

ច្រើនបានសួរខ្ញុំថាតើអ្នកអាចធ្វើការឲ្យមនុស្សដែលប្រឆាំងនឹងអ្នកដោយរបៀបណា? ដោយសារតែយើងទាំងពីរនាក់ស្រឡាញ់ប្រទេសជាតិ ដូច្នេះជម្លោះនយោបាយត្រូវតែបញ្ចប់ ។ នយោបាយនឹងធ្វើឲ្យអ្នកដែលចង់ដោះស្រាយបញ្ហាអាចជួយដល់ប្រជាជននៅក្នុងប្រទេសបាន ។ ហើយប្រសិនបើអ្នកជឿបែបនេះ អ្នកប្រាកដជាអាចធ្វើ ការជាមួយមនុស្សដែលអ្នកប្រឆាំងផ្នែកនយោបាយដើម្បីដោះស្រាយបញ្ហាដូចជាសុខាភិបាល ការអប់រំ សេដ្ឋកិច្ច ឬអ្វីៗផ្សេងៗទៀត ។

ដូច្នេះសំណួររបស់អ្នកពិតជាមានសារសំខាន់ណាស់ ។ ហើយខ្ញុំធ្លាប់ឃើញប្រទេសប្រជាធិបតេយ្យថ្មីៗជាច្រើនដូចជាប្រទេសកម្ពុជាមានប្រជាជនចូលរួមនៅក្នុងនយោបាយ និងមិនអាចជឿថាមនុស្សដែលធ្លាប់ប្រឆាំងនឹងគ្នាអាចធ្វើការជាមួយគ្នាបាន ។ ខ្ញុំជឿថាការជួយដល់ ប្រជាជនឲ្យរួបរួមគ្នាគឺជាគោលបំណងនយោបាយ ។ ការចូលរួមក្នុងនយោបាយមិនមែនគ្រាន់តែការបោះឆ្នោតនិងឈ្នះឆ្នោតទេ ។ យើងចូលរួមក្នុងនយោបាយដើម្បីជួយដល់ប្រជាជន ។ ខ្ញុំជឿជាក់ថា ចំពោះសេវាសាធារណៈ ខ្ញុំបានធ្វើការជាច្រើនដើម្បីបម្រើដល់ប្រទេសដែលបានធ្វើឲ្យខ្ញុំមានសព្វថ្ងៃនេះ ។

ខ្ញុំគិតថា រឿងនេះស្រដៀងទៅនឹងអ្វីដែលទើបតែកើតឡើងនៅចក្រភពអង់គ្លេស ។ នៅទីនោះមានរដ្ឋាភិបាលរួបរួមគ្នារវាងគណបក្សអភិរក្ស និងប្រជាធិបតេយ្យ ។ នេះមានន័យថា ដេវីឌ ខេមឺរូន រដ្ឋមន្ត្រីម្នាក់មកពីបក្សមួយអាចធ្វើការជាមួយ នីក គ្លេច ឧបនាយករដ្ឋមន្ត្រីដែលមកពីគណបក្សផ្សេងទៀត ។ ហើយអ្នកទាំងពីរនេះបានធ្វើការសម្រេចចិត្តដ៏លំបាកដើម្បីប្រទេសជាតិជាមួយគ្នា ។ ដូច្នេះខ្ញុំគិតថាអ្វីដែលយើងត្រូវគិតនៅក្នុងចិត្ត គឺនយោបាយមិនអាចបញ្ចប់ដោយខ្លួនឯងបានទេ ប៉ុន្តែយើងអាចបញ្ចប់នយោបាយដើម្បីអភិវឌ្ឍ ជីវិតរបស់ប្រជាជនយើង ។ (ទះដៃ)

ចុះចំណែកបុរសម្នាក់ដែលអង្គុយនៅក្រោយ? ចាស៎! គឺអ្នកដែលពាក់វ៉ែនតា និងអាវខៀវ ។ វាប្រហែលជាត្រូវចំណាយពេលយូរបន្តិចដើម្បីយកមេក្រូឲ្យគាត់ ។

***សំណួរ*** ៖ ជាបឋម ខ្ញុំចង់និយាយពាក្យសួស្តីដល់លោកស្រីដែលមកពី (ស្តាប់មិនច្បាស់) ។ ខ្ញុំចង់សួរសំណួរថាតើលោកស្រីមានទស្សនៈអ្វីទាក់ទងនឹងការស្នើរបស់ប្រទេសកម្ពុជាឲ្យសហរដ្ឋអាមេរិកលុបចោលនូវបំណុល ។

***លោកស្រី ក្លីនតុន*** ៖ ខ្ញុំមិនប្រាកដថាខ្ញុំអាចយល់សំណួរនេះបានទេ ។

***សំណួរ*** ៖ ខ្ញុំមានន័យថា ខ្ញុំចង់បានយោបល់របស់លោកស្រីអំពីប្រទេសកម្ពុជាស្នើឲ្យលុបបំបាត់បំណុល ។

***ពិធីករ*** ៖ លោកស្រី នេះមានន័យថាគឺការលុបបំបាត់បំណុល ។

***លោកស្រី ក្លីនតុន*** ៖ បំណុល?

***ពិធីករ*** ៖ បាទ

***លោកស្រី ក្លីនតុន*** ៖ បំណុលចាស់? ចំពោះបំណុលចាស់ ខ្ញុំបានរៀបចំនឹងចាប់ផ្តើមដំណើរការជាមួយរដ្ឋាភិបាលដើម្បីដោះស្រាយនឹងបញ្ហានេះ ។ ដូច្នេះ ខ្ញុំជឿថាវាគឺជាការព្រួយបារម្ភមួយ ។ វាគឺជាការព្រួយបារម្ភរបស់ខ្ញុំមួយដែរ ។ ដូច្នេះនៅពេលដែលខ្ញុំជួបជាមួយនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងមន្ត្រីក្រសួងការបរទេស ខ្ញុំនឹងស្នើឲ្យមានការពិភាក្សាម្តងទៀត ។ យើងមិនបានបន្តពិភាក្សាពីរឿងនេះចាប់តាំងពីឆ្នាំ២០០៦ ដូច្នេះយើងចង់ពិភាក្សាម្តងទៀតដើម្បីដោះស្រាយពីរឿងនេះ ពីព្រោះខ្ញុំចង់ឲ្យកម្ពុជាវិនិយោគថវិការដ្ឋាភិបាលដើម្បីអភិវឌ្ឍសេវាបម្រើប្រជាជនកម្ពុជា ។

ចាស៎! អ្នកដែលអង្គុយនៅគាច់ជ្រុង ។ ចាស៎! អ្នកដែលអង្គុយនៅច្រកដើរ ។ ចាស៎! គឺបុរសម្នាក់នោះ ។ ចាស៎! គឺបុរសពាក់អាវខៀវ ។

***សំណួរ*** ៖ សួស្តី លោកស្រី ។ ខ្ញុំឈ្មោះ (មិនច្បាស់សំឡេង) ជានាយកប្រតិបត្តិសេរីភាពកម្ពុជា ។ យើងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយកម្ពុជា ដូច្នេះខ្ញុំធ្លាប់ដឹងច្រើនថាលោកស្រី មានការព្រួយបារម្ភចំពោះប្រទេសកម្ពុជា (ចំពោះស្តាប់មិនច្បាស់) បញ្ហាកម្មវិធីនៅកម្ពុជា

សូម្បីតែ (មិនឮសំឡេង) ។ ដូច្នេះ សំណួរខ្ញុំគឺថា តើលោកស្រីមានយោបល់អ្វី (ឬមិនឮសំឡេង) ចំពោះការជួយដល់ប្រជាជនកម្ពុជា ឧទាហរណ៍ដូចជាការសេពគ្រឿងញៀនឬ (មិនឮសំឡេង) ក្មេង (មិនឮសំឡេង) ។ ដូច្នេះ (មិនឮសំឡេង) តើអ្វីគឺជាការព្រួយបារម្ភរបស់អាមេរិកចំពោះកម្ពុជា? អរគុណ ។

***លោកស្រី គ្លីនតុន*** ៖ ហេតុផលមួយដែលធ្វើឲ្យខ្ញុំមកដល់ទីនេះគឺប្រធានាធិបតី អូបាម៉ា និងខ្ញុំមានការព្រួយបារម្ភចំពោះប្រជាជនកម្ពុជា ។ យើងបានចំណាយថវិការាប់លានដុល្លារ ដើម្បីជួយដល់គម្រោងជួយដល់ប្រជាជននៅកម្ពុជា ។ ខ្ញុំចង់ដឹងថាតើយើងអាចធ្វើអ្វីឲ្យវាប្រសើរជាងនេះ? តើយើងអាចធ្វើដូចម្ដេចដើម្បីជួយដល់រដ្ឋាភិបាលកម្ពុជា បុគ្គល ស្ថាប័នផ្សេងៗនៅកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល? យើងអាចអង្គុយនៅសហរដ្ឋអាមេរិកហើយនិយាយថា យើងត្រូវតែជួយកម្ពុជាដោះស្រាយបញ្ហាអេដស៍ និងតម្រូវសាលារៀននៅតំបន់ដាច់ស្រយាល ឬការបណ្ដុះបណ្ដាលគ្រូបង្រៀន ។ នៅអាមេរិក យើងអាចបង្កើតគំនិតច្រើនអំពីរបៀបនៃការជួយដល់ប្រជាជនកម្ពុជា ប៉ុន្តែវានឹងមានលក្ខណៈប្រសើរជាងនេះប្រសិនបើយើងឮពីប្រជាជនកម្ពុជា និងរដ្ឋាភិបាលកម្ពុជាថាតើអ្វីគឺចំណុចអត្ថិភាពដោយផ្ទាល់ ។

ដូច្នេះ អ្វីដែលខ្ញុំកំពុងតែធ្វើនេះគឺនិយាយជាមួយរដ្ឋាភិបាល និងអ្នកដទៃទៀត ។ ឯកអគ្គរដ្ឋទូតរបស់យើងបានមកជួបជាមួយប្រជាជនកម្ពុជាដើម្បីស្វែងយល់ថាតើយើងអាចធ្វើអ្វីដ៏ល្អបំផុតដើម្បីជួយ ។ យើងនឹងព្យាយាមឆ្លើយតបគ្រប់បែបយ៉ាង ។ ហើយចំពោះបញ្ហាបំណុលដែលអ្នកទាំងពីរបានលើកឡើងគឺជាបញ្ហាដែលខ្ញុំនឹងដោះស្រាយ ពីព្រោះខ្ញុំបានឮពីបញ្ហានេះនៅកម្ពុជាផ្ទាល់ ។

***សំណួរ*** ៖ សួស្ដី លោកស្រីរដ្ឋមន្ត្រីក្រសួងការបរទេស ។ ខ្ញុំស្ដាប់ (មិនឮ) ខ្ញុំមកពី (មិនឮសំឡេង) ។ ដូច្នេះខ្ញុំចង់សួរលោកស្រីពីរសំណួរ ខ្ញុំគិតថាវាមានបញ្ហាលំបាកជាច្រើន ដូច្នេះខ្ញុំចង់ដឹងពីវិធីសាស្ត្រដើម្បី (មិនឮសំឡេង) និងវិធីសាស្ត្រដើម្បីឈ្នះ (មិនឮសំឡេង) នៅក្នុងកិច្ចចរចា ។

***លោកស្រី គ្លីនតុន*** ៖ ខ្ញុំមិនយល់សំណួរទេ ។

***ពិធីការ*** ៖ គាត់ចង់ដឹងពីវិធីសាស្ត្ររបស់លោកស្រីដើម្បីយកឈ្នះនៅក្នុងការជជែកពិភាក្សា និងការចរចា ។

***លោកស្រី គ្លីនតុន*** ៖ នៅក្នុងស្ថានភាពទូទៅ? ទូទៅ?

***សំណួរ*** ៖ រឿងសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នក (ស្ដាប់មិនឮ) ។

***លោកស្រី គ្លីនតុន*** ៖ ការអនុវត្តច្រើន ។ តើអ្នកធ្លាប់ដឹងទេថាមនុស្សច្រើននៅក្នុងពិភពលោកមានការភ័យខ្លាចចំពោះការនិយាយជាសាធារណៈជាជាងការដែលត្រូវបានគេធ្វើបាបដោយបទល្មើសណាមួយ ឬស្លាប់នៅក្នុងភ្នក់ភ្លើង? មនុស្សជាច្រើនមានការភ័យខ្លាចចំពោះការឈរនៅពីមុខក្រៃលែងមាន មនុស្សជាច្រើន និងនិយាយ ។ តើមានអ្នកណាខ្លះធ្លាប់មានអារម្មណ៍បែបនេះទេ? វាគឺជាអ្វីមួយនៅក្នុងជីវិតរបស់យើង ។ ប្រសិនបើអ្នកទាំងអស់គ្នាចង់ធ្វើបែបនេះ អ្នកទាំងអស់គ្នាត្រូវតែអនុវត្ត និងដាក់បន្ទុកឲ្យគ្រួសារ និងមិត្តភក្តិ ដូច្នេះអ្នកទាំងនោះអាចធ្វើការរិះគន់ល្អៗ និងរិះគន់ដើម្បីស្ថាបនា ។

ហើយចំពោះកិច្ចចរចា ខ្ញុំគិតថាវាមានសារសំខាន់ណាស់ដែលយើងត្រូវដឹងពីតួនាទីរបស់អ្នកដទៃ ។ នៅពេលដែលអ្នកចរចាជាមួយនរណាម្នាក់ ហើយអ្នកគិតតែពីអ្វីដែលអ្នកចង់បាននោះ អ្នកនឹងមិនដឹងថាអ្នកដទៃចង់បានអ្វីទេ ។ ដូច្នេះអ្នកទាំងអស់គ្នាត្រូវតែស្វែងយល់ពីចិត្តអ្នកដទៃ នេះគឺជាពាក្យចាស់ៗ ។ ខ្ញុំព្យាយាមចរចាអំពីវា ហើយអ្នកដទៃក៏ចង់បានអ្វីមួយពីខ្ញុំ ។ តើយើងត្រូវធ្វើដូចម្ដេចដើម្បីសម្រេចបានយុត្តិសាស្ត្រឈ្នះ-ឈ្នះ? តើយើងត្រូវធ្វើដូចម្ដេច ដើម្បីសម្រេចបានលទ្ធផលមួយដែលធ្វើឲ្យយើងទាំងអស់គ្នាសុទ្ធតែទទួលបានការចរចាដ៏ជោគជ័យមួយ?

ពេលខ្លះវាមិនអាចទៅរួចទេ ប៉ុន្តែភាគច្រើនយើងអាចសម្រេចវាបានដែរ ។ យើងគ្រាន់តែត្រូវអនុវត្តច្រើន ។ វាមិនមានការធ្វើអ្វីកាត់កាត់ឲ្យខ្លីទេ ។ ហើយប្រសិនបើអ្នកចាប់អារម្មណ៍នឹងជីវិតសាធារណៈ ការនិយាយជាសាធារណៈ ការជជែកពិភាក្សា ឬការ

បរចា អ្នកត្រូវអានសៀវភៅច្រើនទាក់ទងនឹងវា មើលទូរទស្សន៍ ស្វែងរកព័ត៌មានពីមនុស្សជាច្រើន បន្ទាប់មកអនុវត្តន៍ ។ អ្នកត្រូវចាប់ផ្តើមពីជំហានដំបូង បន្ទាប់មកដើរឲ្យលឿនពីមួយជំហានៗ ។ ហើយខ្ញុំសង្ឃឹមថាអ្នកនឹងដំណើរការល្អប្រសិនបើអ្នកចង់ធ្វើវា ។

ចាស៎! អ្នកដែលនៅកាច់ជ្រុង ក្មេងស្រីម្នាក់ដែលនៅខាងចុង ។ ចាស៎!

***សំណួរ*** ៖ (ស្តាប់មិនឮ)

***លោកស្រី គ្លីនតុន*** ៖ រង់ចាំបន្តិច ខ្ញុំមិនឮទេ ។ និយាយដាក់មីក្រូ ។

***សំណួរ*** ៖ ខ្ញុំឈ្មោះ (មិនឮសំឡេង) សិស្សមកពីវិទ្យាស្ថាន (មិនឮសំឡេង) សេដ្ឋកិច្ច ។ ខ្ញុំគិតថា ខ្ញុំសួរសំណួរដែលលោកស្រីនិយាយថាតម្រូវការជាអត្ថិភាពដំបូងគេគឺការអភិវឌ្ឍសេដ្ឋកិច្ច ដូច្នេះខ្ញុំចង់សួរទៅកាន់លោកស្រីថា តើសហរដ្ឋអាមេរិកមានផែនការអនាគតធ្វើអ្វីខ្លះដើម្បីគាំទ្រប្រទេសកម្ពុជា ជាពិសេសការវិនិយោគ?

***លោកស្រី គ្លីនតុន*** ៖ វិនិយោគ វិនិយោគខាងបរទេស?

***សំណួរ*** ៖ ចាស៎! ខាងបរទេស (សំឡេងទះដៃ) អរគុណ ។ ខ្ញុំសរសើរលោកស្រីខ្លាំងណាស់ ។

***លោកស្រី គ្លីនតុន*** ៖ អរគុណ ។ អរគុណ ។ សហរដ្ឋអាមេរិកនឹងផ្តល់ជំនួយឲ្យរដ្ឋាភិបាល ដើម្បីជួយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែវិធីប្រសើរបំផុតដើម្បីអភិវឌ្ឍគឺទាក់ទាញការវិនិយោគបរទេស ។ សម្រាប់អ្នកវិនិយោគបរទេសមកប្រទេសកម្ពុជា អ្នកទាំងនោះចង់មានប្រព័ន្ធច្បាប់ការពារការវិនិយោគគេ ការពារកិច្ចសន្យារបស់ខ្លួន ។ អ្នកវិនិយោគត្រូវតែជឿថាអំពើពុករលួយនឹងមិនរារាំងដល់លទ្ធភាពនៃការវិនិយោគ និងការផ្តល់ផលចំណេញល្អដល់ការវិនិយោគនោះទេ ។ ការធ្វើឲ្យពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាប្រសើរឡើង គឺជាគន្លឹះសំខាន់ដែលអាចទាក់ទាញវិនិយោគបរទេស ។

ឥឡូវនេះ ខ្ញុំគិតថា វិស័យទេសចរគឺជាឱកាសយ៉ាងល្អមួយសម្រាប់ការវិនិយោគបរទេស ។ ប្រេង និងឧស្ម័នដែលមាននៅតំបន់សមុទ្រគឺជាអ្វីដែលត្រូវរុករក ហើយវាតម្រូវឲ្យមានការប្រកួតប្រជែងច្រើន ទើបធ្វើឲ្យប្រទេសកម្ពុជាអាចដោះស្រាយបានល្អ ។ មានឱកាសកសិកម្មជាច្រើនសម្រាប់ធ្វើការជាមួយកសិដ្ឋានខ្នាតតូច និងមធ្យម ។ មានក្រុមហ៊ុនវាយនភណ្ឌជាច្រើន ។ សហរដ្ឋអាមេរិកគឺជាអតិថិជនខាងវាយនភណ្ឌដ៏ធំរបស់ប្រទេសកម្ពុជា ។ ប្រសិនបើអ្នកត្រឡប់ទៅមើលក្រោយនិងសិក្សាពីទសវត្សរ៍ឆ្នាំ៨០ និង៩០ សហរដ្ឋអាមេរិកនិងកម្ពុជាបានធ្វើការជាមួយគ្នាដើម្បីធ្វើឲ្យលក្ខខណ្ឌការងាររបស់កម្មករ នៅក្នុងរោងចក្រវាយនភណ្ឌប្រសើរជាងមុន ដែលធ្វើឲ្យវាយនភណ្ឌដែលផលិតនៅកម្ពុជាអាចនាំចេញទៅកាន់ទីផ្សាររបស់សហរដ្ឋអាមេរិកនិងប្រជាជនសហរដ្ឋអាមេរិកនឹងគិតថាវាល្អក្នុងការទិញអាវ ឬខោពីព្រោះវា អាចធ្វើឲ្យប្រជាជនកម្ពុជាយល់ថាខ្លួនត្រូវបានគេយកចិត្តដាក់នៅក្នុងប្រទេសផ្សេងទៀត ។ ដូច្នេះប្រទេសកម្ពុជាបានធ្វើការនាំចេញយ៉ាងច្រើនទៅសហរដ្ឋអាមេរិកពីព្រោះអតិថិជនសហរដ្ឋអាមេរិកយល់ស្របនឹងគំនិតនៃភាពជាដៃគូនេះ ។

ដូច្នេះ យើងនិងវិស័យឯកជនរបស់យើងនឹងធ្វើការដើម្បីស្វែងរកនូវវិធីថ្មី ដើម្បីជំរុញឲ្យមានការវិនិយោគបរទេស ។ ខ្ញុំគិតថាប្រទេសកម្ពុជានឹងមានទីផ្សារ ដែលអាចទាក់ទាញវិនិយោគបរទេស ។ យើងបាននិងកំពុងជួបប្រទះនឹងបញ្ហាពិភពលោក ដូច្នេះវាមិនមែនជាឆ្នាំល្អនោះទេ ប៉ុន្តែយើងនឹងធ្វើឲ្យដូចដើម ហើយនៅពីរ-បីឆ្នាំខាងមុខ ខ្ញុំគិតថាអ្នកនឹងឃើញការវិនិយោគបរទេសកាន់តែច្រើន ដោយសន្មតថាអ្វីៗទាំងអស់នៅក្នុង ប្រទេសកម្ពុជានឹងបន្តដំណើរការអភិវឌ្ឍពីបច្ចុប្បន្នទៅ ។ (សំឡេងទះដៃ)

យើងនៅចាំមើលទាំងអស់គ្នា ។ មានដៃច្រើនណាស់ ខ្ញុំពិតជាមិនចង់ទុកចោលនរណាម្នាក់ទេ ។ សូមឲ្យបុរសក្មេងម្នាក់នោះដែលឈរនៅជាប់ជញ្ជាំង ។ ខ្ញុំស្ទើរតែមើលមិនឃើញអ្នក ប៉ុន្តែខ្ញុំឃើញដោយសារតែអ្នកកំពុងតែឈរ ។

***សំណួរ*** ៖ ខ្ញុំចង់បង្ហាញពីការគោរពដ៏ជ្រាលជ្រៅ (ស្តាប់មិនឮ) ដល់រដ្ឋមន្ត្រីក្រសួងការបរទេស ។ ខ្ញុំឈ្មោះ (មិនឮសំឡេង) ជានិស្សិតដែលរៀនផ្នែកទំនាក់អន្តរជាតិនៅសាកលវិទ្យាល័យស្តាប់មិនឮ) ។ ខ្ញុំចង់ដឹងថាកាលពីមុន ប្រធានាធិបតី ប៊ូស មិនដែលយកចិត្តទុកដាក់ទៅលើតំបន់អាស៊ានទេ គាត់គិតតែពីអ៊ីរ៉ាក់ និងអាហ្វហ្គានីស្ថាន ។

***លោកស្រី គ្លីនតុន*** : *នេះគឺជាសំណួរដ៏គួរឲ្យចាប់អារម្មណ៍មួយ ។*

***សំណួរ*** : *ប៉ុន្តែ ឥឡូវមានប្រធានាធិបតីដែលរឹងមាំ មានយកការចិត្តទុកដាក់ទៅលើតំបន់អាស៊ី ។ តើអ្វីជាហេតុផលសំខាន់ដែលធ្វើឲ្យប្រធានាធិបតីដ៏រឹងមាំនេះយកចិត្តទុកដាក់ទៅលើតំបន់នេះ?*

***លោកស្រី គ្លីនតុន*** : *ចាំខ្ញុំឆ្លើយនឹងសំណួរនេះ ។ នៅពេលដែលខ្ញុំក្លាយទៅជារដ្ឋមន្ត្រីក្រសួងការបរទេស ខ្ញុំមានការព្រួយបារម្ភចំពោះប្រជាជននៅតំបន់អាស៊ីមិនជឿថា សហរដ្ឋអាមេរិកបានយកចិត្តទុកដាក់នឹងខ្លួនដូចមុន ដូចដែលអ្នកនិយាយទេ ។ ដូច្នេះដំហានដំបូងបង្អស់របស់ខ្ញុំគឺអាស៊ី ។ នេះគឺជាដំណើរទស្សនកិច្ចលើកទី៦ នៃដំណើរ២០ ខែមកកាន់អាស៊ីរបស់ខ្ញុំ ។ ដំហានដំបូង ខ្ញុំបានទៅដល់ឥណ្ឌូនេស៊ី គឺខ្ញុំទៅចាកាតា ដែលជាទីបញ្ជាការអាស៊ាន ហើយខ្ញុំក៏បាននិយាយថា សហរដ្ឋអាមេរិកចង់ចូលរួមយ៉ាងសកម្មនឹងអាស៊ាន ហើយនៅក្រោមការគ្រប់គ្រងរបស់ប្រធានាធិបតី អូបាម៉ា សហរដ្ឋអាមេរិកបានចុះហត្ថលេខាលើអនុសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ ។ ខ្ញុំទើបតែមកពីហាណូយដែលជាលើកទីមួយ ដែលសហរដ្ឋអាមេរិកបានចូលរួមនឹងកិច្ចប្រជុំអាស៊ីបូព៌ា ពីព្រោះយើងចង់ធ្វើការជាមួយមិត្តភក្តិអាស៊ីដើម្បីដោះស្រាយទៅលើបញ្ហាទាំងនេះ ។*

*ដូច្នេះប្រសិនជាមានការព្រួយបារម្ភ ឬទស្សនៈអ្វីចំពោះអតីតកាល ខ្ញុំសង្ឃឹមថាយើងនឹងលុបបំបាត់វាចោល ពីព្រោះខ្ញុំនិងប្រធានាធិបតី អូបាម៉ា មានឆន្ទៈចង់ធ្វើការជាមួយអាស៊ី ។ តាមការពិតនៅចុងសប្តាហ៍នេះ ប្រធានាធិបតី អូបាម៉ា នឹងបន្តធ្វើដំណើរទៅឥណ្ឌា កូរ៉េខាងត្បូង ជប៉ុន និងឥណ្ឌូនេស៊ី ។ ខ្ញុំនឹងបន្តដំណើរពីកម្ពុជាទៅម៉ាឡេ ប៉ាប៉ូញ៉ូវហ្គីណេ ញ៉ូវហ្សឺឡែន និងអូស្ត្រាលី ។ ដូច្នេះយើងកំពុងតែបន្ថែមថាមពលយ៉ាងខ្លាំងដើម្បីគ្របដណ្តប់ទៅលើមូលដ្ឋានអាស៊ីដើម្បីបង្ហាញថា អាមេរិកមានឆន្ទៈធ្វើការជាមួយមិត្តនៅអាស៊ី យើងមានឆន្ទៈធ្វើការជាមួយប្រជាជនអាស៊ី ដើម្បីឲ្យអ្នកទាំងនោះដឹងពីសក្តានុពលរបស់ខ្លួន ហើយសហរដ្ឋអាមេរិកនឹងបង្ហាញខ្លួនកាន់តែច្រើននៅក្នុងតំបន់នេះនៅពេលអនាគត ។ អរគុណ!*

*អ៊ូ នារីម្នាក់នោះ ។ ចាស៎!*

***សំណួរ*** : *សួស្តី រដ្ឋមន្ត្រីក្រសួងការបរទេស គ្លីនតុន ។ ខ្ញុំពិតជាមានសេចក្តីរំភើបណាស់ ដែលលោកស្រីអនុញ្ញាតឲ្យខ្ញុំសួរសំណួរ*




***លោកស្រី ហ៊ីលឡារី គ្លីនតុន និយាយទៅកាន់យុវជនកម្ពុជា***

លោកស្រី ។ ខ្ញុំមានសំណួរពីរ ប៉ុន្តែជាបឋមខ្ញុំសូមណែនាំខ្លួនខ្ញុំបន្តិច ។ ខ្ញុំមកពី(មិនឮសំឡេង) ហើយខ្ញុំ (មិនឮសំឡេង) មានសំណួរពីរសួរលោកស្រី ។ សំណួរទីមួយគឺ តើលោកស្រីមានទស្សនៈអ្វីចំពោះបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ ។ ហើយទីពីរគឺ តើលោកស្រីជួបប្រទះនឹងឧបសគ្គអ្វីខ្លះមុននឹងលោកស្រីក្លាយទៅជារដ្ឋមន្ត្រីក្រសួងការបរទេស?

***លោកស្រី គ្លីនតុន*** ៖ *អរគុណ ។ តើសំណួរទីមួយរបស់អ្នកគឺជាអ្វី?*

***ពិធីការ*** ៖ *លោកស្រី គឺកម្ពុជា*

***លោកស្រី គ្លីនតុន*** ៖ *អូ៎ គឺកម្ពុជា*

***សំណួរ*** ៖ *អរគុណ!*

***លោកស្រី គ្លីនតុន*** ៖ *ខ្ញុំគិតថាវាគឺជាបញ្ហាដែលកម្ពុជានិងថៃត្រូវតែដោះស្រាយ ។ ខ្ញុំគិតថា ការដោះស្រាយបញ្ហាព្រំដែនគឺជាផលប្រយោជន៍ប្រយោជន៍របស់ប្រទេសទាំងពីរ ដូច្នេះខ្ញុំសង្ឃឹមថានឹងមានកិច្ចខំប្រឹងប្រែងសាជាថ្មីដើម្បីដោះស្រាយវាម្តងទៀត ។ ហើយខ្ញុំនឹងជំរុញប្រទេសទាំងពីរឲ្យធ្វើការជាមួយគ្នាដើម្បីដោះស្រាយនូវបញ្ហាព្រំដែន ។*

*ហើយចំពោះបញ្ហាកិច្ចចរចាវិញ យើងត្រូវស្វែងរកមធ្យោបាយខ្លះដើម្បីបំបែកបញ្ហា គឺយើងត្រូវស្វែងរកដំណោះស្រាយឈ្នះ-ឈ្នះ ដែលអាចធានាឲ្យព្រំដែនមានសន្តិភាព ហើយជំនួញពាណិជ្ជកម្ម និងទេសចរណ៍នឹងដំណើរការល្អដូចដើម ។ វាគឺជាការល្អដែរ ប្រសិនបើជម្លោះនោះអាចដោះស្រាយបាន ពីព្រោះនៅពេលដែលខ្ញុំដើរទស្សនាប្រាសាទដ៏ប្រណីតកាលពីម្សិលមិញ មានមនុស្សមួយចំនួនរួមទាំងមគ្គុទ្ទេសក៍បានប្រាប់ខ្ញុំថា មិនមានមនុស្សទៅទស្សនាប្រាសាទទៀតទេពីព្រោះវាមានជម្លោះ ភាគីទាំងពីរសុទ្ធតែអាចស្វែងរកចំណូលបាន ខ្ញុំសង្ឃឹមថានឹងអាចដោះស្រាយបាន ។*

*ចំពោះលេខាធិការក្រសួងការបរទេស វាគឺការងារដ៏អស្ចារ្យមួយ ។ វាពិតជាការងារដ៏អស្ចារ្យ ពីព្រោះខ្ញុំត្រូវធ្វើការងារដ៏សំខាន់និងលំបាក ។ ខ្ញុំត្រូវតែតំណាងឲ្យប្រទេសយើង ហើយខ្ញុំត្រូវតែមកប្រទេសដូចជាកម្ពុជាដើម្បីនិយាយជាមួយប្រជាជនផ្ទាល់ ។ ដូច្នេះចំពោះខ្ញុំ វាគឺជាការងារដ៏មានន័យមួយ ។ វាលំបាក ។ ប៉ុន្តែយើងត្រូវតែធ្វើវា ។ ខ្ញុំដឹងថា ខ្ញុំប្រហែលជាមិនអាចគេងគ្រប់គ្រាន់ទេ ប៉ុន្តែ*


ក្រុមយុវជនកម្ពុជាស្តាប់លោកស្រី ហ៊ីលឡារី គ្លីនតុន ថ្លែងសុន្ទរកថានៅក្នុងសាលសន្និសីទចតុមុខ

ខ្ញុំមានមោទនភាពនឹងធ្វើវាជាមួយប្រធានាធិបតី អូបាម៉ា ។ អរគុណ (សំឡេងទះដៃ)

ចាស៎! បុរសម្នាក់នៅផ្លូវដើរ ។ ហ្នឹងហើយ ចាស៎! ។

សំណួរ ៖ សួស្តី លោកស្រីរដ្ឋមន្ត្រីក្រសួងការបរទេស ។ ខ្ញុំ (មិនឮសំឡេង) ជានិស្សិតនៅមិនឮសំឡេង) នៅក្នុងខេត្ត (មិនឮសំឡេង) ។ នៅថ្ងៃនេះ ខ្ញុំពិតជាមានមោទនភាពចំពោះខ្លួនឯងដែលបានមកទីនេះនិងសួរសំណួរលោកស្រី ។ ខ្ញុំដឹងថាអាមេរិកបានជួយកម្ពុជាច្រើនទៅលើវិស័យអប់រំ ដូច្នេះសំណួររបស់ខ្ញុំគឺថាតើអាមេរិកមានគោលនយោបាយដូចម្តេចក្នុងការជួយកម្ពុជាទៅលើវិស័យអប់រំ? អរគុណ!

**លោកស្រី គ្លីនតុន ៖** ជួយកម្ពុជា

**សំណួរ ៖** ខ្ញុំដឹងថាអាមេរិកបានជួយកម្ពុជាច្រើនទៅលើវិស័យអប់រំ ។

**លោកស្រី គ្លីនតុន ៖** ចាស៎!

**សំណួរ ៖** (មិនឮសំឡេង) អាហារូបករណ៍ដល់សិស្សនិងនិស្សិតកម្ពុជា ។ ដូច្នេះសំណួររបស់ខ្ញុំគឺថា តើអាមេរិកមានគោលនយោបាយដូចម្តេចក្នុងការជួយប្រជាជនកម្ពុជាឲ្យរៀនបន្ថែម? អរគុណ!

**លោកស្រី គ្លីនតុន ៖** ខ្ញុំមានយោបល់ខ្លះ ហើយខ្ញុំគិតថាអ្នកនឹងអនុញ្ញាតឲ្យខ្ញុំ ឬស្ថានទូត ឬស្ថាប័នអាមេរិកផ្សេងទៀតជួយ ។ មានន័យថា យើងចង់ឲ្យមានការផ្លាស់ប្តូរ ការសិក្សាច្រើនជាងមុន ដូច្នេះសិស្សនិស្សិតនៅកម្ពុជាអាចទៅសហរដ្ឋអាមេរិកបាន ។ យើងចង់ឲ្យមានអ្នកទៅអាមេរិកច្រើនជាងមុន ដូច្នេះទើបប្រជាជនកម្ពុជាដែលធ្វើការនៅផ្នែកដូចជា សុខាភិបាល ឬអប់រំ អាចទៅអាមេរិកនិងស្វែងយល់ពីស្ថាប័នយើង ។ យើងចង់ឲ្យមានកម្មវិធីអាហារូបករណ៍ច្រើនជាងមុន ដូច្នេះប្រសិនបើអ្នកបម្រើការងារឲ្យរដ្ឋាភិបាលកម្ពុជា អ្នកអាចទៅអាមេរិក ហើយសិក្សាពីសភា ឬការងាររបស់រដ្ឋាភិបាលរបស់យើង ។ យើងនឹងពង្រីកកម្មវិធីផ្លាស់ប្តូរគ្រប់បែបយ៉ាង ។ យើងក៏ចង់ឲ្យមានមហាវិទ្យាល័យអាមេរិកច្រើនជាងមុន ដំណើរការនៅក្នុងប្រទេសកម្ពុជា ដូច្នេះសិស្សដែលមិនអាចទៅអាមេរិកក៏អាចរៀនពីកម្មវិធីបែបនេះបានដែរ ។ យើងចង់ធ្វើការជាច្រើនដើម្បីជួយដល់កម្ពុជា ជាពិសេសក្មេងៗឲ្យរៀនភាសាអង់គ្លេស ។ ខ្ញុំពិតជារំភើបដែលអ្នកទាំងអស់គ្នាសួរសំណួរខ្ញុំជាភាសាអង់គ្លេសទាំងអស់ ខ្ញុំចង់ជួយក្មេងៗកម្ពុជាឲ្យរៀនភាសាអង់គ្លេស ។ ដូច្នេះយើងនឹងស្វែងរកមធ្យោបាយដើម្បីបង្កើនគ្រូបង្រៀនភាសា អង់គ្លេស និងឱកាស ។

ដូច្នេះទាំងនេះគឺជាមធ្យោបាយខ្លះ ។ ហើយខ្ញុំគិតថាការវិនិយោគទៅលើមហាវិទ្យាល័យនៅកម្ពុជាដើម្បីជួយឲ្យកម្មវិធីសិក្សាសម្ភារ បច្ចេកទេស កាន់តែប្រសើរជាងមុនមានសារសំខាន់ណាស់ ហើយយើងនឹងធ្វើបែបនេះ ។

ប៉ុន្តែការផ្លាស់ប្តូរខ្លាំងបំផុតដែលអ្នកទាំងអស់គ្នាក៏ដឹងគឺបច្ចេកវិទ្យា ដោយប្រើប្រាស់ទូរសព្ទចល័ត ដូចជា អាយហ្វូន ឬអាយផេត ឬកុំព្យូទ័រ អ្នកអាចភ្ជាប់នឹងប្រព័ន្ធអ៊ីនធឺណែតបាន ។ អ្នកអាចភ្ជាប់ទំនាក់ទំនងជាមួយពិភពលោកទាំងមូល ។ សហរដ្ឋអាមេរិកចង់ដាក់កម្មវិធីច្រើនជាងនេះនៅ ក្នុងប្រព័ន្ធបណ្តាញដែលអាចជួយដល់ប្រជាជនក្មេងៗនៅកម្ពុជា ។ ដូច្នេះ យើងបានរិះរកគ្រប់គំនិតទាំងអស់ ។ ប្រសិនបើអ្នកមានគំនិតអ្វី អ្នកអាចប្រាប់យើងបាន ។ ជាឧទាហរណ៍ យើងទើបតែបញ្ចប់ការងារជាមួយសហគ្រិននៅអាហ្វ្រិក ។ យើងបានឧបត្ថម្ភកម្មវិធីប្រកួតប្រជែងពីរបៀបប្រើប្រាស់ទូរស័ព្ទចល័តដើម្បីបង្កើនផលិតភាពកសិកម្ម ។ ប្រសិនបើអ្នកប្រើប្រាស់ទូរស័ព្ទចល័ត អ្នកអាចទទួលបានការព្យាករណ៍អាកាសធាតុប្រសើរជាងមុន អ្នកអាចដឹងពីព័ត៌មានទាក់ទងនឹងតម្លៃនៃគ្រាប់ពូជនិងជី អ្នកអាចទំនាក់ជាមួយពេទ្យសត្វអំពីអ្វីដែលកើតឡើងមិនប្រក្រតីចំពោះគោក្របីរបស់អ្នក ទោះបីជាអ្នកនៅតំបន់ដាច់ស្រយាលក៏ដោយ ។ យើងអាចប្រើប្រាស់បច្ចេកវិទ្យាមកជួយសម្រួលដល់ការងាររបស់យើងជាច្រើន ដូច្នេះសហរដ្ឋអាមេរិកក៏ចង់ធ្វើការជាមួយស្ថាប័ននៅកម្ពុជាដើម្បីជួយដល់កម្ពុជាដែរ ។

ដូច្នេះវាមានគំនិតជាច្រើនទាក់ទងនឹងការអប់រំ គឺមិនមែនមានតែការអប់រំនៅក្នុងបន្ទប់រៀនប៉ុណ្ណោះទេ វាមានការអប់រំគ្រប់

របៀបយ៉ាងដែលយើងកំពុងតែស្វែងរកដើម្បីធ្វើការជាមួយអ្នក ។ (សំឡេងទះដៃ)

**ពិធីការ ៖** លោកស្រី ខ្ញុំជឿថាយើងមានពេលសម្រាប់តែសំណួរមួយទៀតប៉ុណ្ណោះ ។

**លោកស្រី គ្លីនតុន ៖** បានតែសំណួរមួយ ប៉ុន្តែមើលទៅសុទ្ធតែដៃ ។ ខ្ញុំអាចឆ្លើយនឹងសំណួរមនុស្សម្នាក់ទៀតប៉ុណ្ណោះ ដូច្នេះប្រសិនបើអ្នកផ្សេងទៀតមិនទាន់សួរ អ្នកអាចយកសំណួរទៅដាក់នៅស្ថានទូត យើងនឹងឆ្លើយវា ។

ចាស់! ស្ត្រីក្មេងម្នាក់នៅទីនោះ ។ ចាស់!

**សំណួរ ៖** សួស្តី លោកស្រីរដ្ឋមន្ត្រីក្រសួងការបរទេស ។ ខ្ញុំឈ្មោះ (មិនឮសំឡេង) ខ្ញុំមកពី (មិនឮសំឡេង) ។ ខ្ញុំជានិស្សិតឆ្នាំទីបីនៅ (មិនឮសំឡេង) ។ ខ្ញុំមានសំណួរមួយចង់សួរលោកស្រី (មិនឮសំឡេង) គឺថាកម្ពុជាមានបញ្ហាជាច្រើន ដូចជាអំពើពុករលួយ ភាពក្រីក្រ ឬអំពើហិង្សាផ្សេងៗ ដូច្នេះសំណួររបស់ខ្ញុំគឺថាខ្ញុំចង់ឲ្យលោកស្រីបង្ហាញថា ប្រសិនបើលោកស្រីគឺជាមេដឹកនាំកម្ពុជា តើលោកស្រីមានយុត្តិសាស្ត្រ(មិនឮសំឡេង) អ្វីសម្រាប់ដោះស្រាយបញ្ហានៅកម្ពុជា(មិនឮសំឡេង) ស្ថានភាពនៅកម្ពុជា(មិនឮសំឡេង) ។ (សំឡេងទះដៃ)

លោកស្រី គ្លីនតុន ៖ វាគឺជាការពិតដែលមេដឹកនាំរបស់អ្នកត្រូវដោះស្រាយអំពីបញ្ហារបស់អ្នក ។ ខ្ញុំពិតជាមានសេចក្តីរីករាយណាស់ ដែលថ្មីៗនេះរដ្ឋាភិបាលបានអនុម័តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ច្បាប់នេះនឹងត្រូវបានអនុវត្តនិងគោរពតាម ។ អំពើពុករលួយជាបញ្ហាមួយយ៉ាងធំដែលកើតឡើងនៅលើពិភពលោក ។ ប៉ុន្តែនៅក្នុងប្រទេសកំពុងអភិវឌ្ឍដែលមានសក្តានុពលច្រើនដូចប្រទេសកម្ពុជា វាអាចកាត់បន្ថយនូវលទ្ធភាព និងមហិច្ឆតារបស់មនុស្ស ។ អ្នកខ្លះមានអារម្មណ៍ថាខ្លួនបានធ្វើការយ៉ាងនឿយហត់ ប៉ុន្តែមិនបានទទួលបានអ្វីដូចដែលបានរំពឹង នេះជាចំណុចដែលបង្កើតឲ្យមានអំពើពុករលួយ ។ ខ្ញុំសង្ឃឹមថា រដ្ឋាភិបាលនឹងបន្តធ្វើការនេះទៀត ។

ខ្ញុំក៏មានសេចក្តីរីករាយផងដែរដែលថ្មីៗនេះរដ្ឋាភិបាលរបស់អ្នកបានអនុម័តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស ។ ការជួញដូរនេះគឺជាទម្រង់នៃទាសភាពថ្មីមួយ ហើយវាបានផ្តល់ផលប៉ះពាល់ដល់មនុស្សរាប់លានអ្នកជុំវិញពិភពលោក ។ វាជាបញ្ហាដ៏គួរឲ្យរន្ធត់មួយ ។ មានន័យថា នៅពេលដែលខ្ញុំមើលឃើញអ្នកទាំងអស់គ្នា ខ្ញុំឃើញក្មេងប្រុសស្រីដែលមានភាពទាក់ទាញ និងត្រចះត្រចង់ ។ វាគឺជាបញ្ហានៅពេលដែលជនណាម្នាក់មកចាប់អ្នក ឬចាប់ជីវិតអ្នក បន្ទាប់មកបង្ខំឲ្យអ្នកធ្វើការ ឬជួញដូរផ្លូវភេទ វាពិតជាធ្វើឲ្យគ្រួសាររបស់អ្នកឬអ្នកដែលធ្លាប់ស្គាល់អ្នកឈឺចាប់ជាទីបំផុត ។ ដូច្នេះ យើងទាំងអស់គ្នាត្រូវទប់ស្កាត់វាបន្ថែមទៀត ។ រដ្ឋាភិបាលកម្ពុជាក៏បានដើរជំហានសំខាន់ៗសំដៅទៅទិសដៅនេះដែរ ។

រដ្ឋាភិបាលទាំងអស់ត្រូវទទួលខុសត្រូវ រួមបញ្ចូលទាំងខ្លួនរបស់ខ្ញុំដែរ ។ រដ្ឋាភិបាលទាំងអស់ត្រូវមានស្តង់ដារខ្ពស់ រួមទាំងខ្ញុំផងដែរ ។ ហើយខ្ញុំសង្ឃឹមថា ប្រជាជនកម្ពុជានិងរដ្ឋាភិបាលកម្ពុជានឹងរៀបចំរបៀបវារៈដែលអ្នកនឹងអនុវត្ត ដើម្បីពង្រឹងប្រជាធិបតេយ្យ សេដ្ឋកិច្ច និងប្រព័ន្ធអប់រំ ពីព្រោះចង់ឃើញដំណើរការវិវឌ្ឍដ៏ច្រើននេះនៅប៉ុន្មានឆ្នាំខាងមុខ នៅពេលដែលខ្ញុំមកប្រទេសកម្ពុជាម្តងទៀត ។ ដំណើរការនេះពិតជានឹងផ្អែកទៅលើឱកាសនេះដែលអ្នកទាំងអស់គ្នាយល់ថាមាន ។ ដូច្នេះ ខ្ញុំសង្ឃឹមថា ប្រជាជនកម្ពុជានឹងចង់បានអ្វីដែលជាស្តង់ដាខ្ពស់សម្រាប់ខ្លួន និងបន្ទាប់មកអ្នកនឹងអាចជំរុញ និងទាមទារឲ្យរដ្ឋាភិបាលរបស់អ្នកមានស្តង់ដានោះដែរ ពីព្រោះនេះជាវិធីដែលការងារនេះដំណើរការ ។ វាគឺជារបៀបដែលរដ្ឋាភិបាលអាចទទួលឥទ្ធិពល និងទទួលខុសត្រូវ ។

ដូច្នេះ ខ្ញុំពិតជាមានសុទិដ្ឋិនិយមចំពោះប្រទេសកម្ពុជាណាស់ ។ ខ្ញុំគិតថាអ្នកទាំងអស់គ្នារឹងមាំ អាចជម្នះរាល់ការលំបាកនិងឧបសគ្គដ៏ពិបាក ។ ដូច្នេះ ខ្ញុំសង្ឃឹមថាអ្នកនឹងបន្តដំណើរការអភិវឌ្ឍប្រទេសកម្ពុជាឲ្យកាន់តែរឹងមាំ ថ្កុំថ្កើង និងជាអ្នកដឹកនាំ មិនត្រឹមតែប្រជាជននោះទេ តែថែមទាំងជាអ្នកដឹកនាំក្នុងតំបន់ទៀតផង ។ ខ្ញុំជូនពរឲ្យជីវិតរបស់អ្នកទាំងអស់គ្នាកាន់តែប្រសើរឡើង ។ អរគុណ! ហើយសូមឲ្យព្រះថែរក្សាអ្នក ។ (សំឡេងទះដៃ) ។

# វិញ្ញាណចងចាំ

***(តពីលេខមុន)***

## ***អង្ករដូរពេជ្រ***

ខ្ញុំនៅចាំមិនភ្លេចនូវថ្ងៃដំបូងដែលខ្មែរក្រហមបង្អត់អាហារមកលើប្រជាជន ពេលនោះ បងពៅ បានយួរកូនធុងដែកមួយទៅយកបបរដែលចុងភៅចែកឲ្យ ។ ពេលមកដល់ផ្ទះវិញ បងពៅទម្លាក់ធុងនៅចំពោះមុខម្ដាយខ្ញុំ ហើយស្រែកឡើងថា «ស៊ីទៅ» រួចហើយគាត់ក៏ទ្រហោយំឡើង ម៉ាក់ពុំហ៊ានស្ដីមួយម៉ាត់ ព្រោះយល់ថាកូនៗមិនដែលជួបប្រទះការអត់អាហារដូច្នេះទេ ម៉ាក់ក៏ដួសចែកឲ្យកូនៗហូប ។ បន្ទាប់ពីឃើញបបរ ទើបខ្ញុំដឹងថាមូលហេតុដែល បងពៅ យំព្រោះតែក្នុងធុងបបរនោះមានគ្រាប់អង្ករប្រមាណតែមួយវែកប៉ុណ្ណោះ ក្រៅពីនោះសុទ្ធតែទឹករាវថ្លាគ្មានជីវជាតិទេ ។ ចាប់តាំងពីពេលនោះមក របបសម្រាប់មនុស្សម្នាក់ៗកាន់តែតិចទៅៗសូម្បីតែអំបិលក៏គ្មានស៊ីដែរ ។

នៅឆ្នាំដំបូងយើងអាចយករបស់របរដូចជា ថ្នាំជក់ ទៅលួចដូរយកអង្ករពីអ្នកស្រុកដើម្បីដាំហូបបន្ថែមពីលើបបរដែលចុងភៅចែកឲ្យដើម្បីបានរស់ជីវិតបន្តទៀត ។ ប៉ុន្តែមានអ្នកស្រុកដែលរស់នៅជាមួយយើងខ្លះចាំតាមដានពីសកម្មភាពយើងគ្រប់ពេលរួចរាយការណ៍ទៅអង្គការខ្មែរក្រហម ។ ក្រោយដឹងថាយើងមានថ្នាំពេទ្យអង្គការបានបញ្ជាឲ្យកងឈ្លបមកឆែកយក ប៉ុន្តែពេលទទួលបានព័ត៌មាននោះ ពេលព្រលប់ប៉ាក៏ទៅជីកដីកប់ក្រោមដើមមៀន ។ ស្រាប់តែកងឈ្លបមកដល់ ក៏ដើរសំដៅទៅកាយកន្លែងដែលប៉ាកប់ពីល្ងាចយកថ្នាំពេទ្យទៅអស់ ព្រោះពេលប៉ាយកថ្នាំពេទ្យទៅកប់ មានគ្រួសារអ្នកមូលដ្ឋានដែលរស់នៅក្បែរផ្ទះខ្ញុំឃើញ រួចហើយប្រាប់ទីតាំងទៅឈ្លបនោះ ។ នៅទីនោះ សុខភាពយើងម្នាក់ៗកាន់តែដុនដាបទៅៗព្រោះគ្មានអាហារបរិភោគ ខ្ញុំឃ្លានខ្លាំងណាស់ហើយអ្វីក៏ហូបដែរ ។ ដោយសារតែឃើញយើងឃ្លានដូច្នេះ ពេលព្រលប់មើលគ្នាមិនស្គាល់ ចែថា ក៏ដាច់ចិត្តយកបន្តោងខ្សែកពេជ្ររបស់គាត់ទៅលួចដូរយកអង្ករជាមួយប្រជាជនមូលដ្ឋានរស់នៅភូមិរកាដែលពេលនោះខ្ញុំក៏ទៅជាមួយនឹងគាត់ ។ បន្តោងខ្សែកពេជ្រតម្លៃរាប់ពាន់ដុល្លារ យើងដូរបានអង្ករម្ដៅកំប៉ុងនិងមេមាន់មួយប៉ុណ្ណោះ ។ បងខ្ញុំ និងខ្ញុំដើរកាត់តាមព្រៃខាងក្រោយភូមិដោយលាក់ការណ៍មិនឲ្យអ្នកណាឃើញឡើយ ។ មកដល់ផ្ទះ ម៉ាក់ប៉ា ប្រញាប់ប្រញាល់ដាំបាយ និងស្ងោរមាន់នេះមិនឲ្យអ្នកណាដឹងទេ ព្រោះប្រសិនបើអ្នកមូលដ្ឋាននៅក្បែរផ្ទះដឹងគេប្រាដកជាចោទយើងថាខ្មាំង រួចហើយប្រមូលយករបស់របរយើងទៅទាំងអស់មិនខាន ។ យប់នោះគ្រួសារខ្ញុំបានហូបបាយមួយពេលយ៉ាងឆ្ងាញ់ដែលយើងខានបានហូបជាយូរណាស់មកហើយ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្មែរក្រហមចេះតែបន្ថយរបបអាហារបន្តិចម្ដងៗ ពីបាយទៅបបរខាប់ ទៅបបររាវ ហើយរហូតដល់អង្ករមួយកំប៉ុងសម្រាប់មនុស្ស៣០នាក់ ។ ម្នាក់ៗស្គម បាក់កម្លាំង នៅសល់តែស្បែកដណ្ដប់ឆ្អឹងប៉ុណ្ណោះ ។ ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា ខ្មែរក្រហមចាប់ផ្ដើមបង្អត់អាហារប្រជាជនថ្មីម្ដងទៀត ។ នៅពេលនេះគ្រួសារខ្ញុំខិតខំរកវិធីយកថ្នាំជក់ដែលយកមកពីផ្ទះកុងស៊ិន ថ្នាំពេទ្យនិងគ្រឿងមាសពេជ្រដែលសល់ពីភ្នំពេញដើម្បីដូរយកអង្ករហូបបន្តទៀត ។

## ***ថ្នាំប៉ូវកម្លាំង***

ខ្ញុំនៅចាំថា ថ្ងៃមួយប៉ាចង់ជក់បារីខ្លាំងណាស់ ហើយដោយអត់ទ្រាំពុំបានគាត់បានប្រើខ្ញុំ និងប្អូនប្រុស អាញ៉ី ទៅរោងបាយរួមដើររើសកន្ទុយបារីមូលស្លឹកចេកដែលគេជក់ហើយបោះចោល យើងដើររើសបានមួយចំនួនយកមកឲ្យគាត់ ។ ប៉ាលាកន្ទុយបារីរួចប្រមូលកម្ទេចថ្នាំជក់ចាក់ចូលគ្នារួចមូរជាមួយស្លឹកសង្កែដើម្បីជក់ ។ ខ្ញុំរន្ធត់ចិត្តខ្លាំងណាស់ ព្រោះកាលពីមុនគាត់ជាមនុស្សមានមុខមាត់ម្នាក់ ហើយក្លាយទៅជាអ្នកដើររើសកន្ទុយបារីគេជក់ ។ ចំណែក ប៉ុសែ (បងរបស់ ប៉ា) ជាមនុស្សហូបច្រើនដូច្នេះហើយគាត់មានសភាពយ៉ាប់យ៉ឺនជាងគេព្រោះ ដៃ ជើងពោះ និងមុខគាត់ឡើងហើមលឹប ដោយសារខ្វះជីវជាតិ ហើយអ្វីដែលដក់ក្នុងកែវភ្នែកខ្ញុំគឺ បន្ទាប់ពីការប្រួតកាត់រួច អង្គការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ ដោយមានកាប់ក្របីមួយក្បាលស្លចែកឲ្យប្រជាជនហូប ។ ពេលនោះ ដោយសារស្រេកឃ្លានខ្លាំងពេក ប៉ុសែ

លូកដៃឆក់យកសាច់ក្របីមួយដុំប៉ុនកដៃ ស្រាប់តែចុងភៅយកវែកវាយក្បាលគាត់ដូចគាត់ជាសត្វធាតុ ។ ប៊ុសៃ បានយកសាច់មួយដុំនោះទៅដាក់ក្នុងគុកភ្លើងរួចកាយមកវិញ ឃើញប្រឡាក់ផេះស្រមក ហើយគាត់យកមកខាំទាញទាំងនៅមានឈាមស្រក់តាមដៃគាត់ផង ។ ខ្ញុំឮ ប៊ុសៃ និយាយថា «សាច់ហ្នឹងគេស៊ីឆៅអីចឹង» ប៉ុន្តែតាមពិតដោយសារគាត់ឃ្លានខ្លាំងពេកពុំអាចទ្រាំបាន ។

**ជីវិតចុងក្រោយ**

រដូវប្រូតកាត់កន្ទងផុតទៅរដូវវស្សាក៏មកដល់ គ្រួសារខ្ញុំបានឆ្លងកាត់មួយរដូវទាំងលំបាកក្រៃលែង ពេលនេះយើងពុំមានសល់អ្វីសម្រាប់ដោះដូរអង្ករជាមួយអ្នកមូលដ្ឋានផ្សេងទៀតទេម៉្លោះ ហើយអ្នកដែលងាយនឹងរងគ្រោះជាងគេគឺ ប៊ុសៃ ដែលហូបច្រើន ។ ប៊ុសៃ បានស្លាប់ដោយអត់អាហារបរិភោគ ព្រោះពេលព្រឹកឡើង មានអ្នកភូមិមកប្រាប់ប៉ាថា ប៊ុសៃ បានដេកស្លាប់នៅរោងស្នាក់នៅរបស់គាត់ហើយ ។ ពេលនោះ ប៉ា មិនមានចេញស្តីមួយម៉ាត់ទេ ប៉ុន្តែខ្ញុំដឹងថា ប៉ាសោកស្តាយនិងអាណិតអាសូរបងគាត់ណាស់ ។ ខ្មែរក្រហមបានយកកន្ទេលដែល ប៊ុសៃ សម្រាន្តរុំសាកសព គាត់រួចយកឃ្នាបឫស្សីមកសែងគាត់យកទៅកប់ ។ បងស្រីច្បង ចែថា បានហែកក្រដាសតូចមួយមកសរសេរឈ្មោះ ប៊ុសៃ រួចប្រុកចូលក្នុងកូនដបប៉េនីស៊ីលីន ដោយសន្យាថា នៅថ្ងៃណាមួយពេលដែល ស្រុកខ្មែរបានស្រួលបួលឡើងវិញគាត់នឹងទៅកាយផ្នូរ ប៊ុសៃ ដើម្បីយកឆ្អឹងមកធ្វើបុណ្យ ។ នៅឆ្នាំនោះ មនុស្សស្លាប់ដោយសារអត់បាយមានជារៀងរាល់ថ្ងៃក្នុងភូមិដែលខ្ញុំរស់នៅ គឺភូមិចក សង្កាត់កំពង់ចិនជើង ស្រុកស្ទោង ដោយក្នុងមួយថ្ងៃៗមានចាប់ពីប្រាំនាក់ឡើងទៅ ។ គ្រួសារណាដែលមានសល់របស់របរគ្រាន់ដោះដូរអង្ករអាចនៅរស់បានមួយវស្សាទៀត ។

ថ្ងៃមួយ មានគ្រួសារមួយមានសមាជិក៣នាក់ ឪពុកម្តាយ និងកូនស្រីម្នាក់ ជាអ្នកមានស្តុកស្តម្ភនៅភ្នំពេញបានរត់មកពីងពាក់ ចែថា ឲ្យជួយដូរអង្ករឲ្យគាត់ដើម្បីដាំបាយហូប ។ ខ្ញុំភ្ញាក់ផ្អើលខ្លាំងណាស់ ព្រោះឃើញគ្រួសារនោះយកបន្តោងខ្សែកពេជ្រមួយយ៉ាងធំឲ្យបងខ្ញុំដើម្បីជួយដូរអង្ករឲ្យគាត់ ។ ចែថា ក៏ទៅនិយាយជាមួយអ្នកភូមិដែលគាត់ធ្លាប់ដូរពីមុនមក ចែថា ដូរបានអង្ករចំនួន៣៥កំប៉ុងមកឲ្យគ្រួសារនោះ ។ តាមពិតទៅ ចែថា ប្រថុយជីវិតណាស់ ព្រោះប្រសិនបើឈ្លបខ្មែរក្រហមចាប់បានមុខជាគេសម្លាប់គាត់ជាមិនខាន ។ ក្រោយមក ខ្ញុំមិនដែលបានជួបគ្រួសារនោះទៀតទេ ព្រោះត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលទាំងគ្រួសារបាត់ហើយ ដោយចោទថា គ្រួសារនោះមិនសកម្មជាមួយនឹងការងារដែលអង្គការដាក់ឲ្យធ្វើ ។

មនុស្សចេះតែស្លាប់រាល់ថ្ងៃដោយសារអត់អាហារ ហើយជារឿយៗខ្ញុំតែងឃើញខ្មែរក្រហមសែងសាកសពចេញទៅវាលស្រែ ។ នៅតាមទីទួលនីមួយៗពោរពេញដោយផ្នូរខ្មោចរកកន្លែងទំនេរគ្មានទេ ចាប់ពីជិតភូមិរហូតដល់ទីវាលឆ្ងាយពីភូមិ ។ នៅក្នុងគ្រួសារខ្ញុំម្នាក់ៗកាន់តែស្គមស្គាំង បាក់កម្លាំង រាករូស ហើយយើងនៅសល់ថ្នាំពេទ្យបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ព្យាបាលខ្លួន ។ អ្នកស្រុកដែលនៅក្បែរផ្ទះ ខ្ញុំដឹងថា យើងនៅសល់ថ្នាំពេទ្យគេក៏បានរាយការណ៍ទៅប្រធានភូមិឲ្យមកឆែកឆេរ ចែថា បានដឹងរឿងនោះ គាត់ក៏យកថ្នាំសេសសល់ទាំងនោះទៅលាក់នឹងបងមុំព្រោះពេលនោះគាត់ឈឺដេកដណ្តប់ភួយ ដោយគាត់យកថ្នាំនោះដាក់ក្នុងអាវហើយស្រែកថ្ងូរ ។ ប្រធានភូមិវាវើរុះសព្វកន្លែងរកមិនឃើញ ប៉ុន្តែអ្នករាយការណ៍ទៅគេច្បាស់ណាស់ថាយើងនៅមានសល់ថ្នាំពេទ្យ ។

**ចោរលួចបេះក្រូច**

ខ្ញុំនៅចងចាំមិនភ្លេចទេនូវអ្វីដែលបានកើតឡើងចំពោះក្មួយៗបីនាក់ដែលជាកូនរបស់ចែថា ។ អាវ៉ាត់ (ប្រុស) ពេលនោះមានអាយុប្រមាណប្រាំមួយឆ្នាំ អាវ៉ែន (ស្រី) អាយុប្រាំឆ្នាំ និងអាវ័ត្ន (ស្រី) អាយុបួនឆ្នាំ ។ ខ្ញុំឃើញក្មួយៗទាំងអស់ស្គមកំព្រឹងដូចជាគេយកស្បែកទៅដណ្តប់លើឆ្អឹងអីចឹង ហើយឆ្អឹងកដៃប៉ុនដងវែកប៉ុណ្ណោះ ។ ថ្ងៃមួយ ពេលយប់ទៅហើយ ខ្ញុំឮសំឡេងអ្វីមួយធ្លាក់ក្តុកមកលើដី ខ្ញុំក៏ចុះទៅមើល ហើយអ្នកស្រុកដែលជាម្ចាស់ផ្ទះដែលយើងស្នាក់នៅជាមួយក៏ចុះទៅមើលដែរ ពេលចុះទៅដល់ដី ខ្ញុំឮក្មួយប្រុសខ្ញុំ អាវ៉ាត់ ស្រែកឡើងថា «នុ៎ះៗវារត់ទៅខាងនោះហើយ» ដោយវាប្រាប់ថាជាចោរលួចបេះក្រូច ។ តាមពិតទៅពុំមានចោរឯណាក្រៅពី អាវ៉ាត់ ខ្លួនឯងលួចបេះក្រូចម្ចាស់ផ្ទះទេ ដោយសារពេលនោះវាឃ្លានខ្លាំងពេក ។ ***(នៅមានត)***

**ថៃ ច័ន្ទរិទ្ធ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ ៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ ៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 132, December 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.